00222145

D99/3/3

Declassified to Public
06 September 2012

ការសិក្សា ច្បាប់គ្រប់មាត្រា ទាំងអស់

ក្នុង

# ក្រមព្រហ្មទណ្ឌ

របស់ អេង - សុត
នៅ ក្រសួង យុត្តិធម៌

*បោះពុម្ពលើកទីពីរ*

រោងពុម្ព គីមគី បណ្ណាគារ
លេខ ៩៥ វិថីយុគន្ធរ ភ្នំពេញ

ព. ស. ២៥០៧ គ.ស . ១៩២៤

# គន្ថី មួយ

# អំពី ទោស

## DES PEINES

## មាតិកា មួយ

### បទបញ្ញត្តិទូទៅ

### DISPOSITIONS GÉNÉRALES

មាត្រា ១ – ច្បាប់ បញ្ញត្តិ ថា ត្រូវទុក អំពើខ្លះ របស់មនុស្ស ជាជា បទល្មើស ហើយបទល្មើសនេះត្រូវតែបានទទួលទោស ព្រោះ ថា បទល្មើសនោះ អាចធ្វើ ឲ្យសង្គមមនុស្ស កករល្អក់បាន ។

មាត្រា ២ – ទោស ដែលច្បាប់ បញ្ញត្តិមកនេះ អាចធ្វើ ឲ្យជន· ម្នាក់ៗ វិនាសជីវិត , សេរីភាព , ធនធាន , និង សមត្ថភាព ក្នុងការ ប្រើ សិទ្ធិខ្លះ បាន ។

មាត្រា ៣ – ទោស ចែក ជាមូលទោស និង ជាអនុទោស ។ មូលទោស គឺ ទោស ដែលគេ អាចយក ទៅសម្រេច ដាច់

តែឯងក៏បាន មិនចាំបាច់ បញ្ចូល អនុទោស មក ក៏បាន ឬ បញ្ចូល អនុទោស មក ក៏បាន ។

ឯ អនុទោស គឺ ជាទោស ដែលគេ មិនអាច យកទៅសម្រេច ដាច់តែឯងក៏បាន ទេ គឺថា គេ នឹងសម្រេចអនុទោសណាមួយបាន, លុះតែគេបានសម្រេចមូលទោសណាមួយសិន, ពីព្រោះអនុទោស គ្រាន់តែ ជាកម្មវិបាក របស់ មូលទោស តែប៉ុណ្ណោះ ។

មាត្រា ៤- ច្បាប់ ចែក មូលទោស តាមទម្ងន់ របស់វា ជា បីថ្នាក់ គឺ ទុក្រឹដ្ឋទោស មជ្ឈិមទោស និង លហុទោស ។

មាត្រា ៥ – បទល្មើស ទាំងឡាយ ដែលត្រូវទុកថា ជាបទទុក្រិដ្ឋ ឬ ទុក្រិដ្ឋកម្ម, បទមជ្ឈិម ឬ មជ្ឈិមកម្ម ឬ បទលហុ ឬ លហុកម្ម ក៏ចាត់ ទៅ តាមទោស របស់ បទល្មើសនោះដែរ គឺថា បទល្មើសណា ត្រូវផ្តន្ទា ដោយទោសទុក្រឹដ្ឋ, បទល្មើសនោះ ត្រូវទុកថា ជាទុក្រិដ្ឋកម្ម ឬ បទទុក្រឹដ្ឋ; បទល្មើសណា ត្រូវផ្តន្ទា ដោយទោសមជ្ឈិម, បទល្មើសនោះ ត្រូវទុកថា ជាមជ្ឈិមកម្ម ឬ បទមជ្ឈិម ; បទល្មើសណា ត្រូវផ្តន្ទា ដោយទោសលហុ, បទល្មើសនោះ ត្រូវទុកថា ជាលហុកម្មឬ បទលហុ ។

00222148





ឧក្រិដ្ឋកម្ម និង មជ្ឈិមកម្ម ត្រូវបែកជាថ្នាក់ទីមួយ, ទីពីរ, និង ទីបី ដូចគ្នា និង ថ្នាក់ របស់ទោស ឧក្រិដ្ឋ ឬ មជ្ឈិម ដែល ត្រូវយកទៅផ្ដន្ទា បទល្មើស ទាំងនោះដែរ ។

មាត្រា ៦– ច្បាប់ព្រហ្មទណ្ឌ គ្មានអានុភាព ជាប្រតិសកម្ម ទេ គឺ ថា បទល្មើសណា បានប្រព្រឹត្ត មុន បទបញ្ញត្តិ របស់ច្បាប់, បទល្មើស នោះ មិនអាចត្រូវទិគ្រោះ ដោយ ទោស របស់ច្បាប់ ដែលទើបនឹងបញ្ញត្តិ ថ្មីនេះបាន ទេ ។

ប៉ុន្តែ បើ ច្បាប់ថ្មី លុបចោល បទល្មើស ណាមួយ ឬ សម្រាល ទោស របស់បទល្មើស ណាមួយវិញ បទល្មើស ដែល បានប្រព្រឹត្ត មុន ច្បាប់ថ្មីនេះ ត្រូវបានរួចផុត ពីទោស ឬ ក៏ ទោសនោះ ត្រូវបានស្រាល តាម ច្បាប់ថ្មីនេះ ដែរ កុំឡៀត បទល្មើសនោះ បានទទួល ការផ្ដន្ទា ជា ស្ថាពរ រួចអស់ទៅហើយ ៖

មាត្រា ៧– ទោសគុក គឺ ទោស ដែលបំបាត់សេរីភាពមាន កំណត់កាល ។ ទោសនេះ បើ កាត់ ដល់ទៅឆ្នាំ គេត្រូវរាប់កន្ទមួយ ឆ្នាំៗឲ្យគ្រប់ ដប់ពីរខែ តាមសុរិយគតិ; បើ កាត់ មានកំណត់ ត្រឹមតែ ខែ គេ ត្រូវរាប់ថា ដាក់គុក ពីថ្ងៃ ទីប៉ុន្មាន នៃខែណា ខាងសុរិយគតិ

00222149





ទៅដល់ ខួបថ្ងៃ ទីប៉ុណ្ណោះ នៃខែបន្ទាប់នោះ ត្រូវទុក ជាមួយខែ, ពោះបើ កន្លះ មួយខែៗ នោះមានថ្ងៃ ចំនួនប៉ុន្មាន ក៏ដោយ; បើ កាត់ មានកំណត់ ត្រឹមតែថ្ងៃ គេ ត្រូវរាប់ថា មួយថ្ងៃ មាន ម្ភៃបួន ម៉ោង ដោយគិតថា ពីម៉ោង ៦ ព្រឹកនេះ ទៅ ម៉ោងប្រាំមួយព្រឹកនៃថ្ងៃ ន្ទាប់នោះ ជាមួយថ្ងៃ ។

ទណ្ឌិត ដែលត្រូវអស់ទោស ត្រូវចាប់ដោះ នៅម៉ោងប្រាំមួយព្រឹក នៃថ្ងៃជាបន្ទាប់ ពី ថ្ងៃគ្រប់ទោស ។

អំពីរបៀប គិត រយៈវេលា ទោសនោះ, គេ ត្រូវគិតថា ថ្ងៃដែល យកមនុស្ស មកដាក់គុក ជាដំបូងនោះ, ពោះ ម៉ោងប៉ុន្មានក៏ដោយ, ហេតុមកដល់ ថ្ងៃស្អែកឡើងវិញ ពេលម៉ោង ប្រាំមួយ ព្រឹក ត្រូវទុកថា ជា មួយថ្ងៃពេញ ដោយមិនបាច់គិត ថា ថ្ងៃនោះ ពេញម្ភៃបួនម៉ោង ឬ មិនពេញនោះឡើយ ។

មាត្រា ៨– តាម គោលច្បាប់ រយៈវេលា ដែលឃុំជាបណ្ដោះ អាសន្ននោះ ត្រូវយកមកកាត់កន្លង ទីង រយៈវេលា នៃទោសដែរ, គឺថា រយៈវេលា នៃទោស ត្រូវគិត តាំងពីថ្ងៃ ដែលវិនិច្ឆ័យ មកនៅ កន្លឃុំ ។ ក៏ប៉ុន្តែ តុលាការ អាចបញ្ជា ឲ្យគិតថា រយៈវេលា ទោស ត្រូវចាប់រាប់ ពីថ្ងៃ ដែលបានកាត់ទោស តទៅ ក៏បាន ។

រឿងក្តី ដែលប្តឹង មកដល់ឧទ្ធរណ៍ ត្រូវតែជំរះឲ្យហើយ ក្នុង រយៈពេល ពីរខែ ។

មាត្រា ៩ – ទោសពិន័យ គឺជា ទោស ដែលតម្រូវ ឲ្យទណ្ឌិត បង់ មានកំណត់ចំនួន , នូវប្រាក់ ដែលច្បាប់ អនុញ្ញាតឲ្យចាយ ក្នុង ប្រទេសកម្ពុជា ។

ប្រាក់ ជាផល នៃពិន័យនេះ ត្រូវបាន ជាប្រាក់ចំណូល របស់ ថវិកាជាតិ ។

មាត្រា ១០ – ធនទណ្ឌ គឺប្រាក់ពិន័យ, ប្រាក់សំណង, ប្រាក់ ជម្ងឺចិត្ត ។ ដើម្បី ទារ ធនទណ្ឌនេះ, គេ អាចបូករួមប្រាក់ ទាំងបី ផែកនេះ បញ្ចូលគ្នា ហើយ តឹងទារ ពីទណ្ឌិត តាមផ្លូវច្បាប់ និងតាម របៀប ដាក់គុកបន្ទឹទារ ។

ការទារ ធនទណ្ឌនេះ ត្រូវទារ តាមអំណាច កំណត់ដៃ នៃសាលក្រមតុលាការ ដែលមានលក្ខណៈ ជាស្ថាពរហើយ ។ ប្រាក់សំណង និងប្រាក់ជម្ងឺចិត្ត ត្រូវទារ តាមបណ្តឹង របស់ភាគីស៊ីវិល ដែលតុលាការ បានកាត់ឲ្យ; ប្រាក់ពិន័យ និង ប្រាក់សំណង ឬ ប្រាក់ជម្ងឺចិត្ត ដែល ត្រូវបាន ទៅរាជការ ត្រូវទារ តាមបណ្តឹង របស់រដ្ឋមន្ត្រីយុត្តិធម៌ ។

មាត្រា ១១ – ក្នុងការណ៍ ដែលត្រូវទារ ប្រាក់ពិន័យផង ប្រាក់សំណង ឬ សោហ៊ុយជម្ងឺចិត្តផង ពីទណ្ឌិត ដែលមានធនធាន មិនគ្រប់គ្រាន់ គេ ត្រូវទារ សំណង ឬសោហ៊ុយជម្ងឺចិត្ត មុន ប្រាក់ពិន័យ ។

មាត្រា ១២ – ការដាក់គុកបង្ខំដល់រូបកាយ មិនមែនទុកជាសំណង កាត់ឲ្យរួច ជំពាក់គេនោះទេ គឺជា ការដាក់គុកបង្ខំនេះ ជាមធ្យោបាយតែមួយ សម្រាប់បង្ខំចិត្ត មនុស្សនោះ ឲ្យសង ប្រាក់គេ តែប៉ុណ្ណោះ ។ ក្នុងពេល ដែលផុត កំណត់កាល នៃការដាក់គុកបង្ខំដល់រូបកាយហើយ ប្រាក់ ដែលមិនទាន់បានសង ទាំងប៉ុន្មាន ត្រូវនៅតែជំពាក់ទាំងអស់ ដដែល, ក៏ប៉ុន្តែ មនុស្សនេះ មិនត្រូវ គេយក ទៅដាក់គុក ពីរដង ដើម្បីបង្ខំទារប្រាក់ជំពាក់ ដដែលនោះ ឡើយ ។

ជន ដែលច្បាប់ស៊ីវិល ឲ្យផុត ពីការដាក់គុកបង្ខំទារប្រាក់ នោះ មិនត្រូវបានផុត ពី ការដាក់គុកបង្ខំទារប្រាក់ ក្នុងបទព្រហ្មទណ្ឌ ឡើយ ទោះបើ ប្រាក់ ដែលជំពាក់នោះ ជាប្រាក់ពិន័យក្តី, ជាប្រាក់សំណងក្តី, ឬ ជាសោហ៊ុយជម្ងឺចិត្តក្តី ។ ក៏ប៉ុន្តែ អនីតិជន អាយុ តិចជាង ដប់ប្រាំបីឆ្នាំ ដូច មានសំដែងក្នុង មាត្រា ១២១ និងមនុស្សវិកលចរិត ដូច មានសំដែង ក្នុង មាត្រា ៨៩ នោះ មិនត្រូវយក ទៅដាក់គុកបង្ខំ ទារប្រាក់នោះឡើយ ។

ឯខណ្ឌិត ជាអនីតិជន មានអាយុ ច្រើនជាង ដប់ប្រាំបីឆ្នាំ ទើប អាចត្រូវដាក់គុកបន្ទំទារ ប្រាក់ បាន ។

ក្នុង បទព្រហ្មទណ្ឌ ការសុំឲ្យដាក់គុកបន្ទំទារប្រាក់នេះ ឥតមាន ឲ្យបង់ ដម្លៃក្ដីទេ គឺជា ចាងហ្វាង សាលាក្តី ក្នុងខេត្ត ជាទីលំនៅ របស់ខណ្ឌិតនោះ បញ្ជាដោយដីកា (Ordonnance) ឲ្យដាក់គុកបន្ទំទារ ប្រាក់នោះ តាមបណ្តឹង របស់ភាគីស៊ីវិល ឬ របស់រដ្ឋមន្ត្រី យុត្តិធម៌ ដោយគ្មានឲ្យបញ្ចេញថ្លៃ ឬ ឲ្យដំកល់ប្រាក់ថ្លៃអាហារ ទេ, ប៉ុន្តែ មានប្រើ សិទ្ធិអ្នកសុំលក់តាមផ្លូវច្បាប់នូវចលវត្ថុ, អចលវត្ថុក៏ដោយ ។ ចាងហ្វាង ចេញដីកានេះ ដោយសំអាងទៅលើ កំណត់ដៃ ដែលមានសេចក្តី សំរេចជាស្ថាពរ ។

រដ្ឋមន្ត្រីយុត្តិធម៌ អាចអនុញ្ញាត ឲ្យបង្អង់ប្រតិបត្តិ នូវការបន្ទំនេះ បាន កាលណាបើ ខណ្ឌិតនោះ មានសុខភាពមិនល្អ គួរឲ្យបង្អង់, ហើយ បើក្នុងពេល ដែលថាឲ្យនៅក្រៅគុក នោះទៀត ខណ្ឌិត ឥតមានជាប់ គុក ពីបទល្មើសណាទៀតទេ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលនឹងអនុញ្ញាតឲ្យនេះ កំលុះតែមាន សេចក្តីសន្និដ្ឋាន របស់ ពេទ្យ ដែលពិនិត្យ អាការរោគ ជាតិកតាំងផង ដែរ ។ សាមីជន អ្នក សុំឲ្យពេទ្យ ពិនិត្យនេះ ត្រូវបង់ប្រាក់ថ្លៃពិនិត្យនេះ នៅមន្ទីរក្រឡាបញ្ជី នៃសាលា ដែលនៅ ក្នុងស្រុក របស់ខ្លួននោះ ។

រដ្ឋមន្ត្រីយុត្តិធម៌ អនុញ្ញាត ឲ្យបន្ថែមយ៉ាងនេះ បានតែ ក្នុងរយៈវេលា មួយខែគត់; ប៉ុន្តែ បើទណ្ឌិត សុំជាថ្មីទៀត បាន គឺសុំម្ដង មួយខែៗ ។ កាលណា ទណ្ឌិត សុំបន្ថែមម្ដងៗ ត្រូវឲ្យមាន សេចក្ដីសន្និដ្ឋាន របស់ពេទ្យ ជាថ្មីទៀត គ្រប់តែ ដង ជាដាច់ខាត ។

មាត្រា ១៣– ត្រូវដាក់គុក មួយថ្ងៃ ក្នុងប្រាក់ជំពាក់ មានចំនួន ពីហាសិបរៀល ចុះមក ។ បើប្រាក់ជំពាក់នោះមានចំនួនច្រើន ដល់ មួយម៉ឺនរៀល (១០០០០៛) ត្រូវដាក់គុក ដោយកាត់មួយថ្ងៃហាសិប រៀលៗ ដរាបអស់ប្រាក់ មួយម៉ឺន រៀល ។ បើ ប្រាក់ជំពាក់នោះ លើសពី មួយម៉ឺនរៀលទៅ ត្រូវកាត់ ពីត្រឹមប្រាក់លើសនោះ ១០០រៀល មួយថ្ងៃវិញ ។ ប៉ុន្តែ បើទោះជា ប្រាក់ជំពាក់នោះ ច្រើនយ៉ាងណា ក៏ដោយ ក៏រយៈវេលា ដែលត្រូវដាក់គុកតាមប្រាក់នោះ, ដោយសារុប ទាំងអស់ទៅ, មិនត្រូវឲ្យលើសពី ពីរឆ្នាំ ទេ នេះ ចំពោះតែទណ្ឌិត ម្នាក់ ក្នុងរឿងតែមួយ ។

បើទណ្ឌិត តែម្នាក់ ឬ ច្រើននាក់ ជាប់ ធនទណ្ឌ ជាពារ៍ នៃបទ ល្មើស មួយបទ ឬ ច្រើនបទ ដែលត្រូវរួមគ្នា សង កាតិស៊ីវិល តែម្នាក់ នោះរយៈវេលា នៃការដាក់គុកបង្ខំតាមប្រាក់ ត្រូវកំណត់ ដោយបូកសារុប ចំនួន ធនទណ្ឌ នោះ ទាំងអស់ ។ បើឃើញ ចំនួនប្រាក់ប៉ុន្មាន

ត្រូវដាក់គុក ដោយគិត ដូចខាងលើនេះ គ្រប់ទណ្ឌិត ។

បើ ទណ្ឌិត តែម្នាក់ ឬ ច្រើននាក់ ជាការី នៃបទល្មើស មួយបទ ឬ ច្រើនបទ ដែលត្រូវរួមគ្នា បង់ជនទណ្ឌ ឲ្យភាគីស៊ីវិល ច្រើននាក់ នោះរយៈវេលា ដាក់គុកទារប្រាក់ ត្រូវបំបែក ចំនួនប្រាក់ តាមភាគីស៊ីវិលម្នាក់ៗ មិនត្រូវបូករួម សំណង ឬ ជម្ងឺចិត្ត របស់ភាគីទាំងអស់ធ្វើជាចំនួនមួយ ហើយកំណត់ចំនួនថ្ងៃ សម្រាប់ដាក់គុក នោះ ទេ ។

ករណីសារណ៍ ដែលមាន ជនទណ្ឌ ខាងពិន័យផង ខាងជម្ងឺចិត្តផង ត្រួតគ្នាយ៉ាងនេះ នោះរយៈវេលា ដាក់គុក ត្រូវញែក ប្រាក់ពិន័យ នឹងប្រាក់ជម្ងឺចិត្ត ឲ្យដាច់ពីគ្នា ហើយ គិតថ្ងៃដាក់គុក តាមពិន័យ តាមជម្ងឺចិត្ត កុំបូកគ្នាឡើយ ។

កាលណាបើ ទណ្ឌិតច្រើននាក់, ខ្លះជាការី, ខ្លះជាសហការី, ខ្លះជាអ្នកចូលគំនិត ហើយត្រូវទណ្ឌកម្ម ឲ្យរួមគ្នា សង ជម្ងឺចិត្ត គេ ដោយអនុវត្ត តាមបទបញ្ញត្តិ មាត្រា៧០ នោះរយៈវេលា ដាក់គុកបង្ខំទារប្រាក់ ត្រូវគិតទៅ លើទណ្ឌិតម្នាក់ៗ នូវចំនួនថ្ងៃ ដាក់គុក ដូចជាទណ្ឌិតនោះ ត្រូវទារតែម្នាក់ឯង គឺថា មិនត្រូវយក ចំនួនប្រាក់នោះមក រំលែកចែកគ្នា ជាប់គុកតាមចំណែក សព្វខ្លួនជននោះ បានទេ ។ រយៈវេលា ដែលត្រូវដាក់ គុកបង្ខំទារប្រាក់នេះ ទៀត ក៏មិនត្រូវបន្ថយបន្ថែម

ក្ដី ឲ្យខុសអំពីរបៀបគិតថ្ងៃ ដូចបានពោលមកនោះទេ ។

ឯប្រាក់ពិន័យ ដែលតុលាការ ដាក់ទណ្ឌកម្ម ឲ្យបង់ម្នាក់ៗ នោះ មិនត្រូវយក ចំនួនប្រាក់ពិន័យ នោះ មកសារុបគ្នាបង់ទេ គឺ ត្រូវបង់តាម ចំណែក សត្វខ្លួន ; ការដាក់គុកបន្ទំពារប្រាក់ នោះទៀត ក៏ត្រូវជាប់គុក តាមចំណែក ប្រាក់ពិន័យ សត្វខ្លួនដែរ ។

មាត្រា ១៤- ជនណា មាន ពិរុទ្ធ ជា បានប្រព្រឹត្ត បទល្មើស ច្រើន បទ, ជននោះ ត្រូវ ទទួល ទណ្ឌកម្មច្រើន លើកដែរ ។

ត្រូវទុក ជា មាន បទល្មើស ច្រើន បទ បាន :

១- កាលណា បើអំពើ ទាំងឡាយ ដែលបានប្រព្រឹត្ត នោះ ជា បទល្មើស ផ្សេងគ្នា ដោយ ប្រភេទ ព្រហ្មទណ្ឌ (nature pénale) ។

២- កាលណាបើ អំពើទាំងឡាយ ដែល បានប្រព្រឹត្តនោះ, ថ្វី បើ មាន ប្រភេទព្រហ្មទណ្ឌ ដូចគ្នា មែន , ប៉ុន្តែ បើកាលៈទេសៈដែល បានប្រព្រឹត្ត បទល្មើសនោះ ផ្សេងពេល ឬ ផ្សេងកន្លែងគ្នា ការនាំឲ្យ ញែក អំពើ ទាំងនោះ ផ្សេង ៗ ពីគ្នាបាន ។

៣- កាលណាបើ អំពើទាំងឡាយ ដែល បានប្រព្រឹត្តនោះ ថ្វីបើ មាន ប្រភេទព្រហ្មទណ្ឌ ដូចគ្នា ហើយប្រព្រឹត្ត ក្នុង ទីកន្លែង និង ពេល ជា មួយគ្នា មែន ប៉ុន្តែ អំពើល្មើសនោះ បានធ្វើឲ្យមាន ព្យសនកម្ម ដល់

00222156



រូបកាយ នៃ បុគ្គលផ្សេងៗគ្នា ។

មិនត្រូវទុក ជា បទល្មើស ច្រើនបទទេ ៖

១- កាលណា បើអំពើល្មើស ច្រើនបទ ដូចគ្នា តែមានឈ្មោះខាង ព្រហ្មទណ្ឌ ផ្សេងៗ គ្នា ដែលមានលក្ខខណ្ឌ នាំឲ្យគេអាចយកអំពើតែមួយ មកផ្ដន្ទាទោសច្រើនដងបាន ។

២- កាលណា បើអំពើទាំងឡាយ ដដែល ៗ នោះ មាន ប្រភេទព្រហ្មទណ្ឌ ដូចគ្នាផង, បានប្រព្រឹត្តក្នុង ក្នុងពេល និង ទីកន្លែង ជាមួយគ្នាផង, ហើយ បានធ្វើ ឲ្យខូចខាត ដល់ធនធាន របស់ជន ច្រើននាក់ផ្សេងគ្នាផង, ប៉ុន្ដែ ធនធានទាំងនោះ ទុកដាក់ ជុំគ្នា ក្នុងផ្ទះតែមួយ, ក្នុងកន្លែងតែមួយ, ជាមួយគ្នា, នៅវេលាដែល មាន បទល្មើសនោះ ។

មាត្រា ១៤- ក្នុងករណី ដែលត្រូវផ្ដន្ទាទោស ដល់ជនតែម្នាក់ដដែល ៗ ដែលបានប្រព្រឹត្ត បទឧក្រិដ្ឋ ច្រើនបទ នោះត្រូវ សម្រេចដូច តទៅ ។

១- បើ បានយក ទោសឧក្រិដ្ឋថ្នាក់ ទីបី មកសម្រេច ដើម្បីនិគ្រោះ បទឧក្រិដ្ឋ ណាមួយហើយ នោះ បទឧក្រិដ្ឋ ដែលសល់ពីនោះ មិនត្រូវផ្ដន្ទាទោស ទៀតទេ ។

២- បើ បានយក ទោសឧក្រិដ្ឋ ថ្នាក់ ទីពីរ មកសម្រេច ដើម្បីនិ-

គ្រោះ បទឧក្រិដ្ឋ ណាមួយហើយ នោះ បទឧក្រិដ្ឋ ដទៃទៀត ដែលនៅសល់ មិនត្រូវ ផ្ដន្ទាទោស ទៀតទេ ។

៣– បើ មិនយក ទោសឧក្រិដ្ឋ ថ្នាក់ ទីពីរ ឬ ថ្នាក់ ទីបី មក សំរេច ដើម្បីនិគ្រោះ បទឧក្រិដ្ឋ ណាមួយទេ នោះត្រូវយក ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ មកសំរេច គ្រប់តែ បទឧក្រិដ្ឋ ដែលត្រូវនិគ្រោះ ; ទោស និមួយៗ ដែលយកមកផ្ដន្ទានេះ អាចសំរេច ដាក់គុកបន្ទំ ឲ្យធ្វើការជាទម្ងន់ ពីមួយឆ្នាំទៅ ម្ភៃឆ្នាំបាន កុំឲ្យតែ ទោស ដែលកាត់ទាំងអស់នោះ សរុបគ្នាទាំងអស់ទៅ មានរយៈពេលតិចជាង អប្បបរមា ឬ ច្រើនជាង ទ្វេភាគនៃអតិបរមា នៃទោស ដែលមានកំណត់ ក្នុងមាត្រា ៣៣ ស្ដីពី រយៈពេល នៃទោសឧក្រិដ្ឋ ថ្នាក់ ទីមួយ នោះឡើយ ។

៤– ប្រសិនបើ មិនបានយក ទោសឧក្រិដ្ឋ ណាមួយ មកនិគ្រោះ បទឧក្រិដ្ឋ ទាំងនោះទេ ព្រោះមានបញ្ចូល ស្ថានត្រាប្រណីផង នោះត្រូវ យកទោសគុក មធ្យមមកសំរេច គ្រប់តែ បទឧក្រិដ្ឋ ដែលត្រូវនិគ្រោះ កុំឲ្យតែ ទោសទាំងនោះ, កាលបើបូករួមគ្នាទៅ, មានរយៈពេល លើសពីទ្វេភាគ នៃអតិបរមា ដែលមានកំណត់ក្នុងមាត្រា ៣៦ ស្ដីពីរយៈពេល នៃទោសមធ្យម ថ្នាក់ ទីបី ឡើយ ។

មាត្រា ១៦– ក្នុងករណី ធ្វើឧណ្ហកម្ម ដល់ជន តែម្នាក់ ព្រោះ

00222158

D99/3/3



ប្រព្រឹត្ត បទឧក្រិដ្ឋ និងបទមជ្ឈិម ច្រើនបទ នោះការអនុវត្ត ទោស លើ វិរុទ្ធជន មាន ដូច តទៅនេះ :

១ – បើបានយក ទោសឧក្រិដ្ឋ ណាមួយ មកសំរេច ដើម្បីនិគ្រោះ បទឧក្រិដ្ឋ មួយបទ ឬ ច្រើនបទ រួចហើយ នោះមិនត្រូវសំរេច ទោស ណាមួយ ដើម្បីនិគ្រោះ បទមជ្ឈិម ទៀតឡើយ ។

២ – ប្រសិនបើ មិនបានយក ទោសឧក្រិដ្ឋ ណាមួយ មកសំរេច ដើម្បីនិគ្រោះ បទឧក្រិដ្ឋ ទាំងឡាយនោះទេ ដោយសារមាន ការបញ្ចូល ស្ថានត្រាប្រណី ផង នោះត្រូវសំរេច ទោសមជ្ឈិម គ្រប់តែបទមជ្ឈិម ដែល ត្រូវនិគ្រោះ កុំឲ្យតែ ទោស ទាំងនោះ កាលបូករួមគ្នាទៅ មានរយៈវេលា លើសពីទ្វេភាព នៃអតិបរមា ដែលមានកំណត់ ក្នុងមាត្រា ៣៦ស្តី ពីរយៈ វេលា នៃទោសមជ្ឈិម ថ្នាក់ ទីបី ។ ឯទោសពិន័យ អាចសម្រេច ចំនួន ប៉ុន្មាន ក៏បាន គ្មានកំណត់ទេ ។

មាត្រា ១៧– បើផ្តន្ទាទោស ដល់ជន តែម្នាក់ ដែលបាន ប្រព្រឹត្ត បទមជ្ឈិម ច្រើនបទ នោះ ចៅក្រម ត្រូវយកទោសមជ្ឈិមមក សម្រេចឲ្យបានគ្រប់ បទ នៃទោសកម្ម កុំឲ្យ តែទោសគុក នោះ, កាល បូករួមគ្នាទៅ, មាន រយៈវេលា លើស ពីទ្វេភាព នៃអតិបរមា ដែល មានកំណត់ក្នុង មាត្រា ៣៦ស្តី ពីរយៈវេលា នៃទោសគុក មជ្ឈិម ថ្នាក់

ទីបី ៗ ឯទោសពិន័យ គាប់សម្រេច ដល់ចំនួន ប៉ុន្មានក៏បាន ឥតមានព្រំដែនទេ ។

មាត្រា ១៨ — បើផ្ដន្ទាទោស ដល់ជន តែម្នាក់ ដែលបាន ប្រព្រឹត្ត បទលហុ ច្រើនបទ, នោះ ចៅក្រម ត្រូវកាត់ ទោស គ្រប់តែ បទលហុ កុំឲ្យតែទោសគុក នោះ, កាលបូករួមគ្នាទៅ, មានចំនួន លើស ពីទ្វេភាគ នៃអតិបរមា ដែលមានកំរិត ក្នុងមាត្រា ៤១ ស្ដី ពីទោសគុក នៃបទលហុ ៗ ឯទោសពិន័យ គាប់សំរេច ឲ្យដល់ចំនួន ប៉ុន្មាន ក៏បាន ឥតមានកំណត់ទេ ។

បើផ្ដន្ទា ទោស ដល់ជន តែម្នាក់ ពីបទឧក្រិដ្ឋ ឬ មជ្ឈិម ផង និង បទលហុ ផង, ប្រសិនបើ ជននោះ បានទទួល ទោសឧក្រិដ្ឋ ឬ មជ្ឈិម ហើយ នោះចៅក្រមមិនត្រូវយក ទោស អ្វីមួយ មកផ្ដាល់ បទលហុនេះ ទៀតទេ ។ ក្នុងករណី ដែល មិនបានយក ទោសឧក្រិដ្ឋ ឬ ទោសគុក មកនិគ្រោះ បទឧក្រិដ្ឋ ឬ ទោសកម្មទេ នោះបើមាន បទលហុ ប៉ុន្មាន ត្រូវយក ទោសលហុ ប៉ុណ្ណោះ មកសំរេច ដោយគ្មាន ព្រំដែនអ្វី ក្រៅពី ព្រំដែន ដែលមានសំដែង ហើយ ជាពិសេស ក្នុង កថាខណ្ឌទី មួយ នៃមាត្រានេះទេ ។

មាត្រា ១៩ — អំពីបទបញ្ញត្តិ ក្នុងមាត្រា ១៤ ដល់ ១៨ ស្ដី

ពីការប្រព្រឹត្ត ច្រើនបទល្មើស, ពីបទល្មើស ស្របគ្នា ឬ ពីការតម្រួត មានព្រំដែននៃទោស នោះ ទៅក្រម ត្រូវពិចារណា ដូច តទៅនេះ

ទណ្ឌកម្ម ច្រើនបទនោះ សំរេច ក្នុងពេលកើតក្តី (Instance) មួយ ឬ ច្រើនដង ។ បើពេលកើតក្តី ច្រើនដង ទៅក្រម ត្រូវញែកថា បទ ល្មើស ដែលត្រូវសំរេច ទណ្ឌកម្ម លើកក្រោយនេះ ជាបទល្មើស កើតឡើង ក្នុងពេល ដែលទណ្ឌិត ទទួល ទោស មុន អស់ហើយ ឬ មិនទាន់អស់ ទេ ។ បើទោស នៃទណ្ឌកម្មមុន មិនទាន់ទទួលនៅអស់ ទេនោះ ទណ្ឌកម្ម ដែលសំរេច លើកក្រោយនេះ ត្រូវអនុវត្ត ទៅតាម បទបញ្ញត្តិ ក្នុងមាត្រា ១៤ ដល់ ១៨ ។ បើទោស នៃទណ្ឌកម្ម មុន បាន ទទួល អស់ហើយ នោះ ទណ្ឌកម្ម ដែលត្រូវសំរេច លើកក្រោយនេះ មិនត្រូវអនុវត្ត តាមបទបញ្ញត្តិ ក្នុងមាត្រា ១៤ ដល់ ១៨ ទេ ។

ក្នុងករណី ដែលជនម្នាក់ មានទោសគុកមធ្យម ហើយក្នុងពេលដែល កំពុងរង ទោសនេះ មិនទាន់ផុតផង ជននេះ ក៏មានទោសមធ្យម មួយបទ ឬ ច្រើនបទ ជាថ្មីទៀត, នោះ រយៈវេលា នៃទោសក្រោយ នេះ ត្រូវយក ទៅតម្រួត លើរយៈវេលា នៃទោសមុន ដោយអនុវត្ត តាមមាត្រា ១៤ ដល់ ១៨ ។ បើទោសមុន ជាទោសគុកមធ្យម ហើយទោសក្រោយ ជាទោសទុក្រិដ្ឋ, នោះ រយៈវេលា នៃទោសក្រោយ

00222161



នេះ ក៏ត្រូវយក ទៅបូកតម្រួតគ្នា លើរយៈពេល នៃទោសមុន ដែរ ។ ប៉ុន្តែបើ ទោសមុន ជាទោសឧក្រិដ្ឋ ហើយទោសក្រោយ ជាទោសមជ្ឈិម នោះទោសមជ្ឈិមក្រោយនេះ មិនត្រូវសំរេច ទៀតទេ ដោយហេតុថា ទោសមជ្ឈិមនេះ ត្រូវស្រូបចូល ទៅក្នុងទោសឧក្រិដ្ឋមុន ។

មាត្រា ២០-(ព្រះរាជក្រមលេខ ៩៣៣-នស. ចុះថ្ងៃ ២១ កុម្ភៈ ១៩៥៤ បានលុប មាត្រា ២០ នេះចោល ឥតមានជំនួសវិញទេ) ។

# មាតិកាពីរ

## អំពី មូលទោស

## DES PEINES PRINCIPALES

មាត្រា ២១ ទោសឧក្រិដ្ឋ មានបីយ៉ាង

១- សម្លាប់ ,

២- បង្ខំឲ្យធ្វើការជាទម្ងន់ អស់មួយជីវិត

៣- បង្ខំឲ្យធ្វើការ ជាទម្ងន់ មានកំណត់ កាល ។

ទោសសម្លាប់ ជាទោសឧក្រិដ្ឋ ថ្នាក់ទី ៣ ។ ឧក្រិដ្ឋកម្មណា ត្រូវនិគ្រោះ ដោយសម្លាប់, ឧក្រិដ្ឋកម្មនោះ ជា ឧក្រិដ្ឋកម្មថ្នាក់ទីបី ។

ទោសបង្ខំឲ្យធ្វើការ ជាទម្ងន់ អស់មួយជីវិត ជាទោសឧក្រិដ្ឋ

ថ្នាក់ទី ពីរ ។ ឧក្រិដ្ឋកម្មណា ត្រូវនិគ្រោះ ដោយទោសបង្ខំឲ្យធ្វើការ ជាធ្ងន់អស់មួយជីវិត ឧក្រិដ្ឋកម្មនោះ ជា ឧក្រិដ្ឋកម្ម ថ្នាក់ទី ពីរ ។

ទោសបង្ខំឲ្យធ្វើការជាធ្ងន់ មានកំណត់ ជាទោសឧក្រិដ្ឋថ្នាក់ទីមួយ ។ ឧក្រិដ្ឋកម្មណា ត្រូវនិគ្រោះ ដោយទោសបង្ខំឲ្យធ្វើការ ជាធ្ងន់ មានកំណត់ ឧក្រិដ្ឋកម្មនោះ ជា ឧក្រិដ្ឋកម្មថ្នាក់ទីមួយ ។

មាត្រា២២– ទោសមជ្ឈិម មានពីរយ៉ាង គឺ:

១– ទោសគុក

២– ទោស ពិន័យ ។

ទោសទាំងពីរយ៉ាងនេះ មានបី ថ្នាក់ គឺ ថ្នាក់ទីបី, ទីពីរ និង ទីមួយ ។ ទោសមជ្ឈិម ថ្នាក់ទី បី :

ក) ដាក់គុក ពីមួយឆ្នាំ ទៅប្រាំឆ្នាំ ,

ខ) ពិន័យ ពី ៤០០១៛ ទៅ ៤០ ០០០៛ ;

ទោសមជ្ឈិម ថ្នាក់ ទីពីរ ;

ក) ដាក់គុក ពីមួយខែ ទៅ មួយឆ្នាំ

ខ) ពិន័យ ពី ១៤០១៛ ទៅ ៤ ០០០៛

ទោសមជ្ឈិម ថ្នាក់ ទីមួយ :

ក) ដាក់គុក ពីប្រាំមួយថ្ងៃ ទៅ មួយខែ

ខ) ពិន័យ ពី ១៥១៛ ទៅ ១២០០៛

ទោសមជ្ឈិម ទាំងបីថ្នាក់នេះ នឹងយក តែទោសគុក ឬតែទោស ពិន័យ ទៅផ្តន្ទា ក៏បាន , យក ទាំងគុក ទាំងពិន័យ ទៅផ្តន្ទា ក៏បាន ។

ទោសកម្ម (បទល្មើសជាមជ្ឈិម) ណា ត្រូវទិត្រោះ ដោយទោស មជ្ឈិម ថ្នាក់ទីបី, ទោសកម្មនោះ ជា បទល្មើសមជ្ឈិម ថ្នាក់ទីបី ឬ ទោសកម្ម ថ្នាក់ទីបី ។

ទោសកម្មណា ត្រូវទិត្រោះ ដោយទោសមជ្ឈិម ថ្នាក់ពីរ; ទោស កម្មនោះ ឈ្មោះថា បទល្មើសមជ្ឈិម ថ្នាក់ទីពីរ ឬ ទោសកម្ម ថ្នាក់ទីពីរ ។

ទោសកម្មណា ត្រូវទិត្រោះ ដោយទោសមជ្ឈិម ថ្នាក់ទីមួយ ទោស កម្មនោះ ឈ្មោះថា បទល្មើសមជ្ឈិម ថ្នាក់ទីមួយ ឬ ទោសកម្ម ថ្នាក់ទីមួយ ។

មាត្រា២៣- ទោសលហុ មានពីរយ៉ាង គឺ

១- ទោស គុក ពីមួយថ្ងៃ ទៅ ប្រាំថ្ងៃ

២- ទោស ពិន័យ ពីដប់ប្រាំរៀល ទៅ មួយរយហាសិបរៀល ;

ទោសទាំងពីរយ៉ាងនេះ នឹងយកទៅផ្តន្ទា តែមួយយ៉ាង ក៏បាន ឬ ទាំងពីរយ៉ាង ក៏បាន ។

00222164





# ចំពូក មួយ
# អំពី ទោសឧក្រិដ្ឋ

DES PEINES CRIMINELLES

## ផ្នែក ទី មួយ
## អំពី សម្លាប់ជីវិតបង់

De la peine de mort

មាត្រា ២៨ - ថ្មី: (ព្រះរាជក្រមលេខ ៣៦៦-នស ចុះថ្ងៃ ៦.១.៦០)

មនុស្សត្រូវទោស ប្រហារជីវិតបង់ ត្រូវពិឃាត ដោយបាញ់នឹងកាំភ្លើង លុះត្រាដល់ស្លាប់ ។ ផ្នែកពិឃាត ត្រូវមានចំនួន ១២ នាក់យ៉ាងតិច ។ ផ្នែកនេះ មានទាហានជាសមាសភាព កាលណាតុលាការសឹកជម្នុំ ឬ តុលាការសឹកពិសេស កាត់ទោសប្រហារជីវិតនោះ ។ ផ្នែកពិឃាតនេះមានកងពលតម្រួត ជាអ្នកពិឃាត, កាលណា បើតុលាការសឹកមិនបានកាត់ទោសនេះទេ ។

របៀបពិឃាត ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

មាត្រា ២៩ - ថ្មី: (ព្រះរាជក្រមលេខ ៣៦៦- នស. ចុះថ្ងៃ ៦-១-៦០)

មនុស្សទោស ត្រូវនាំទៅ កាន់ពិឃាតដ្ឋាន ។ នៅទីនោះ, មុននឹងពិ-ឃាត អ្នករាជការដែលត្រូវចាត់មក ដើម្បីការនេះ ត្រូវសូត្រសាលក្រម

00222165

D99/3/3



ដែលកាត់ទោសនោះ ឲ្យឮខ្លាំងៗ ។ តមក ត្រូវរុំក្លក មនុស្សទោស ដោយផ្ទាំងសំពត់ ។ ប៉ុន្តែ បើមនុស្សទោសនោះ បានសុំ ដោយជាក់ច្បាស់ថា កុំឲ្យរុំក្លកខ្លួន ទើបត្រូវអនុញ្ញាត ឲ្យតាមសុំ ។

មាត្រា ២៦ - ដែលទីពិឃាតនោះ ត្រូវពិឃាត នៅទីកន្លែងណាមួយ ដែលក្រសួងរដ្ឋបាល ប្រាប់បង្ហាញ ក្នុងដែនសីមាខេត្ត, ស្រុក ដែលមានអធិប្បាយ ក្នុងសាលក្រម ។

មាត្រា ២៧- ហាមផ្ដាច់ មិនឲ្យពិឃាត មនុស្សទោស ក្នុងថ្ងៃសីល ឬ ថ្ងៃអាទិត្យណាមួយ ។ ថ្ងៃសីល, ថ្ងៃអាទិត្យនោះគឺ:

១- ថ្ងៃទី ១ និង ថ្ងៃទី ២ ដើមឆ្នាំបារាំងសេស; ថ្ងៃសុក្រ, ថ្ងៃសៅរ៍, ថ្ងៃអាទិត្យ និង ថ្ងៃចន្ទ បុណ្យប៉ាក់, ថ្ងៃអាស្សង់ស្យុង, ថ្ងៃអាទិត្យ និងថ្ងៃចន្ទបុណ្យប៉ង់តេកុត, ថ្ងៃបុណ្យ ១៤ ស្វយេត, ថ្ងៃ ១៥ អ៊ូត, ថ្ងៃទី ១- ទី ២- និងទី ១១ ខែណូវែម; ថ្ងៃ ២៥ ខែដេសម ។

២- ថ្ងៃសីលទាំងអស់, ថ្ងៃសូត្រភាណយក្ស, ៣ ថ្ងៃដំបូងចូលឆ្នាំខ្មែរ, ថ្ងៃច្រត់ព្រះនង្គ័ល, ៣ ថ្ងៃ បុណ្យតាំងតុ ចំរើនព្រះជន្មវស្សាព្រះមហាក្សត្រ, ថ្ងៃភ្ជុំបិណ្ឌ, ៣ ថ្ងៃបុណ្យចុះនៃ លយប្រទីប ។

៣- បីថ្ងៃដំបូងចូលឆ្នាំចិន-យួន ។

មាត្រា ២៨ - សពដែលពិឃាត, បើគ្រួសាររបស់សពសុំ, នឹង

ប្រគល់ឲ្យ យកទៅកប់ ឬ ដុតបាន តែកុំហែ និង ធ្វើបុណ្យរុងរឿង ។

មាត្រា ២៩– បើស្ត្រីណាមួយ មានគភ៌ ហើយត្រូវមានទោស ដល់ប្រហារជីវិតបង់, ស្ត្រីនោះ ត្រូវទុក ឲ្យសំរាល កូន រួចសិន ទើប ត្រូវយកទៅ ពិឃាត បាន ។

មាត្រា ៣០– មុននឹងពិឃាត មនុស្សទោសម្នាក់ៗ, គណៈកម្មការ ត្រូវនាំ សេចក្តី ក្រាបបង្គំទូល ព្រះមហាក្សត្រ សុំព្រះអង្គ ទ្រង់ វិនិច្ឆ័យ ពីគួរសំរាលទោស ឬ ដូចម្តេច ជាមុនសិន ទើបពិឃាតបាន ។ អាស្រ័យហេតុនេះ, សំណុំរឿង និង សាលក្រម, ដែលកាត់ទោស ប្រហារជីវិតបង់ នោះ, ត្រូវជូនទៅ គណៈកម្មការមួយ ពិនិត្យ ។ គណៈកម្មការនោះ មាន នាយក នៃគណៈកម្មការ អចិន្ត្រៃ នៃគណៈរដ្ឋមន្ត្រី ជាប្រធាន, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃ, ចាងហ្វាងសាលាវិនិច្ឆ័យ និង សាលាឧទ្ធរណ៍ ជាសមាជិក ។ ក្រោយដែលបានស្តាប់ សេចក្តីរាយការណ៍ របស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ រួចហើយ, គណៈកម្មការ ក៏ជូន យោបល់ ដែលគួរសុំ ព្រះគុណវិសេស អំពីព្រះ

មហាក្សត្រ ។ ក៏ប៉ុន្តែ យោបល់នេះ មិនជាគ្រឿងជំទាស់ ដល់ព្រះតម្រិះ ដែលព្រះមហាក្សត្រ ទ្រង់យល់ឃើញយ៉ាងណា ៗ នោះទេ ។

## ផ្នែក ទី ពីរ

## អំពី បង្ខំឲ្យធ្វើការជាទម្ងន់

Des Travaux Forcés

មាត្រា ៣១ – ទណ្ឌិត នៃទោស បង្ខំ ឲ្យធ្វើ ការ ជាទម្ងន់នោះ ត្រូវបង្ខំ ឲ្យធ្វើ ការ ដែលមាន កំណត់ ក្នុងបទបញ្ញា (ព្រះរាជក្រមលេខ ១២ ន ស. ចុះថ្ងៃ ២៤-៣-៤៥) ទណ្ឌិត ទាំងនោះ នឹងដាក់បញ្ចូលទៅ ក្នុងគុក ដែលមាននៅ ក្នុងក្រុងកម្ពុជា ហើយដែលជាកន្លែង ផ្សេង សម្រាប់តែ ទទួលឃុំ មនុស្សនោះ ។

ឯ ស្ត្រី, ដែលត្រូវ ទោស បង្ខំ ឲ្យធ្វើ ការ ជាទម្ងន់នោះ, មិនត្រូវ យកចេញទៅ ក្រៅ ទេ, ត្រូវនៅទទួល ទោស ក្នុង គុក នៅក្រុងភ្នំពេញ ។ ទោស បង្ខំ ឲ្យធ្វើ ការ ជាទម្ងន់នេះ មិនត្រូវ យក ទៅអនុវត្ត លើអនីតិជន អាយុ តិចជាងដប់ប្រាំបីឆ្នាំ នឹង លើជនជរា អាយុ ជាងហុកសិបឆ្នាំ ទេ ។ ពួកក្មេង នឹង ចាស់ ក្នុងសណ្ឋាននេះ ដែលជាប់ជំនុំជំរះ ត្រូវចូល ក្នុងរបៀប ដែលមានបញ្ញត្តិ ក្នុងមាត្រា ១១៨ នឹង មាត្រា១២៣ ។

00222168





មាត្រា ៣២- ទោស បង្ខំ ឲ្យធ្វើ ការ ជាទម្ងន់ អស់មួយជីវិត ត្រូវសំរេច ដាក់គុក មនុស្ស ដែលមានទោសនោះ អស់មួយជីវិត។

មាត្រា ៣៣- ទោស បង្ខំ ឲ្យធ្វើ ការ ជាទម្ងន់ មាន កំណត់ ត្រូវសំរេចធ្វើ ទោស ពីប្រាំឆ្នាំ យ៉ាងតិច ដល់ម្ភៃឆ្នាំ យ៉ាងច្រើន, វៀរតែ កាលណា ត្រូវសំរេច តាមសេចក្ដីបញ្ញត្តិ ត្រង់ ១៣ នៃមាត្រា ១៨ ដែលសំដែង ពីត្រូវតម្រួត ទោសក្រិដ្ឋ ថ្នាក់ទីមួយ, បើ យ៉ាងដូច្នេះ នឹងសំរេចធ្វើ ទោស កំណត់ តិចជាង ប្រាំឆ្នាំ ក៏បាន តែបើ បូករួម ទោសទាំងអស់ទៅ កុំឲ្យតែ កំណត់នោះថយ ពីប្រាំឆ្នាំ និង កុំឲ្យលើស ពីសែសិបឆ្នាំ ។

## ជំពូក ពីរ

## អំពី ទោសមជ្ឈិម

## DES PEINES CORRECTIONNELLES

### ផ្នែកទី មួយ

### អំពី ការដាក់គុកជាមជ្ឈិម

### De l'emprisonnement correctionnel

មាត្រា ៣៤- ទណ្ឌិត ដែលត្រូវជាប់គុក ត្រូវឃុំខ្លួន ក្នុងគុក

ក្នុងព្រះនគរ គឺគុកធំ នឹង គុក ក្នុងខេត្ត ។ មនុស្សនេះ ត្រូវធ្វើ ការ ដែលមាន នៅទីគុកនោះ នឹងធ្វើ ការ ជាប្រយោជន៍ សាធារណៈ ខាងក្រៅគុក ក៏បាន ។

មាត្រា ៣៥ – លប់ចោលហើយដាក់ជំនួសវិញ ដោយព្រះរាជក្រមលេខ ១២ ន ស. ថ្ងៃ ២៤-៣-៤៥ ដែលស្តីពី របប រស់នៅ ក្នុងគុកជាមជ្ឈិម ។

មាត្រា ៣៦ (ព្រះរាជក្រមលេខ ៦-នស ចុះថ្ងៃ ១៨ ឧសភា ១៩៥៥)

ទោស គុក មាន រយៈវេលា ពីប្រាំមួយ ថ្ងៃ ទៅ ប្រាំឆ្នាំ, លើកតែ មានស្ថាន ទម្ងន់ ឬ សម្រាល ទោស, ទើបសម្រេច ផ្សេង ពីនេះ បាន ។

ទោសមជ្ឈិម ថ្នាក់ទីបី ត្រូវដាក់គុក ពីមួយឆ្នាំ ទៅដល់ ប្រាំឆ្នាំ, ហើយ នឹងពិន័យជាប្រាក់ ពីបួនពាន់មួយរៀល (៤០០១រ) ទៅដល់ បួនម៉ឺនរៀល (៤០០០០រ) ថែមទៀត ក៏បាន ។

ទោសមជ្ឈិម ថ្នាក់ទីពីរ ត្រូវដាក់គុក ពីមួយខែ ទៅដល់ មួយឆ្នាំ ហើយ នឹងពិន័យ ជាប្រាក់ ពីមួយពាន់ពីររយមួយរៀល (១២០១) ទៅដល់ បួនពាន់រៀល (៤០០០រ) ថែមទៀត ក៏បាន ។

ទោសមជ្ឈិម ថ្នាក់ទីមួយ ត្រូវដាក់គុក ពីប្រាំមួយថ្ងៃ ទៅ មួយខែ ហើយ នឹងពិន័យជាប្រាក់ ពីមួយរយ ហាសិបមួយរៀល (១៥១រ) ទៅដល់ មួយពាន់ពីររយរៀល (១២០០រ) ទៀត ក៏បាន ។

# ផ្នែក ទី ពីរ

# អំពី ពិន័យជា មជ្ឈិម

## De l'amende correctionnelle

មាត្រា ៣៧- (ព្រះរាជក្រមលេខ ៦. នស. ចុះថ្ងៃ ១៨ ឧសភា ១៩៥៥)

ទោសពិន័យ អាចត្រូវសម្រេចបាន ពីមួយរយហាសិបមួយរៀល (១៥១៛) ទៅដល់ បួនម៉ឺនរៀល (៤០ ០០០៛) លើកមួយតែមានស្ថាន ទម្ងន់ ឬ សម្រាល ទោស, ទើបសម្រេច ផ្សេងទៅវិញបាន ។

ទោសពិន័យ ថ្នាក់ទីបី ពីបួនពាន់មួយរៀល (៤ ០០១៛) ទៅដល់ បួនម៉ឺនរៀល (៤០ ០០០៛), បើ យក ទោសគុក ពីមួយឆ្នាំ ទៅដល់ ប្រាំឆ្នាំ មកបន្ថែម ទៀត ក៏បាន ។

ទោសពិន័យ ថ្នាក់ទីពីរ ពីមួយពាន់ពីររយមួយរៀល (១២០១៛) ទៅដល់ បួនពាន់រៀល (៤ ០០០៛), បើយកទោសគុក ពីមួយខែ ទៅដល់ មួយឆ្នាំ មកបន្ថែមទៀត ក៏បាន ។

ទោសពិន័យ ថ្នាក់ទីមួយ ពីមួយរយហាសិបមួយរៀល (១៥១៛) ទៅដល់ មួយពាន់ពីររយរៀល (១ ២០០៛), បើ យកទោសគុក ពី. ប្រាំមួយថ្ងៃ ទៅដល់ មួយខែ មកបន្ថែមទៀត ក៏បាន ។

តាមគោលការណ៍, ទោសពិន័យ មិនត្រូវយក ទៅសម្រេច លើ

00222171

D99/3/3



ទណ្ឌិត ដែលទីទ័លក្រខ ។

មាត្រា ៣៨- ប្រាក់ពិន័យ ត្រូវចាប់ការ តាំងពីថ្ងៃ ដែលសេចក្តីសំរេច ពីពិន័យនេះ ចូលក្នុងភាព ជាស្ថាពរ ។ កំណត់ដៃ នៃសាលក្រមនោះ ទុក ជាបណ្ណ សំរាប់ទារ ប្រាក់ ពីទណ្ឌិត តាមផ្លូវច្បាប់ ហើយនឹង តាមផ្លូវដាក់គុកទារប្រាក់ ផង ។

មាត្រា ៣៩- បើ ទណ្ឌិតនោះ នៅក្រៅឃុំ ហើយ មាន ជម្ងឺ នោះ ការដាក់គុក នឹងបង្អង់សិន ក៏បាន ។ ការបង្អង់ អនុវត្តនេះ ជាការៈ របស់រដ្ឋមន្ត្រីក្រសួងនីតិធម៌ ជាអ្នកអនុញ្ញាតឲ្យ តាមលក្ខខណ្ឌ ដូចមានសំដែង ក្នុងមាត្រា ១៤ ។

មាត្រា ៤០- ទណ្ឌិត ដែលត្រូវទោសពិន័យ អាចសុំ បង់ ប្រាក់មួយរំពេច ក្នុងវេលា ដែលកាត់ សេចក្តី នោះក៏បាន ។ ក្នុងករណីនេះ, ប្រាក់នេះ ត្រូវបង់ ឲ្យក្រឡាបញ្ជី នៅសាលា ដែលកាត់ សេចក្តី; ក្រឡាបញ្ជី ត្រូវប្រគល់ បង្កាន់ដៃ ឲ្យ ។ ការព្រមបង់ប្រាក់ដូច្នេះ ត្រូវទុក ថា ទណ្ឌិត សុខចិត្តទទួល ទោស តាមសាលក្រមនេះហើយ គឺថា មិនប្តឹង តវ៉ា ទៅទៀត ទេ ។

# ជំពូកបី

# អំពីទោសលហុ

# DES PEINES DE SIMPLE POLICE

## ផ្នែកទី មួយ

## អំពីទោសគុកជាលហុ

## De l'emprisonnement des peines de simple police

មាត្រា៤១- ទោសគុកជាលហុ មានកំណត់ ពីមួយថ្ងៃ យ៉ាងតិច ទៅដល់ ប្រាំថ្ងៃ យ៉ាងច្រើន ។

មាត្រា៤២- ទណ្ឌិត ដែលត្រូវទោសគុកជាលហុ នឹងទទួលទោស ក្នុងទីគុកពិសេស សំរាប់ តែទោសលហុនោះ ក៏បាន ឬ នឹងទទួល ទោស ក្នុងគុកជាមួយ នឹងទណ្ឌិត ដែលមាន ទោសគុក ជាមជ្ឈិម ក៏ បាន ។

មាត្រា៤៣- ក្នុងរយៈវេលា ដែលទទួល ទោសនោះ ទណ្ឌិត ជាប់គុកជាលហុ គាបត្រូវគេប្រើឲ្យធ្វើការ ដូចជា ទណ្ឌិត ដែលជាប់គុក ជាមជ្ឈិម បានដែរ ។ មនុស្សទាំងនេះ ត្រូវទទួលប្រតិបត្តិ តាមរបប សំរាប់ គុក ដូចគ្នា ។

## ផ្នែក ទី ពីរ

## អំពី ពិន័យ ជាលហុ

De l'amende de simple police.

មាត្រា៤៤- ពិន័យជាលហុ មានកំណត់ យ៉ាងតិច ដប់ប្រាំរៀល(១៥រ)យ៉ាងច្រើន មួយរយ ហាសិប រៀល (១៥០រ) ។

មាត្រា៤៥ របៀបទារ ប្រាក់ពិន័យជាលហុនោះ ត្រូវធ្វើ ដូចរបៀប ដែលទារប្រាក់ពិន័យជាមធ្យម ដែរ ។

មាត្រា៤៦- ទណ្ឌិតណា ត្រូវទោសពិន័យ ជាលហុហើយ គ្មានប្រាក់បង់, ទណ្ឌិតនោះ អាចសុំធ្វើ ការ ជាប្រយោជន៍រួម ក្នុងស្រុក ជាទីលំនៅ ឬ ទីសំចត របស់ខ្លួននោះ ដើម្បីឲ្យរួច ប្រាក់ពិន័យក៏បាន។ ក្នុងករណីនេះ, ទណ្ឌិតនោះ ត្រូវគេ ប្រើឲ្យធ្វើ ការ ជាប្រយោជន៍រួម ក្នុងមួយថ្ងៃ ប្រាំបីម៉ោង ។ ការ ដែលបានធ្វើ ក្នុងមួយថ្ងៃៗត្រូវកាត់កង នឹងប្រាក់ពិន័យ ម្ភៃប្រាំរៀល (២៥រ) ។ ទណ្ឌិត ត្រូវធ្វើការកាត់ យ៉ាងនេះ ដរាបដល់អស់ ប្រាក់ពិន័យ ។ បើកាលណា កាត់យ៉ាងនេះហើយ នៅ សល់ប្រាក់ពិន័យខ្លះទៀត មិនគ្រប់ចំនួន ម្ភៃប្រាំរៀលទេ នោះទណ្ឌិតក៏ ត្រូវធ្វើការ មួយថ្ងៃទៀតដែរ ដើម្បីកាត់នឹងប្រាក់សល់នោះ ។

មាត្រា ៤៧ - ថ្មី (ព្រះរាជក្រមលេខ ៩៨ ប.រ ២៦-៦-៦២) បទបញ្ញត្តិទាំងឡាយ នៃក្រមនេះ មិនយកទៅប្រតិបត្តិ លើពិន័យសមាសភាព, ពិន័យសរុប និង ពិន័យអន្តរការណ៍ ដូចដែលបានសម្តែង ក្នុងច្បាប់ ជាធរមាននោះទេ ។

## ចំពូក មួយ
## ពិន័យសមាសភាព

មាត្រា ២- ចៅក្រមនៃសាលាលហុ, កាលបានទទួល កំណត់ហេតុ ដែលពិនិត្យ បទល្មើសលហុហើយ, ត្រូវ ឲ្យដំណឹង ទៅអ្នកល្មើសជាលហុនោះ តាមសំបុត្រអនុសិដ្ឋជា ឲ្យអ្នកនេះមកបង់ តាមស្ម័គ្រចិត្ត នូវពិន័យសមាសភាព ជាប្រាក់មានចំនួន ដូចដែលចៅក្រមនេះបានកំណត់ ក្នុងព្រំដែន ដែលមានសម្តែង ក្នុងមាត្រា ៤៤ ក្រមព្រហ្មទណ្ឌ ឬ ក្នុងព្រំដែន ដែលមានសម្តែង ក្នុងច្បាប់ពិសេសទាំងឡាយ ។

មាត្រា ៣- បើអ្នកល្មើសជាលហុ បង់ចំនួនប្រាក់ ពិន័យសមាសភាព ក្នុងរយៈវេលា សាមសិបថ្ងៃគត់, រាប់ពីថ្ងៃ ដែលចារិក លើដំណឹងនៃការទទួល, នោះ បណ្តឹងអាជ្ញា ត្រូវរលត់ហើយ ។

00222175



សេចក្ដីសម្រេច ដែលកំណត់ចំនួនប្រាក់ ពិន័យសមាសភាពនោះ មិនបើក អំណាចឲ្យ អ្នកល្មើសលហុ តវ៉ា សោះ ទេ ។

មាត្រា៤ - ក្នុងករណី ដែលចំនួនប្រាក់ពិន័យ សមាសភាពនេះ មិនបានបង់ ក្នុងរយៈវេលា ដែលបានអនុញ្ញាតឲ្យបង់នោះទេ, សាលាលហុ ត្រូវចាត់ការ ជំនុំជំរះ តាមច្បាប់ ក្រមពិភាក្សាព្រហ្មទណ្ឌ ដែលស្ដី អំពីសាលាលហុ ។

មាត្រា៥ - ការបង់ ប្រាក់ពិន័យ សមាសភាពនេះ ត្រូវបង់ ទីន ក្រឡាបញ្ជី នៃសាលាលហុ ដែលជាអ្នកចេញ បង្កាន់ដៃ ប្រាក់ពិន័យ ។

និតិវិធី នៃប្រាក់ពិន័យ សមាសភាពនេះ មិនឲ្យមានការ សោហ៊ុយ តុលាការអ្វី លើសពី សោហ៊ុយ ត្រឹមតែ សំណង ថ្លៃបញ្ញើ សំបុត្រអនុសិដ្ឋ មានពាំងដំណាង នៃការទទួលនោះ ទេ ។

មាត្រា៦ - បទបញ្ញត្តិ នៃមាត្រា ២ ដល់ ៥ ខាងលើនេះ មិនត្រូវយកទៅប្រតិបត្តិ ក្នុងករណី ដូចតទៅនេះ ទេ :

១ - បើ ចៅក្រម យល់ឃើញថា កាលៈទេសៈ ដែលបានប្រព្រឹត្ត បទល្មើសជាលហុនោះ មានប្រភេទ គួរឲ្យផ្ដន្ទា ទោសគុក ដល់

អ្នកប្រព្រឹត្តនោះ ;

២ – បើ អំពើល្មើសជាលហុ ដែលបានកត់ត្រាមកនោះ មុខជាបណ្ដាលឲ្យ អ្នកប្រព្រឹត្តនោះ ជួសជុល សេចក្ដីអន្តរាយ ដែលធ្វើឲ្យខូចខាត ដល់រូបបុគ្គល ឬ ដល់ធនធាន ;

៣ – បើ អ្នកល្មើសជាលហុនោះ ជាមនុស្សមិនពន់ពាល ;

៤ – បើ អំពើល្មើសជាលហុនោះ មានសម្ដី និង មានទិគ្រោះ តាមច្បាប់ពិសេស ដែលបដិសេធចេញ ដោយប្រាកដប្រជា នូវនីតិវិធីនៃពិន័យ សមាសភាព ។

## ចំពូកពីរ
## ពិន័យសរុប

មាត្រា ៧ – នៅគ្រប់ បទទាំងអស់, អំពើល្មើសជាលហុ អាចនាំឲ្យ បង់ភ្លាមៗ នូវ ពិន័យសរុប និងភ្នាក់ងារ ធ្វើ កំណត់ហេតុនោះបាន ។

ពិន័យសរុប មិនត្រូវឲ្យលើសពី ២០០ រៀលទេ ។ ក៏ប៉ុន្តែកាលណា មានច្បាប់ពិសេស ណាមួយ សម្ដែង ជាដាច់ខាត នូវការសរុបមួយផ្សេង, នោះអ្នកទារពិន័យ ត្រូវទារតាមច្បាប់ពិសេសនេះវិញ ។

ជាទីបំផុត, បើ ច្បាប់ពិសេសនោះ មិនចែង ពីការសរុបនេះ ទេ, មានចែង តែពីអប្បបរមា និង អតិបរមាផ្សេង ពីអប្បបរមា និង អតិ-

00222177



បរមា ដែលមានចង្អុល ក្នុងក្រមព្រហ្មទណ្ឌ , នោះ ភ្នាក់ងារ ត្រូវទារ ពិន័យនេះ ត្រឹមតែ ពីរភាគបី នៃអតិបរមា ដែលមានចង្អុល ក្នុងច្បាប់ ពិសេសនោះ ។

ក្នុងករណី មិនព្រមបង់ ពិន័យសរុបនេះ, ចៅក្រម គប្បីតែ ចាត់ ការឲ្យស្រប តាមច្បាប់ នៃក្រមពិភាក្សា ព្រហ្មទណ្ឌ ដែលស្តីអំពីសាលា លហុ ហើយ ពិន័យសមាសភាគ ក៏មិនអាចតម្រូវ ដល់អ្នកល្មើសជា លហុនេះ ទៀតដែរ ។

មាត្រា ៨- បទបញ្ញត្តិ នៃមាត្រា ៧ មិនត្រូវយកមកប្រតិបត្តិ ក្នុងករណីទាំងឡាយ ដូចតទៅនេះទេ

១- បើ អំពើល្មើស ដែលបានកត់ត្រាមកនោះ មុខជាតម្រូវឲ្យ អ្នកល្មើស មានទោសគុក ឬ ឲ្យជួសជុល សេចក្តីអន្តរាយ ដែលធ្វើឲ្យខូចខាត ដល់រូបបុគ្គល ឬ ដល់ធនធាន ;

២- បើ កំណត់ហេតុ តែមួយនោះ ស្តីថា ជនតែម្នាក់ បានប្រព្រឹត្ត អំពើល្មើសជាលហុ លើសពី បីបទឡើងទៅ ។

មាត្រា ៩- ភ្នាក់ងារ អ្នកធ្វើកំណត់ហេតុ សុទ្ធតែ មានទីតិសម្បូរ ឲ្យទារ ពិន័យសរុប ។ កាលណា ចាប់ទារ ពិន័យសរុប , ភ្នាក់ងារ

00222178



ទាំងនេះ ត្រូវតែយកជាប់ទៅ នឹងខ្លួន នូវឯកសារ ដែលបញ្ជាក់ ថាខ្លួន មានទិតសម្បទា ក្នុងមុខនេះ ផង ។

មាត្រា១៩- អ្នកបង់ ពិន័យសរុប នឹងទុក ជាបានបង់មែន លុះត្រាតែ អ្នកនោះ មាន បង្កាន់ដៃ ដែលភ្នាក់ងារ ហែកចេញ ពីក្នុងសៀវភៅ ដែលមានចុង មានគល់នោះ មក ។

ចុងសន្លឹក នឹងគល់សន្លឹក ត្រូវចុះ ថ្ងៃបំណង់ , ចំនួនប្រាក់ពិន័យ ដែលបង់រួចហើយ , ប្រភេទ នៃអំពើល្មើសជាលហុ , ឈ្មោះ នឹង អាសយដ្ឋាន អ្នកល្មើសជាលហុ, ឈ្មោះ នឹង គុណភាព នៃភ្នាក់ងារ ដែលចេញបង្កាន់ដៃ នឹងហត្ថលេខា នៃភ្នាក់ងារនោះ ។

សៀវភៅបង្កាន់ដៃនេះ ត្រូវចុះ លេខរៀង នឹង ចុះហត្ថលេខា ចៅក្រមសាលាលហុ ក្នុងដែនជាចំណុះ នៃៈចៅក្រមនេះ ដែលភ្នាក់ងារនោះ ត្រូវបំពេញ បេសកកម្ម របស់ខ្លួន ។ ក្នុងករណី ដែលភ្នាក់ងារនេះ មានសមត្ថកិច្ចពេញ លើផ្ទៃដែនទាំងមូល សៀវភៅបង្កាន់ដៃនេះ ត្រូវចុះលេខរៀង នឹង ចុះហត្ថលេខា ចៅក្រមសាលាលហុ ភ្នំពេញ ។

នៅថ្ងៃទីមួយ នៃខែនីមួយ ១ អ្នកពជ្ឈរដ្ឋបាល ដែលភ្នាក់ងារ អ្នកធ្វើកំណត់ហេតុនេះ នៅក្រោមបង្គាប់ ត្រូវចាត់ឲ្យបញ្ជូន មកសាលាលហុ នូវបញ្ជីពិន័យសរុប ដែលបានទារហើយ ក្នុងខែ ដែលទើបនឹងកន្លង

00222179

D99/3/3



ទោសនេះ ។ អ្នកពន្ធនាររដ្ឋបាលនេះ ត្រូវយក ចំនួនប្រាក់ពិន័យទាំងនោះ ទៅដាក់ នៅធនាគារ ដោយខ្លួនឯង ។

## ចំពូកបី

## ពិន័យ អន្តរការណ៍

មាត្រា១១– ច្បាប់ទាំងឡាយ ជាធរមាន ដែលជូន អំណាច ដល់អ្នកពន្ធនាររដ្ឋបាល ឲ្យសម្រុះសម្រួល លើបណ្ដឹងអាជ្ញានោះ មិនមានកែប្រែទេ ។

## បទបញ្ញត្តិ ជាទីបំផុត

មាត្រា ១២– បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយ នឹងព្រះរាជក្រមនេះ ត្រូវបដិសេធចោល ។

## មាតិកា បី

## អំពីអនុទោស

Des peines accessoires

មាត្រា៤៨– អនុទោស មានពី ស្ថាន:

១ ការបន្ថយ សិទ្ធិពលរដ្ឋ (Dégradation civique)

២ ឃំហាត់ ជានិត្យានុកូល (Interdiction légale)

៣ តំហាត់ លំនៅ (Interdiction de séjour)

៤ ប្រកាសទណ្ឌកម្ម (Publicité des condmnations)

៥ រើប (Confiscation)

៦ ទណ្ឌកម្មឲ្យសងសំណង និង ឲ្យបង់ជម្ងឺចិត្ត (Condamnation aux restitutions et dommage-intérêts)

៧ បញ្ជនីយកម្ម (Relégation)

## ចំពូក មួយ

## អំពី ការបន្ថយ សិទ្ធិពលរដ្ឋ

## De la dégradation civique

មាត្រា ៤៩– បន្ថយសិទ្ធិពលរដ្ឋ គឺ ដកហូត សិទ្ធិ សម្រាប់ពលរដ្ឋ, សិទ្ធិ ខាងនយោបាយ និង សិទ្ធិគ្រប់គ្រង គ្រួសារ ពីទណ្ឌិត មិនឲ្យប្រើប្រាស តទៅទៀត ។ ជន ដែលត្រូវ អនុទោសត្រង់ស្ថាន នេះ ត្រូវគ្មាន សមត្ថភាព ដូចតទៅ:

១– គ្មានសមត្ថភាព ក្នុងការបោះឆ្នោត ;

២– ហូតងារ ឬ បណ្ដេញចេញ ពីមុខងារ សាធារណៈ ឬ មុខងារ ជាកិត្តិយស ;

៣– តំហាត់ មិនឲ្យតាក់តែង ជាក្រុមជំនុំ សាលាឧក្រិដ្ឋ, មិនឲ្យរើស

ធ្វើ ជាអ្នកជំនាញ, ជាអាជ្ញាកណ្តាល ឬ ជាអ្នកថណាយក្តីឡើយ ;

៤– គ្មានសមត្ថភាព ក្នុងការធ្វើជាសាក្សី ក្នុងកិច្ចការទាំងឡាយ ឬ ឆ្លើយឲ្យការ ក្នុងតុលាការ ប៉ុន្តែបើឆ្លើយ គ្រាន់តែជាពត៌មានបាន;

៥– គ្មាន សិទ្ធិ ពាក់គ្រឿងឥស្សរិយយស ឬ គ្រឿងកិត្តិយស;

៦– គ្មាន សិទ្ធិ កាន់គ្រឿងសស្ត្រាវុធ អ្វី ;

៧– គ្មានសិទ្ធិ កាន់កាប់ សាលារៀន ឬ បង្រៀន ហើយមិនឲ្យធ្វើជាគ្រូ, ជាសាស្ត្រាចារ្យ ឬ ជាអនុរក្ស ក្នុងសាលារៀន ណាមួយ ;

៨– មិនឲ្យធ្វើ ជាកងពលតម្រួត ឬ ជាទាហាន ក្នុងខេមរភូមិន្ទ ;

៩– គ្មានសិទ្ធិ ធ្វើជាបណ្ណាធិការ នៃកាលិកប័ត្រ ;

១០– តំហាត់ មិនឲ្យចូលរួម ក្នុងក្រុមប្រឹក្សាញាតិ, ក្រុមប្រឹក្សាយុត្តិធម៌, ធ្វើ ជាហិតុប្បត្ថម្ភក៍ ឬ អាណាព្យាបាល នៃអនីតិជន, វៀរតែអនីតិជននោះ ជាកូនបង្កើតនៃខ្លួនប៉ុណ្ណោះទើបធ្វើបាន; ប៉ុន្តែ ខត្រង់នេះ ក៏ត្រូវឲ្យក្រុមប្រឹក្សាញាតិ យល់ព្រម ផងដែរ ;

១១– គ្មានសមត្ថភាព នឹងធ្វើ ជាតំណាងពេញផ្លូវការ នៃសមូហភាព ស៊ីវិល ឬ សាសនា ដូចជាធ្វើ ប្រតិភូ ឬអាណត្តិជន ជាដើម ។

មាត្រា៥០.– ទោសឧក្រិដ្ឋ បន្ថយ សិទ្ធិ ពលរដ្ឋ របស់ទណ្ឌិត ដោយឯង ៗ; ចៅក្រម មិនបាច់បញ្ជាក់ ត្រង់នេះ ជាពិសេស

00222182





ទៀតទេ ហើយ ចៅក្រម ក៏មិនអាចឲ្យ ទណ្ឌិត ឧក្រិដ្ឋនេះ រួច អនុទោស ត្រង់ស្ថាននេះ បានដែរ ។

មាត្រា ៨១- ទោសគុកមធ្យម នឹងបន្ថយ សិទ្ធិ នៃពលរដ្ឋនេះ បាន, លុះណាតែ ចៅក្រម បានសំរេចថា ត្រូវបន្ថយសិទ្ធិដូច្នេះផង ។ ចៅក្រម អាចនឹងកាត់ សេចក្តី ឲ្យបន្ថយ សិទ្ធិ ដែលជាអនុទោស របស់ទោសគុកជាមធ្យមនេះ ក៏លុះណាតែ ច្បាប់ អនុញ្ញាតឲ្យកាត់ផង ទើបបាន ។ បើច្បាប់អនុញ្ញាតហើយ ចៅក្រម អាចបន្ថយទាំងអស់ ឬ ខ្លះ ពីទណ្ឌិត នូវសមត្ថភាព ដូចពោល ក្នុងមាត្រា៤៩នេះបាន ។

មាត្រា ៨២- ទណ្ឌិត ត្រូវទទួល អនុទោស ត្រង់ស្ថានបន្ថយ សិទ្ធិពលរដ្ឋនេះ នៅវេលា ដែលខ្លួន បានទទួល មូលទោសអស់ហើយ គឺ អស់ ព្រោះគ្រប់កំណត់ទោសនោះ ក៏មាន, អស់ព្រោះដោះឲ្យនៅ ក្រៅឃុំ ដោយសារប្តូរទោស ឬ បន្ថយទោសអស់ជីវិត ក៏មាន ។

មាត្រា ៨៣- បើ ការបន្ថយ សិទ្ធិ នៃពលរដ្ឋនេះ ជាកម្មវិបាក នៃទោសឧក្រិដ្ឋ នោះ អនុទោសនេះ បន្ថយសិទ្ធិ របស់ទណ្ឌិត អស់មួយជីវិត ។ បើ ការបន្ថយ សិទ្ធិ នៃពលរដ្ឋនេះ ជាកម្មវិបាក

00222183





នៃទោសគុកមជ្ឈិមវិញ នោះអនុទោសនេះ អាចបន្ថយ សិទ្ធិ របស់ ទណ្ឌិត បានតែក្នុងរយៈវេលា ពីប្រាំឆ្នាំ ទៅដល់ ដប់ឆ្នាំ ប៉ុណ្ណោះ ។

## ចំពូកពីរ

## អំពី គំហាត់ ជានិត្យានុកូល

### De l'interdiction légale

មាត្រា៨៤– គំហាត់ ជានិត្យានុកូល គឺ ការដកសិទ្ធិ ពីទណ្ឌិត មិនឲ្យគ្រប់គ្រង និងចាត់ចែង សម្បត្តិ, ធនធានខ្លួន តាមអំពើចិត្ត ។

មាត្រា៨៥ ក្នុងរយៈវេលា ដែលខ្លួន កំពុងរងទោស, ទណ្ឌិត ដែលមានទោស ឧក្រិដ្ឋ ត្រូវនៅ ក្នុងគំហាត់ ជានិត្យានុកូលដោយឯង ។ គំហាត់ ជានិត្យានុកូលនេះ មាន អានុភាព ធ្វើឲ្យ ទណ្ឌិត បាត់បង់ នូវ សិទ្ធិគ្រប់គ្រង និង ចាត់ចែង បេតិកភណ្ឌ របស់ខ្លួន ។ បេតិកភណ្ឌ នៃទណ្ឌិតនោះ ត្រូវចាត់ ឲ្យមនុស្សណាម្នាក់ កាន់កាប់ជំនួស តាម បញ្ញត្តិ មាត្រា ៤៦៨ ទៅដល់ មាត្រា ៤៧៣ ក្រមរដ្ឋប្បវេណី ។

មាត្រា ៨៦ – ទណ្ឌិត ដែលមាន ទោសឧក្រិដ្ឋ ឬ ទោស

00222184

D99/3/3



គុក ព្រោះបានប្រព្រឹត្ត បទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ មិនអាច ទុកជាប់នឹងខ្លួន, ក្នុងខណៈ ដែលខ្លួន កំពុងនៅទោស, នូវប្រាក់កាស អ្វី ឬ ស្បៀងអាហារអ្វី ឬ ភាគសម្បត្តិទ្រព្យ ឬ ផលអាករ អ្វី បានឡើយ ។ អំណោយ, ដែលឲ្យ ដោយសទ្ធា ដល់ឈ្មោះណា ។, ក្នុងខណៈដែលខ្លួន កំពុងនៅទោសនោះ, ត្រូវទុក ជាមោឃៈ ។ វៀរតែ ឲ្យទៅញាតិសាលោហិត ក្នុងត្រកូលខ្លួន ឬ ក្នុងករណី នៃ បទបញ្ញត្តិ ស្តី ពីសំបុត្របណ្តាំនោះ ទើបបាន ។

## ជំពូក បី

## អំពី គំហាត់ លំនៅ

## De l'interdiction de séjour

មាត្រា ៨៧ – គំហាត់ លំនៅ គឺ ការឃាត់ហាម ទណ្ឌិត ដែលទើបនឹងរួច ពីរងមូលទោសនោះ មិនឲ្យទៅនៅ ទីកន្លែងណា ។, ដែលបានប្រាប់ ឲ្យទណ្ឌិតនោះ បានដឹងជាមុន, ក្នុងរយៈវេលា មានកំណត់ ។ ទណ្ឌិត អាចសុំ ឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បង្អង់ អនុវត្តិ អនុទោសនោះ បាន ១៨ ថ្ងៃ ។ រដ្ឋមន្ត្រីយុត្តិធម៌ នឹងអនុញ្ញាតឲ្យបាន តែដោយសារ ថាទណ្ឌិត មានធុរៈអ្វីមួយជាទម្ងន់ ដែលទណ្ឌិត ត្រូវជូន កស្តុតាង ឲ្យឃើញពិតប្រាកដ ជាតប្បីផង ៖

មាត្រា ៥៨ – អំពី អនុទោស គំហាត់ លំនៅនេះ បើចៅក្រម ចង់ ធ្វើ ទោសនេះ ក៏បាន មិនធ្វើ ក៏បាន ។

មាត្រា ៥៩ – ក្នុងរឿងទុច្ចរិត, គំហាត់លំនៅ អាចសំរេចបាន ជាដាច់ ក្នុងវេលា យ៉ាងតិចប្រាំឆ្នាំ យ៉ាងច្រើនម្ភៃឆ្នាំ ។

មាត្រា ៦០ – ក្នុងរឿងមជ្ឈិម, គំហាត់លំនៅ អាចនឹងសំរេចបាន តែ ក្នុងករណីណា ដែលច្បាប់ អនុញ្ញាតឲ្យធ្វើផង ទើបបាន ហើយ កំណត់ហាមឃាត់នោះ យ៉ាងតិចប្រាំឆ្នាំ យ៉ាងច្រើនដប់ឆ្នាំ ។

មាត្រា ៦១ – រយៈវេលា របស់ អនុទោសនោះ ត្រូវគិត តាំង ពីថ្ងៃ ដែលបានទទួលរង មូលទោស រួចហើយ ។

មាត្រា ៦២ – ទណ្ឌិតណា បានរងទោស ដែលផ្តូរ ពីទុច្ចរិតអស់ មួយជីវិត មកទោសស្រាលវិញ រួចអស់ហើយ ទណ្ឌិតនោះ នឹងត្រូវជាប់ គំហាត់លំនៅទៀត លុះណាបើព្រះរាជក្រឹត្យដែលអនុគ្រោះឲ្យផ្តូរទោស នោះ បានដាក់អនុទោសនេះ ដល់ទណ្ឌិតនោះ ។

មាត្រា ៦៣ – គំហាត់លំនៅ នឹងទុក ជាត្រឹមត្រូវ តាមច្បាប់

បាន លុះតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបង្គាប់ឲ្យ ឲ្យដំណឹង ដល់ទណ្ឌិត អំពីកន្លែង ទីង ខែត្រ ដែលសាលក្រម ហាមមិនឲ្យទណ្ឌិតនោះ ទៅនៅ ។

មាត្រា ៦៤ – បើដំណឹងនេះ ប្រាប់ ដល់ទណ្ឌិត ដោយយឺតយូរនោះ, ពេល ដែលកន្លង តាំងពីថ្ងៃ ដែលដោះទណ្ឌិត ទៅដល់ថ្ងៃ ដែលឲ្យដំណឹង ដល់ទណ្ឌិតនោះ ត្រូវយកមកកាត់ ទីងរយៈវេលា គំហាត់ នោះចេញ ។

## ចំពូក បួន
## អំពី ប្រកាស ទណ្ឌកម្ម
### De la publicité des condamnations

មាត្រា ៦៥ – ទណ្ឌកម្ម ជាទោសឧក្រិដ្ឋ ត្រូវផ្សាយ តាមសេចក្តីសុំ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ដោយយក កំណត់ដៃ នៃសាលដីកា (Arrêt) ទៅបិទ :

១.– នៅ សាលាឧក្រិដ្ឋ ;

២.– នៅ កន្លែង ដែលប្រព្រឹត្ត បទឧក្រិដ្ឋ ;

៣.– នៅ លំនៅ របស់ទណ្ឌិត ;

៤.– នៅ ទីឃាត, ប្រសិនបើ ជាទោស ប្រហារជីវិតបង់ ។

00222187

D99/3/3



# ចំពូក ប្រាំ

## អំពី របឹប

## De la confiscation

មាត្រា ៦៦- របឹប គឺ កិរិយារឹបអូស វត្ថុអ្វីៗ ដែលជាបច្ច័យទាក់ទង នឹងបទល្មើស ដើម្បីជាប្រយោជន៍រាជការ ។

មាត្រា ៦៧ - វត្ថុ ដែលគប្បីរឹបអូសយកនោះគឺ :

១- វត្ថុ ជារូប នៃទោសកម្ម គឺវត្ថុទាំងពួង ដែលជាសម្ភារៈ របស់បទល្មើស ;

២- វត្ថុទាំងឡាយ ដែលកើត អំពីបទល្មើស, គឺវត្ថុ ដែលជាផល នៃបទល្មើសនោះ ;

៣- ប្រដាប់ប្រដា សំរាប់ប្រព្រឹត្ត បទល្មើស, គឺគ្រឿងប្រដាប់ ដែលយកទៅប្រើ ឬ ដែលត្រូវយកទៅប្រើ ដើម្បីប្រព្រឹត្តបទល្មើសនោះ ។

មាត្រា ៦៨ - ក្នុងបទឧក្រិដ្ឋ, មជ្ឈិម ឬ លហុ, ចៅក្រម អាចសំរេច អនុទោសរឹបនេះបាន ។ ប៉ុន្តែ ក្នុងបទលហុ, ចៅក្រមនឹងបង្គាប់ឲ្យរឹបអូស បាន, លុះតែ អត្ថបទច្បាប់ ដែលយកមកអនុវត្តនោះ អនុញ្ញាតឲ្យ រឹបអូសផង ទើបបាន ។

វត្ថុ ដែលរឹបអូស ត្រូវប្រគល់ ឲ្យក្រុមសាធារណៈ ណាមួយ ឬ

ត្រូវលក់ ឬ ត្រូវបំផ្លាញចោល ។ វត្ថុ ដែលត្រូវប្រគល់ ឲ្យក្រុមសាធារណៈ ណាមួយនោះ គឺវត្ថុ ដែលក្រុមនោះ អាចយកទៅប្រើប្រាស់បាន ហើយ ដែលឯកជន នឹងទិញ ដោយសេរី ពុំបាន; ដូច ជាគ្រឿងសស្ត្រាវុធ, គ្រាប់រំសេវ នឹង ប្រដាប់ប្រដា សំកប់ទោរ ជាដើម ។

វត្ថុ ដែលសាលាជំបូង ត្រូវលក់ឡាយឡុងបាន គឺ វត្ថុដែលអ្នកដទៃ នឹងទិញយកទៅប្រើប្រាស់បាន ដោយសេរី ។

វត្ថុ ដែលត្រូវបំផ្លាញចោល តាមកំណត់ហេតុ ដែលមាន ហត្ថលេខា របស់ចាងហ្វាង នឹង ក្រឡាបញ្ជីនោះ គឺវត្ថុ ដែលក្រុមសាធារណៈ យកទៅប្រើប្រាស់ ពុំបាន ហើយលក់ ឲ្យទៅឯកជន ក៏ពុំបានដែរ; ដូចជាវត្ថុក្លែង, រូបិយវត្ថុក្លែង, ឧបករណ៍ក្លែង, ឬ មិនត្រឹមត្រូវ តាមច្បាប់ សម្រាប់ថ្លឹង ឬ វាល់, ទំនិញក្លែងក្លាយ, បន្លំធ្វើតាម, គ្រឿងបរិភោគ នាំឲ្យខូច ដល់សុខភាព ជាដើម ។

## ជំពូក ប្រាំមួយ

## អំពី ទណ្ឌកម្ម ឲ្យសង សំណង នឹង ឲ្យបង់ ជម្ងឺចិត្ត

De la condamnation aux restitutions et dommage- intérêts

មាត្រា ៦៩.– ចៅក្រម ត្រូវកាត់ទោស តាមកំរិតទោស ដែលមានបញ្ញត្តិ ក្នុងច្បាប់ ជាដកប ហើយកុំឲ្យមានព្យសនកម្ម ដល់ពាក្យ

00222189

D99/3/3



សុំ សំណង ទាំង ជម្ងឺចិត្ត ដែលអ្នករងគ្រោះ បានតាំងខ្លួន ជាភាគីស៊ីវិល ឡើយ ប្រសិនបើ ពាក្យនោះត្រឹមត្រូវគួរកាត់ឲ្យបាន ។

នាកាលបើ បទល្មើសនោះ បណ្ដាល ឲ្យខូច ប្រយោជន៍ជាសម្ភារៈ របស់ពលការសាធារណៈ, ចៅក្រម ត្រូវតែកាត់សេចក្ដី ឲ្យជួសជុល សេចក្ដីវិនាស ជាការតព្វកិច្ច ទាំងដោយឯង ។ ដោយឥតបាច់ ឲ្យមាន តាំងខ្លួនជាភាគីស៊ីវិលឡើយ ។ ភាគីស៊ីវិល អាចនឹងសុំឲ្យធ្វើ អំណួស បង្ការ (Saisie conservatoire) ទ្រព្យសង្ហារិម និង អសង្ហារិម របស់ មនុស្សត្រូវចោទ ព្រមទាំង អំណួសឃាត់ (Saisie-arrêt) ទ្រព្យប្រាក់ដែល ត្រូវបានមក មនុស្សត្រូវចោទនេះ ទៀតក៏បាន ។ ចាងហ្វាងសាលា ដែលទទួលជំនុំជំរះ រឿងនោះ ត្រូវចេញដីកា (ordonner) បង្គាប់ឲ្យឃាត់ ទ្រព្យ របស់ តាមសុំ ឬ ក៏ បដិសេធ ពាក្យសុំ ឃាត់នោះ ភ្លាម ដោយគ្មានចារថ្ងៃ ទាំង ដោយឥតត្រូវបង្អែបង្អង់ឡើយ ។

បើ ភាគី ខាងណា មិនសុខចិត្ត នឹងដីកា ដូចមាននិយាយ ខាងលើនេះទេ, ភាគីខាងនោះ ត្រូវឧទ្ធរណ៍ ទៅសាលាក្រុមចោទ ក្នុងរវាង ដប់ថ្ងៃ, គិត តាំងពីថ្ងៃ ដែលបានទទួល ដំណឹងពីដីកានោះ ។ បើសេចក្ដី សម្រេច របស់សាលាក្រុមចោទ នៅតែ មិនពេញចិត្តទៀត, ភាគី នោះ ត្រូវប្ដឹងសារទុក្ខ ទៅសាលាវិនិច្ឆ័យ ក្នុងរវាង ដប់ថ្ងៃ ដូចគ្នា, គិត តាំងពីថ្ងៃ ដែលទទួលដំណឹង ពីសេចក្ដីសម្រេច របស់សាលាក្រុមចោទ

នោះ ៗ បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខ ដល់សាលាវិនិច្ឆ័យនោះ ផងត្រូវឲ្យបង់តម្លៃក្ដីទេ គឺត្រូវប្ដឹងបាន ទទេ ហើយ សាលា ត្រូវសម្រេច សេចក្ដី ជាប្រញាប់ ។ បើសាលា អនុញ្ញាតឲ្យឃាត់ របស់ទ្រព្យ តាមសុំហើយ, ចៅហ្វាយត្រូវចាត់សមុហបញ្ជីម្នាក់ ឬ មន្ត្រីក្រុមព្រះនគរបាលយុត្តិធម៌ម្នាក់, ឲ្យធ្វើ បញ្ជី កត់ របស់ទ្រព្យ ហើយចាត់ឆ្មាំម្នាក់ ឲ្យថែរក្សា របស់ទ្រព្យទាំងនោះ ដោយទទួលខុសត្រូវ លើខ្លួន ។

នាកាលបើ ជំនុំជំរះទៅហើយ, ចៅក្រម យល់ថា ត្រូវឲ្យ មនុស្សត្រូវចោទ រួចខ្លួន ពីសេចក្ដីចោទ, ចៅក្រមត្រូវបង្គាប់, ក្នុងសេចក្ដីសម្រេចរបស់ខ្លួន, ថាឲ្យលើក អំណួសនោះចេញ ។

មាត្រា ៧០– មនុស្សទាំងឡាយណា ត្រូវទោស ឧក្រិដ្ឋ ឬ មជ្ឈិម ជាមួយគ្នា ជាសហចារីក្ដី ជាអ្នកចូលគំនិតគ្នាក្ដី មនុស្សទាំងឡាយនោះត្រូវមានទោសឲ្យរួបរួមគ្នា សង ប្រាក់សំណងនិងបង់សោហ៊ុយជម្ងឺចិត្ត ឲ្យដើមក្ដី ស៊ីវិល ។

មាត្រា ៧១– របៀបចារ ប្រាក់សំណង និង ប្រាក់ជម្ងឺចិត្ត នេះ ត្រូវចារ តាមវិធាន ដូចមាន បញ្ញត្តិ ក្នុងមាត្រា ១០ ទៅដល់ មាត្រា ១៣ ។

00222191

D99/3/3



មាត្រា ៧២- ចៅក្រម អាចកាត់ ឲ្យបង្វិល របស់តាំង ដល់ កម្មសិទ្ធិករ ជាធម្មានុរូបនោះ បាន ជាដរាប, មិនបាច់ ឲ្យកម្មសិទ្ធិករ តាំងខ្លួនជាភាគីស៊ីវិល ទេ ។

កាលណាបើ សាលក្រម មានលក្ខណៈ ជាស្ថាពរហើយ, ក្រឡាបញ្ជី, ដែលបានទទួលទុក របស់តាំងនោះ, ត្រូវប្រគល់ របស់នោះ ដល់កម្មសិទ្ធិករ ហើយ ត្រូវឲ្យអ្នកទទួលនោះ ទុកសញ្ញាអ្វី ជាគ្រឿងសំគាល់ ថាខ្លួន បានយក របស់នោះហើយ ។

របស់តាំង, ដែលពុំបានប្ដឹងសុំ យកវិញ ក្នុងរយៈវេលា មួយឆ្នាំ, គិត តាំងពីថ្ងៃ ដែលសាលក្រម មានលក្ខណៈ ជាស្ថាពរមក, ត្រូវលក់ឡាយឡុង ទៅសាលាដំបូង ដែលរក្សា របស់តាំងទាំងនោះ ។ ការលក់ឡាយឡុង ម្ដង ១ ត្រូវលក់ តាមបង្គាប់ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្រឡាបញ្ជី ត្រូវឲ្យ ដំណឹង យ៉ាងតិច មួយខែ មុនថ្ងៃ ដែលសម្រេចថា លក់ ទៅម្ចាស់របស់ ប្រសិនបើស្គាល់ ។ ក្នុងរវាង មួយខែ មុនថ្ងៃលក់ នេះ, ម្ចាស់ របស់តាំង អាចចូលទៅ សុំដកយក របស់តាំងនោះ បាន ឬ ជូនដំណឹងថា: ខ្លួន មិនជំទាស់ នឹងការលក់ នោះ ទេ, ហើយថា ខ្លួន សុំទាមទារ តែថ្លៃលក់ ប៉ុណ្ណោះ ។

របស់តាំង នឹងប្រគល់ឲ្យវិញ ឬលក់បាន, លុះតែ ប្រភេទ នៃរបស់

ការនោះ មិនតម្រូវឲ្យរើបអូស ទេ , ដូចដែលមានសំដែង ក្នុងមាត្រា ៦៣ ទៅដល់មាត្រា ៦៨ នោះ ។

## ជំពូក ប្រាំពីរ
## អំពី បព្វាជនីយកម្ម
## De la relégation

មាត្រា ៧៣ – បព្វាជនីយកម្ម គឺ ការយក ទណ្ឌិត ពុំកង់ចាល ដែលប្រកប គ្រប់លក្ខខណ្ឌ ដូចមានសំដែង ក្នុងមាត្រា ១៦ នៃក្រមនេះ ទៅឃុំឃាត់ ជាអង្វែង ក្នុងទីឃុំឃាត់ ជាពិសេសណាមួយ ។ ទោសនេះ មិនត្រូវអនុវត្ត ទៅលើមនុស្សជក អាយុជាង ហុកសិប ឆ្នាំ , ទៅលើស្ត្រី ទីង ទៅលើអនីតិជន អាយុតិចជាង ដប់ប្រាំបីឆ្នាំទេ ។

មាត្រា ៧៤ – មនុស្សមានទោស បព្វាជនីយកម្មនេះ ត្រូវនៅ ក្នុងរបប ច្បាប់ បញ្ញត្តិ ជាធរមាន ។

មាត្រា ៧៥ – ចំពោះអនុទោស បព្វាជនីយកម្មនេះ , តុលាការ នឹងកាត់សេចក្ដី ធ្វើទោស ឬ មិនធ្វើ បានជាដរាប ។ ក៏ប៉ុន្តែ បើ អនុ-ទោសនោះ គួរដល់ការអនុវត្តហើយ តែចៅក្រម យល់ថា មិនគួរអនុវត្តសោះវិញទេ, នោះ ចៅក្រម ត្រូវដាក់ឲ្យច្បាស់ថា មនុស្សនេះ ត្រូវបាន រំលោះលា ចាកអនុទោស បព្វាជនីយកម្ម ។

# គន្ថី ពីរ

# អំពី ជនដែលគួរដាក់ទណ្ឌកម្ម

## DES PERSONNES PUNISSABLES

## បទ បញ្ញត្តិ បុរេភាគ

## DISPOSITIONS PRÉLIMINAIRES

មាត្រា ៧៦ – ជនទាំងពួងណា មានសតិ ជាល្អ, មានវិចារបញ្ញា ស្គាល់ ល្អ, អាក្រក់, ជនទាំងពួងនោះ ត្រូវមានការៈ ទទួលខុសត្រូវ តាមច្បាប់ ព្រហ្មទណ្ឌ ចំពោះបទល្មើស ដែលខ្លួនប្រព្រឹត្ត, ចំពោះបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលខ្លួន សមគំនិត នឹង ចំពោះបំណង ជាឧក្រិដ្ឋ ឬ បំណង ជា មជ្ឈិមខ្លះ ដែលខ្លួន បានធ្វើ ឲ្យប្រកប នឹងលក្ខខណ្ឌ ដូចដែលមាន បញ្ញត្តិ ក្នុងច្បាប់ ។

ជននេះ នឹងរួច ពីគោលច្បាប់នេះ បាន ក៏លុះណាតែមានច្បាប់ បញ្ញត្តិផ្សេងទៅទៀត គឺផ្សេង ដោយហេតុថា មានកាលៈទេសៈ នាំឲ្យអំពើនោះ ប្រកបដោយធម្មានុរូប, ប្រកបដោយយុត្តិកម្ម ឬ ក៏គួរឲ្យសន្តោស, ឬ មួយ ផ្សេង ដោយហេតុថា ពេល, កាល, ដែលប្រព្រឹត្ត បទល្មើសនោះ កន្លងទៅ យូរនៃថ្ងៃពេក ។

# មាតិកា មួយ
## អំពី បំណង
### De la tentative

មាត្រា ៧៧ – ជនណា មានបំណង នឹងប្រព្រឹត្ត បទល្មើស, ជននោះ ត្រូវមាន ទោស ។ ដែលហៅថា បំណង គឺអំពើ ដែលមាន លក្ខណៈ ពីរយ៉ាង ដូចតទៅនេះ ៖

១ – ការចាប់ផ្ដើម ធ្វើ នូវអំពើល្មើសណាមួយ

២ – អំពើនោះ មិនបានសម្រេចទៅវិញ ដោយសារមាន កាលៈ ទេសៈអ្វីមួយ មកបង្អាក់ ឲ្យខានសម្រេច ខុសពីឆន្ទៈ នៃចារី

មាត្រា ៧៨ – ឯការរៀបចំ បម្រុង នឹងប្រព្រឹត្ត បទល្មើស មិនទាន់ទុកជា ការចាប់ផ្ដើម ប្រតិបត្តិ បានទេ ។

មាត្រា ៧៩ – បំណង នឹងប្រព្រឹត្ត បទឧក្រិដ្ឋណាមួយ ត្រូវ ទុក ដូចជា បានប្រព្រឹត្ត បទឧក្រិដ្ឋនោះ ដែរ ។

មាត្រា ៨០ – បំណង ក្នុងទោសកម្ម នឹងទុក ដូចជា បាន ប្រព្រឹត្ត ទោសកម្ម នោះ បាន, លុះតែ ច្បាប់ មានបញ្ញត្តិ ជាពិសេស បានបញ្ជាក់ ទៀតផង ទើបបាន ។

មាត្រា ៨១ – បំណង ក្នុងលហុកម្ម មិនត្រូវធ្វើទោសទេ ។

00222195





# មាតិកា ពីរ

## អំពី ការចូលរួមប្រព្រឹត្ត ជាមួយ

## De la participation

មាត្រា ៨២ – ជនណា ចូលរួមប្រព្រឹត្ត ដោយចេតនា នូវ ឧក្រិដ្ឋកម្ម, ទោសកម្មណាមួយ ដោយផ្ទាល់ក្តី, ដោយប្រយោលក្តី, ជននោះត្រូវមាន ទោស ដូចជា កាទិការី ។ ការរួមប្រព្រឹត្ត ដោយផ្ទាល់នោះ ទុក ជាសហការី, ឯ ការរួមប្រព្រឹត្ត ដោយប្រយោល ទុក ជា សមគំនិត ។

មាត្រា ៨៣ – ការរួមប្រព្រឹត្ត ដោយប្រយោល ឬ ដោយសមគំនិត នឹងអាចមាន ទោស បាន គឺលុះតែ អំពើនោះ បានសម្រេច មក ពីការនាំអាទ៌, ការឲ្យអនុទ្ទេស, ការផ្តល់ មធ្យោបាយ, ការជួយ ឬ ការទំនុកបំរុង ។

មាត្រា ៨៤ – ការនាំអាទ៌ គឺ ការចាក់រុក, អុចអាល, ឲ្យ អ្នកដទៃ ប្រព្រឹត្ត នូវអំពើ ណាមួយ ដោយសារពាក្យខ្លួន, បង្គាប់ ឬ ណែនាំ របស់ខ្លួន ។

អ្នកទូន្មាន ឬ អ្នកបង្គាប់ ត្រូវមាន ទោសបាន, លុះតែ អ្នកនោះ

មាន អំណាច លើមនុស្ស អ្នកប្រព្រឹត្ត បទល្មើសនោះ ឬ, ពុំនោះទេ, អ្នកនោះ ធ្វើអំណោយ ឬ សន្យាអ្វីមួយ, ឬ គំរាម ឬ បង្ខំ ជារីនោះ ។

ពាក្យណែនាំ ត្រូវមានទោសបាន, លុះតែ ពាក្យនោះ ជាឧបាយកល ណាមួយ សម្រាប់ ញុំាងចិត្ត ជារ៍ ឲ្យញាប់ញ័រ ហើយជម្រុញជននោះ ឲ្យប្រព្រឹត្ត បទល្មើសនោះ ទានមិនបាន ។

មាត្រា ៨៥ – អនុទេស គឺពត៌មាន ដែលឲ្យ ដោយដឹងច្បាស់ ក្នុងចិត្តឯង ជាមុន ថា ជារ៍ នឹងយក ពត៌មាននេះ ទៅប្រើប្រាស់ក្នុងការប្រព្រឹត្ត បទល្មើសនោះ ជាមិនខាន ។

មាត្រា ៨៦ – មធ្យោបាយ គឺសម្ភារៈ ដែលគេយក ទៅសម្រេច បទល្មើសនោះ បាន ហើយកាលឲ្យ គ្រឿង ប្រដាប់នោះ ក៏បានដឹងថា របស់នេះ មុខជា ជារ៍ នឹងយកទៅប្រព្រឹត្ត បទល្មើសនោះ ហើយ ។

មាត្រា ៨៧ – ជំនួយ ឬ ការទំនុកបំរុង គឺ ការជួយ ដោយដឹងច្បាស់ ថានឹងសម្រួល ឬ ធ្វើឲ្យងាយ ប្រព្រឹត្ត អំពើល្មើសនោះ ។ ក្នុង ១ នេះ, ទំនុក ជំនួយ ឬ សេចក្តីទំនុកបំរុងនោះ ថាជា

សហចារី ដោយផ្ទាល់ បាន, លុះតែ សហចារីនោះ ធ្វើឲ្យបាន អំពើល្មើសនោះ សម្រេចផង ។

មាត្រា ៨៨ - ក្នុងរឿងលហុ, ការរួមប្រព្រឹត្ត មិនមានទោសទេ ។

## មាតិកា បី

## អំពី ជន គ្មាន ភារៈ ទទួល ខុសត្រូវ

## Des personnes non responsables

### ជំពូកមួយ

### អំពីវិបត្តិស្មារតី

### de l' aliénation mentale

មាត្រា ៨៩ - មនុស្ស វិកលចរិត និង មនុស្ស ខ្សោយសតិ ទាំងអស់នេះ មិនមានភារៈ ទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌ ចំពោះ អំពើល្មើស ដែលខ្លួនគេ បានប្រព្រឹត្ត នោះទេ, កាលណាបើ មានតឹកតាងច្បាស់ ថា វេលា ដែលប្រព្រឹត្តអំពើល្មើសនោះ, មនុស្សនេះពិតជា មានចរិត កំពុងវិកល ឬ ពិតជា មានសតិ មិនប្រក្រតី ។

ប៉ុន្តែ ក្នុងបទស៊ីវិល ជនទាំងនេះ នៅតែមាន ភារៈទទួលខុសត្រូវ ដដែល ។ ជនដែលព្យាបាល, ដែលយាម, ដែលអនុរក្ស នូវមនុស្ស

វិកលចរិត ទន់ មនុស្ស ខ្សោយសតិនោះ ក៏ត្រូវមានការៈទទួលខុសត្រូវ ជួសជុល ព្យសនកម្ម ដែលបណ្ដាលមក ពីបទល្មើសនោះដែរ ; ក៏ប៉ុន្តែ ជនទាំងនេះ មិនត្រូវ គេ ដាក់ គុក បន្ទំទោស សំណងនោះ ឡើយ ។

មាត្រា ៩០ – បរិតវិកល ឬ សតិ បញ្ញា មិនប្រក្រតីនេះ ត្រូវ មានតឹកតាង ជាពិតប្រាកដ ណាស់, បើ មានការ សង្ស័យ, ចៅក្រម ត្រូវតែ ប្រើ គ្រប់មធ្យោបាយ ខាងស៊ើបសួរ ដើម្បី ឲ្យខ្លួន ចុះ ចិត្តស៊ប់ ក្នុងជំនឿនោះ ផង ។ កាលបើ លទ្ធផល នៃការស៊ើបសួរ នៅតែ មិនគ្រប់គ្រាន់ ទៀតទេ, នោះ ចៅក្រម ត្រូវតែ ពឹង ផ្អែក ទៅ លើកោសលវិច្ច័យ របស់ ពេទ្យ ទើបបាន ។

## ចំពូក ពីរ
## អំពី អនីតិភាព ក្នុងបទព្រហ្មទណ្ឌ
## DE LA MINORITÉ PÉNALE*

(ព្រះរាជក្រមលេខ ១៦៥ – ce ចុះថ្ងៃ៣–១–៦៤ បាននិរាករ បទបញ្ញត្តិ មុន នៃ មាត្រា៩១, ៩២, ៩៣, ៩៤, ៩៥ ហើយ យក បញ្ញត្តិ ថ្មី ខាងក្រោមនេះ មកជំនួសវិញ)

មាត្រា ៩១ (ថ្មី).– មនុស្សជាប់ចោទ ដែលគេ ប្រាស់ថា ជាពិរុទ្ធជនហើយ តែ មាន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ក្នុងខណៈ

00222199





ប្រព្រឹត្តបទល្មើស នោះត្រូវប្រមាណ ថា វាមិនទាន់ដឹង ខុសត្រូវ នឹង មិនត្រូវទទួល ខុសត្រូវ ទេ

ជននេះ ត្រូវបានផុត ពីការទោសប្រឆាំង , ផុត ពីទោសដែរ ទាំងអស់, ប៉ុន្តែ តុលាការ ត្រូវសំរេច ថា ឲ្យ ជននោះ នៅ ក្រោមការ ឧបត្ថម្ភ, ការសង្គ្រោះ , ការត្រួតត្រា , ការអប់រំ ឬ ការកែខ្លួន ណាមួយ ក្នុងថិរវេលា ដែលមានកំណត់ ។

ទោះបើ មានហេតុការណ៍ យ៉ាងណា ក៏ដោយ ក៏តុលាការ មិនអាច ឲ្យក្មេងនោះ នៅ ក្រោមវិធានការ ខាងលើនេះ ហួសថ្ងៃ ដែលវាដល់ អាយុ ម្ភៃមួយ ឆ្នាំ ដែរ ។

មាត្រា ៩២ (ថ្មី).- អនីតិជន អាយុ ពីដប់ប្រាំ ឆ្នាំ ដល់ដប់ប្រាំពីរ ឆ្នាំ ដែលបានប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ ទោសកម្ម នោះ មិនត្រូវ ប្រមាណឲ្យផុត ពីការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌ ទេ កាល ណាបើ កាលៈទេសៈ ឬ បុគ្គលភាព នៃអនីតិជននោះ តម្រូវ ឲ្យ ទទួលខុសត្រូវ ។ ក្នុងករណីនេះ អនីតិជននោះ ត្រូវមាន ទោស ដូចមានសម្តែង ក្នុងមាត្រា ពី ១១៧ ដល់ ១២១ ។

មាត្រា ៩៣ (ថ្មី).- ប៉ុន្តែ បើអនីតិជននោះ បានត្រូវប្រមាណ

00222200

D99/3/3



ឲ្យផុតពីការទទួលខុសត្រូវវិញ តុលាការត្រូវសម្រេច ទៅ តាមកាលៈទេសៈ ថា ក្មេងនោះ ត្រូវ :

១.– ប្រគល់ឲ្យ ឪពុក ម្តាយ , អាណាព្យាបាល ឬជន ដែល ធ្លាប់បានថែរក្សាមក ។

២.– ប្រគល់ឲ្យ ជនណា ដែលគួរទុកចិត្តបាន ឬ អង្គការណា មួយ ដែលមាន និតិសម្បទា ខាងថែរក្សាបាន ។

៣.– យកទៅដាក់ ក្នុងគ្រឹស្ថាន ដែលមានសម្បទា ខាងសិក្សាអប់រំ , ប្រដៅ ឬ បង្ហាត់វិជ្ជាជីវៈ ដែលជារបស់សាធារណៈ ឬ របស់ឯកជន ។

៤.– យកទៅដាក់ ក្នុងគ្រឹស្ថានដែលមាននីតិសម្បទា ខាងពេទ្យ ឬ វិទ្យាល័យ ខាងវិចត្តបវេត ចាប់តាំងពីថ្ងៃ ដែលចោទប្រកាន់មក សុភាចារបុរស អាចបង្គាប់ ឲ្យនៅក្នុងវិធានណាមួយ បណ្តាវិធាន ទាំងបួន ខាងលើនេះ ជាបណ្តោះអាសន្នបាន ។

មាត្រា ៩៤ (ថ្មី).– នាកាល បើ សុភាចារបុរសបានបង្គាប់ ជាបណ្តោះអាសន្ន ដូចមានសំដែង ក្នុងមាត្រា ៩៣ ខាងលើនេះហើយ ហើយសំណុំរឿងនោះ ក៏ត្រូវចេញ ពីសុភាចារបុរស មកជូនតុលាការ ជាអ្នកកាត់សេចក្តីវិញ នោះតុលាការ អាចនឹង បន្ត វិធានការ របស់

សុភាចារបុរសនោះ ដោយចេញមក ពីចិត្តឯង ក៏បាន, ដោយសារមាន សេចក្តីភយការណ៍ របស់អង្គការ ឬរបស់បុគ្គល ដែលទទួលភារៈខាង អនុរក្ស អនីតិជនល្មើសនោះក៏បាន, ដោយសារ មានពាក្យ ពីជន ដែល គ្រប់គ្រងក្មេងនោះ ប្តឹង មក ក៏បាន ។

តុលាការ មុន នឹងសម្រេច អំពីបន្ត ឬ មិនបន្ត វិធានការនេះ ត្រូវតែ ឲ្យស៊ើបសួរ ឬ, បើមានការ ចាំបាច់ទៅទៀត, ត្រូវតែ ឲ្យ ពេទ្យ ពិនិត្យ ពីរបត្តបរិត ជាមុនសិន ។

មាត្រា ៩៨ (ថ្មី) .– អនីតិជន អាយុ ពីដប់ប្រាំ ឆ្នាំ ដល់ដប់ប្រាំបី ឆ្នាំ ដែលពិតជាវិវដ្ឍន មែន ហើយដែលត្រូវតែទទួល ខុសត្រូវ នោះ ត្រូវឲ្យទៅទទួល ទោស ក្នុងគ្រឹស្ថានជាពិសេស ខាងអប់រំ ដែល ស្ថាបនាឡើង សម្រាប់ អប់រំ និងកែខ្លួន អនីតិជនល្មើស ។

ចំណែកខាង សុភាចារបុរស វិញ កាលសំណុំរឿង នៅលើដៃ ខ្លួននោះ, បើពិនិត្យទៅ ឃើញថា ត្រូវឃុំ អនីតិជន ដែលជាប់ចោទ ជាបណ្តោះអាសន្ននោះ ក៏ត្រូវយកទៅឃុំ ក្នុងគ្រឹស្ថាននោះដែរ ។

ព្រះរាជក្រមដែលនេះ បន្ថែមបទបញ្ញត្តិដូចខាងក្រោមនេះទៀត ។

មាត្រា ៣:- ការចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬ មជ្ឈិម មិនអាចសំរេច ទៅ លើ អនីតិជនអាយុពី ១៥ ឆ្នាំ ទៅដល់ ១៨ ឆ្នាំ បានឡើយ បើគ្មានការស៊ើបអង្កេត ជាមុនទេ ។

មាត្រា ៤ :- នៅតាមសាលាដំបូងណា ដែលមានមន្ទីរស៊ើបសួរច្រើន, ការស៊ើបសួររឿងក្តីដែលជាប់ទាក់ទង ដល់អនីតិជន អាយុពី ១៤ ឆ្នាំ ទៅទល់ ១៨ ឆ្នាំ ត្រូវប្រគល់ទៅឲ្យចៅក្រមស៊ើបសួរដដែល ដែលបានចាត់ឲ្យបំពេញ បេសកកម្មនោះ សម្រាប់ បី ឆ្នាំ តាមសេចក្តីសំរេច នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មាត្រា ៥ :- ក្នុងរឿងក្តីទាំងឡាយ ដែលជាប់ទាក់ទង ដល់អនីតិជន, គណប្រឹក្សាតុលាការត្រូវតែរៀបចំ រើសយកដោយខានមិនបាន នូវជន ដែលមានគុណសម្បត្តិគ្រប់គ្រាន់ ប្រកបដោយវិជ្ជាជីវៈក្តី ដោយការយកចិត្តទុកដាក់ ដែលជនទាំងនោះមាន ទៅលើកិច្ចការ នៃក្មេងនោះក្តី ។

ទីប្រឹក្សា តុលាការ ឯកទេសទាំងនោះ ត្រូវចាត់តាំងសម្រាប់ បី ឆ្នាំ តាមសេចក្តីសំរេច នៃរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្នុងចំណោម ជនដែលមានអាយុលើសពី ៣០ ឆ្នាំ ដោយជ្រើសរើសយក ពីក្នុងបញ្ជីមួយ ដែលបានធ្វើឡើង ក្រោយដែលបានពិគ្រោះសួរ ដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ក្រសួងអប់រំជាតិ និង ក្រសួង សង្គមកិច្ច ។

មាត្រា ៦ :- រឿងក្តីណា ដែលទាក់ទងទៅលើ អនីតិជន អាយុពី ១៤ ឆ្នាំ ទៅទល់ ១៨ ឆ្នាំ ត្រូវតែជំនុំជំរះ ជាចាំបាច់ នៅក្នុងបន្ទប់ស្ងាត់ ហើយដោយឡែកពីគ្នា គឺដាក់ឃាំងមុខ នៃមនុស្សត្រូវចោទក្នុងរឿងឯទៀតទាំងឡាយទោះជានីតិជនក្តី ជាអនីតិជនក្តីនៅក្នុងបន្ទប់ជំនុំនោះ ។

ការផ្សាយជាសាធារណៈ នូវសេចក្តីពិភាក្សា ត្រូវហាមផ្តាច់ បើមិនដូច្នោះទេ ត្រូវផ្តន្ទាទោសគុកតាមដឺក្រេថ្នាក់ទី ២ ។

ការផ្សាយជាសាធារណៈ នូវសេចក្តីសំរេច នៃតុលាការ ត្រូវដាក់នាម នៃអនីតិជន តែត្រឹមអក្សរខាងដើម បើមិនដូច្នោះទេ ត្រូវផ្តន្ទាទោសដូចគ្នា ។

បើប្រយោជន៍ នៃអនីតិជន តម្រូវ, ចាងហ្វាង អាចមិនឲ្យអនីតិជននោះ ចូលមកកាន់ទីប្រជុំផ្ទាល់ខ្លួនបាន ។ ដូច្នេះ ចាងហ្វាង ត្រូវចាត់តាំងជន ដែលមានគុណសម្បត្តិ គ្រប់គ្រាន់ណាមួយរូប ឲ្យតំណាងហើយនិងការពារជួស ។

មាត្រា៧ :- បើអនីតិជនមានគូកន ឬអ្នកសមគំនិត អាយុច្រើនជាង ១៨ ឆ្នាំ រឿងក្តី

នោះក៏ត្រូវចៅក្រមឯកទេសសម្រាប់រឿងអនីតិជន ស៊ើបសួរដែរ ប្រសិនបើ នៅក្នុងសាលាជំនុំទាំងឡាយមានចៅក្រមឯកទេសនេះ ។

កាលបើរឿងក្តីនៅក្រោមសមត្ថភាព នៃសាលាជំនុំសឹក ឬ សាលាជំនុំជាពិសេសណាមួយ រឿងក្តីនោះ ត្រូវឱ្យសុភាចារបុរស អមសាលាជំនុំ ជាពិសេសទាំងនោះ ធ្វើការស៊ើបសួរ ។ ប្រសិនបើមានសេចក្តីសំរេច បញ្ជូនទៅចំពោះមុខសាលាជំនុំ វិនិច្ឆ័យសេចក្តី , រឿងក្តីរបស់អនីតិជន ត្រូវជំនុំជំរះ នៅក្នុងបន្ទប់ស្ងាត់ ។ ឯអ្នកសមគំនិត ឬ តួកនដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវសាលា ជំនុំដែលមានសមត្ថភាព ជាប្រក្រតី ជំនុំជំរះដោយឡែកពីគ្នា ។ បើការជំនុំជំរះរឿងនោះ ត្រូវអនុញ្ញាតហៅឈ្មោះ អនីតិជន,រឿងក្តីនេះ ត្រូវតែជំនុំជំរះនៅក្នុងបន្ទប់ស្ងាត់ដែរ ។

ប្រសិនបើ មានសេចក្តីសំរេច បញ្ជូនទៅចំពោះមុខ សាលាជំនុំសឹក ឬសាលាជំនុំជាពិសេសណាមួយវិញ,រឿងក្តី នៃអនីតិជន ហើយនឹងរឿងក្តីនៃតួកន ឬអ្នកសមគំនិត ដែលមានអាយុលើសពី ១៨ ឆ្នាំត្រូវជំនុំជំរះ ជាមួយគ្នា តែត្រូវបិទទ្វារ ។

មាត្រា ៨ : – ជនគ្រប់រូប អង្គការឬគ្រឹស្ថាន ដែលសុខចិត្តទទួលចិញ្ចឹម តាមរបៀបជាទម្លាប់នូវអនីតិជន ដែលបានប្រព្រឹត្តបទល្មើស ដោយអនុវត្តតាមច្បាប់នេះ ត្រូវតែបានទទួលនូវនីតិសម្បទា ជាពិសេស ពីរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្នុងលក្ខណ៍ខ័ណ្ឌ ដែលបានកំណត់តាមព្រះរាជក្រឹត្យ ។
ការរៀបចំ,ការប្រព្រឹត្តទៅ,ការឲ្យរង្វាន់ ហើយនឹងការត្រួតត្រានៃជន អង្គការ គ្រឹស្ថានឬ គ្រឹស្ថានអប់រំទាំងនោះត្រូវកំណត់តាមព្រះរាជក្រឹត្យ ។

មាត្រា៩:– អ្នកតំណាង នៃក្រសួងយុត្តិធម៌ នឹងក្រសួងសង្គមកិច្ច ត្រូវបំពេញការត្រួតត្រាជាអចិន្ត្រៃយ៍ លើជន,អង្គការ គ្រឹស្ថានឬគ្រឹស្ថានអប់រំ ដែលមាននីតិសម្បទា នឹងទទួលចិញ្ចឹមអនីតិជនដែលប្រព្រឹត្តបទល្មើសទាំងនោះ ក្នុងលក្ខណ៍ខ័ណ្ឌ ដែលបានកំណត់ តាមព្រះរាជក្រិត។

មាត្រា ១០: – ត្រូវបង្កើតឲ្យមាន គ្រឹស្ថានអប់រំឡើងវិញមួយសម្រាប់អនីតិជន ដ៏មានទីកន្លែងការរៀបចំ,ការប្រព្រឹត្តទៅ ហើយ នឹងបទបញ្ញត្តិពិសេសដែលនឹងកម្រិតតាមព្រះរាជក្រឹត្យ។

# មាតិកា បួន

## អំពី យុត្តិកម្ម នៃ បទល្មើស

## DE LA JUSTIFICATION DE L' INFRACTION

## ចំពូក មួយ

## ករណី នៃប្រធានសក្តិ

Cas de force majeure

មាត្រា៩៦ - កាលបើ មានភស្តុតាង ថា មាន កម្លាំង អ្វីមួយ បានបង្ខំ ជន ណាម្នាក់ ឲ្យប្រព្រឹត្ត បទល្មើសអ្វីមួយ ហើយជននោះ, កាលមិនអាចទប់ទល់ នឹងកម្លាំង នោះ បាន, ក៏ប្រព្រឹត្ត បទល្មើសនោះ ទៅ ។ ជនអ្នកប្រព្រឹត្តបទល្មើសនេះ មិនត្រូវឲ្យទទួល ខុស ចំពោះអំពើ ដែលខ្លួន ប្រព្រឹត្ត នោះឡើយ ។

មាត្រា ៩៧ - កម្លាំង ដែលមកបង្ខំនោះ គឺអ្វី ? - កម្លាំងនោះ គឺ គ្រោះថ្នាក់ ដែល បណ្តាល ឲ្យមាន អាសន្ន យ៉ាងធំបំផុត ។

ពាក្យថា «អាសន្នយ៉ាងធំបំផុត» បានន័យថា គ្រោះថ្នាក់យ៉ាងធំបំផុត នឹងត្រូវធ្លាក់មក លើអ្នកណាម្នាក់ ក្នុងពេល ជាបន្ទាន់ក្រៃពេក មិនអាចនឹងចៀសបាន ដោយងាយ, ហើយអ្នកមានគ្រោះនោះ នឹងដោះខ្លួន ឲ្យរួច ពីគ្រោះនេះបាន, ក៏លុះតែ បានប្រព្រឹត្ត បទល្មើសណាមួយ ទើបរួច, ម្យ៉ាងទៀត គ្រោះថ្នាក់នោះ កាលកើតមក ក៏មិនមែនកើតមក

00222205

D99/3/3



ពីឆន្ទៈផ្ទាល់ របស់ការី នៃបទល្មើសនោះដែរ ទឹង មិនមែនខ្លួនការី នោះជាអ្នកបង្កបង្កើត បណ្ដាលឲ្យ មានគ្រោះថ្នាក់នោះដែរ ។

មាត្រា ៩៨– ក្នុងករណី ទាំងអស់ នោះ, ភស្តុតាង នៃការព ការសន្ទនោះ ជាភារៈ របស់មនុស្សត្រូវចោទ ជាអ្នករកជូន តុលាការ; ភស្តុតាងនេះ ទឹងត្រូវ ចៅក្រម ពឹងយកជាការបាន, លុះណាតែ ភស្តុតាងនោះ ចេញមក ពីអំពើ ដ៏ពិតប្រាកដណាស់ ។

## ចំពូក ពីរ

## អំពី សេចក្ដី បង្គាប់ របស់ច្បាប់

## De l'ordre de la loi

មាត្រា ៩៩– មិនទុកជាអំពើល្មើស ក្នុងបទព្រហ្មទណ្ឌ ទេ កាលណាបើ អំពើទាំងឡាយ នោះ ធ្វើតាមបង្គាប់ របស់ច្បាប់, ហើយអ្នកបញ្ជាឲ្យធ្វើ ក៏ជាអាជ្ញាធរ ធម្មានុរូប ដែរ ។

មាត្រា ១០០– ក្នុងករណី ដែលសេចក្ដីបង្គាប់ ជាអនិត្យានុកូល, ហើយអ្នកបញ្ជា ជាអាជ្ញាធរធម្មានុរូប នោះ, ចៅក្រម ត្រូវថ្លឹងមើល តាមការណ៍គួរ ទូរភាព នៃការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌ របស់ភ្នាក់ងារ អ្នកសម្រេចការណ៍នោះ ។

# ជំពូក បី
# អំពី កិច្ច ការពារ ជាធម្មានុរូប

## DE LA LÉGITIME DÉFENSE

មាត្រា ១០១ - កាលណាបើ ការចាំបាច់ តម្រូវឲ្យសម្លាប់, កាប់ ឬ វាយ ជនណាម្នាក់ ដើម្បីការពារខ្លួនឯង ឬ ខ្លួនអ្នកដទៃ ដោយធម្មានុរូប, នោះ អំពើ សម្លាប់, កាប់, វាយនេះ មិនចូល ជាឧក្រិដ្ឋកម្ម ឬ ទោសកម្ម ទេ ។

មាត្រា ១០២– កិច្ចការពារ ខ្លួនឯង ឬ ការពារ អ្នកដទៃ នឹង ទុកជា ធម្មានុរូប បាន, លុះតែ មានការរំលោភ ពីគេមកមុន គឺថា គេវាយ កាប់ ដោយអយុត្តិធម៌ជាមុន ។ កិច្ចការពារនេះត្រូវធ្វើ ឲ្យតំណាល នឹងការរំលោភ ហើយតែ ឲ្យល្មមគ្រប់គ្រាន់ នឹងបៀសវាង អន្តរាយ បាន តែប៉ុណ្ណោះ ។

មាត្រា ១០៣– បើអំពើ ដែលបានធ្វើ ក្នុងកិច្ចការពារ ជាធម្មានុរូបនេះ បណ្ដាលឲ្យមាន អន្តរាយ ដល់អ្នករំលោភហួសប្រមាណពេក នោះអ្នកសម្លាប់, កាប់, វាយ ដើម្បីកិច្ចការពារនោះ នៅតែ ត្រូវទទួល ខុស ក្នុងបទព្រហ្មទណ្ឌខ្លះដែរ; ក៏ប៉ុន្តែ ត្រូវ ។

នេះ ទៅក្រមត្រូវថ្លឹងមើល តាមករណីគួរផង ។

មាត្រា ១០៤ - អំពើសម្លាប់, កាប់, វាយ ដើម្បីទឹងដេញ
មនុស្ស ដែលពានពារ ឬ ធ្វើសន្ធិច្ឆេទកម្ម របង, ជញ្ជាំង, ទ្វារ, បង្អួច
ផ្ទះ ជាទីនៅ ឬ ជារបៀងផ្ទះ ក្នុងវេលាយប់ក្តី, ដើម្បីការពារ ខ្លួន
ឯង ឬខ្លួន អ្នកដទៃ ទល់នឹងចោរលួច ឬ ចោរប្លន់ ក្តី, ដើម្បីទឹងដេញ
តាម ចោរទាំងនេះ នៅពេល ដែលវា មាន គ្រឿងអាវុធ ឬ ដែលវា
តដៃ មកវិញ ក្តី, អំពើទាំងអម្បាលនេះ ត្រូវរាប់បញ្ចូល ទៅ ក្នុងកិច្ចការ-
ពារ ជាធម្មានុរូប ដែរ ។

## ចំពូក បួន

## អំពី សន្ដោស ទោស

## DES EXCUSES

មាត្រា ១០៥– ប្តីណា បានប្រទះឃើញ ប្រពន្ធទី ១ ឬ ទី ២
ផិតខ្លួន ដោយជាក់ស្តែង ហើយសម្លាប់, កាប់, វាយ ប្រពន្ធទីមួយ ឬ
ទីពីរ ព្រមទាំង ប្រុសសហាយផង ឬ សម្លាប់, កាប់, វាយ តែប្រពន្ធ
ឬ តែសហាយ, ប្តីនោះ អាច ត្រូវសន្តោស ទោស បាន ។

មាត្រា ១០៦– ជនណា បានទាន់ឃើញ ស្ត្រី ណាម្នាក់

កំពុងបៀតបៀន ដោយវិហិង្សាក្តី, ដោយអវិហិង្សាក្តី នូវកេរ្តិ៍ខ្មាស របស់ក្មេង អាយុតិចជាង ដប់បីឆ្នាំ ហើយសម្លាប់, កាប់ ឬ វាយ វ័យស្ក នោះ, ជននោះ គាប ត្រូវសន្តោស ទោស ឲ្យបានដែរ ។

មនុស្ស ដែលត្រូវទុក ជាវ័យស្កនោះ គឺមនុស្ស ដែលមាន អាយុ ល្មមរៀប អាពាហ៍ពិពាហ៍ តាមមាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីបាន ។

មាត្រា ១០៧– នាយក្រាន ណា បានប្រទះឃើញ, ក្នុងផ្ទះ ជាលំនៅ របស់ខ្លួន, នូវសេវនៈកិច្ច រវាងស្ត្រី, ដែលនៅ ក្នុងព្យាបាល ខ្លួន ឬ ក្នុងក្រាន ជាមួយខ្លួន, នឹងវ័យស្ក, ដែលមិនធ្លាប់ ចូលមក ដណ្តឹង ស្ត្រីរូបនោះសោះ, ហើយ វាយ វ័យស្កនោះ ឬ ស្ត្រីនោះ ដោយគ្មានចេតនា នឹងឲ្យស្លាប់ ទេ, នាយក្រាននោះ ក៏ត្រូវបានសន្តោស ទោស ដែរ ។

មាត្រា ១០៨– នាយក្រានណា វាយប្រដៅ គ្រប់កាលៈទេសៈ នូវមនុស្ស ដែលនៅ ក្នុងព្យាបាល ខ្លួន, នាយក្រាននោះ នឹងត្រូវមាន ទោស បាន, លុះតែ កិច្ច ដែលវាយប្រដៅនោះ ចូល ក្នុងបទ ធ្វើ ទុក្ខបុកម្នេញ គឺថា លុះតែ អំពើនោះជាកំពេលគេក ដែលសរឲ្យឃើញ ច្បាស់ថានាយក្រាននោះ គ្មានអធ្យាស្រ័យ ត្រាប្រណីស្តីប្រដៅ ដោយចិត្ត សប្បុរសដល់មនុស្ស ដែលនៅ ទីដ៏ខ្លួននោះសោះ ។

D99/3/3



# មាតិកា បួន

## អាជ្ញាយុកាល នៃបទល្មើស

De la prescription de l'nfraction

មាត្រា ១០៩– អ្នកណា ប្រព្រឹត្ត ឧក្រិដ្ឋកម្ម កន្លងលើស ពីដប់ឆ្នាំ, ពេសកម្ម លើស ពីប្រាំឆ្នាំ និង លហុកម្ម លើស ពីដប់ពីរខែ, អ្នកនោះ បានរួចផុត ពីមានទោស ហើយ ។

ឆ្នាំ និង ខែទាំងនេះ ត្រូវរាប់ តាមសុរិយគតិ ។

មាត្រា ១១០– កាលណា រយៈពេល ដូចមានសំដែង ជាពិសេស ខាងលើនេះ បានកន្លងហួស អស់ទៅហើយ, បណ្ដឹង របស់ភាគីស៊ីវិល ដែលសុំ សំណងបង់ខាតនោះ ក៏អស់ អាជ្ញាយុកាល ស្មើគ្នា នឹង បណ្ដឹងអាជ្ញានេះដែរ ។

មាត្រា ១១១– រយៈពេល នៃអាជ្ញាយុកាលនេះ ត្រូវកំណត់ ថ្ងៃ ពីត្រឹមថ្ងៃ ដែលបទល្មើសនោះ បានប្រព្រឹត្តមក ឬ ពីត្រឹមថ្ងៃឈប់ ធ្វើ នូវអំពើ ដែលជាតួ នៃបទល្មើសនោះ, ប្រសិនបើ បទល្មើសនោះ ត្រូវប្រព្រឹត្តជាប់រៀងមក ឬ ប្រព្រឹត្ត តៗ មក ។

មាត្រា ១១២ – រយៈពេល នៃអាជ្ញាយុកាលបទល្មើស របស់មនុស្សត្រូវចោទ ទាំងឡាយ ដែលបានប្រព្រឹត្ត បទល្មើស ជាមួយគ្នា ត្រូវឈប់គិត ពីត្រឹមថ្ងៃ ដែលអាជ្ញាធរ ខាងតុលាការ ផ្ដើមស៊ើបសួរ ឬ ផ្ដើមចោទប្រកាន់ ពីបទល្មើសនោះ លើមនុស្សត្រូវចោទណា តែម្នាក់ ឬ ទាំងអស់គ្នា ។

មាត្រា ១១៣ – ក្នុងពេល ដែលតុលាការ កំពុងតែស៊ើប បទល្មើសមួយ នៃជនណាម្នាក់ ហើយ លោជាមានលេច បទល្មើសមួយ មកទៀត ដែលជននោះ បានប្រព្រឹត្ត ជាយូរមកហើយ, នោះ រយៈពេល នៃអាជ្ញាយុកាល របស់បទល្មើស ដែលទើបលេចថ្មី នេះ ត្រូវឲ្យឈប់គិត ពីត្រឹមថ្ងៃដែលលេច ឮ មកនោះ តទៅទៀតដែរ ។

មាត្រា ១១៤ – រយៈពេល នៃអាជ្ញាយុកាល ដែលឈប់គិត ព្រោះតុលាការ បានដំណើរ ពីបណ្ដឹងនោះ ត្រូវលើកយកមកគិត, មក រាប់ សាជាថ្មីឡើងវិញ, កាលណាបើ តុលាការ ចប់កិច្ចស៊ើបអង្កេត ជំនុំជំរះ អស់ហើយ ។

# គន្ថីបី

# អំពី អនុវត្តន៍ ទោស

# DE L' APPLICATION DES PEINES

## បទបញ្ញត្តិ ប្រារភ

## DISPOSITIONS PRÉLIMINAIRES

មាត្រា ១១៥ – នាកាល ចៅក្រម ប្រកាសថា មនុស្សត្រូវចោទ នោះ បានប្រព្រឹត្ត អំពើ ដែលចោទ លើខ្លួនគេនោះ មែនហើយ, ចៅក្រម ត្រូវផ្ដន្ទា មនុស្សនោះ តាមទោស ដែលបានគ្រោងទុក ក្នុងច្បាប់ សម្រាប់ជាទណ្ឌកម្ម នៃបទល្មើស ដែលប្រកបព្រម ដោយអង្គ ឲ្យ ទៀងទាត់ តាមបរមា របស់ទោស ដោយមិនអាចកាត់ ឲ្យច្រើនលើស ពីអតិបរមា ឬ បន្ថយ ឲ្យតិចជាង អប្បបរមា ដែលច្បាប់ បានគ្រោងទុកមកនោះទេ, លើកលែងតែ ក្នុងករណី ដែលត្រូវបន្ថែម ឬ បន្ថយ ទោស ដូចដែលមានសំដែង ជាពិសេស ក្នុងគន្ថីនេះ ។

## មាតិកា មួយ

### អំពី ការគ្រាប្រណី ទោស នឹង ការបង្អង់ ប្រតិបត្តិ ទោស

### De l'atténuation des peines et du sursis à leur exécution

មាត្រា ១១៦ – ទោស ដែលមានគ្រោងទុក ក្នុងច្បាប់ សម្រាប់

ជាទណ្ឌកម្ម នៃបទល្មើស ត្រូវតែកែប្រែ ទ្រង់ទ្រាយ ឬ ត្រូវតែបន្ថយ ខ្លះ ព្រោះអនីតិភាព ឬ ជរាភាព នៃទណ្ឌិត ; ត្រូវតែបន្ថយ ខ្លះទៀត ប្រសិនបើ រកទៅឃើញថា ក្នុងហេតុ ជាទីកើត នៃបទល្មើសនោះ មានកាលៈទេសៈ ជាច្រើន គួរឲ្យត្រាប្រណី ដែរ ; ជាទីបញ្ចប់ ចៅ-ក្រម អាចអនុញ្ញាត ឲ្យបន្ធូរប្រតិបត្តិ ទោស ដែលកាត់រួចហើយនោះ តាមលក្ខខណ្ឌ ដែលមានកំណត់ទុក ក្នុងជំពូកបួន នៃមាតិកានេះ ក៏បានៗ

បទបញ្ញត្តិទាំងឡាយ ដែលស្តីពីការត្រាប្រណី ទោស, ពីការបន្ធូរ ប្រតិបត្តិ ទោស, ត្រូវយកទៅអនុវត្ត គ្រប់តែការបង្ក្រាប បទល្មើស ដែលមានគ្រោងទុក ក្នុងក្រមព្រហ្មទណ្ឌ ៗ មិនតែប៉ុណ្ណោះសោត សូម្បី បទល្មើស ដទៃទៀត, ដែលអំណាចនីតិបញ្ញត្តិ ទើបនឹងបង្កើតឡើង ផ្សេង ពីក្រមព្រហ្មទណ្ឌ ក៏ដោយ, ក៏បទបញ្ញត្តិនេះ អាចយកទៅអនុវត្ត ក្នុងការបង្ក្រាបនោះ បានដែរ, វៀរលែងតែ ច្បាប់ដទៃនេះ មានបទបញ្ញត្តិ ផ្សេង យ៉ាងណាទៀត ទើបឈប់អនុវត្ត បាន ៗ

## ជំពូកមួយ

## អំពី ការបន្ថយ ទោស បណ្តាលមក ពីអនីតិភាព នៃទណ្ឌិត

### De la réduction des peines résultant de l' état de minorité du condamné

មាត្រា ១១៧ ទោសណា ត្រូវអនុវត្ត លើអនីតិជន អាយុតិច

00222213

D99/3/3



ជាង ដប់ប្រាំបីឆ្នាំ ដែលតុលាការ រកឃើញថា ជាវិញ្ញូជនពិត ហើយ ជាមនុស្សមានវិចារបញ្ញា ទៀតផង,ទោសនោះ ត្រូវបន្ថយ ដូចតទៅនេះ

មាត្រា ១១៨– ក្នុងបទឧក្រិដ្ឋ :

បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីបី, ចៅក្រម ត្រូវអនុវត្ត ទោសគុកមជ្ឈិម ដែលមានកំណត់ មិនឲ្យ តិចជាង ដប់ឆ្នាំ នឹង មិនឲ្យ ច្រើនជាង ម្ភៃឆ្នាំ ទេ ។

បើ ទោស ដែលត្រូវផ្តន្ទានោះ ជាទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ចៅ-ក្រម ត្រូវអនុវត្ត ទោសគុកមជ្ឈិម ដែលមានកំណត់ មិនឲ្យតិចជាង ប្រាំឆ្នាំ នឹង មិនឲ្យ ច្រើនជាង ដប់ឆ្នាំទេ ។

បើ ទោស ដែលត្រូវផ្តន្ទានោះ ជាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ, ចៅ-ក្រម ត្រូវអនុវត្ត ទោសគុកមជ្ឈិម ដែលមានកំណត់ មិនឲ្យតិចជាង មួយឆ្នាំ នឹង មិនឲ្យ ច្រើនជាង ប្រាំឆ្នាំ ទេ ។

មាត្រា ១១៩– ក្នុងបទមជ្ឈិម ចៅក្រម មិនអាចកាត់ទោស ដាក់គុកឲ្យមានកំណត់ លើស ពីពាក់កណ្តាល នៃអតិបរមា ដែល មានគ្រោងទុក ក្នុងច្បាប់ ទេ ។

បទបញ្ញត្តិទាំងឡាយ នៃមាត្រា ១៣០, ១៣១, ១៣៣, ១៣៩

00222214



១៥០, ១៥១, ១៥២, ១៥៣, ១៥៤, ១៥៧, ១៥៩, ១៦០, ១៦៣ ដែលស្តីពីស្ថានទម្ងន់ទោសនោះ មិនត្រូវយកមកអនុវត្ត លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឡើយ ។

ទោស ទាំងឡាយនោះ អាចបន្ថយ តាមលក្ខខណ្ឌ ដែលមានចែងទុក ក្នុងមាត្រា ១៣៦ បាន ជាដរាប, កាលណាបើ មានកាលៈទេសៈ គួរឲ្យត្រាប្រណី ដល់អនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ, ពោះបើ មានបទបញ្ញត្តិ ជាពិសេសណាមួយ បង្គាប់ឲ្យនិគ្រោះ បទល្មើសនោះ ដល់អតិបរមា នៃទោសមធ្យម ក៏ដោយ ឬ ដោយហេតុ មានកាលៈទេសៈ តម្រូវឲ្យដាក់ទម្ងន់ ទោស ក៏ដោយ ។

ការបន្ធូរប្រតិបត្តិ ទោស, ដូចដែលបានពណ៌នា ក្នុងមាត្រា១៣៥ នោះ, អាចអនុញ្ញាត ឲ្យទណ្ឌិត ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំបាន ជាដរាប, ពោះបើ អតីតកាល នៃជននោះ អាក្រក់ យ៉ាងណា ក៏ដោយ ទឹង ពោះបើ បទបញ្ញត្តិ នៃច្បាប់ តម្រូវឲ្យផ្តន្ទា ទោស នោះ ជាអតិបរមា ក៏ដោយ ។

មាត្រា ១២០– ទោសគុក ដែលបានកាត់ តាមមាត្រាទាំងឡាយ ខាងលើនេះ ត្រូវយកទៅដាក់ ឲ្យប្រតិបត្តិ ក្នុងគុកប្រដៅ រហូតដល់ឆ្នាំ ដែលទណ្ឌិតនោះ បានគ្រប់ អាយុ ជានីតិភាព ។

00222215

D99/3/3



មាត្រា ១២១ - អនុទោស ទាំងឡាយ គឺការបង្ខាំ សិទ្ធិ នៃ ពលរដ្ឋ ១, គំហាត់លំនៅ ១, ការបិទផ្សាយ ដល់សាធារណជន នូវសាលក្រម ស្ដីពីទណ្ឌកម្ម ១, បញ្ជនីយកម្ម ១, ទាំងប៉ុននេះ, មិនត្រូវយកទៅ អនុវត្ត លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឡើយ ។

ការឲ្យបង់ ប្រាក់ពិន័យ និង ធនទណ្ឌ ផ្សេងៗ, ដែលបាន សម្រេច ទៅលើអនីតិជន នោះ, ត្រូវជាភារៈ របស់បុគ្គល ដែលមាន អំណាចមេបា ឬ ដែលជាអ្នកព្យាបាល លើអនីតិជន នោះ បង់ ។ ឯការ ដាក់គុកបង្ខំទារប្រាក់វិញ មិនអាចយក ទៅអនុវត្ត បាន សោះឡើយ ។

មាត្រា ១២២ - អត្ថបទនៃមាត្រានេះ បានត្រូវព្រះរាជក្រម លេខ ១៦៥ CE ចុះថ្ងៃ ៧-១-៦៤ និរាករ ហើយ

## ជំពូក ពីរ

## អំពី ការកែទម្រង់ ទោសឧក្រិដ្ឋ មក ជាទោសគុកមជ្ឈិម វិញ ព្រោះ ជរាភាព នៃទណ្ឌិត

De la transformation des peines criminelles en peines privatives de liberté en raison de le sénilité du condamné

មាត្រា ១២៣ - ទណ្ឌិត អាយុ លើស ពីហុកសិប ឆ្នាំ ដែល

00222216

D99/3/3



ត្រូវ ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ នឹង ថ្នាក់ទីពីរ នោះ, ត្រូវយក ទោសគុក មជ្ឈិម ដែលមាន រយៈវេលា ស្មើគ្នា នឹងទោសឧក្រិដ្ឋ នោះ មកដាក់ ជំនួសវិញ ។

ឯទោសបព្វាជនីយកម្ម មិនត្រូវយកមកអនុវត្ត លើទណ្ឌិត ជុន នេះឡើយ ។

មាត្រា ១២៤ – ទណ្ឌិត ណា កំពុងរង ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ឬ ថ្នាក់ទីពីរ, ហើយ វ័យ របស់ខ្លួន ក៏ចូល ដល់អាយុ ហុកសិប ឆ្នាំ ទៅ, វេលានោះ គឺវេលា ដែលខ្លួន ចូល ដល់វ័យជកនោះ ទណ្ឌិត នោះ ត្រូវបានមកដើ ទោស តាមរបប គុកមជ្ឈិម វិញ ។

ទោសបព្វាជនីយកម្ម, បើមាន, ក៏ត្រូវផុត ពីថ្ងៃនោះមកដែរ ។

មាត្រា ១២៥ – ទោះ ក្នុងករណី ណា ក៏ដោយ, ការប្តូរ ទោសឧក្រិដ្ឋ មក ជាទោសគុកមជ្ឈិម ដោយគ្រាប្រណី ដល់មនុស្សជក អាយុ ច្រើនជាង ហុកសិប ឆ្នាំនេះ មិនអាចបំបាត់ អនុទោសទាំងឡាយ ដែល បានកាត់រួចទៅហើយ នោះឲ្យបាត់ បានទេ ។

មាត្រា ១២៦ – អ្នកមានទោសលហុ មានអាយុ ច្រើនជាង ហុកសិប ឆ្នាំ មិនត្រូវ ឲ្យទទួល ទោសគុក លើសពីមួយ ថ្ងៃឡើយ ។

00222217



# ជំពូក បី

## អំពី ការបន្ថយ ទោស ព្រោះមាន កាលៈ ទេសៈ គួរត្រាប្រណី

De la réduction des peines résultant des circonstances atténuantes

មាត្រា ១២៧-នាកាល តុលាការកាន់ពិគ្រោះ, ដែលបានទទួល ជំរះរឿងណាមួយ , ក្រោយដែលបានពិភាក្សា រួចសព្វគ្រប់ហើយ , យល់ឃើញថា: ទណ្ឌកម្ម ដែលមានគ្រោងទុក ក្នុងច្បាប់ព្រហ្មទណ្ឌ នោះ ប្រសិនបើ យកទៅធៀប នឹងអំពើអាក្រក់ នៃរឿង នោះក្តី , ប្រសិនបើ យកទៅធៀប នឹងវិរុទ្ធភាព នៃចារី នោះ ក្តី, មានទម្ងន់ ធ្ងន់ ហួសហេតុពេក , តុលាការ អាច ត្រាប្រណី ទោស ឲ្យទណ្ឌិត បាន ។ សេចក្តីត្រាប្រណី នេះ មានអានុភាព ឲ្យបន្ថយ ទោស ដែលត្រូវអនុវត្តនោះ ឲ្យថយតិចមក , ដូចមានលក្ខខ័ណ្ឌ ដែលមានកំណត់ទុក ក្នុងមាត្រាតាំងឡាយ ដូចតទៅ នេះ ។

សេចក្តីត្រាប្រណីនេះ ឲ្យឬមិនឲ្យ ស្រេចលើឥស្សរៈចិត្ត របស់ចៅក្រម ៗ ចៅក្រមនេះ, ថើឡើ, មិនចាំបាច់ អធិប្បាយ ហេតុ ដែលឲ្យនោះ ក្នុងសាលក្រម របស់ខ្លួនទេ; សេចក្តីត្រាប្រណីនេះ មានអានុភាព តែទៅលើបុគ្គលម្នាក់ៗ ប៉ុណ្ណោះទេ ហើយទោស ដែលត្រូវបន្ថយនោះ ក៏បន្ថយតែទៅលើទណ្ឌិតណា ដែលបានទទួល សេចក្តីត្រាប្រណីនោះដែរ ។

មាត្រា ១២៨– ក្នុងបទឧក្រិដ្ឋ, សេចក្តីត្រាប្រណី បណ្តាលឲ្យបន្ថយ ទោស ដូចតទៅនេះ :

១.– បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីបី ចៅ-ក្រម ត្រូវបន្ថយ ទោសនោះ មកនៅ ត្រឹមតែ ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ឬ ទីមួយ វិញ ។

២.– បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ចៅក្រម ត្រូវបន្ថយ ទោសនោះ មកនៅ ត្រឹមតែ ទោសឧក្រិដ្ឋថ្នាក់ ទីមួយ ឬ ទោសគុកមជ្ឈិម ដែលមិនត្រូវឲ្យ រយៈវេលា តិចជាង ពីរ ឆ្នាំ និងច្រើនជាង ប្រាំ ឆ្នាំឡើយ ។

៣.– បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ចៅក្រម ត្រូវបន្ថយ ទោសនោះមកនៅ ត្រឹមតែ ទោសគុកមជ្ឈិម ដែលមាន រយៈវេលា មិនតិចជាង មួយឆ្នាំ និង មិនច្រើនជាង ប្រាំ ឆ្នាំឡើយ ។

ទោសគុកមជ្ឈិម ដែលបានសំរេច ទៅលើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ដោយអនុវត្ត តាមមាត្រា ១១៨ នោះ, ចៅក្រម អាចបន្ថយមកនៅ ត្រឹមតែ មួយ ឆ្នាំ បាន ជាដរាប ។

មាត្រា ១២៩– គ្រាណា ដែលត្រូវសំរេច ទោសគុកមជ្ឈិម ទៅលើទណ្ឌិត អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ ដោយអនុវត្ត តាមកថា

ខណ្ឌទី ២ និងទី ៣ នៃមាត្រា ខាងលើនេះហើយ ចៅក្រម អាចនៅតែយក អនុទោស ត្រង់ ១ បន្ថយសិទ្ធិពលរដ្ឋ និងគំហាត់លំនៅ មកអនុវត្ត បាន ដូចមានលក្ខខណ្ឌ ដែលបានគ្រោងទុក ក្នុងមាត្រា ៥៣ វគ្គ ចុងបំផុត និង មាត្រា ៦០ ស្រាប់ ។

មាត្រា ១៣០– នាកាល ចៅក្រម មានសេចក្តីត្រាប្រណី ដល់ទណ្ឌិតឧក្រិដ្ឋ អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ ដែលជាមនុស្ស មិនកាន់ពាល ជាទិត្យានុកូលហើយ, ទោស ដែលត្រូវផ្តន្ទា មិនត្រូវបន្ថែមឲ្យធ្ងន់ ទៀតទេ, ប៉ុន្តែទោសនេះ ត្រូវបន្ថយ ទៅតាមលក្ខខណ្ឌ ដូចមានគ្រោងទុកក្នុងមាត្រា ១៥៧ វិញ ។

បើទណ្ឌិត នៃឧក្រិដ្ឋកម្មនោះ ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ហើយ ជាមនុស្ស មិនកាន់ពាល ជាទិត្យានុកូល ទៀតផង, ទោសដែលត្រូវផ្តន្ទានោះ គំរោតែ អាចបន្ថយ រហូត ដល់ទោសគុកមធ្យមតែ មួយឆ្នាំ បាន ។

មាត្រា ១៣១– ក្នុងបទមជ្ឈិម, កាលបើ មានជាក់កំហិត ឲ្យអនុវត្ត ទោស ជាអតិបរមា, ព្រោះមាន បទបញ្ញត្តិ ជាពិសេស របស់ច្បាប់ ស្តីពីបង្ក្រាប បទល្មើស ដែលនាំឲ្យមាន ទណ្ឌកម្មនោះ ក្តី ឬ

00222220



ដោយសារយក កាលៈទេសៈ គួរទម្ងន់ មកផ្សំផង ដូចដែលមានត្រាទុកក្នុងមាត្រា ១៣៩, ១៥០, ១៥១, ១៥២, ១៥៣, ១៥៤, ១៥៨, ១៥៩, ១៦០, ១៦១ យ៉ាងនេះក្ដី, ក៏សេចក្ដីត្រាប្រណីនោះ គាប់នាំឲ្យចៅក្រម បន្ថយទោស តាំងនោះបាន ដូចតទៅនេះ

១.– បើ ទោស ដែលត្រូវផ្ដន្ទា ដល់អតិបរមានោះ ជាទោសមជ្ឈិម ថ្នាក់ទីបី, ចៅក្រម ត្រូវអនុវត្ត ទោសមជ្ឈិម ថ្នាក់ទីបី ដែលមានកំរិត តិចជាង អតិបរមា របស់វា ឬ ទោសមជ្ឈិម ថ្នាក់ទីពីរ ថយរហូត មក ដល់អប្បបរមា នៃទោសនេះ ក៏បាន ។

២.– បើ ទោស ដែលត្រូវផ្ដន្ទា ដល់អតិបរមានោះ ជាទោសមជ្ឈិម ថ្នាក់ទីពីរ, ចៅក្រម ត្រូវអនុវត្ត ទោសមជ្ឈិម ថ្នាក់ទីពីរ ដែលមានកំរិត តិចជាងអតិបរមា របស់វា ឬ ទោសមជ្ឈិម ថ្នាក់ទីមួយ ថយរហូត មក ដល់អប្បបរមា នៃទោសនេះ ក៏បាន ។

៣.– បើ ទោស ដែលត្រូវផ្ដន្ទា ដល់អតិបរមានោះ ជាទោសមជ្ឈិម ថ្នាក់ទីមួយ, ចៅក្រម ត្រូវអនុវត្ត ទោសមជ្ឈិម ថ្នាក់ទីមួយ ដែលមានកំរិត តិចជាងអតិបរមា របស់វា ឬ ក៏ដាក់ទោសលហុ ។ ប៉ុន្តែបើ ទោសលហុ នោះ មិនមែនជាទោសគុក ទេ គឺទោសពិន័យ វិញ ចៅក្រម មិនត្រូវពិន័យ ឲ្យតិចជាង អតិបរមា នៃទោសពិន័យជាលហុឡើយ ។

ចៅក្រម មិនត្រូវយក បទបញ្ញត្តិតាំងឡាយ ក្នុងមាត្រានេះ ទៅ

អនុវត្ត លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឡើយ ។ ទោស ដែលត្រូវផ្តន្ទា ដល់អនីតិជន អាចត្រូវបន្ថយ តាមលក្ខខ័ណ្ឌ ដែលមាន គ្រោងទុក ក្នុងមាត្រា ១៣២ វគ្គចុងបំផុត បាន ជាដរាប ។

មាត្រា ១៣២– ក្នុងបទមជ្ឈិម, កាលបើ គ្មានបទបញ្ញត្តិ ជាពិសេស នៃច្បាប់ អ្វីក្រៅ ពីទិគ្រោះ បទល្មើស ដែលនាំឲ្យមាន ទណ្ឌកម្ម នោះ ទេ ឬ បើគ្មាន កាលៈទេសៈគួរទម្ងន់ ដូចដែលមាន គ្រោងទុក ក្នុងមាត្រា ១៣៩, ១៤០, ១៤១, ១៤២, ១៤៣, ១៤៤, ១៤៨, ១៤៩, ១៦០, ១៦១ ទេ, នោះ សេចក្តីប្រណី បណ្តាលឲ្យ បន្ថយទោស នោះ ដូចតទៅនេះ:

១.– បើ ទោស ដែលត្រូវផ្តន្ទា ជាទោសមជ្ឈិម ថ្នាក់ទីបី, ចៅក្រម ត្រូវអនុវត្ត ទោសមជ្ឈិម ថ្នាក់ទីពីរ ឬ ថ្នាក់ទីមួយ វិញ ។

២.– បើ ទោស ដែលត្រូវផ្តន្ទា ជាទោសមជ្ឈិម ថ្នាក់ទីពីរ, ចៅក្រម ត្រូវអនុវត្ត ទោសមជ្ឈិម ថ្នាក់ទីមួយ ឬ ទោសលហុវិញ ។ ក៏ប៉ុន្តែ បើ ទោសលហុ នោះ មិនមែនជាទោសគុក ទេ គឺ ជាទោស ពិន័យ ទៅវិញ, ចៅក្រម មិនត្រូវពិន័យ ឲ្យតិចជាង អតិបរមា នៃ ទោសពិន័យ ជាលហុ ឡើយ ។

៣– បើទោស ដែលត្រូវផ្តន្ទា ជាទោសមជ្ឈិម ថ្នាក់ទីមួយ, ចៅ

00222222





ក្រុម ត្រូវអនុវត្ត ទោសលហុ ។

ទោសមជ្ឈិម ទាំងឡាយ, ទោះបី មានថ្នាក់ទីប៉ុន្មាន ក៏ដោយ ដែលត្រូវផ្តន្ទា ដល់អនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ, គាបត្រូវបន្ថយ រហូត ដល់អប្បបរមា នៃទោសលហុ បាន ជាដរាប ។

មាត្រា ១៣៣- សេចក្តីត្រាប្រណី នេះ មិនមែន ជាការឃាត់ ចៅក្រម មិនឲ្យសម្រេច អនុទោស ត្រង់ខ បន្ថយ សិទ្ធិ នៃពលរដ្ឋ និង គំហាត់ លំនៅ ដល់ទណ្ឌិត ដែលមាន អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ នោះទេ, ប្រសិនបើ ចៅក្រម យល់ថា គួរសម្រេច, ហើយ ច្បាប់ ក៏បានអនុញ្ញាត ឲ្យអនុវត្ត អនុទោស នោះ ក្នុងបទមជ្ឈិម ទៀត ផងដែរ ។

មាត្រា ១៣៤- ក្នុងបទលហុ សេចក្តីត្រាប្រណី បណ្តាលឲ្យ បន្ថយ ទោសលហុនោះ មកនៅ ត្រឹមតែ ពិន័យ ម្ភៃសេន ហើយ ទោសគុក ជាលហុ មិនអាចសំរេច បានឡើយ ។

# ជំពូក បួន

## អំពី ការបង្អង់ ប្រតិបត្តិ ទោស

Du sursis à l'xècution des peines

មាត្រា ១៣៥– ក្នុងករណី ដែលមាន ទណ្ឌកម្ម ឲ្យបង់ ពិន័យ ឬ ដាក់គុកមធ្យម, សាលក្រម ឬ សាលដីកា អាចបញ្ជា ឲ្យបង្អង់ ប្រតិបត្តិ ទោស បាន, ប៉ុន្តែ សាលក្រម ឬសាលដីកានោះ ត្រូវអធិប្បាយ បង្ហាញ ហេតុ នៃសេចក្តីសំរេច របស់ខ្លួននោះ ឲ្យច្បាស់លាស់ ៗ ទណ្ឌិត ដែលគួរ ដល់ការបង្អង់ ប្រតិបត្តិ ទោសនេះ, ត្រូវឲ្យ មានលក្ខខណ្ឌ ដូចតទៅនេះ ៖

ក– ពីអតីតកាលមក ទណ្ឌិត មិនដែលមាន ទោសឧក្រិដ្ឋ ឬ ទោសគុកមធ្យម ព្រោះឧក្រិដ្ឋកម្ម ឬ ទោសកម្ម ដល់ម្តងសោះ ៗ

ខ– ទោស ដែលទណ្ឌិត ត្រូវទទួល ជាទណ្ឌកម្ម ក្នុងពេលនេះ ទៀត, ក៏ច្បាប់ មិនមានដាក់ កំហិត ឲ្យផ្តន្ទា ជាអតិបរមា តាមបទ បញ្ញត្តិ ជាពិសេស ស្តីពីបង្ក្រាប បទល្មើស ដែលនាំឲ្យមាន ទណ្ឌកម្ម នោះ ក៏ទេ, ដោយសារមាន កាលៈទេសៈ គួរទម្ងន់ ជាប្រត្យក្ស ឬគួរ ទម្ងន់ព្រោះបុគ្គល ដូចមានត្រាទុក ក្នុងមាត្រា ១៣៩, ១៥០, ១៥១, ១៥២, ១៥៣, ១៥៤, ១៥៨, ១៥៩, ១៦០, ១៦១, ក៏ទេដែរ ៗ

បើ កន្លងរយៈពេលា ប្រាំឆ្នាំ, គិតពីថ្ងៃ កាត់សេចក្តីចំពោះមុខ ឬ គិតពីថ្ងៃ ប្រគល់ ដីកាដាច់ព្រាត់ នោះ មក, ខុណ្ឌិត មិនបានត្រូវខុណ្ឌកម្ម ជាទោសតុកមជ្ឈិម ព្រោះខុក្រិដ្ឋកម្ម ឬ ទោសកម្ម ជាថ្មីទៀតទេ, នោះទោស ដែលបានបង្គាប់មក ត្រូវទុក ជាអសារសូន្យ ។ ក្នុងករណីផ្ទុយទៅវិញ គឺថា ក្នុងរយៈពេលា ៥ ឆ្នាំនោះ ខុណ្ឌិត បានប្រព្រឹត្ត ខុក្រិដ្ឋកម្ម ឬ ទោសកម្មជាថ្មី ទៀត, ខុណ្ឌិត នេះ ត្រូវទទួល ទោសទាំងមុន ទាំងក្រោយ រួមគ្នា, តែមិនមែនស្រុបបូកគ្នា ដូចមាន ក្នុងលក្ខខណ្ឌ ដែលគ្រោងទុក ក្នុងមាត្រា ១៤ ដល់ ១៧ នោះឡើយ ។

ខុណ្ឌិត ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ អាចគ្រាប្រណី ឲ្យបង្អង់ប្រតិបត្តិ ទោស នេះ បាន ជាដរាប, ទោះបី អតីតកាលរបស់វា អាក្រក់យ៉ាងណា ក៏ដោយ, ទោះបី បទល្មើស ដែលត្រូវបង្ក្រាបនោះ ត្រូវផ្តន្ទា ដល់អតិបរមា ក៏ដោយ ។ ( ស្រង់ពីព្រះរាជក្រមលេខ ៣៣ ន.ស. ចុះថ្ងៃ ២៥ សីហា ១៩៥២ )

មាត្រា ១៣៦- នាកាល បានអនុញ្ញាត ឲ្យបង្អង់ប្រតិបត្តិទោស យ៉ាងនេះហើយ, ចៅក្រម មិនអាចសំរេច អនុទោស ត្រង់ការបន្ថយសិទ្ធិពលរដ្ឋ និង តំហាត់លំនៅនោះ បានទេ, ប៉ុន្តែចៅក្រម ត្រូវតែបញ្ជា ឲ្យខុណ្ឌិត បង់ សោហ៊ុយជម្ងឺចិត្ត និងបង្វិល ទ្រព្យតាង ទៅឲ្យគេវិញ, ប្រសិនបើ មាន ។

00222225





មាត្រា ១៣៧– នីតិវិធី (សំណុំរឿង) ទាំងមូល, ដែលមានសាលក្រម អនុញ្ញាត ឲ្យបង្អង់ប្រតិបត្តិទោសនេះ, ត្រូវជូន ទៅទីស្តីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ពិនិត្យ ភ្លាម ។

## មាតិកា ពីរ

### អំពី ទម្ងន់ ទោស

### DE L'AGGRAVATION DES PEINES

មាត្រា ១៣៨– ទោសទាំងឡាយ ដែលបានគ្រោងទុក ក្នុងច្បាប់ សំរាប់ ជាទណ្ឌកម្ម របស់បទល្មើស ត្រូវតែបន្ថែម ទម្ងន់ ឡើងទៀត, ដូចដែលមានសំដែង ជាពិសេស ក្នុងមាតិកានេះ, កាលណាបើមានកាលៈទេសៈទាំងឡាយ ណា មកទម្លាក់ដាក់ទម្ងន់ លើឧក្រិដ្ឋភាព នៃអំពើ នោះ ឬ លើវិរុទ្ធភាព នៃជន ឲ្យកាន់តែធ្ងន់ឡើង គឺធ្ងន់ ព្រោះតែលក្ខខណ្ឌ នៃបទល្មើស ដែលបានប្រព្រឹត្តមក នោះ ក៏មាន, ធ្ងន់ ព្រោះតែ គុណភាព នៃអ្នកធ្វើអំពើល្មើស ឬ គុណភាព នៃជន ក៏មាន ឬ ធ្ងន់ ព្រោះតែ, ក្នុងពេល ដែលប្រព្រឹត្តលើកនេះ, ជននោះ ចូល ក្នុងភាព មិនរៀងចាល ជានិត្យានុកូល ក៏មាន ។

# ជំពូកមួយ

## អំពី ទម្ងន់ទោសបណ្ដាលមក ពីល័ក្ខខ័ណ្ឌ របស់បទល្មើស

De l'aggravation des peines résultant des conditions de l'infraction

មាត្រា ១៣៩– កាលបើច្បាប់ មិនបានបញ្ញត្តិ ផ្សេងទៅទៀតទេ, បទល្មើស ទាំងឡាយ ជាមជ្ឈិម, ដែលបានប្រព្រឹត្ត ក្នុងកាលៈទេសៈ ដូចខាងក្រោមនេះ, ត្រូវផ្ដន្ទា រហូត ដល់អតិបរមា នៃទោស ដែលត្រូវផ្ដន្ទា :

១.– ប្រព្រឹត្ត បទល្មើសមជ្ឈិម ច្រើនបទ ដំណាលៗគ្នា,

២.– មាន ការគិតទុក ជាមុន,

៣.– មាន គូកន គ្នាច្រើន,

៤.– មាន កាន់អាវុធ,

៥.– មាន កងកម្លាំងបើកមុខ (force ouvert) ឬ ប្រយុទ្ធតដៃ (vive force),

៦.– ដោយសន្ធិប្បទកម្ម,

៧.– បានប្រព្រឹត្ត នៅលើផ្លូវគោក, តាមទន្លេ, តាមសមុទ្រ ឬ តាមអាកាស, ក្នុងកំពែង នៃគេហស្ថាន របស់សាសនា ឬ របស់រាជ-ការសាធារណៈ ឬ

បទបញ្ញត្តិទាំងនេះ មិនត្រូវយកទៅអនុវត្ត លើអនីតិជន អាយុតិចជាង ដប់ប្រាំបី ឆ្នាំ ឡើយ ។

កាលៈទេសៈ គួរទម្ងន់ ១ ណាមួយ, បណ្តា ១ ទាំង ៧ នោះ, នឹងអាចយក ទៅប្រកបផ្សំ នឹងបទល្មើស ណាមួយ ដើម្បីឲ្យបទល្មើស នោះធ្ងន់ ទៅបាន, កំលុះតែ កាលៈទេសៈ នោះ មិនមែន ជាអង្គនៃបទល្មើស ដែលត្រូវនិគ្រោះ នោះ ទេ ។

មាត្រា ១៤០- បទបញ្ញត្តិ នៃមាត្រា ខាងលើ, ដែលនិយាយពីនិគ្រោះ បទល្មើស ប្រព្រឹត្ត ដំណាលៗ គ្នា, នឹងយកទៅអនុវត្ត បាន ក៏លុះតែ បទបញ្ញត្តិនោះ ស៊ីសេចក្តីគ្នា នឹងមាត្រាទាំងឡាយ ពី១៤ដល់ ១៩ ដែលស្តី ពីការស្រូប ទោស នឹង តម្រួតទោស មានព្រំដែន នោះ ផង ។

មាត្រា ១៤១ - បទមជ្ឈិម នឹងក្លាយ ទៅជាបទឧក្រិដ្ឋ បាន កាលណាបើ បទល្មើសនោះ ប្រព្រឹត្ត ដោយមាន លក្ខណ៍ ដែលប្រកប នឹងកាលៈទេសៈ គួរទម្ងន់ ដូចមានគ្រោងទុក ក្នុងមាត្រា ១៣៩ នោះ ចំនួនបី ១ យ៉ាងតិច ។

បើ បទល្មើស នោះ ប្រកប គ្រប់ កាលៈទេសៈ គួរទម្ងន់ ទាំងបី ១ ហើយ នោះ, ចៅក្រម ត្រូវយក ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ មកអនុវត្ត ។

បើ បទល្មើស ប្រព្រឹត្ត ប្រកប កាលៈទេសៈគួរទម្ងន់ លើស ពីបី ១ ទៅ, ចៅក្រម ត្រូវយក ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ មកអនុវត្ត ។

បញ្ញត្តិទាំងអស់នេះ ត្រូវយកទៅអនុវត្ត លើអនីតិជន អាយុ តិច ជាង ដប់ប្រាំ ឆ្នាំ ដែរ ។

កាលៈទេសៈ គួរទម្ងន់, ដែលយកទៅ ប្រកបផ្សំ នឹងបទមជ្ឈិម ដើម្បីឲ្យបទមជ្ឈិម ក្លាយទៅ ជាបទឧក្រិដ្ឋនោះ, មិនត្រូវចូល ជាអង្គ នៃ បទល្មើស ដែលត្រូវពិគ្រោះ នោះទេ ។

មាត្រា ១៤២- គ្រាណាបើ បទល្មើស ណាមួយ, បណ្ដាបទល្មើសទាំងឡាយ ដែលប្រព្រឹត្ត ដំណាលៗគ្នានោះ, មាន គោលបំណង ថា នឹងធ្វើ មនុស្សឃាត ដោយចេតនា ក្ដី ឬធ្វើឲ្យ មាន របួសស្នាម, គ្មានចេតនា ចង់សម្លាប់ទេ ក្ដី, ប៉ុន្តែផលានុភាព របួស នោះ បាន បណ្ដាល ឲ្យស្លាប់, នោះចារី ក្ដី, សហចារី ក្ដី, អ្នកចូលគំនិត ដោយ ជួយទំនុកបំរុង ក្ដី, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ដូចគ្នា ។

មាត្រា ១៤៣- ត្រូវទុកថា បានប្រព្រឹត្ត បទល្មើស ច្រើន បទដំណាលៗគ្នា កាលណាបើ ជននោះ បានប្រព្រឹត្ត បទល្មើស ច្រើនបែប ផ្សេងៗគ្នា ក្នុងពេល ជាមួយគ្នា ។

00222229





អំពើ ទាំងឡាយ ដែលធ្វើឡើង ដើម្បីរៀបចំ ដំណើរ របស់ បទល្មើស, ដើម្បីឲ្យងាយ ក្នុងការប្រព្រឹត្ត បទល្មើស ឬដើម្បីឲ្យ បទល្មើសនោះ បានសម្រេចពិត ព្រមទាំងអំពើ ដែលធ្វើឲ្យ ចារី គេចខ្លួន បានដោយស្រួយ ឬ កាស់កាង ជាទីជួយទំនុកបំរុង ឲ្យចារី ឬ អ្នកសមគំនិត បានផុតខ្លួន ពីការផ្ដន្ទាទោស ទាំងអស់នេះ ត្រូវទុក ថា ជាបានប្រព្រឹត្ត ដំណាលៗគ្នា បាន ។

មាត្រា១៤៤– ការគិតទុកជាមុន គឺការតាំងចិត្តជាស្រេចថា នឹង ប្រព្រឹត្តនូវអំពើ ណាមួយ មុនពេល ដែល ប្រព្រឹត្តនូវអំពើ នោះ គឺ ជាពេលដែល សម្រេចចិត្ត នឹងពេលដែល ប្រព្រឹត្ត មានបន្ទោះឃ្លាត ពីគ្នា ល្មមឲ្យ ចារី រៀបចំ ដំណើការ នោះបាន ។

មាត្រា១៤៥–ដែលទុកថា ជាគួកនច្រើននាក់នោះ គឺថា កាល ណា មានមនុស្ស ពីរនាក់យ៉ាងតិច បានមូលមាត់គ្នាថា នឹងប្រព្រឹត្ត បទល្មើស ណាមួយ ជាមួយគ្នា ដោយខ្លះ ជាសហការី ក្ដី, ខ្លះជាអ្នក ចូលគំនិត ដោយជួយទំនុកបំរុង ក្ដី, បទល្មើសនោះ ត្រូវទុកថា ជាបទ ល្មើស ប្រព្រឹត្ត ដោយមានគួកន ច្រើននាក់ ។

00222230





មាត្រា ១៨៦- ឧបករណ៍ទាំងឡាយ ដែលគ្មានមុខ ក្តី, ដែលមានមុខមុត ក្តី, ដែលមានចុងស្រួច ក្តី ឬ ដែលផ្ទុះ ក្តី ត្រូវទុកថាជា អាវុធ ។

កាំបិត ទាំងគ្រឿង ដែលដាក់ ក្នុងហោប៉ៅបាន, ដំបង ខឹង ឈើច្រត់ ត្រូវរាប់ថា ជាអាវុធដែរ កាលណាបើ ចោរ បានយក គ្រឿងទាំងនេះ ទៅប្រហារគេ ។

មាត្រា ១៨៧- ដែលហៅថា អំពើសម្រេច ដោយកម្លាំងចេញមុខនោះ គឺអំពើ ដែលបានសម្រេច ដូចប្រាថ្នា ព្រោះតែបានផ្ទុះសំបែងគេ ឬ ពាធាគេ, ទោះបីគេ មិនបានទទួល គ្រោះវិហិង្សានោះ ដោយសារគេ តស៊ូ ក្តី ដោយសារគេ មិនហ៊ាន តប ត ក្តី ។

អំពើ ដែលបានសម្រេច ដោយប្រយុទ្ធ នដៃ នោះ គឺចោរនោះ បានប្រើ វិហិង្សា លើរូបមនុស្ស, ប្រើអាការគំរាម, ដំលាចប្រយោជន៍ ទាំងបំបាក់បំបប កុំឲ្យមានការតស៊ូ តប មកវិញ ។

មាត្រា ១៨៨- សន្ធិច្ឆេទកម្ម ជាអំពើ ដែលធ្វើ ដោយកម្លាំង ដើម្បីទម្លាយ គ្រឿងបិទអ្វីមួយ ដោយបំបាក់បំបែក ក្តី ឬ បំផ្លាញខ្សែរូប ក្តី, ដោយរបៀបអ្វី ដទៃទៀត ក្តី, ឲ្យមានប្រហោង ល្មម មនុស្សម្នាក់ អាចចូលទៅ ក្នុងកន្លែង ដែលគេ បិទនោះ បាន, ឬ ដើម្បី

និងយក របស់ ដែលគេ ទុក ក្នុងទីបិទបាំង នោះ ។

ការប្រើកូនសោ ក្លែង ឬ កូនសោដែលលួចលាក់ ពីម្ចាស់គេ មក ឬ គ្រឿងស្ទីវ ដើម្បីនឹងដោះបើក ទ្វារគ្រឿងបិទ របស់គេ, ក៏រាប់បញ្ចូល ទៅ ក្នុងសន្ធិច្ឆេទកម្ម ដែរ ។

មាត្រា ១៤៩– ផ្លូវគោក គឺថ្នល់, ផ្លូវទូទៅ, ផ្លូវលំ និងផ្លូវដើរ សម្រាប់ ជាគមនាគមន៍ របស់មនុស្ស, ផ្លូវអយស្ម័យយាន, ស្ថានី រថភ្លើង, កន្លែងជាទីចេញ និង ជាទីចូល នៃរថភ្លើង ។

ផ្លូវទន្លេ គឺផ្លូវទឹក ដែលនាវា បើកចេញចូលបាន, បឹង, ត្រពាំង និង មាត់ច្រាំង, ឃ្លាំងដាក់ទំនិញ កំពង់ផ្ទុកទំនិញ ។

ផ្លូវសមុទ្រ ផ្លូវទឹកមាត់សមុទ្រ នៃប្រទេសកម្ពុជា និង ទឹក ដែល ជ្រៅឆ្ងាយ ពីមាត់សមុទ្រ, កាលណាបើ បើបទល្មើសនោះ បានប្រព្រឹត្ត ទៅលើនាវារបស់ខ្មែរ, កំពង់ផែ, តរវិថី, ព្រមទាំងគ្រឿងស្ពាន ដែលសង់ នៅទីនោះ ដើម្បីសេចក្ដីត្រូវការរបស់នាវាចរណ៍ និង សេចក្ដីត្រូវការ របស់ការដឹកនាំ អ្នកដំណើរ ឬ ទំនិញទាំងឡាយ ។

ផ្លូវអាកាស គឺវាលយន្តហោះ, កន្លែងចំណត និង កន្លែងហោះ ចេញ, គ្រឿងស្ពានទាំងឡាយ ដែលសង់ ដើម្បីសេចក្ដីត្រូវការ របស់ អាកាសចរណ៍ និង យន្តហោះ ដឹកនាំ អ្នកដំណើរ និងទំនិញ, ផ្ទៃ

0[illegible]2232

D99/3/3



អាកាស ដែលនៅ លើដី ប្រទេសខ្មែរ ។

គេហដ្ឋាន សម្រាប់ សាសនា គឺវិហារ, កុដិ, សាលាទាន, សាលាប្រជុំ សាសនា របស់បព្វជិត ក្នុងសាសនា របស់រដ្ឋ, ព្រមទាំងសំណង់ ដទៃទៀត ដែលមាននៅ ក្នុងកំពែង វត្តនោះ ។

គេហដ្ឋាន សាធារណៈ ទាំងឡាយ គឺផ្ទះសម្បែង សព្វសារពើ សម្រាប់រាជការ សាធារណៈ ។

## ចំពូក ពីរ

### អំពី ទម្ងន់ទោស បណ្ដាលមក ពីគុណភាព នៃ អ្នករងបទល្មើស

De l' aggravation des peines résultant
de la qualité des victimes de l'infraction

មាត្រា ១៥០– ប្រសិនបើ ច្បាប់ មិនបានបញ្ញត្តិអ្វី ជាពិសេសទៅទៀតទេ, បទមជ្ឈិមណា ដែលគាបធ្វើ ឡើងខូច ផលប្រយោជន៍ជាសម្ភារៈ របស់រាជការ ឬ របស់សាសនា, បទល្មើសមជ្ឈិមនោះ ត្រូវផ្ដន្ទា ជាអតិបរមា នៃទោស ដែលបានគ្រោងទុក សម្រាប់ ជាទណ្ឌកម្ម នៃបទល្មើស នោះ ។

បទបញ្ញត្តិ នៃមាត្រានេះ មិនគាបយកទៅអនុវត្ត លើអនីតិជនអាយុ តិចជាង ដប់ប្រាំបី ឆ្នាំទេ ។

មាត្រា ១៥១– ប្រសិនបើ ច្បាប់ មិនបានបញ្ញត្តិ អ្វី ជាពិសេស ទៅទៀតទេ, បទមជ្ឈិមណា បណ្តាលឲ្យមាន ព្យសនកម្ម ទៅលើបព្វជិត ក្នុងសាសនា របស់រដ្ឋ, អ្នករាជការ, ភ្នាក់ងាររដ្ឋាភិបាល, អ្នកដំណាង អាជ្ញាធរ សាធារណៈ, ជនអ្នកទទួល ភារៈ ពីមន្ត្រី នៃក្រុមរាជការ សាធារណៈ ដែលកំពុងធ្វើការ មុខក្រសួង ឬ ក្នុងឱកាស ធ្វើការ មុខ ក្រសួង របស់ខ្លួន ឬ មុខងារ ដែលគេ ប្រគល់ មកឲ្យខ្លួន, បទមជ្ឈិម នោះ ត្រូវផ្តន្ទា ជាអតិបរមា នៃទោស ដែលជាទណ្ឌកម្ម នៃបទល្មើស នោះ, លើកមួយ តែ ការីនោះ ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ តែប៉ុណ្ណោះ ។

មាត្រា ១៥២ – បទមជ្ឈិមណា ដែលច្បាប់ គ្មានបញ្ញត្តិ ជា ពិសេស ដូចម្តេចទៀតទេ ហើយប្រព្រឹត្ត ឲ្យមានព្យសនកម្ម លើរូប អនីតិជន អាយុ តិចជាង ដប់បី ឆ្នាំ, លើរូបជន មានអាយុ ច្រើន ជាង ហុកសិប ឆ្នាំ ឬ លើរូបមនុស្ស ពិការ, បទមជ្ឈិមនោះ ត្រូវផ្តន្ទា ជាអតិបរមា នៃទោស ដែលទុក ជាទណ្ឌកម្ម នៃបទល្មើសនោះ, លើកមួយតែ ការីនោះ ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ។

# ជំពូក បី

## អំពី ទម្ងន់ទោស បណ្តាលមកពីគុណភាព នៃអ្នកប្រព្រឹត្តបទល្មើស

De l'aggravation des peines résultant
De la qualité de l'auteur de l' infraction

មាត្រា ១៨៣ - ជនណា, ដែលមាន អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ, ជាអ្នកពន្ធដារ, ភ្នាក់ងារពន្ធដារ, អ្នកដំណាង អាជ្ញាធរ សាធារណៈ, អ្នកទទួល ការៈ ពីមន្ត្រី របស់ក្រុមពន្ធដារ សាធារណៈ, បានប្រព្រឹត្ត, ក្នុងពេលកំពុងធ្វើការ មុខក្រសួង ឬ ក្នុងឱកាស ធ្វើការ មុខក្រសួង, នូវបទមជ្ឈិម ដែលច្បាប់ មិនបានបញ្ញត្តិ អ្វី ជាពិសេស ទៀតទេ, ជននោះ ត្រូវផ្តន្ទា ជាអតិបរមា នៃទោស ដែលជាទណ្ឌកម្ម នៃបទល្មើសនោះ ។

មាត្រា ១៨៤ - ជនណា មានអាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ, ជាបាវព្រាវ, ឈ្នួល, និយោជិត, និយោជក, ឬ អ្នករៀនធ្វើការ ក្នុងផ្ទះ របស់ជនណាម្នាក់, ហើយបានប្រព្រឹត្ត, ដោយផ្ទាល់ ឬ ដោយចូលគំនិត, ក្នុងរយៈវេលា ដែលខ្លួន នៅធ្វើការ ឲ្យគេ ឬ ដែលបានធ្វើការ ឲ្យគេ ពីពេលមុន មក, នូវបទមជ្ឈិមណាមួយ បណ្តាលឲ្យមាន ព្យសនកម្ម ដល់ជន ជាចៅហ្វាយ, ជាភ្ញៀវ ឬ ចៅកែនោះ, តែច្បាប់ មិនបានបញ្ញត្តិ

អ្វី ជាពិសេសទៀតទេ, ជននោះ ត្រូវផ្តន្ទា ជាអតិបរមា នៃទោស ដែល ទុក ជាទណ្ឌកម្ម នៃបទល្មើសនោះ ។

បទល្មើសណា បានធ្វើ ឲ្យមាន ព្យសនកម្ម ដល់សមាជិក នៃគ្រួសារ របស់ចៅហ្វាយ, ជន្លោ, ចៅកែ ទីង ដល់អ្នកក្រៅគ្រួសារ, តែ ដែលបានមកនៅ ស្នាក់អាស្រ័យ ទីផ្ទះ ចៅហ្វាយ, ជន្លោ, ចៅកែនោះ បទល្មើសនោះ ក៏ទុកដូចជា បានធ្វើ ឲ្យមាន ព្យសនកម្ម ដល់ចៅហ្វាយ, ជន្លោ, ចៅកែនោះដែរ ។

## ចំពូក បួន

## អំពី ទម្ងន់ ទោស បណ្តាលមក ពីទណ្ឌិត ជាមនុស្ស មិនរាងចាល ។

De l'aggravation des peines résultant
de l' état de récidive du condamné

## ផ្នែកទី មួយ

## អំពី ភាព មិនរាងចាល ក្នុងបទឧក្រិដ្ឋ

De l' état de récidive en matière criminelle.

មាត្រា ១៨៨– ក្នុងបទឧក្រិដ្ឋ, ទណ្ឌិត ដែលបានរងទោស ឧក្រិដ្ឋ រួចហើយ ហើយទៅប្រព្រឹត្ត បទឧក្រិដ្ឋមួយថ្មី ទៀត, ទោះបី កាល នៃការទទួល ទោសមុន នឹង កាល នៃការប្រព្រឹត្ត បទឧក្រិដ្ឋថ្មីនេះ

00222236





ឃ្លាត ពីគ្នា ចម្ងាយ ប៉ុន្មានឆ្នាំៗ ក្តី, ទោះបី បទឧក្រិដ្ឋថ្មីនេះ មានប្រភេទ ដូច ឬ មិនដូចគ្នា នឹងបទឧក្រិដ្ឋមុនក្តី, ក៏ទណ្ឌិតនោះ ត្រូវចូល ក្នុងភាព មិនពន្យាល ជានិត្យានុកូល ដែរ ។

បទបញ្ញត្តិនេះ មិនឲ្យយកទៅ អនុវត្ត លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ នឹង មនុស្សជរា ដែលប្រព្រឹត្ត បទឧក្រិដ្ឋ ហើយដាក់គុក មធ្យម ដោយអនុវត្ត តាមមាត្រា ១១៨ នឹង ១២៣ នោះទេ ។

មាត្រា ១៥៦- ទោស ដែលត្រូវអនុវត្ត លើទណ្ឌិតឧក្រិដ្ឋ ដែល នៅ ក្នុងភាពមិនពន្យាល ត្រូវកំណត់ ដូចនេះ :

១ – បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ចៅក្រម ត្រូវអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីបី ,

២–បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ, ចៅក្រម ត្រូវអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ,

ទោសឧក្រិដ្ឋទាំងឡាយ, ដែលត្រូវផ្តន្ទា លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ នឹងមនុស្សជរា អាយុ ច្រើនជាង ហុកសិប ឆ្នាំ ហើយ ដែលនៅ ក្នុងភាពមិនពន្យាល ជានិត្យានុកូល, ត្រូវសម្រេច តាមលក្ខ-ខណ្ឌ ដូចមានគ្រោងទុក ក្នុងបទបញ្ញត្តិ នៃមាត្រា ១១៨ នឹង ១២៣ ។

មាត្រា ១៥៧- កាលបើ មានការ ត្រាប្រណី ដល់ទណ្ឌិតឧក្រិដ្ឋ ដែលនៅ ក្នុងភាពមិនពង់ចាល ជាទិត្យានុកូលផង, ទោសឧក្រិដ្ឋ ដែលត្រូវផ្តន្ទា មិនត្រូវបន្ថែម ឲ្យធ្ងន់ ឡើងទៀតទេ គឺត្រូវបន្ថយ ដូចតទៅនេះ :

១- បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីបី, ចៅក្រម ត្រូវអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ វិញ ។

២- បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ហើយ ភាពមិនពង់ចាល ជាទិត្យានុកូល នាំឲ្យអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីបី, ចៅក្រម ត្រូវអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីពី ឬ ថ្នាក់ទីមួយ វិញ ។

៣- បើ ទោស ដែលត្រូវផ្តន្ទា ជាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ, ហើយ ភាពមិនពង់ចាល ជាទិត្យានុកូល នាំឲ្យអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ចៅក្រម ត្រូវអនុវត្ត ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ឬ ទោសគុកមធ្យម ដែលមានរយៈវេលា មិនតិចជាង ពីរ ឆ្នាំ និង មិនច្រើនជាង ប្រាំ ឆ្នាំ វិញ ។

បទបញ្ញត្តិ នៃមាត្រា ១១៨ និង ១២៣ ត្រូវយកទៅអនុវត្ត លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ និង មនុស្សជរា អាយុ ច្រើនជាង ហុកសិបឆ្នាំ ដែលនៅ ក្នុងភាពមិនពង់ចាល ជាទិត្យានុកូល ហើយ បាន ទទួល នូវសេចក្តីត្រាប្រណី ពីចៅក្រមដែរ ។

00222238





## ផ្នែកទីពីរ

## អំពីភាព មិនរាងចាល ក្នុងបទមជ្ឈិម

### De l'état de récidive en matière correctionnelle

មាត្រា ១៥៨– ក្នុងបទមជ្ឈិម, ទណ្ឌិតណា មានអាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ, ធ្លាប់មាន ទោសគុកមជ្ឈិម លើសពីមួយ ឆ្នាំ ព្រោះបទឧក្រិដ្ឋ ឬ ព្រោះបទមជ្ឈិម ហើយក្នុងរយៈវេលា ប្រាំ ឆ្នាំ, គិតតាំងពីថ្ងៃ ដែលបានទទួល ទោសមុន រួចហើយ ឬ ក្នុងករណី បន្ធូរប្រតិបត្តិទោស, គិតតាំងពីថ្ងៃ ដែលបានកាត់ទោសមក, បានប្រព្រឹត្ត ទោសកម្មមួយថ្មីទៀត ទោះបី ទោសកម្មថ្មីនេះ មិនមានប្រភេទ ដូចគ្នា នឹងទោសកម្មមុន ក៏ដោយ, ក៏ត្រូវទុកជា ទណ្ឌិតនោះ មិនរាងចាលដែរ ។

ទណ្ឌិតណា មានអាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ, ធ្លាប់មាន ទោសគុកមជ្ឈិម មួយ ឆ្នាំ ឬ តិចជាង មួយ ឆ្នាំ ហើយក្នុងរយៈវេលា ដូចបានពោលមក ជាពិសេស ក្នុងកថាខណ្ឌខាងលើ របស់មាត្រានេះ, បានប្រព្រឹត្ត ទោសសកម្មមួយ ថ្មី ទៀត, ទណ្ឌិតនោះ ត្រូវទុក ជាមនុស្ស មិនរាងចាល ហើយ, ប៉ុន្តែ ទោសកម្មថ្មីនេះ ត្រូវឲ្យមាន ប្រភេទ ដូចគ្នា នឹង ទោសកម្មមុន ផង ។

មាត្រា ១៥៩ – ដទៃអំពីករណី ដូចដែលពោលថា ទោសកម្មថ្មី ត្រូវឲ្យមាន ប្រភេទ ដូចគ្នា នឹងទោសកម្មមុននោះ, ច្បាប់បានរាប់បញ្ចូល

ទៅ ក្នុងភាពមិនកងចាល ដែរ គឺ:

១- ទោសកម្ម ដែលមានសំដែង ក្នុងក្រម ព្រហ្មទណ្ឌ ចំពួក ជាមួយគ្នា ;

២- ទោសកម្ម ក្នុងបទវិហិង្សា ដោយចេតនា ទោះបី អ្នកនឹងគ្រោះ នោះ មានគុណភាព ដូម្ដេច ក៏ដោយ ;

៣- ទោសកម្ម ទាំងឡាយ ទីនបំណងរបស់ទោសកម្មនេះ , ប្រសិនបើ ច្បាប់ បានបញ្ញត្តិ ឲ្យមានទោស ដល់បំណង ផង ។

៤- ទោសកម្ម ទីន សមគំនិត ។

មាត្រា ១៦០- ក្នុងបទឧមជ្ឈិម , ទណ្ឌិត អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ, ហើយនៅ ក្នុងភាពមិនកងចាល ជាទិត្យានុកូល , ត្រូវផ្តន្ទា ឲ្យដល់ អតិបរមា នៃទោស ដែលត្រូវផ្តន្ទា; បើ ទីនធ្វើ ទោសនោះ ជាទ្វេគុណ គឺមួយ ជាពីរ ក៏បាន ។

អនុទោស ត្រង់បន្ថយសិទ្ធិពលរដ្ឋ ទីន គំហាត់លំនៅ ទាំងពីរនេះ អាចយកទៅសម្រេច លើទណ្ឌិត ក្នុងបទឧមជ្ឈិម ដែលនៅ ក្នុងភាព មិនកងចាល ជាទិត្យានុកូល បាន, ទោះបី ច្បាប់ មិនគ្រោងទុក ឲ្យ អនុវត្ត នៃអនុទោសនោះ ទុកជាទណ្ឌកម្ម នៃទោសកម្ម ដែលត្រូវ និគ្រោះ នោះ ក៏ដោយ ។

ទណ្ឌិត ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ មិនអាចទុកជា ជា មនុស្សមិនកងតាល ជានិត្យានុកូល ក្នុងបទមជ្ឈិម បានទេ ។

មាត្រា១៦១ – នាកាល ចៅក្រម មាន ត្រាប្រណី ដល់ ទណ្ឌិត ក្នុងបទមជ្ឈិម ដែលមិនកងតាល ជានិត្យានុកូលហើយ , ទោស ទាំងឡាយ ដែលត្រូវផ្តន្ទា មិនត្រូវបន្ថែម ទៀតទេ, គឺថាទោសនោះ ត្រូវបន្ថយ តាមលក្ខខណ្ឌ ដូចបានពោល ជាពិសេស ក្នុងមាត្រា ១៣១ ទៅវិញ ។

មាត្រា ១៦២– នាកាល ទណ្ឌិត ឧក្រិដ្ឋ ឬ មជ្ឈិមណា រត់ ពីទីឃុំឃាំង ក្នុងពេល កំពុងរងទោស, ទណ្ឌិតនោះ ត្រូវទុកជា ជាមនុស្សមិនកងតាល ជានិត្យានុកូល តាមលក្ខខណ្ឌ ដូចជា បានរងទោស រហូត គ្រប់កំណត់ ដូច្នោះដែរ ។ រយៈវេលា ប្រាំ ឆ្នាំ ដូច មានគ្រោងទុក ក្នុងមាត្រា ១៩៨ ត្រូវរាប់ ពិត្រឹមថ្ងៃ ដែលត្រូវគ្រប់ កំណត់ទោស ទុកដូច ជាទណ្ឌិត គ្មានរត់ ពីទីឃុំឃាំង ទេ ។

អំពីទណ្ឌិត ដែលដោះលែង ព្រោះសេរីការ មានលក្ខខណ្ឌនោះ, រយៈវេលា ប្រាំឆ្នាំ ត្រូវគិតពីថ្ងៃ ដែលដោះលែង ។

## ផ្នែកទី បី

## អំពី ភាពមិនរាងចាល បណ្តាលឱ្យមាន បញ្ជាជនីយកម្ម

**De l'état de récidive entraînant relégation**

មាត្រា ១៦៣ – *អនុទោស ត្រង់បញ្ជាជនីយកម្ម មិនត្រូវយកទៅអនុវត្ត លើស្ត្រី, លើអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ និងលើមនុស្សជរា អាយុ ច្រើនជាង ហុកសិប ឆ្នាំ ទេ ។*

មាត្រា ១៦៤ – *បញ្ជាជនីយកម្ម តម្រូវឱ្យបន្ថយ សិទ្ធិ នៃពលរដ្ឋ ។ កំណត់ដែ សាលក្រម ដែលបញ្ជាឱ្យធ្វើ បញ្ជាជនីយកម្ម ត្រូវយកទៅ បិទផ្សាយ របៀបគ្នា និងសាលដីកា កាត់ទោសទុក្រិដ្ឋ ដែរ ។*

មាត្រា ១៦៥– *ក្នុងរវាង ដប់ ឆ្នាំ, ដោយមិនយក រយៈវេលានៃទោស ដែលកាត់ហើយនោះ មករាប់ផងទេ, ទោះបី បានរងទោសនោះ គ្រប់កំណត់ក្តី, រត់ ពីគុក មុនកំណត់ក្តី, មនុស្ស មិនរាងចាលនោះ ត្រូវទទួល អនុទោស បញ្ជាជនីយកម្មទៀត, ប្រសិនបើវា បាន ត្រូវ ទណ្ឌកម្ម ចំនួន ដូចមានរាយ ខាងក្រោមនេះ*

*១ – ទណ្ឌកម្ម ពីរ ដង សុទ្ធតែទោសទុក្រិដ្ឋ ទាំងអស់ ;*

00222242





២- ទណ្ឌកម្ម បីដង គឺមួយដង, ជាទោសឧក្រិដ្ឋ ហើយ ពីរទៀត, ជាទោសគុកមធ្យម ដែលមាន រយៈវេលាត្រឹមតែ មួយឆ្នាំ ឬ ច្រើនជាងមួយឆ្នាំ ព្រោះឧក្រិដ្ឋកម្ម ឬ ទោសកម្មថ្នាក់ទីបី ហើយនឹង អនុទោសពីរ គឺឃារបន្ថយ សិទ្ធិ នៃពលរដ្ឋ ១, គំហាត់លំនៅ ១ ;

៣- ទណ្ឌកម្មបួនដង សុទ្ធតែ ជាទោស គុកមធ្យម ដែលមាន រយៈវេលា ត្រឹមតែ មួយ ឆ្នាំ ឬ តិចជាង មួយ ឆ្នាំ ព្រោះឧក្រិដ្ឋកម្ម ឬ ទោសកម្ម ដូចបានសំដែង ជាពិសេស ខាងលើនេះ ។

មាត្រា ១៦៦- សំណុំរឿង ទាំងអស់, ដែលបញ្ជា ឲ្យឃើញ បញ្ចាជនីយកម្មនេះ, ត្រូវជូន ជាដំណឹង ដល់ទីស្តីការ រដ្ឋមន្ត្រី យុត្តិធម៌ក្រាម ។

## ផ្នែកទី បួន

## អំពី ភាពមិនរាងចាល ក្នុងបទលហុ

De l' état de récidive en matière de simple police

មាត្រា ១៦៧- ក្នុងបទលហុ, ក្នុងរយៈវេលា ដប់ពីរ ខែរាប់ ពីត្រឹមថ្ងៃ ដែលមាន ទណ្ឌកម្ម ទីមួយហើយ, ជនណា បានត្រូវ ទោសប្រឆាំង ពីបទលហុ មានប្រភេទ ដូចមុនទៀត, ជននោះ ត្រូវទុក ជាអ្នកមិនរាងចាល ។

00222243





មាត្រា ១៦៨– ទណ្ឌកម្ម ជាលហុ, ដែលទណ្ឌិតលហុ បាន ទទួលរង តាមលក្ខខណ្ឌ ដែលមានគ្រោងទុក ក្នុងព្រះរាជប្រកាស លេខ ១៤៥ ចុះថ្ងៃ ២៧ ធ្នូ ១៩៦២ នោះ, មិនត្រូវលើកយកមក គិត ក្នុងកាតមិនកន៍ពាល បានទេ ។

មាត្រា ១៦៩– ទណ្ឌិតលហុណា មិនកន៍ពាល, ទណ្ឌិតនោះ ត្រូវមានទោស ជាអតិបរមា នៃទោស ដែលមានគ្រោងទុក ក្នុងច្បាប់ ហើយទោសពិន័យ ត្រូវតែ ទ្វេ អតិបរមា នៃទោសពិន័យ ។ បើ ទណ្ឌិតលហុ នោះ បានទទួល សេចក្តីគ្រាប្រណីផង ទៅក្រុម មិនត្រូវ ឆាត់ ទោសគុក ទេ, ប៉ុន្តែ ចំនួនប្រាក់ពិន័យ មិនត្រូវបន្ថយ ឲ្យតិច ជាង អតិបរមា នៃកំណត់ពិន័យ ឡើយ ។

# គន្ថី បួន

# អំពី ការរំលត់ និង ការលោះទោស

## De L'extinction et de L'exemption des peines

## បទ បញ្ញត្តិ ប្រារភ

## DISPOSIIINOS PRÉLIMINAIRES

មាត្រា ១៧០– គ្រប់ទណ្ឌិត ត្រូវទទួលរង ទោសទាំងឡាយ ដែលតុលាការ បានផ្តន្ទា ខ្លួន ឲ្យគ្រប់កំណត់, វៀរតែ កាលណា មាន ហេតុណាមួយ នាំឲ្យរំលត់ ឬ នាំឲ្យរំលោះ ទោស ដូចមានគ្រោងទុក ក្នុងគន្ថីនេះ ឬ បានត្រូវបន្ធូរ ប្រតិបត្តិ ទោស លើសពីប្រាំ ឆ្នាំ តាម លក្ខខណ្ឌ ដែលមានគ្រោងទុក ក្នុងមាត្រា ១៣៤ នោះ ទើបផុត ពីការរង ទោស ឲ្យគ្រប់ កំណត់បាន ។

## មាតិកា មួយ

## អំពី អាជ្ញាយុកាល នៃទោស

## De la prescription des peines

មាត្រា ១៧១– អាជ្ញាយុកាល នៃទោស គឺអាយុ នៃទណ្ឌកម្ម ដែលនៅមាន អំណាចអាចធ្វើទោសទណ្ឌិតបាន ។ អាជ្ញាយុកាល នៃ ទោសត្រូវក្ស័យ កាលណាបើ ថ្ងៃកាត់ទោស និងថ្ងៃតម្រូវឲ្យទណ្ឌិត ទទួលទោស នោះ មានរយៈវេលាឃ្លាតដាច់ពីគ្នា ជាយូរអង្វែង ពេក ។

មាត្រា ១៧២– អាជ្ញាយុកាល របស់ៈ

ក) ទោសឧក្រិដ្ឋ មានកំណត់ ម្ភៃ ឆ្នាំ,

ខ) ទោសមជ្ឈិម មានកំណត់ ដប់ ឆ្នាំ,

គ) ទោសលហុ មានកំណត់ ពីរ ឆ្នាំ,

ឯទោសឧក្រិដ្ឋ របស់អនីតិជន ទីង របស់ជនដក ដែលតុលាការ យក ទោសតុកមជ្ឈិម មកអនុវត្ត តាមបញ្ញត្តិ មាត្រា ១១៨ ទីង ១៦៣ នោះ នៅតែមានលក្ខណៈជាឧក្រិដ្ឋ ក្នុងការគិត អាជ្ញាយុកាល របស់ទោស ទាំងនោះ ដដែល ។

មាត្រា ១៧៣– ថ្ងៃទីមួយ របស់អាជ្ញាយុកាល នៃទោសនោះ គឺថ្ងៃ ដែលទណ្ឌកម្មនោះ ចាប់ផ្ដើម មានភាព ជាស្ថាពរ, គឺថា បើ ទណ្ឌកម្មនោះ ជាសេចក្ដីសម្រេច ចំពោះមុខ, រយៈវេលា ត្រូវគិតតាំង ពីថ្ងៃ ដែលផុត អំណាច ឧទ្ធរណ៍ ឬ អំណាចសាទុក្ខ; ថាបើ ទណ្ឌកម្មនោះ ជាសេចក្ដីសម្រេចដាច់ណាត់, រយៈវេលា ត្រូវគិត តាំងពីថ្ងៃ ដែលផុតអំណាច ប្ដឹងទាស់ ។ សេចក្ដីសម្រេចដាច់ណាត់នេះ ត្រូវឲ្យដឹង ដល់សាមីខ្លួន ផ្ទាល់ខ្លួន ឬ ដល់ទីលំនៅ ឬ ក៏បិទ នៅសាលាឃុំ នៃឃុំ ដែលជាលំនៅរបស់ទណ្ឌិត, ប្រសិនបើ ទណ្ឌិតនោះ គេរៀស ខ្លួនបាត់ ។

សាលក្រម ឬ សាលដីកា ដាច់ណាត់ ណា ដែលបានកាត់ ក្នុង

រយៈពេល ដូចមានសំដែង ក្នុងមាត្រា ១០៩ ហើយមិនបានឲ្យ ដំណឹង ដល់មនុស្សត្រូវទោសទេ, សេចក្ដីសម្រេចនោះ នឹងបណ្ដាល ឲ្យអាជ្ញាយុកាល នៃទោស ទៅជាអាជ្ញាយុកាល នៃបណ្ដឹងអាជ្ញា វិញ ។

មាត្រា ១៧៤– នាកាល ទោស ដែលឃាត់ខ្លួនហើយនោះ,ទណ្ឌិត បានទទួល នៃទោសមួយភាគ ហើយរត់ចេញ ពីគុកទៅ, នោះរយៈពេល អាជ្ញាយុកាល ត្រូវគិត ពីថ្ងៃ ដែលកំណត់ទោស ត្រូវផុត គឺត្រូវគិត ដូចជា ទណ្ឌិតនោះ បានទទួល ទោសនេះ ទាំងអស់ ។ បើ ទណ្ឌិត ជា អ្នកបានទទួល សេរីការ មានលក្ខខ័ណ្ឌវិញ, រយៈពេល ត្រូវគិត ពីថ្ងៃ ដែលបានដោះលែង នោះ ។

មាត្រា ១៧៥– អនុទោស ទាំងឡាយ គឺបព្វាជនីយកម្ម, ទណ្ឌកម្ម ឲ្យសង, ឲ្យជួសជុល ឬ ឲ្យបង់ ជម្ងឺចិត្ត, មិនចេះផុត អាជ្ញាយុកាល ទេ ។ អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិពលរដ្ឋ ដែលបណ្ដាល មកពីទោសឧក្រិដ្ឋ ឬ បណ្ដាលមក ពីទោសបព្វាជនីយកម្មនោះ ក៏មិនចេះ ផុត អាជ្ញាយុកាល ដែរ ។

មាត្រា ១៧៦– ទោស ដែលផុត អាជ្ញាយុកាលហើយ ក៏ត្រូវរក្សា

00222247

D99/3/3



ទុក នូវនិទ្ទេស របស់វា ក្នុងបញ្ជីថ្កោលទោសដែរ ។ និទ្ទេស នៃទោស នេះ ទើនឹងយកមកគិត ពីភាពពុំកន្លងពាល, កាលណាបើ ទណ្ឌិត មានប្រព្រឹត្ត បទល្មើស ជាថ្មីទៀត ។

## មាតិកា ពី

## អំពី សេរីការ មានលក្ខខ័ណ្ឌ

## De la libération conditionnelle

មាត្រា ១៧៧– សេរីការ មានលក្ខខ័ណ្ឌ គឺជាការដោះលែង ទណ្ឌិត ពីគុក ឲ្យមានសេរីភាព, មុនពេលផុតកំណត់ ទោសជាទណ្ឌក្រិដ្ឋ ជាមជ្ឈិម ដែលតុលាការ បានសម្រេចហើយ លើរូបទណ្ឌិតនោះ; ការ ដោះលែងនេះ ទើបដិសេធចោល ទៅវិញ ក៏បាន ។

មាត្រា ១៧៨–(ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ ន.ស ២០-៤-៤៤) សេរីការ មានលក្ខខ័ណ្ឌនោះ ទើនឹងឲ្យ, ក្នុងមួយលើកៗ, តែ ទណ្ឌិតម្នាក់ ឬ ច្រើននាក់ ក៏ បាន ។

មាត្រា ១៧៩ – ( ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ ន.ស ២០-៤-៤៤) ព្រះមហាក្សត្រ គាប់ព្រះរាជទាន នូវសេរីការនេះ ដល់ទណ្ឌិត មួយលើក

00222248





មួយនាក់ៗ បានគ្រប់វេលា ទោះបី ទណ្ឌិតនោះ បានរងទោស បានប៉ុន្មានៗ ទៅហើយក្តី, ឲ្យតែមានពាក្យសុំ ឬ សុំផ្ទាល់មាត់ ពីទណ្ឌិត, ពីប្រពន្ធគេញប្យាប់, ពីបុព្វញាតិ ឬ ពីបច្ឆាញាតិ របស់ទណ្ឌិត ដែលមានជីវិតភាព ។ មុននឹងព្រះរាជទាន ព្រះមហាក្សត្រយ៍ អាចទ្រង់ចាំព្រះសណ្ដាប់ សេចក្ដីអង្កេត អំពីកិរិយា មារយាទ, ពីអតីតកាល របស់ទណ្ឌិត នឹងគ្រួសារ របស់ទណ្ឌិត, ព្រមទាំងទ្រង់ព្រះសណ្ដាប់ យោបល់ នៃនាយកគុក សិនក៏បាន ។ ព្រះមហាក្សត្រ ទ្រង់នឹងបដិសេធ នូវសេរីការនេះវិញ, នៅវេលាណា ក៏បាន ។

មាត្រា ១៨០– ( ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ – ន.ស២០-៤ ៤៤) សេរីការ មានលក្ខណ្ឌនេះ នឹងអនុញ្ញាត ឲ្យទណ្ឌិត ច្រើននាក់ ក្នុងមួយលើក ៗ ក៏បាន, កាលណាបើ ទណ្ឌិតទាំងនោះ មាន កិរិយា មារយាទ ត្រឹមត្រូវល្អ ក្នុងខណៈ ដែលរងទោសនោះ ។

ដើម្បីនឹងទទួល នូវសេរីការនេះ, ទណ្ឌិត ត្រូវបានរង ទោស ២ ភាគ ៣ ឬ ពាក់កណ្ដាល តាមភាពខ្លួន ជាទណ្ឌិតធម្មតា ឬ ទណ្ឌិតមិនពន់ពាល សិន ។ ឯទណ្ឌិត ក្នុងទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ត្រូវរងទោសឧក្រិដ្ឋ ឲ្យបាន ១៥ ឆ្នាំសិន, បើ អ្នកនេះ បានត្រូវអនុទោសត្រង់ស្ថានបញ្ញាជទីយកម្ម ព្រោះខ្លួន ជាមនុស្សមិនពន់ពាលនោះ, ត្រូវ

ឲ្យទទួល ទោសបព្វាជនីយកម្មនេះ ដប់ឆ្នាំសិន ។

ទណ្ឌិត ជាអនីតិជន មានអាយុ តិចជាង ដប់ប្រាំបី ឆ្នាំ អាចទទួល សេរីភាពមានលក្ខខណ្ឌនេះ បាន ទោះបីបានរង ទោសនោះ បានចំនួន ប៉ុន្មាន ៗ ក៏ដោយ ។

មាត្រា ១៨១– (ស្រង់ន័យពីព្រះរាជក្រមលេខ ០៣៣ ន.ស ២០ ៤-៤៤) សេចក្ដីស្នើសុំ សេរីភាពមានលក្ខខណ្ឌ ឲ្យទណ្ឌិតច្រើននាក់នោះ ជាភារៈ របស់អាជ្ញាធរ រដ្ឋបាល ខាងត្រួតត្រាគុក, ដែលទណ្ឌិតជាប់នោះ នៅរង ទោស, ជាអ្នកផ្ដើមសុំឲ្យ ។ ទណ្ឌិត ដែលគេសុំឲ្យនេះ ត្រូវមាន មូលដ្ឋាន ពីរយ៉ាង ជាដាច់ខាត គឺ ១– មានកិរិយាមារយាទល្អ , ២– មានការកែ ប្រែចិត្តគំនិតល្អ គួរឲ្យសំគាល់បាន តាំងពីពេលនេះទៅ ។

សេចក្ដីស្នើសុំសេរីភាពនេះ ត្រូវស្នើសុំ តាមពេលដែលបានកំណត់ ទុកមក គឺនៅឱកាស បុណ្យតាំងតុ ទីង ចូលឆ្នាំ, ឬនៅ ឱកាសបុណ្យ សាធារណៈ ជាឧឡារិកម្ដង ៗ ។ សេចក្ដីស្នើសុំ សេរីភាព ត្រូវបញ្ជូន មកក្រសួងយុត្តិធម៌ ។

មាត្រា ១៨២– (ស្រង់ន័យពីព្រះរាជក្រមលេខ ០៣៣-នស ២០-៤-៤៤) សេរីភាព មានលក្ខខណ្ឌ មួយលើក ៗ ច្រើននាក់នេះ ត្រូវអនុញ្ញាត

ដោយព្រះរាជក្រឹត្យ តាមសេចក្ដីយល់ឃើញរបស់គណៈកម្មការ ពិសេសមួយ មាននាយករដ្ឋមន្ត្រី ជាប្រធាន , ចាងហ្វាង សាលាវិនិច្ឆ័យ , ចាងហ្វាងសាលាឧទ្ធរណ៍ និងចាងហ្វាង សាលាដំបូង ភ្នំពេញ ជាសមាជិក មន្ត្រីមួយនាក់ ក្នុងក្រសួងតុលាការ ជាលេខាធិការ ។ គណៈកម្មការនេះ ត្រូវវិនិច្ឆ័យ តាមសេចក្ដីរាយការណ៍ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មាត្រា ១៨៣ – (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ នស ២០ ៤-៤៤)
បើបានពិនិត្យទៅ ឃើញថា ទណ្ឌិត មានអាការកេត គួរឲ្យដោះលែងបាន, សេរីការមានលក្ខខ័ណ្ឌ អាចអនុញ្ញាតឲ្យបាន, ទោះបី ទោសនោះ មានកំណត់ ប៉ុន្មាន ៗ ក៏ដោយ, ទោះបីទណ្ឌិតបានរង ទោសចំនួនប៉ុន្មាន ៗ ក៏ដោយ ។

មាត្រា ១៨៤ – (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣.នស ២០-៤-៤៤ )
ដីកាដែលអនុញ្ញាតឲ្យសេរីការមានលក្ខខ័ណ្ឌ ត្រូវកំណត់ ទីលំនៅ ឲ្យទណ្ឌិត នឹងអាចដាក់ កំហិតផ្សេងៗ ឲ្យទណ្ឌិត ដើម្បីឲ្យរក់ រាងចាលផង, ឲ្យបានសេចក្ដីរៀបរយ ដល់ប្រជាជន ផង ។

មាត្រា ១៨៥ – (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ នស ២០-៤-៤៤)
ទណ្ឌិត ដែលត្រូវដោះលែង ត្រូវឲ្យរួច តាំងពីថ្ងៃ ដែលបានប្រគល់ ព្រះ

រាជក្រឹត្យ ទៅឲ្យនាយគុក ដែលទណ្ឌិតនោះ នៅរង់ទោស ។ សេរីភាពនេះ ខានទៅជាស្ថាពរ ក្នុងថ្ងៃ ដែលផុត កំណត់ទោស ដោយយក រយៈវេលា, ដែលបានទទួល ទោស មុនដោះលែង ពីគុកនោះ, មកគិតផង ។

មាត្រា ១៨៦ – (ស្រង់ចេញពីព្រះរាជក្រមលេខ ១៣៣-ន.ស.២០.៤.៥៥)
សេរីភាពមានលក្ខខណ្ឌនេះ ត្រូវតែបដិសេធវិញ ជាចាំបាច់, តាមយោបល់ របស់គណៈកម្មការ ដូចមានបញ្ញត្តិ នៅមាត្រា ១៨១ ខាងលើនេះ កាលណា បើ គណៈកម្មការនេះ យល់ឃើញថា ទណ្ឌិតនោះ នៅតែកាន់ កិរិយាមារយាទអាក្រក់ ដដែល ឬ ល្មើស នឹងលក្ខខណ្ឌផ្សេង ៗ ដែលមានដាក់កំហិត ក្នុងដីកាដោះលែងនោះ, ឬក៏ ទណ្ឌិត, ដែលបាន សេរីភាព ដោយសារខ្វះសុខភាពនោះ, បានសះជាវិញហើយ ។ កាលណាបើ មានការដកហូត ដីកានោះហើយ, អាជ្ញាធរខាងតុលាការ ត្រូវចាប់ឲ្យបាន ខ្លួនទណ្ឌិត ដែលបានសេរីភាពនោះ មកដាក់គុកវិញ ។

បើ ទណ្ឌិត ដែលបាន សេរីភាពនេះហើយ, បានប្រព្រឹត្ត បទល្មើស ជាមជ្ឈិម ឬ ជាឧក្រិដ្ឋ ក្នុងខណៈដោះលែងនោះទៀត, អំពើ ដែលប្រព្រឹត្ត នេះ នាំឲ្យបដិសេធ ដីកាអនុញ្ញាត សេរីភាពនោះ ពេញច្បាប់ ។

00222252





មាត្រា ១៨៧- (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣-នស.២០-៤-៤៤) កាលបើបដិសេធ ដីកាសារការនោះហើយ ទណ្ឌិត នោះ ត្រូវមកជាប់គុកវិញ, ត្រាតែគ្រប់កំណត់ទោស ដែលនៅសល់ខាន ពីថ្ងៃ ដែល បដិសេធ ដីកាដោះលែង នោះ គឺថា រយៈវេលា នៃទោសទាំងមូល ដែលតុលាការ បានកាត់ សេចក្ដីនោះ ត្រូវដក រយៈវេលា ដែល មនុស្សនោះបានទទួលដេកក្នុងគុក ពីថ្ងៃកាត់សេចក្ដី ដល់ថ្ងៃដែលដោះ លែង នេះចេញ, ត្រូវដក រយៈវេលា ដែលមនុស្សនោះ បាននៅ ក្រៅគុក ចេញ ហើយនឹង ត្រូវដក រយៈវេលា ដែលមនុស្ស នេះ បានជាប់ឃុំ ជាបណ្ដោះអាសន្ននោះ ចេញទៀត ។

មាត្រា ១៨៨- (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣-នស.២០-៤-៤៤) សេរីការមានលក្ខណៈនេះ គ្មានអានុភាពអ្វី ទៅលើកម្រៃបាក ទាំងឡាយ មានអនុទោសជាដើម ដែលកើតមក ពីទណ្ឌកម្ម នោះទេ ។ បាន សេចក្ដីថា ទណ្ឌិត ដែលបានសេរីការហើយ, ប្រសិនបើមិនទាន់បាន សង សំណងជួសជុល ដម្លៃចិត្តគេ ឲ្យជ្រះស្រឡះ តាមដែល ខ្លួន ជំពាក់ ភាគីស៊ីវិល ទេ, ទណ្ឌិតនោះ ត្រូវនៅ ក្នុងគុក ពីដំណើរ ដាក់គុក បង្ខំទាប្រាក់នោះ ទៀត តាមលក្ខណ៍ ដែលមានបញ្ញត្តិ នៅ មាត្រា ១៦ និង ១៣ នោះ ។ ឈ្មោះទណ្ឌិតនេះ ត្រូវបំណាយ ចេញ

ពីបញ្ជី ទណ្ឌិត ហើយបញ្ចូល ឈ្មោះនេះ ទៅក្នុងបញ្ជី មនុស្សជាប់គុក បន្ទោរប្រាក់វិញ, តាំងពីថ្ងៃ ទទួលដំណឹង ពីព្រះរាជក្រឹត្យ អនុញ្ញាតឱ្យសេរីការ មាន លក្ខ័ណ្ឌ ពីមូលទោសនោះមក ។ រយៈពេលដាក់គុកបន្ទោរប្រាក់នេះ ត្រូវឱ្យគិត តាំងពីថ្ងៃនេះតទៅ ។ នឹងបញ្ឈប់ដាក់គុកបន្ទោរប្រាក់វិញបាន, ឈលណាបើ ភាគីស៊ីវិល ជាម្ចាស់ជំពាក់ សុំឱ្យបញ្ឈប់ ឬក៏ មនុស្សត្រូវដាក់គុកបន្ទោរប្រាក់នេះ មានជម្ងឺឈឺ ហើយជម្ងឺនោះ តម្រូវឱ្យបញ្ឈប់ ។

មាត្រា ១៨៩ — (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣.នស .២០.៤-៥៥)

ទណ្ឌិត ដែលបាន សេរីការនេះ ហើយ នៅតែមានជាប់ឈ្មោះ ក្នុងបញ្ជីថ្កោលទោសដដែល ពីព្រោះថាទោសនេះ នឹងត្រូវយកទៅគិត ពីការ មិនពន្យាល ទៀត, ប្រសិនបើ ទណ្ឌិត បានប្រព្រឹត្ត បទល្មើសថ្មីទៀត ។

នាកាលបើ ទណ្ឌិត កំពុងនៅ ក្នុងពេលសេរីការ ឬក្រោយពេលសេរីការ ត្រូវតុលាការ យកខ្លួនមកកាត់ទោស ពីដំណើរ មានបទល្មើសណាមួយទៀត ដែលខ្លួន បានប្រព្រឹត្ត ជាយូរណាស់មកហើយ មុនបទល្មើស ដែលខ្លួនមានទោស ហើយ បានសេរីការ នោះទៅទៀត, នោះចៅក្រម ត្រូវយកវិធាន ដែលស្តី ពីបទល្មើសច្រើនបទ ពីបទល្មើសស្របចូលគ្នា និង ការតម្រួត មានព្រំដែន នៃទោស មកអនុវត្ត ។

# មាតិកា បី

## អំពី លោះលា ទោស នឹង បន្ថយ ទោស

## De la remise et de la réduction des peines

មាត្រា ១៩០– (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ នស ២០-៤-៤៤)

លោះលា ទោស គឺលោះ ទោសទាំងអស់ របស់ទណ្ឌិត ដែលមិនទាន់បានទទួល នៅឡើយ ឬ ឲ្យសេរីភាព ដល់ទណ្ឌិត ជាស្ថាពរ មុនផុតកំណត់ទោស ។ បន្ថយ ទោស គឺបន្ថយកំណត់ទោស ដែលនៅសល់ខាន មិនទាន់បានទទួល នៅឡើយ ឲ្យថយតិចចុះមក ។

មាត្រា ១៩១– (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣ នស ២០-៤-៤៤)

សេចក្តីប្រោសប្រណី ទាំងពីរខាងលើនេះ ជារបស់ព្រះមហាក្សត្រិយ៍ ។ បណ្តា សេចក្តីប្រោសប្រណី ទាំងពីរមុខនេះ, មួយមុខ ៗ មានពីរបែប :

១– បើ ព្រះមហាក្សត្រទ្រង់ប្រោសប្រទាន ទោស ដល់ទណ្ឌិត តែម្នាក់ ក្នុងមួយលើក ៗ នោះទ្រង់អាចធ្វើបាន គ្រប់ពេលវេលា ក្នុងមួយឆ្នាំ ៗ ទោះបីបទល្មើសនោះយ៉ាងដូចម្តេចក្តី ដូចដែលមានសម្តែង នៅមាត្រា ១៧៩ ខាងលើនេះ ។

២– បើ ទណ្ឌិតច្រើននាក់ ក្នុងមួយលើក ៗ វិញ, ការនេះ ជាការៈ របស់អាជ្ញាធរ ខាងរដ្ឋបាល ដែលត្រូវធ្វើ តាមលក្ខខណ្ឌ និងនីតិវិធី

00222255





ដូចមានសម្តែងក្នុងមាត្រា ១៨១ នឹង ១៨២ ជាអ្នកសុំ ឲ្យទណ្ឌិតមជ្ឈិម ឬ ទក្រិដ្ឋ ដែលបានរង ទោសគុក ២ភាគ៣ យ៉ាងតិច ឬ ពាក់កណ្តាល, ប្រសិនបើ ត្រូវបន្ថយ, លើកមួយតែ ទណ្ឌិតនោះ ជាអនីតិ-ជន អាយុ តិចជាង ដប់ប្រាំបីឆ្នាំ ។

មាត្រា ១៩២– (ស្រង់ន័ពីព្រះរាជក្រមលេខ ១៣៣-នស ២០·៤·៤៤ )
លោះលា ទោស ដល់ទណ្ឌិតទាំងពួងនេះ, ព្រះមហាក្សត្រ នឹងព្រះរាជទាន ឲ្យតែទណ្ឌិត ដែលជាប់ទោសគុកមជ្ឈិម កំណត់ប្រាំឆ្នាំយ៉ាងតិចតែប៉ុណ្ណោះ លើកមួយតែ ទណ្ឌិតនោះ ជាអនីតិជន អាយុតិចជាងដប់ប្រាំបី ឆ្នាំ ។ ទណ្ឌិត ត្រូវបញ្ជាជនីយកម្ម ត្រូវរងទោស ឲ្យបានដប់ ឆ្នាំ ឯទណ្ឌិត ទោសទក្រិដ្ឋ ថ្នាក់ទីពីរ ត្រូវរងទោសឲ្យបានដប់ប្រាំ ឆ្នាំ ។

មាត្រា ១៩៣– (ស្រង់ន័យពីព្រះរាជក្រមលេខ ១៣៣-នស ២០-៤-៤៤)
ការបន្ថយទោស ឲ្យទណ្ឌិតទាំងពួងនេះ ទឹងអនុញ្ញាតឲ្យ ទណ្ឌិត ម្នាក់បានតែមួយដង ក្នុងមួយឆ្នាំ ហើយក្នុងមួយដង ១ មិនត្រូវបន្ថយឲ្យលើស ពីពីរឆ្នាំទេ ។ រយៈកាល ដែលបានបន្ថយឲ្យនេះ ត្រូវទុកដូចជា ទណ្ឌិត បានទទួល ទោស រួចហើយ ។

00222256





មាត្រា ១៩៤– លោះលាទោស ទីង បន្ថយទោសនេះ ទុកឲ្យនៅមានផងដែល នូវកម្មវិបាកខាងស៊ីវិល ឬ ខាងព្រហ្មទណ្ឌ ដែលកើតមក ពីទណ្ឌកម្ម ដើម្បីទីងយកទៅគិត ពីភាពមិនកែងចាល ។

## មាតិកា បួន
## អំពី លើកលែង ទោស
### DE L' AMNISTIE

មាត្រា១៩៥– លើកលែង ទោស គឺលើកចោលទាំងអស់ ឬ លែងឲ្យនឹកទៅទៀត នូវទោស ជាទណ្ឌកម្ម នៃបទល្មើស ដែលមានព្រះរាជក្រម លើកលែងទោសឲ្យ ។ លើកលែងទោស នេះ ជាការៈកិច្ច របស់ព្រះរាជក្រម គឺថា ទីងលើកលែងទោសបាន លុះតែមានព្រះរាជក្រមស្ដីពីលើកលែងទោសនោះ ដោយពាយពង់ នូវបទល្មើសទាំងឡាយ ដែលត្រូវលើកលែងទោសនោះ យ៉ាងច្បាស់លាស់ផង ។ លើកលែងទោសនេះ មានអានុភាព ពីរយ៉ាង គឺ :

១.– ធ្វើឲ្យលែង បណ្ដឹងអាជ្ញា ដែលត្រូវប្ដឹង ឬបានប្ដឹងហើយ ពីបទល្មើស ទាំងឡាយណា ដែលមានចែង ក្នុងព្រះរាជក្រម នោះ ។

២.– លើកចោលស្រឡះ នូវទោសទាំងឡាយ គឺមូលទោស និងអនុទោស នៃបទល្មើស ដែលត្រូវលើកលែងនោះ មិនឲ្យមាន តទៅទៀត

ទេ ។ ក៏ប៉ុន្តែ បើទោសនោះ ជាទោសពិន័យ ហើយទណ្ឌិត ក៏បានបង់ពិន័យនោះ រួចទៅហើយផង នោះតុលាការ មិនត្រូវសង ប្រាក់ពិន័យនោះ ទៅទណ្ឌិត វិញទេ ។

ព្រះរាជក្រមនេះ នឹងលើកលែង ទោស ទៀត បទល្មើស ណា ដែលបានប្រព្រឹត្តមុន ថ្ងៃ ប្រកាសឲ្យប្រើ ព្រះរាជក្រមនោះ ។

មាត្រា ១៩៦– បទល្មើស ឬ ទណ្ឌកម្ម ដែលត្រូវ លើកលែងទោសនោះ ត្រូវនៅមាន កម្មវិបាកស៊ីវិលដដែល ៗ ជនណា បង់ខាតប្រយោជន៍ ដោយសារបទល្មើស ដែលត្រូវបានលើកលែងនោះ, ជននោះ អាចនឹងប្តឹងសុំ ដល់សាលានិគ្រោះ មានសមត្ថកិច្ច ឲ្យសោហ៊ុយជួសជុល នឹង ការបង់ខាតបាន ។ តុលាការ, កាលបើ ពិនិត្យទៅហើយ ឃើញថា មានពិរុទ្ធ លើជនដែលគេប្តឹង នោះមែន, ត្រូវសម្រេចឲ្យបាន តាមពាក្យសុំ របស់ភាគី ស៊ីវិល ; ក៏ប៉ុន្តែ តុលាការមិនត្រូវផ្តន្ទា ទោសអ្វី ដើម្បីនិគ្រោះ បទល្មើស នោះឡើយ ។

ក្នុងបទល្មើស ជាឧក្រិដ្ឋវិញ, ត្រូវសាលាក្រមទោស ជាមុខក្រសួងពិនិត្យ ពីមានពិរុទ្ធ ឬ មិនមាន ហើយនឹងបញ្ជាក់ ពីសេចក្តីបង់ខាតព្រមទាំង បង្គាប់ ឲ្យជួសជុល សេចក្តីបង់ខាតផង ។ សាលដីកា ដែលសាលាក្រមទោស បានសម្រេចហើយនោះ ភាគី ដែលមិនសុខចិត្ត អាចប្តឹង

សារទុក្ខ ទៅសាលាវិនិច្ឆ័យបាន, ក្នុងកំណត់ដប់ថ្ងៃ, គិតពីថ្ងៃ ដែលបានទទួល ដំណឹង ពីសាលដីកានេះ ។

មាត្រា ១៩៧– ទណ្ឌកម្មទាំងឡាយ ដែលត្រូវបាន លើកលែងនោះ ត្រូវលុបចេញ ពីបញ្ជីថ្កោលទោស ព្រោះទណ្ឌកម្មនោះមិនត្រូវយកមកគិត ក្នុងការសម្រេច ពីស្ថានពុំកន្ទាលទេ ។

## មាតិកាប្រាំ

## អំពី ការលុបលាង ទោស

## DE LA RÉHABILITATION

មាត្រា ១៩៨– លុបលាង ទោសគឺ ធ្វើឲ្យទៅ ជាមោឃ ពួងអនាគត នូវអានុភាព របស់ទណ្ឌកម្ម ដែលតុលាការ បានផ្តន្ទាហើយ ហើយ ទណ្ឌិត ក៏បានទទួល ទោសនោះ រួចហើយដែរ ។ លុបលាង ទោសនេះ ជាមុខក្រសួង សាលាវិនិច្ឆ័យ គឺជាសាលានេះ ជាអ្នកចេញសាលដីកា អនុញ្ញាតឲ្យ ក្រោយដែលបានឲ្យធ្វើអង្កេត ជាពិសេស រួចហើយ ។

មាត្រា ១៩៩– លុបលាងទោសនេះ នឹងអនុញ្ញាតឲ្យ បាន តែទណ្ឌិតណា ដែលបានទទួលទណ្ឌកម្ម តុលាការផ្តន្ទានោះ រួចស្រឡះ,

ហើយ ឬ ដែលទណ្ឌកម្មនោះ ហួស អាជ្ញាយុកាលហើយ, ហើយ ទណ្ឌិត ក៏បានជូន សំគាល់ថា ខ្លួន បានបង់ប្រាក់ពិន័យ និងសំណង ឬ ប្រាក់ជួសជុលជម្ងឺចិត្ត ដែលខ្លួន ត្រូវបង់នោះ រួចស្រឡះ ហើយផង ។

មាត្រា ២០០- ការសុំ លុបលាង ទោស ជាឧក្រិដ្ឋ, និងអាច សុំបាន កាលណា ទណ្ឌិត បានរួច ពីទោស មក ដប់ ឆ្នាំ ហើយ បើទោស ជាមជ្ឈិមវិញ លុះត្រាតែទណ្ឌិត បានរួច ពីទោស មកប្រាំឆ្នាំ ចំពោះទណ្ឌិត ដែល មានភាពមិនកង់ចាល ឬ ចំពោះទោស ដែល ហួស អាជ្ញាយុកាលហើយ, កំណត់ កាលខាងលើនេះ ត្រូវគិតទ្វេ ។

រយៈវេលាខាងលើនេះ ត្រូវគិតពីថ្ងៃ ដែលបានទទួលរង ទោស ផុតហើយ ឬ ពីថ្ងៃ ដែលហួសអាជ្ញាយុកាលហើយ ។

សេចក្ដីអនុញ្ញាត និងឲ្យតាមពាក្យសុំ បាននោះ, លុះតែឃើញថា វិរុទ្ធជននោះ មានសេចក្ដីកង់ចាល ជួនល្មម ផង ។

មាត្រា ២០១- លុបលាងទោស នាំឲ្យលុបចោល នូវអសមត្ថភាពទាំងអស់, ដែលបណ្ដាលមក ពីទណ្ឌកម្ម ។ ទោសដែលត្រូវលុបលាងនោះ លែងឲ្យគ្រាទុក ក្នុងបញ្ជីថ្កោលទោស តទៅទៀតហើយ, ហើយ និងមិនត្រូវយកទៅធ្វើ ជាមូលដ្ឋាន ដើម្បីអនុវត្ត ពីភាពពុំកង់ចាល ទៀតទេ ។

# គន្ថី ប្រាំ

# អំពី បទល្មើស

# DES INFRACTIONS

## បទ បញ្ញត្ត ប្រារភ

## DISPOSITIONS PRÉLIMINAIRES

មាត្រា ២០២- អំពើណា ប្រឆាំង នឹងរដ្ឋ, ប្រឆាំង នឹង អ្នកតំណាង របស់រដ្ឋ, អំពើណា ធ្វើ ឲ្យសៅហ្មង ដល់ការប្រើ អំណាច របស់រដ្ឋ, ដល់សម្បូណ៌ភាព នៃសិទ្ធិ នឹង បុព្វសិទ្ធិ របស់រដ្ឋ អំពើណា ធ្វើ ឲ្យមាន ព្យសនកម្ម ដល់ប្រយោជន៍ទូទៅ នៃ សមូហភាព, អំពើនោះៗ ជា បទល្មើស ប្រឆាំង នឹងវត្ថុសាធារណ ។

អំពើណា ប្រឆាំង នឹងបុគ្គល ជាឯកជន, ប្រឆាំង នឹងកេរ្តិ៍ ឈ្មោះ របស់ឯកជន, ប្រឆាំង នឹងធនធាន របស់ឯកជន, អំពើនោះ ជា បទល្មើស ប្រឆាំង នឹង ជន ជាសាមញ្ញ ។

## មាតិកា មួយ

## អំពីបទល្មើស ប្រឆាំនឹងវត្ថុសាធារណ :

## DES INFRACTIONS CONTRE LA CHOSE PUBLIQUE

មាត្រា ២០៣- អំពើណា ល្មើស ចំពោះព្រះមហាក្សត្រ

នឹងចំពោះព្រះរាជវង្សានុវង្ស, នឹងសាសនា, ប្រឆាំង នឹងសេចក្ដីសុខសាន្ត ខាងក្រៅ នឹងខាងក្នុងរដ្ឋ, អំពើណា ល្មើស ក្នុងពេល កំពុងធ្វើការមុខក្រសួង, អំពើណា ធ្វើ ឲ្យសៅហ្មង ដល់សេរីភាព ក្នុងការប្រើសិទ្ធិ នៃពលរដ្ឋ, ធ្វើឲ្យសៅហ្មង ដល់របៀបរៀបរយ សាធារណៈ, ធ្វើ ឲ្យសៅហ្មង ដល់ធនធាន នឹង សីលធម៌សាធារណៈ, អំពើនោះៗ ត្រូវទុកជា ជាបទល្មើស ប្រឆាំង នឹងវត្ថុសាធារណៈ ។

## ចំពូកមួយ

## បទល្មើស ប្រឆាំង ព្រះមហាក្សត្រិយ៍ នឹង ព្រះរាជវង្សានុវង្ស

## Des infractions contre le Roi et les Membres de la Famille Royale

មាត្រា ២០៨– ការព្យាបាទ ដល់ព្រះជន្ម ឬ ដល់ព្រះកាយ នៃព្រះមហាក្សត្រិយ៍ ម្ចាស់ផែនដី ត្រូវផ្តន្ទា ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

ការព្យាបាទ ដល់ព្រះជន្ម នៃព្រះរាជវង្សានុវង្ស ត្រូវផ្តន្ទាទោស ដូចគ្នា ។

ការព្យាបាទ ដល់ព្រះកាយ នៃព្រះរាជវង្សានុវង្ស ត្រូវផ្តន្ទាទោស ឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ២០៩– សេចក្ដីប្រមាថមើលងាយ ព្រះមហាក្សត្រិយ៍

ដោយលិខិត, គំនូរ, រូប, រូបថត, ទស្សនីយភាព, វាចា ឬ សូរសៀង, អាកប្បកិរិយា, កាយវិការ ឬ កំហែងគំរាម ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីបី ។

ប៉ុន្តែ បើ សេចក្តីប្រមាថមើលងាយនោះ មិនបានប្រព្រឹត្ត ក្នុងទី សាធារណៈទេ, បើ សេចក្តីប្រមាថនោះ មិនធ្វើឡើងទៅ ជាសាធារណ៍ ទេ ឬ បើ ការនេះ មិនបានប្រព្រឹត្ត ក្នុងទី ចំពោះព្រះភក្ត្រ ព្រះមហាក្សត្រិយ៍ ទេ ឬ មិនបានប្រព្រឹត្ត ក្នុងទី ចំពោះមុខ បុគ្គល អ្នកតំណាងព្រះអង្គ ជាផ្លូវការ ទេ, អំពើនោះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីពីរ ។

សេចក្តី ប្រមាថមើលងាយ ដល់ព្រះរាជវង្សានុវង្ស តាមលក្ខណៈ ដូចគ្នា ក្នុងទី ដូចវគ្គ ទីមួយ នៃមាត្រានេះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីពីរ, បើ ក្នុងទី ដូចវគ្គទីពីរ នៃមាត្រានេះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ក្នុងករណីទាំងអស់នេះ អនុទោស គ្រឿងស្លាក បន្ថយសិទ្ធិពលរដ្ឋ និង គំហាត់លំនៅ សុទ្ធតែ អាចយកមក ផ្តន្ទា បាន ។

បទបញ្ញត្តិ នៃមាត្រា ២៩៩ អាចយកមកអនុវត្តបាន គ្រឿង ១ ដែល ត្រូវ កំណត់វិរុទ្ធជន, គ្រឿង ២ ដែលត្រូវហាមប្រកាន់ និង គ្រឿងគំហាត់ មិនឲ្យបញ្ចេញផ្សាយ ខ្ទីវត្ថុ ដែលជាអង្គ នៃបទល្មើសនោះ ។

00222263



មាត្រា ២០៦ – ព្រះរាជវង្សានុវង្ស គឺ

១– ព្រះវររាជមាតា

២– ព្រះអគ្គមហេសី

៣– ព្រះរាជបព្វញាតិ រហូតត្រឹម បី តំណ វង្ស ។

មាត្រា ២០៧ – បទល្មើស ដែលប្រព្រឹត្ត ឲ្យកន្លង នឹង ព្រះរាជប្រកាស ស្តីពីបទបញ្ជា ខាងកងព្រះរាជវាំង ត្រូវផ្តន្ទាទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២០៨ – បទល្មើស ដែលប្រព្រឹត្ត ឲ្យកន្លង នឹង ព្រះរាជប្រកាស កំណត់ របៀបពិធីបុណ្យ និង របៀបរៀបចំហ្លួង ត្រូវមានទោស ជាលហុ ។

## ចំពូក ពីរ

## បទល្មើស ប្រឆាំង នឹង សាសនា របស់រដ្ឋ

### Des infractions contre la religion

មាត្រា ២០៩ – ការព្យាបាទ ដល់ជីវិត របស់បព្វជិត ក្នុងសាសនា របស់រដ្ឋ, នៅវេលា ដែលលោក កំពុងធ្វើវត្តប្រតិបត្តិ ឬ នៅ

ឱកាស ដែលលោក ធ្វើវត្តប្រតិបត្តិ តាមច្បាប់សាសនា, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ២១០- ការព្យាបាទ ដល់រូបកាយ របស់បព្វជិត ក្នុងសាសនា របស់រដ្ឋ, នៅវេលា ដែលលោក កំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាស ដែលលោក ធ្វើវត្តប្រតិបត្តិ តាមច្បាប់សាសនា, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ២១១- សេចក្តីប្រមាថ តាមរបៀប ដូចមានរៀបរាប់ ក្នុងមាត្រា ២០៨ ដល់បព្វជិត ក្នុងសាសនា របស់រដ្ឋ, នៅវេលា ដែលលោក កំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាស ដែលលោក ធ្វើវត្តប្រតិបត្តិ តាមច្បាប់សាសនា, ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើនឹងសម្រេច អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិពលរដ្ឋ នឹងតំហាត់លំនៅ ទៀតក៏បាន ។

បទបញ្ញត្តិ នៃមាត្រា ២៩៩ ត្រូវយកមក អនុវត្ត បាន ត្រង់ ១ ដែលត្រូវកំណត់ វិរុទ្ធជន, ត្រង់ ១ ដែលត្រូវទោទប្រឈន់ នឹង ត្រង់ តំហាត់ មិនឲ្យចេញឆ្ងាយ ខ្ទូវែត ដែលជាអង្គ នៃបទល្មើស ។

00222265

D99/3/3



មាត្រា ២១២–ត្រូវធ្វើទោសមជ្ឈិម ថ្នាក់ទីពីរ ដល់:

១- ជនណា ដែលកំរើក, រំខាន, ឬបង្អាក់ ដោយចេតនា ឲ្យខានធ្វើបុណ្យ ក្នុងសាសនា របស់រដ្ឋ,

២- ជនណា ដែលធ្វើឲ្យលំអក់ពណ៌ ដោយចេតនា ដល់សេចក្ដីរុងរឿង នៃបុណ្យ ក្នុងសាសនា របស់រដ្ឋ,

៣- ជនណា ជេរ ឬប្រមាថ ដោយរបៀប ដូចម្ដេចក្ដី នូវសរណវត្ថុ ដែលទុកដាក់ ក្នុងបូជនីយដ្ឋាន នឹងកន្លែង ជាទីគោរពសាសនា របស់រដ្ឋ ។

មាត្រា ២១៣– ការធ្វើបុណ្យ នឹងការចូលទៅបួស ក្នុង សាសនា របស់រដ្ឋនេះ នឹងអាចធ្វើបាន តែជនណា បានទទួល សិទ្ធិ ក្នុងការនេះ, ឯជនដែលច្បាប់ដក សិទ្ធិនោះ អស់ហើយ នឹងចូលធ្វើជន ឬ ចូលបួសជន មិនបានទេ ។ ការកុសលនេះ ធ្វើបាន តែក្នុងបូជនីយដ្ឋាន នឹង កន្លែងពេញច្បាប់ សម្រាប់ធ្វើ មុខការនោះ, ឯ កន្លែងដែលគ្មានច្បាប់ អនុញ្ញាតនោះ នឹងធ្វើកុសលតាំងនេះ មិនបានឡើយ ។

ជន ដែលអាចបួស ក្នុងសាសនា របស់រដ្ឋ បាន គឺជន ដែលបានទទួល សេចក្ដីយល់ព្រម គឺគណៈសង្ឃ មិនមែនជន ដែលសង្ឃដកសិទ្ធិនោះទេ ។

00222266





បូជនីយដ្ឋាន គឺទី សម្រាប់គោរព សាសនា របស់រដ្ឋ, ពេញច្បាប់ ឬ មិនពេញច្បាប់នោះ, សុទ្ធតែមាន ព្រះរាជប្រកាស សម្រេច ដោយមានសេចក្តីយល់ព្រម ពីគណៈរដ្ឋមន្ត្រី, តាមសេចក្តីស្នើរ របស់រដ្ឋមន្ត្រីក្រសួងធម្មការ ។

២ បុណ្យលទ្ធិសាសនាផ្ទាល់ខ្លួនម្នាក់ៗ ដូចជាបុណ្យខួប, បន់ស្រន់, លាបំណន់ ឬ បុណ្យគ្រួសារដែលធ្វើ នៅផ្ទះរៀងខ្លួន ចំពោះ បុគ្គលអ្នកមានគុណធម៌ ក្នុងការកាន់ សាសនាណាមួយ នោះ, ទាំងអស់នេះ សុទ្ធតែអនុញ្ញាត ឲ្យធ្វើបាន ។ ប៉ុន្តែចំពោះបុគ្គល ដែលច្បាប់ ដកគុណភាព ក្នុងការកាន់សាសនាណាមួយអស់ហើយ មិនគាប់អនុញ្ញាត ឲ្យធ្វើបានឡើយ ។

មាត្រា ២១៤– អំពើណា ល្មើស ខនិបបញ្ញត្តិ នៃមាត្រា ២១៣ នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ, លើកលែងតែ ក្នុងករណី ដែលត្រូវយក មាត្រា ២៩៨ មកអនុវត្ត, នោះទើបយក តាម មាត្រា ២៩៨ នេះវិញ ។

ជនណា មិនបានចូលរួម ដោយផ្ទាល់ ឬ ដោយប្រយោល ក្នុងការរៀបចំចាត់ចែង ទីឯការ កសាង នូវអំពើទាំងឡាយ ដែលល្មើស ដូចមានសម្តែងជាពិសេស ខាងលើនេះ ទេ, ប៉ុន្តែប្រសិនបើ មានក៏ស្ទុ

00222267





គាំថា ជននោះ បានចូល ដោយចេតនា ទៅក្នុងសន្និបាត ឬ ក្នុងបុណ្យ ដែលខ្លួនបានដឹងថា អ្នកដើមបុណ្យ ជាមនុស្ស គ្មានគុណធម៌ជាអ្នកធ្វើបុណ្យទេ ឬ បានដឹងថា បុណ្យនោះ មិនមែនធ្វើ ក្នុងកន្លែង គួរគោរព ឬ ធ្វើ ក្នុងកន្លែង ដែលច្បាប់ អនុញ្ញាតឲ្យទេ , ជននោះ ត្រូវមាន ទោសលហុ ។

មាត្រា ២១៥- មាត្រា ២១៣ និង ២១៤ ត្រូវអនុវត្ត តាមបណ្ដឹង របស់រដ្ឋមន្ត្រីក្រសួងធម្មការ និង តាមលក្ខខណ្ឌ ដូចមានគ្រោងទុក ក្នុងមាត្រា ២៩៩ ដែលស្ដី អំពីកំណត់វិរុទ្ធជន , អំពីរបៀបចោទប្រកាន់ និង អំពីទោស ។

មាត្រា ២១៦- ជនណា យក ឬ បំណងយក ដោយលបលាក់ នូវគ្រឿងភ័ណ្ឌ របស់សាសនាវត្ត ដែលគេ ទុកដាក់ ក្នុងវត្តអារាម ឬ ក្នុងបូជនីយដ្ឋាន ឬ កំពប់នៅ ក្រោមវត្ថុ ជាទីគោរព មានសីមាជាដើម, ជននោះ ត្រូវ ទោសមជ្ឈិម ថ្នាក់ទីបី ហើយនឹងត្រូវអនុទោស ត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និង តំហាត់លំនៅ ទៀតផង ក៏បាន ។

មាត្រា ២១៧- ជនណា ធ្វើអតិក្រម ឬ បំណងធ្វើ អតិក្រម លើទី សុសាន , ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

បើអតិក្រម នោះ បានធ្វើរួចទៅហើយ ឬ គ្រាន់តែបំណងនឹងធ្វើ

00222268





ដោយមានគោលដៅ ថា នឹងយក វត្ថុតាំងឡាយ ដែលកប់នៅ ក្នុងផ្នូរ ឬ ក្នុងស្មសាន, អតិក្រមនោះ ត្រូវផ្ដន្ទា ទោសមជ្ឈិម ថ្នាក់ទីបីដែរ ។

មាត្រា ២១៨– ជនណា ធ្វើ កាយវិកលកម្ម ឬ អភ័ព្វកម្ម លើសាកសព, ធ្វើ អភ័ព្វកម្ម លើធាតុខ្មោច, ជននោះត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីបី ។

ការបំណង នឹងប្រព្រឹត្ត ទោសកម្មនេះក៏ត្រូវមាន ទោស ដូចជា បានប្រព្រឹត្ត ទោសកម្ម ដែរ ។

អនុទោស ត្រង់ការបន្ថយសិទ្ធិពលរដ្ឋ នឹងកំហាត់លំនៅ អាច យកមកសម្រេច ថែមទៀត ក៏បាន ។

ជនណា ធ្វើ កាយវិកលកម្ម ឬ អភ័ព្វកម្ម លើរូបខ្មោចជាមនុស្ស ទុច្ចរិត, ដែលគេ សម្លាប់ ក្នុងពេល កំពុងប្រព្រឹត្ត ទោសកម្មជាក់ស្ដែង ឬ សម្លាប់ ក្នុងពេល ដេញប្រយុទ្ធ ន នឹងវា, វិរុទ្ធជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

សំគាល់ – ក្នុងចំពូក ពីរ នេះក្រមព្រហ្មទណ្ឌយើង បញ្ញត្តិចំពោះ តែសាសនា ដែលរាជរដ្ឋាភិបាលយើង ទទួលស្គាល់ ប៉ុណ្ណោះទេ ។ ប៉ុន្តែក្នុងសម័យឥឡូវនេះ រដ្ឋធម្មនុញ្ញ យើងត្រង់មាត្រា ៨ ទទួលស្គាល់តែព្រះពុទ្ធសាសនាមួយ ជា ជាសាសនាសម្រាប់រដ្ឋ ។ ឯសាសនាដទៃទៀត ពិតមែនតែ មិនបានទទួលស្គាល់ ជាផ្លូវការ, ប៉ុន្តែមាត្រា ដដែលនេះ បើកឲ្យពលរដ្ឋ មានសេរីភាពក្នុងការជឿ តីជាឲ្យកាន់សាសនាអ្វី បានតាមចិត្ត ។

00222269



ដ្បិតព្រោះ អំពើទាំងឡាយណា ល្មើស នឹងព្រះពុទ្ធសាសនា, អំពើទាំងឡាយនោះត្រូវមានទោស តាមមាត្រាទាំងឡាយ ក្នុងជំពូកពីរនេះ ; ឯអំពើ ដែលល្មើស នឹងសាសនាដទៃ មិនត្រូវមាន ទោស តាមមាត្រាទាំងនោះ ទេ ។

អាស្រ័យហេតុនេះ ពាក្យណា ដែលក្រមព្រហ្មទណ្ឌ (ច្បាប់ដើម) ដាក់ថា“សាសនា នៃសរដ្ឋាភិបាលខ្មែរ ទទួលស្គាល់”, យើង ដាក់ថា “សាសនារដ្ឋ” តែម្តង ដើម្បីកុំឲ្យ ពិបាក យល់ ។

# ជំពូកបី

## បទល្មើស ប្រឆាំង នឹងសេចក្តីសុខសាន្ត ខាងក្រៅរដ្ឋ

## Des infractions contre la sûreté extérieure de l'Etat

មាត្រា ២១៩ - (ព្រះរាជក្រមលេខ ន ១-នស. ចុះថ្ងៃទី ២២ កញ្ញា ១៩៥៥ )

*ក្នុងពេល មាន សន្តិភាពក្តី ក្នុងពេល មាន សង្គ្រាមក្តី មានតែតុលាការសឹក ប៉ុណ្ណោះទេ ដែលត្រូវជំនុំជំរះ បទល្មើសទាំងឡាយ ដែលប្រទូស្តរាយ ដល់ សេចក្តីសុខសាន្តខាងក្រៅរដ្ឋ ទោះបី ជាអ្នក ណា ជាស៊ីវិល ក៏ដោយ ជាទាហាន ក៏ដោយ ។*

*ដើម្បីអនុវត្តន៍ នូវបទបញ្ញត្តិ ក្នុងជំពូកនេះ គឺ*

ក.– *ជនបរទេសណា បានប្រព្រឹត្ត បទល្មើសនេះ ក្នុងពេលដែលខ្លួន ចូលមកធ្វើការ ឲ្យរាជការខ្មែរ ហើយបាន បៀវត្ស ពីរាជការខ្មែរទៀត ជនបរទេសនោះ ទោះបីប្រព្រឹត្ត បទល្មើសនោះ ក្នុងពេល*

00222270

D99/3/3



សន្តិភាពក្តី ក្នុងពេល សង្គ្រាមក្តី ត្រូវទុកដូចជា ពលរដ្ឋខ្មែរដែរ ។

២.- ក្នុងពេលសង្គ្រាម

ក.- ការប្រទូស្តរាយ ទំនងសេចក្តីសុខសាន្ត របស់រដ្ឋ ជាមិត្ត នៃប្រទេសខ្មែរ ត្រូវទុក ដូចជា ប្រទូស្តរាយ ទំនងសេចក្តីសុខសាន្ត ខាងក្រៅរដ្ឋ របស់ប្រទេសខ្មែរដែរ ,

ខ.- ដែនដី នៃបរទេសណា ដែលមាន កងយោធាខ្មែរ ទៅនៅសំចត ឬ ទៅនៅប្រតិបត្តិការ ដែនដី នៃបរទេសនោះ ត្រូវទុកដូចជា ដែនដី នៃប្រទេសខ្មែរ ដែរ ,

គ.- អាថ៌កំបាំង ទាំងឡាយណា ដែលមាន ដំណើរ សម្រាប់ការពារ ប្រទេស ជាមិត្រ អាថ៌កំបាំងទាំងឡាយនោះ ត្រូវទុកដូចជា អាថ៌កំបាំង សម្រាប់ការពារ ជាតិខ្មែរដែរ ,

ក្នុងពេល មាន សន្តិភាព, ព្រះរាជក្រឹត្យ ដែលប្រកាសថា រដ្ឋមាន អាសន្ន នោះ នឹងមាន អានុភាព ដូចជា ប្រកាសសង្គ្រាមដែរ, នាកាលបើ មានសេចក្តីប្រឈស យ៉ាងនេះហើយ ព្រះរាជក្រឹត្យនោះ នឹងនាំឲ្យយក ច្បាប់ ក្នុងពេលសង្គ្រាម មកអនុវត្ត ព្រមទាំង ឲ្យបញ្ចូល ពួកគូប្រឆាំង ដែលនៅ ក្នុងប្រទេស មកជាបច្ចាមិត្រ ប្រយោជន៍ ដើម្បីនឹងយកបទបញ្ជា ក្នុងជំពូកនេះ មកអនុវត្ត ។

00222271

D99/3/3



មាត្រា ២១៩ ស្ទួន — ( ព្រះរាជក្រម លេខ ៤១ នស , ២២-៩-៥៥ )

សេចក្ដីទាំងអស់ ដូចខាងក្រោមនេះ ត្រូវទុកជាអាថិកំបាំង សម្រាប់កិច្ចការពារ ជាតិ ។ ជនណា ធ្វើឲ្យខូច អាថិកំបាំងនេះ ជននោះត្រូវទុកជាអ្នកប្រទុស្តរាយ នឹងសេចក្ដីសុខសាន្ត ខាងក្រៅរដ្ឋ :

ក ) ព័ត៌មាន ខាងទូត , ទាហាន , សេដ្ឋកិច្ច ឬ ឧស្សាហកម្ម, ដែលតាមប្រភេទរបស់វាផង និង ជាប្រយោជន៍ សម្រាប់ការពារជាតិផង, ត្រូវឲ្យដឹង តែជនណា ដែលមាន គុណភាព ត្រូវដឹងតែប៉ុណ្ណោះ ហើយត្រូវរក្សាទុក ជាអាថិកំបាំង មិនឲ្យ ជនឯទៀត ដឹងឮឡើយ ។

ខ ) វត្ថុ , សម្ភារៈ , គំនូរ , គម្រោងការ , រូបថត , រូបសំណាក និងឯកសារដទៃទៀត , ដែលតាមប្រភេទរបស់វា ត្រូវឲ្យដឹង និងឲ្យប្រើប្រាស់ តែជនណា ដែលមាន គុណភាព ត្រូវដឹង ត្រូវប្រើ តែប៉ុណ្ណោះ ហើយត្រូវរក្សាទុក ជាអាថិកំបាំង ចំពោះជនឯទៀត ប្រយោជន៍ កុំឲ្យជនដទៃ អាចរកឃើញ នូវព័ត៌មាន ដូចមានសំដែង ក្នុងវគ្គ ក ខាងលើនេះ បាន ។

គ ) ដំណឹងខាងទាហានគ្រប់ប្រភេទ ដែលរដ្ឋាភិបាល មិនបានផ្សាយ ដល់សាធារណជន ទោះបើដំណឹងនោះ មិនចូល ក្នុងរបស់ដែលរៀបរាប់ ដូចខាងលើនេះទេ ក៏ប៉ុន្តែ ព្រះរាជក្រឹត្យ បានឃាត់ហាម មិនឲ្យផ្សាយ មិនឲ្យបែកសា មិនឲ្យធ្វើថែមទៀត ។

00222272





ឃ) តាកង៏ចុះចំនួនទ័ពខ្មែរ,កង ឬ ក្រុម កងទ័ព , សម្ភារៈ របស់ទ័ព សម្រាប់សិក្សា, ប្រើប្រាស់, ឬ បញ្ជា, របៀបប្រើ,ការដែលទ័ពធ្វើហើយ; ស្បៀងទ័ព , បើនិយាយជាទូទៅ គឺឯកសារ ទង៏ពតិមានណា , ប្រសិនបើ បាត់ , ឬ បែកសា ឬ ផ្សាយចេញទៅ នឹងនាំឲ្យអន្តរាយ ដល់ការប្រតិបត្តិ របស់ទ័ព , ឬ សេចក្ដីសុខសាន្ត របស់កងទ័ព , របស់ កន្លែង , តំបន់ ឬគ្រឹស្ថានដទៃទៀត ខាងទ័ព ។

តុលាការសឹក ត្រូវកាត់សេចក្ដី ឲ្យរឹបអូស វត្ថុ ដែលបានយក មកប្រើ ដើម្បីប្រទុស្តរ៉ាយ នឹងសេចក្ដីសុខសាន្ត ខាងក្រៅរដ្ឋនេះ ដោយ មិនបាច់ដេញដោលឲ្យឃើញ ថា វត្ថុជននោះ ជាកម្មសិទ្ធិករ ឬមិនមែន ជាកម្មសិទ្ធិករ នៃវត្ថុនោះឡើយ ។ រង្វាន់ខាន់ទៅ ដែលវត្ថុជន បានទទួល មក ដើម្បីនឹងប្រព្រឹត្តបទល្មើសទាំងនេះ ក៏ត្រូវដាក់ ក្នុងសាលក្រម ដែល កាត់ទោសនោះ ថារឹបអូសជាប្រយោជន៍ឃុំងហើយ ។ ក៏ប៉ុន្តែបើប្រទេស ជាមិត្ររបស់ខ្មែរ មិនបានប្ដឹង មិនបានផ្ញើ មកជាមុនទេ នោះតុលាការ ខ្មែរ ក៏មិនអាចចោទប្រកាន់ ជននោះ ពីបទប្រទុស្តរ៉ាយ នឹងសេចក្ដីសុខ សាន្តខាងក្រៅរដ្ឋ របស់ប្រទេស ជាមិត្ត បានដែរ ។ ម្យ៉ាងវិញទៀត បើ ចោទគណា បានជូនកស្តុតាងថា តុលាការ នៅបរទេស បានកាត់ ទោស ខ្លួន ពីបទ ដូចដែលពោលខាងលើនេះ រួចហើយ ហើយខ្លួន ក៏បានរង ទោសនោះ រួចហើយដែរ ឬ ទោសនោះ ក៏អស់ អាជ្ញាយុកាលហើយ

រាជការ បានលើកទោសនោះឲ្យខ្លួនដោយមេត្តាប្រណីហើយ, ចោទិតនោះ មិនត្រូវមាន ទោសទៀតទេ ។

ក្នុងពេលកើតសឹក ក៏ដូច្នោះដែរ ជនបរទេសណា ជាសមាជិកនៃកងទ័ព របស់បច្ចាមិត្ត ហើយបានល្មើស នឹងបទបញ្ញត្តិ ក្នុងជំពូកខាងលើនេះ ដោយសារធ្វើតាមច្បាប់សឹក , ជនបរទេសនោះ ក៏មិនត្រូវមាន ទោសដែរ ។

មាត្រា ២២០ ( ព្រះរាជក្រមលេខ ៤១-ន ស ២២-៩-៥៥ បាននិរាករណ៍អត្ថបទចាស់នៃមាត្រានេះចោល ហើយ ដាក់អត្ថបទថ្មី ដែលមានសេចក្តីស្រង់ដូចខាងក្រោមនេះ ជំនួសវិញ ).— ជនជាតិខ្មែរ ឬ ជន ដែលទុកជាជាតិខ្មែរ ដូចមានសំដែង ក្នុងជំពូក នេះ មានពិរុទ្ធ ជាបានប្រព្រឹត្ត ដូចខាងក្រោមនេះ ត្រូវទុកជាក្បត់ ហើយ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី :

ក).— ជន ដែលបានកាន់អាវុធ ប្រឆាំងនឹងប្រទេសខ្មែរ ( ព្រះរាជក្រមលេខ ៤២ ន ស. ២២-៩-៥៥ បាននិរាករណ៍វគ្គនេះ ចោលហើយ, ហើយវគ្គថ្មី ដែលដាក់ជំនួសមកនោះ ក៏បានដាក់បញ្ចូល ទៅក្នុងមាត្រា ២២១ នៃក្រមសឹកដែរ ) ។

ខ).— ជនដែល បាន រួមគំនិត នឹងបរទេសណាមួយ ដើម្បីឲ្យបរទេសនោះ ច្បាំង នឹងប្រទេសកម្ពុជា ឬ ផ្តល់ ដល់បរទេសនោះ នូវមធ្យោបាយទាំងឡាយ មានមធ្យោបាយ សម្រួល ដោយរបៀបណា ក៏

00222274



ឲ្យឆាយបញ្ចូល កងកម្លាំងសត្រូវ ក្នុងដែនដី ប្រទេសកម្ពុជា ជាដើម ឬ មកតាក់ក្រុក អុបអាល ដោយមធ្យោបាយណាមួយ ឲ្យកងទ័ពខ្មែរ លែងមានសេចក្តីស្មោះត្រង់ តទៅ ,

គ).- ជន ដែលប្រគល់ ឲ្យបរទេស ឬភ្នាក់ងារ របស់បរទេស ឬពួកខ្មាំង នូវទ័ព របស់ខ្មែរក្តី នូវដែនដី, ក្រុង, បន្ទាយ, ការ្យ, សេីន, ឃ្លាំង, រោងធ្វើសស្ត្រាវុធ, សម្ភារៈ, គ្រាប់រំសេវ, កប៉ាល់ទន្លេ, កប៉ាល់សមុទ្រ, យន្តហោះ ដែលជាសម្បត្តិ របស់ប្រទេសខ្មែរក្តី, ឬទុក របស់ទាំងនេះ ឲ្យទ័ពបរទេស ប្រើប្រាស់ក្តី ,

ឃ).- ក្នុងពេលសង្គ្រាម, ជន ដែលញុះញង់ ជាតិខ្មែរ ឲ្យចូល ទៅធ្វើការ បំរើ បរទេសណាមួយ ឬជួយ មធ្យោបាយ ដល់ជនជាតិខ្មែរ ឲ្យបានសម្រេច នូវការនេះ ដោយឆាយក្តី, រើសតាហាន ឲ្យបរទេស នៅលើដែនដី កម្ពុជា ដោយគ្មានអនុញ្ញាត ពីរដ្ឋាភិបាលខ្មែរ ឬ ដោយ មានអនុសន្ធិសញ្ញា ជាផ្លូវខួន ក្តី ,

ង).- ក្នុងពេលសង្គ្រាម, ជនដែលបានសមគំនិត ឲ្យសំឡេប ទៅបរទេស ដើម្បីឲ្យប្រទេស នេះ មកប្រទូស្តរាយ ទឹងប្រទេសកម្ពុជា ឬប្រទេស ជាមិត្រ នឹងកម្ពុជា ដោយឆាយ ,

ច).- ជន ដែលបានប្រគល់ ឲ្យបរទេស ឬភ្នាក់ងារ របស់បរទេស ឬពួកខ្មាំង ដោយរបៀបណាក្តី នូវកិច្ចការសម្ងាត់ ដែលមាន សារសំខាន់

អាចបណ្ដាល ឲ្យអន្តរាយ ដល់កិច្ចការពារជាតិ ឬពុំនោះទេ ជន ដែល
កប់រង ដោយមធ្យោបាយ យ៉ាងណាក្ដី ជាទីន័យក ឲ្យបាន នូវអាថ៌កំបាំង
ដែលមាន ប្រភេទ ដូចខាងលើ ដោយមាន គោលបំណងជា ទីប្រ
គល់ ឲ្យបរទេស ឬភ្នាក់ងារ របស់បរទេស ,

ង)-ជន ដែលបានសម្រេច ជាទីធ្វើឲ្យ សាហ្វង ដោយមធ្យោ
បាយណាមួយក្ដី ដល់សម្បូណ៌ភាព ខាងដែនដី នៃប្រទេសកម្ពុជា ។

មាត្រា ២២០ ស្ទួន .— (ព្រះរាជក្រមលេខ៤០៦នស ២២-៩-៥៥ )

ក)ជនណា បំផ្លាញ ឬ បង្ខូច ដោយចេតនា នូវសម្ភារៈណាមួយ,
នូវវត្ថុ ដែលគេ ផ្ដល់មក ណាមួយ , នូវសំណង់ណាមួយ , នូវបឋនកម្ម
ណាមួយ ដែលមាន ប្រយោជន៍ សម្រាប់យកទៅប្រើ ក្នុងកិច្ចការពារ
ជាតិ ឬក៏ធ្វើ បឋនកម្ម ឲ្យខុស ចាកគម្រោងក, ក្នុងពេល មិនទាន់ស្ថាបនា
ហើយ ឬពេល ដែលស្ថាបនា រួចហើយ ប្រយោជន៍ កុំ ឲ្យប្រើប្រាស់
បឋនកម្ម នោះបាន ឬ ដើម្បីឲ្យប្រើប្រាស់ នូវបឋនកម្ម នោះ បាន
ដោយពិបាក ឬពុំនោះទេ ដើម្បីបណ្ដាល ឲ្យមាន គ្រោះថ្នាក់ ។

ប្រសិនបើ អនត្ថការនេះ បានធ្វើឡើង ក្នុងទី ចំពោះមុខ នៃបច្ចា
មិត្ត ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

ខ)-ជនណា បានចូលរួម ដោយចេតនា ក្នុងកិច្ចការ ដែលធ្វើ ឲ្យ

00222276





ខូច ទឹកចិត្ត របស់កងទ័ព ឬ របស់ជាតិ ដើម្បីនឹងធ្វើ ឲ្យកិច្ចការពារជាតិ ដល់នូវសេចក្ដីវិនាស ,

គ)- ជនណា បានញុំាងប្រទេសកម្ពុជា ឲ្យប្រឈម សង្គ្រាម ដោយអំពើប្រទូស្ដ របស់ខ្លួន ដែលរដ្ឋាភិបាល មិនយល់ព្រម ផង ,

ឃ)- ក្នុងពេលសង្គ្រាម , ជនណា ធ្វើឲ្យមាន រឿង , ដោយមធ្យោបាយ ទាំងឡាយ ដែលរដ្ឋាភិបាលខ្មែរមិនយល់ព្រម ផង , បណ្ដាលឲ្យ រាស្ត្រខ្មែរ ត្រូវទទួល ការសងសឹក ពីបរទេស ,

ង) ក្នុងពេលសង្គ្រាម, ជនណា មានសំបុត្រ ទាក់ទង ផ្ទាល់ ឬ គ ពីជនណាម្នាក់ ដោយដឹងច្បាស់ នឹងដោយចេតនាទុច្ចរិត ជាមួយបច្ចាមិត្ត ជាមួយនឹងពលរដ្ឋ បច្ចាមិត្ត ឬ ជាមួយ នឹងភ្នាក់ងារ បច្ចាមិត្ត ,

ច)- ក្នុងពេល មានសង្គ្រាម, ជនណា មើលងាយ ពាក្យឃ័ន ខាងលើនេះ ហើយធ្វើ ជំនួញផ្ទាល់ ឬ គ ពីជនណាម្នាក់ ដោយដឹងច្បាស់ ជាមួយ នឹងបច្ចាមិត្ត, ជាមួយ នឹងពលរដ្ឋ របស់បច្ចាមិត្ត ឬ ជាមួយ នឹងភ្នាក់ងារ របស់បច្ចាមិត្ត ,

ឆ)- ជនណា បានរួមគំនិត ជាមួយ នឹងភ្នាក់ងារ របស់ប្រទេស ដោយមាន គោលបំណង ថា នឹងធ្វើ ឲ្យសៅហ្មង ដល់អរិយាបថ ខាងទាហាន ឬ ខាងទូត នៃប្រទេសកម្ពុជា ,

ជ)- ជនណា ពប់រង រក អាថ៌កំបាំង ជាគ្រឿងកិច្ចការពារជាតិ

ដែលខ្លួន មានគុណភាព ជាអ្នករក្សាក្ដី ឬ គ្មានគុណភាព ជាអ្នករក្សាក្ដី ហើយយក អាថិកំបាំងនោះ ទៅប្រាប់ សាធារណជន ឬប្រាប់ ជន ដែល គ្មានគុណភាព ជាអ្នករក្សា នូវអាថិកំបាំងនោះ ឲ្យបានដឹង ឮ, ប៉ុន្តែ កាលប្រាប់ គ្មានគោលបំណង ថា នឹងប្រគល់ នូវអាថិកំបាំង នោះ ទៅឲ្យបរទេស ឬ ភ្នាក់ងារ របស់បរទេស ទេ ,

ឈ)– ជនណា , ដោយធ្វេសប្រហែស , មិនប្រុងប្រយ័ត្ន , មិនប្រតិបត្តិ តាមបទបញ្ញា , បណ្ដែត បណ្ដោយ ឲ្យគេ បំផ្លាញ, ឲ្យគេ ស្រង់យកបាន , ឲ្យគេ លួចបាន ទាំងអស់ ឬ ភាគខ្លះ , សូម្បីតែ មួយក្តែត ក៏ដោយ , នូវវត្ថុ ទាំងឡាយ , ឯកសារ ទាំងឡាយ , ពត៌មាន ទាំងឡាយ ដែលរាជការ ប្រគល់ ឲ្យខ្លួន រក្សា ជាវត្ថុ, ឯកសារ, ពត៌មាន ដែលមាន សារៈសំខាន់ អាចឲ្យគេឃើញ នូវអាថិកំបាំង សម្រាប់ការ ពារជាតិ ឬពុំនោះទេ, ជនណា បណ្ដោយ ឲ្យគេ ដឹង, គេ ចម្លង, គេ ពង្រីក នូវវត្ថុ, ឯកសារ ពត៌មាន នោះ ទាំងមូល ឬ ភាគខ្លះ ,

ញ .– ជនណា គ្មានអនុញ្ញាត ពីអាជ្ញាធរ ដែលត្រូវមុខនោះ ជា មុនទេ, ហើយបញ្ជូន ឲ្យទៅ ជនណាម្នាក់ ដែលធ្វើការ ឲ្យបរទេស នូវតក្កកម្ម ( invention ) ដែលមាន ប្រយោជន៍ ក្នុងកិច្ចការពារជាតិ ឬ នូវពត៌មាន ទាំងឡាយ ដែលមាន ការពាក់ព័ន្ធ នឹងតក្កកម្មនោះ ឬ ដែល មាន ការពាក់ព័ន្ធ នឹងអនុវត្ត ខាងឧស្សាហកម្ម នៃតក្កកម្មនោះ ,

ង.– ទោះមិនបានលាក់ឈ្មោះ, លាក់គុណភាព, ឬលាក់សញ្ជាតិ របស់ខ្លួន ក៏ដោយ, ជនណា បានតាក់តែង ជាផ្លូវសម្ងាត់ នូវមធ្យោបាយ ណាមួយ សម្រាប់ទាក់ទង ពីចម្ងាយ ដែលនាំ ឲ្យ វិនាស ដល់កិច្ចការជាតិបាន ,

ច.– ជនណា គ្មានអនុញ្ញាត ពីរដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាមុនទេ ព្រមទាំងក្រៅករណី ដែលអនុសន្ធិសញ្ញា ខាងផ្លូវទូតទៀតផង ហើយជិះយន្តហោះ បរទេស ដែលមិនមែន ជាប្រទេស ជាមិត្ត ហោះលើដែនដី ប្រទេសកម្ពុជា ,

ឆ.– ជនណា គូរ, ថត, ឬកសាង ដោយគ្មានអនុញ្ញាត, នូវគម្រូ ដែលអាជ្ញាធរ ខាងទាហាន បានចាត់ បំរាម ជាមុន ហើយបំរាម នោះទៀត ក៏បានគេប្រកាស ឲ្យដឹងឮ ដល់សាធារណជន រួចទៅហើយ, ហើយមានទាំងយោង មកលើមាត្រានេះ ទៀតផង ,

ជ.– ជនណា ទៅនៅ ក្នុងវង្វង់ ជុំវិញ បន្ទាយ ឬ ផ្ទះទាហាន ដោយមើលងាយ ដល់បំរាម ដែលមានសំដែង ក្នុងព្រះរាជក្រឹត្យ ,

ជនទាំងឡាយនោះ ត្រូវមានពិរុទ្ធ ជាបានធ្វើឲ្យសៅហ្មង ដល់សេចក្ដីសុខសាន្ត ខាងក្រៅរដ្ឋ ហើយត្រូវមានទោស, ក្នុងពេល សន្តិភាព, ១ ក្រិដ្ឋ ថ្នាក់ទីមួយ, ក្នុងពេលមានសង្គ្រាម, ១ ក្រិដ្ឋ ថ្នាក់ទីពីរ,

មាត្រា ២២០ ត្រី.– (ព្រះរាជក្រមលេខ ៤១ នស, ២២-៩-៥៥)

ជនបរទេសណា បានប្រព្រឹត្ត នូវអំពើ ណាមួយ បណ្ដាអំពើ ទាំងឡាយ ដែលមានបញ្ញត្តិ ទុក ឲ្យផ្ដន្ទាទោស តាមមាត្រា ៤២០ ដល់ ២២០ ស្ទួន, ជនបរទេសនោះ ត្រូវមានពិរុទ្ធ ជាបានធ្វើ ចារកម្ម (espionnage) ហើយ ត្រូវមាន ទោស ដូចមាន ក្នុងមាត្រា ២២០ ដល់ ២២០ ស្ទួននេះ ។

ជនជាតិខ្មែរ ឬជនបរទេសណា បានក្លែងខ្លួន, ឬក្លែងឈ្មោះ, ក្លែងគុណភាព ឬសញ្ជាតិរបស់ខ្លួន ហើយដើរចូលទៅ ក្នុងការ្យ ( ouvrage ) បន្ទាយ ( forteresse ) ប៉ុស្តិ៍ ( poste ) កន្លែងធ្វើសស្ត្រាវុធ ( arsenal ) ការដ្ឋាន ( chantier ) ជំរំទ័ព ( camps ) ជំរំកណ្ដាលវាល (bivouac) ទីបោះទ័ព ( cantonnement d'une armée ) នៅលើកប៉ាល់ចម្បាំង ឬ កប៉ាល់ដឹកជញ្ជូន ដែលជារបស់ ការពារជាតិ នៅលើយន្តហោះទាហាន ឬ យន្តហោះស៊ីវិល ដែលសម្រាប់ប្រើប្រាស់ ក្នុងកិច្ចការពារជាតិ, ក្នុងកន្លែងទាហានជើងគោក ឬ ជើងទឹក ឬ ក្នុងកន្លែងណាមួយ ឬ ការដ្ឋានណាមួយ ដែលជាកន្លែងធ្វើការ កិច្ចការពារជាតិ ដើម្បីនឹងទៅយក ពត៌មាន ឬ ឯកសារ មកឲ្យ បរទេស ឬ បច្ចាមិត្ត ។

## ជំពូក បួន

## អំពី បទល្មើស ដែលប្រឆាំង នឹងសេចក្ដីសុខសាន្ត ខាងក្នុងរដ្ឋ

## Des infractions contre la sûreté intérieure de l'Etat

មាត្រា ២២១ – ( ព្រះរាជក្រមលេខ ៤១ នស - ចុះថ្ងៃ២២ ៩–១៩៥៥ )

ជនណា ព្យាបាទ ដោយ បំណង នឹងផ្លាស់ប្តូរ ឬ នឹងបំផ្លាញ រដ្ឋាភិបាលក្តី, របៀបរៀបចំ អំណាចសាធារណៈក្តី, រដ្ឋធម្មនុញ្ញ នៃព្រះរាជអាណាចក្រក្តី, របៀបរៀបរយក្តី, ឬ របៀប តំណ រាជបល្ល័ង្កក្តី ឬ ញុះញង់ ពលរដ្ឋ ឬ អ្នកស្រុក ឲ្យកាន់ សស្ត្រាវុធ តតាំង នឹងអំណាចម្ចាស់ផែនដីក្តី, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ២២២– ការប្រតិបត្តិ ឬ គ្រាន់តែបំណង នឹងប្រតិបត្តិនូវអំពើ ដូចពោល ខាងលើនេះ ត្រូវទុកថា ជាអំពើព្យាបាទ ដែរ ។

មាត្រា ២២៣– អំពើក្បត់, ដែលមាន គោលបំណង ថា នឹងប្រព្រឹត្ត នូវឧក្រិដ្ឋកម្មទាំងឡាយ ដូចមានត្រាទុក ក្នុងមាត្រា ២០៤ នឹង ២២១ នោះ, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ប្រសិនបើ អំពើក្បត់នោះបានធ្វើ នូវអំពើ ណាមួយ ឬ បានចាប់ផ្តើម រៀបចំ ដើម្បីនឹងញ៉ាំងការក្បត់នោះ ឲ្យសម្រេច ។

បើ ពុំទាន់បានធ្វើ អំពើអ្វីមួយ ឬ ឥតទាន់ផ្តើម រៀបចំ នឹងប្រតិបត្តិទេ, ការក្បត់នេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

នាកាល មនុស្ស ពីរនាក់ ឬ ច្រើននាក់ បានព្រមព្រៀងគ្នា ថា នឹងប្រព្រឹត្ត នូវអំពើ ដូចខាងលើ, សេចក្តីព្រមព្រៀងនេះ ត្រូវទុកថា ជាអំពើក្បត់ដែរ ។

ប្រសិនបើ មាន សេចក្ដីស្នើរ ឲ្យទៅប្រព្រឹត្ត ទុក្រិដ្ឋកម្ម , ដូចដែលមានសំដែង ត្រង់មាត្រា ២០៤ នឹង ២២១ មែន ប៉ុន្តែ មនុស្ស ដែលគេស្នើរនោះ មិនយល់ព្រមផងទេ , អ្នកស្នើរនោះ ត្រូវមាន ទោសមជ្ឈិមថ្នាក់ទីបី ។ វិរុទ្ធជននេះ អាច នឹងត្រូវដក សិទ្ធិ ដូចមានសំដែង ក្នុងមាត្រា ៤៩ ទាំងអស់ ឬ ខាតខ្លះ ទៀតក៏បាន ។

មាត្រា ២២៤– កាលណា ជនណាម្នាក់ បានសម្រេច ចិត្ត តែម្នាក់ឯង, ជានឹងប្រព្រឹត្ត បទទុក្រិដ្ឋណាមួយ, ដូចដែលមានសំដែង ត្រង់មាត្រា ២០៤ នោះ, ប្រសិនបើ កិច្ចរៀបចំ ដើម្បីប្រព្រឹត្ត នោះ បានធ្វើរួចហើយ ឬ ទើបនឹងចាប់ផ្ដើម តែម្នាក់ឯង ឥតមាន អ្នកណា ជួយទំនុកបំរុង ផងទេ, ជននោះ ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២២៥– អំពើព្យាបាទណា មាន គោលបំណង ជានឹងញុះញង់ ឲ្យមាន សង្គ្រាម រវាងគ្នាឯង ដោយចែក អាវុធ ឬដោយញុះញង់ ឲ្យពលរដ្ឋ កាន់អាវុធ ប្រឆាំង គ្នាឯងក្ដី, ញុះញង់ ឲ្យបង្ហិនបំផ្លាញ កាប់ សម្លាប់គ្នា, ប្លន់គ្នា ក្នុងភូមិមួយ ឬ ច្រើនភូមិក្ដី, អំពើព្យាបាទនោះ ត្រូវផ្ដន្ទា ទោស ទុក្រិដ្ឋ ថ្នាក់ទីបី ។

អំពើក្បត់ ដែលបណ្ដាល ឲ្យកើត ជាបទទុក្រិដ្ឋណាមួយ, ដូច

មានសំដែង ក្នុងមាត្រានេះ, ហើយនឹងសេចក្ដីស្មើរ ឡើម ជាពួកក្បត់ នោះត្រូវមាន ទោស ដូចមានសំដែង ក្នុងមាត្រា ២២៣, ទោសធ្ងន់ ឬ ស្រាល ទៅតាមស្ថាន ដែលគេ ព្រម ផង ឬ មិនព្រម ផង ។

មាត្រា ២២៦ -(ព្រះរាជប្រកាសលេខ ៤៨ ចុះថ្ងៃទី ២០-៥-១៩៥០) ឈ្មោះណា បានលើក ទ័ព ឬ ប្រើ អ្នកដទៃ ឲ្យលើកទ័ព ក្ដី, បានរើស ទាហាន ឬ បានយកបញ្ជី ទាហានក្ដី បានប្រើ គេ ឲ្យរើស ឬ ឲ្យ យកបញ្ជីក្ដី បានឲ្យ គ្រឿងសស្ត្រាវុធ ឬ គ្រាប់រំសេវ ទៅកងទាហាន ក្ដី, តែអំពើទាំងនោះ ឥតមានបង្គាប់ ឬ អនុញ្ញាត ពីអំណាច ជាធម្មានុរូប ណាទេ, ឈ្មោះនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

អត្ថបទ បន្ត ពីនេះ នៃព្រះរាជប្រកាសនេះ បានយកទៅ បញ្ចូល ក្នុងក្រមតុលាការសឹកហើយ

មាត្រា ២២៧ - ជនណា ឥតមាន សិទ្ធិ ឬ ឥតមាន ហេតុ ជាធម្មានុរូបសោះ, ហើយធ្វើ ជាមេបញ្ជាការ លើអង្គទ័ពក្ដី, លើកងទ័ពក្ដី, លើកងនាវាក្ដី, លើមហាព្យូហៈក្ដី, លើ កប៉ាល់ចម្បាំងណាមួយក្ដី, លើបន្ទាយ ក្ដី, លើសេនក្ដី, លើកំពង់នាវាក្ដី, លើក្រុងណាមួយក្ដី, ជនណា កាន់ បញ្ជាការសឹក ណាមួយ ទទឹង នឹងបង្គាប់រដ្ឋាភិបាល ។

មេបញ្ជាការសឹកណា ក្រោយ ដែលរាជការ បានបញ្ឈប់ ពីមុខការ

00222283

D99/3/3



ហើយ ឬ បំបែកចេញ ពីកងទ័ពហើយ, នៅតែកាន់ បញ្ជាការ លើកងទ័ព ទៀត, ជននោះៗ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ២២៨– ជនណា ជាអ្នកកាប ប្រើប្រាស់ កងកម្លាំងអាជ្ញាបាន , ហើយ កេណ្ឌ ឬ បង្គាប់ អ្នកដទៃ ឲ្យកេណ្ឌ ឬ ឲ្យបង្គាប់ កងកម្លាំងនោះ ឲ្យលើកគ្នា មកទទឹង នឹងការរើស ទាហាន ដែល ធ្វើ ជានិត្យានុកូល, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

បើ ការកេណ្ឌ ឬ បង្គាប់នោះ, ធ្វើទៅ បាន ផល ដូចបំណងមែន នោះពិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ២២៩– ជនណា ដុត ឬ បំផ្លាញ ប្រាសាទ , វិមាន ឃ្លាំង,រោង ធ្វើ សស្ត្រាវុធ , នាវា ឬ ទ្រព្យសម្បត្តិ ផ្សេងៗ ជារបស់ រាជការ សាធារណៈ ដោយគ្រាប់បែកកប់, ជននោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ២៣០– ជនណា ធ្វើមេ លើពួកក្រុម មាន សស្ត្រាវុធ ក្តី ឬ ធ្វើ ជាមុខការអ្វី ក្នុងពួកក្រុមនោះក្តី ឬ ធ្វើ ជានាយបញ្ជាការ ក្នុងពួកក្រុមនោះក្តី ហើយលុក នាទីដី, ទ្រព្យសម្បត្តិ ឬ ដង្រុក រាជការ , ទីកន្លែង , ទីក្រុង , បន្ទាយ , សេន, ឃ្លាំង , រោងធ្វើសស្ត្រាវុធ , កំពង់

ចែកគ្នា នូវទ្រព្យ

ឬក៏ ទ្រព្យសម្បត្តិ

កងកម្លាំង ការពា

ជននោះ ត្រូវមាន

នដឹកនាំ សមាគមក្តី

ងន៏ ឬប្រើគេ ឲ្យបន្ត

សស្ត្រាវុធ , គ្រាប់

ដ្ឋ ដោយចេតនា ឬ

ត និងមេបោ ឬមេ

នប្រព្រឹត្ត ឧក្រិដ្ឋកម្ម

២០៦ និង ២៦៨ ឡេ

នប្រព្រឹត្តក្តី , ពួកក្រុម

តាំងអស់, កងពួកក្រុម

កម្ម, ត្រូវមាន ទោស

ស់មនុស្សនោះឡើយ ។

អ្នក ដែលដឹកនាំ កុប្បកម្ម ក្តី ដែលធ្វើមុខការអ្វីមួយៗ ក្តី ជានាយ បញ្ជាការ លើពួកក្រុមនោះ ទោះបីចាប់ ខ្លួនមិនបាន នៅទីកន្លែងប្រជុំគ្នា ក៏ដោយ ក៏ត្រូវមាន ទោស ដូចគ្នាដែរ ។

មាត្រា ២៣២– ក្រៅពីការប្រជុំគ្នា ដើម្បីប្រព្រឹត្ត ឧក្រិដ្ឋកម្ម ដូចមានសំដែង ត្រង់មាត្រា ២០៤, ២២១ និង ២២៥ នោះចេញ, ជនណា ចូលរួម ក្នុងពួកក្រុម ខាងលើនេះ ហើយត្រូវពលការ ចាប់ ខ្លួន បាន នៅទីកន្លែង ប្រជុំគ្នានោះ, តែអ្នកនោះ ពុំបានធ្វើ ជាមេ ឬ ជាកោយ អ្វីទេ, ជននោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ២៣៣– ជនណា បានដឹង នូវវត្ថុបំណង និងលក្ខណៈ របស់ពួកក្រុមទាំងនោះ ហើយបានឲ្យផ្ទះ ដល់ពួកក្រុមនោះ ស្នាក់, រក កន្លែង ឲ្យពួន ឬ ឲ្យប្រជុំគិត ការណ៍ទុច្ចរិត ដោយឥតមាន ការបង្ខំ ពីក្រុមនោះសោះ, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២៣៤– ជនណា បានចូល ជាពួកក្រុម, ដូចសំដែង ខាងលើនេះ, តែឥតបានធ្វើ ជាមេបញ្ជាការ, ឥតបានបំពេញ មុខការអ្វី មួយទេ លុះមាន សេចក្តីព្រមាន ជាដំបូង ពីពលការស៊ីវិល ឬ ពលការទា-

ហាន មក, ក៏ដកខ្លួន លែងចូលដៃ ជាមួយពួកក្រុមនោះ ឬ ក៏តាំងពី ពេលព្រមាន មក, កាលបើ រាជការ ចាប់បាន ក្រៅពីកន្លែង ប្រជុំ គិត ពីកុប្បកម្ម, ជននោះ ឥតមាន ទទឹងតដៃវិញទេ, ព្រមទាំង ឥតមាន កាន់ សស្ត្រាវុធអ្វី ផងទេ, ជននោះ មិនត្រូវមាន ទោស ពីបទកុប្ប កម្មនោះ ឡើយ ។

ប៉ុន្តែ បើ ជននោះ បានប្រព្រឹត្ត បទឧក្រិដ្ឋណា ផ្សេង ផ្ទាល់ខ្លួន, ទើប ជននោះ ត្រូវមាន ទោស ពីបទនោះវិញ ។ ប្រសិនណា បើ មាន ភស្តុតាង ថា ជននោះ បានចូលរួម ដោយចេតនា ប្រយោជន៍ ខ្លួនធ្វើ អំពើទុច្ចរិតណាមួយ ដូចមាន ក្នុងមាត្រា ខាងលើនេះ, ជន នោះ នឹងត្រូវជាប់ទោស ជាស័គ្របក្សពួក នៃមនុស្សទុច្ចរិតវិញ ។

មាត្រា ២៣៨– ជនណា មានពិរុទ្ធ ពីបទក្បត់ ឬ ពីបទឧក្រិដ្ឋ ដទៃទៀត, ដែលប៉ះពាល់ ដល់សេចក្ដីសុខសាន្ដ ក្នុងរដ្ឋ ឬ ក្រៅ រដ្ឋ ហើយ មុននឹងចាប់ ប្រតិបត្តិ ឬ បំណង ប្រតិបត្តិ នូវអំពើក្បត់ នឹង អំពើឧក្រិដ្ឋទាំងនោះ, ព្រមទាំងមុន មានការចោទប្រកាន់ លើខ្លួន, បាន ឲ្យដំណឹង មុន គេ ដល់រដ្ឋាភិបាល ឬ ដល់អាជ្ញាធរខាងរដ្ឋបាល ឬ អាជ្ញា ធរខាងក្រុមព្រះនគរបាលយុត្តិធម៌ ឲ្យបានដឹង នូវអំពើក្បត់ ឬ អំពើឧក្រិដ្ឋ ទាំងនោះ ព្រមទាំងឲ្យដឹង នូវអ្នកដែលដល់ នឹងអ្នកសមគំនិត ក្នុងអំពើទាំង

នោះផង, ជននោះ ត្រូវបានផុត អំពីទោស ដែលត្រូវអនុវត្ត លើអ្នកក្បត់ ឬ លើអ្នកឧក្រិដ្ឋនោះ ។

មួយវិញទៀត សូម្បីមាន ការចាប់ផ្ដើម ចោទប្រកាន់ លើវិទ្ធជននោះ ក៏ដោយ, កាលបើ វិទ្ធជននោះ បានជួយទំនុកបំរុង ក្នុងការចាប់អ្នកដែលដល់ នឹងអ្នកសមគំនិត ខាងលើនេះបាន, វិទ្ធជននោះ ក៏ត្រូវបានផុត ពីទោស ដូចគ្នាដែរ ។

ក៏ប៉ុន្តែ វិទ្ធជន, ដែលឲ្យ ដំណឹងទាំងនោះ, បានជួយទំនុកបំរុង ក្នុងការចាប់នោះ, អាចត្រូវផ្ដន្ទា អនុទោស ត្រង់ស្ថាន គំហាត់លំនៅ ដែលមាន កំណត់ ពីប្រាំឆ្នាំ ដល់ម្ភៃឆ្នាំ បាន ។

## ចំពូក ប្រាំ

## បទល្មើស ប្រព្រឹត្ត ក្នុងពេល បំពេញ មុខងារ សាធារណៈ

## Des infractions commises dans l'exercice des fonctions publiques

មាត្រា ២៣៦– អ្នករាជការណា, អ្នកតំណាងអាជ្ញាធរ សាធារណៈណា, ទោះបី រាជការ ឈ្មៀស ខ្លួន ជាត្រឹមត្រូវ តាមច្បាប់ ក៏ដោយ ក៏នៅតែអាក់ខាន ឬ ប្រកែក មិនព្រមចាត់ ឬ មិនព្រមបញ្ជា ឲ្យគេចាត់ កងកម្លាំង ដែលនៅ ក្រោមបង្គាប់ខ្លួន ដើម្បីប្រតិបត្តិ តាមបង្គាប់ជានិត្យានុកូល របស់អាជ្ញាធរ ជាធម្មានុរូប ទេ, អ្នកនោះ ត្រូវមាន ទោស

00222288





មជ្ឈិម ថ្នាក់ទីបី ។ អនុទោស ត្រង់ស្ថានបន្ថយសិទ្ធិ នៃពលរដ្ឋ ក៏អាច នឹងយកទៅសម្រេច លើអ្នកនោះ បានទៀត ។

មាត្រា ២៣៧– អ្នករាជការណា , អ្នកតំណាងអាជ្ញាធរ សាធារណៈណា ឈ្លៀស កងកម្លាំង ដែលនៅ ក្រោមបង្គាប់ខ្លួន ឲ្យប្រឆាំង នឹងការប្រតិបត្តិ ច្បាប់, បទបញ្ញា , សេចក្ដីសម្រេចតុលាការ, ដីកាតុលាការ , ជាឯកល់ទៅទៀត, ឲ្យប្រឆាំង នឹងគ្រប់ សេចក្ដីបង្គាប់ ជានិត្យានុកូល ដែលចេញមក អំពីអាជ្ញាធរ ជាធម្មានុរូប , អ្នករាជការនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២៣៨– បទបញ្ញត្តិ ក្នុងមាត្រាទាំងពីរ ខាងលើនេះ នឹងអនុវត្ត ទៅលើអ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈ តែក្នុងលក្ខខណ្ឌ ដូចដែលមាន គ្រោងទុក ក្នុងមាត្រា ១០០ប៉ុណ្ណោះ , វៀរលែងតែ ពិរុទ្ធជននោះ បានជូន តិកតាង ពីអំពើ ដែលខ្លួន បានធ្វើ ឬ មិនបានធ្វើនោះ ព្រោះប្រតិបត្តិ តាមបង្គាប់ របស់ចៅហ្វាយនាយ ដែលខ្លួន ត្រូវស្ដាប់ ។ បើមានករណីយ៉ាងនេះ , ទោស អាច ត្រូវធ្លាក់បាន តែទៅលើចៅហ្វាយនាយ ដែលជាអ្នកទទួលខុសត្រូវ ក្នុងការចាត់បង្គាប់នេះ ទៅវិញ ប៉ុណ្ណោះទេ ។

00222289





មាត្រា ២៣៩– សន្និដ្ឋាត គឺការព្រមព្រៀងគ្នា ដោយរបៀបយ៉ាងណា ១ មួយ រវាងអ្នករាជការផងគ្នា ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ ផងគ្នា , ក្នុងគោលបំណង ថា នឹងប្រកាន់យក វិធានការទាំងឡាយណា ដែលផ្ទុយ នឹងច្បាប់ នឹងបទបញ្ជា , វិរុទ្ធជន ក្នុងបទនេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី , បើនឹងសម្រេច អនុទោស ត្រង់ស្ថានបន្ថយសិទ្ធិ នៃពលរដ្ឋ ទៀត ក៏បាន ។

មាត្រា ២៤០– អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈណា បំពេញមុខការ ដោយរំលោភអំណាច ឬ បង្គាប់ឲ្យគេបំពេញ មុខងារ ដោយរំលោភអំណាច , អ្នករាជការ ឬ អ្នកតំណាងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ , លើកតែ ក្នុងករណី ដែលច្បាប់ បញ្ញត្តិ ផ្សេងទៅទៀត , ទើបយក ទោស ផ្សេងនោះ មកអនុវត្ត ។

មាត្រា ២៤១– ដែលហៅថា បំពេញ មុខការ ដោយរំលោភអំណាច នោះ គឺបំផ្លាញ ដោយចេតនា នូវសិទ្ធិ របស់បុគ្គល ដទៃ ដែលគ្មានខុសអ្វីសោះ ឡើយ សិទ្ធិធ្វើនយោបាយ , សិទ្ធិស៊ីវិក, សិទ្ធិស៊ីវិល ឬ សិទ្ធិគ្រួសារ ដែលច្បាប់ ទុកឲ្យ ចំពោះពលរដ្ឋ ពេញផ្ទៃព្រះរាជអាណាចក្រ ឬ ឲ្យខាន ប្រើប្រាស់ សេរីភាព ចំពោះខ្លួន , ព្រោះថាសិទ្ធិ

និងសេរីភាពនោះ គាប និងដក ពីពលរដ្ឋ ទៅវិញបាន លុះតែ មាន បង្គាប់ សំដែង យ៉ាងច្បាស់លាស់ណាស់ ។

មាត្រា ៦៦២– នាកាល អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈ, ដែលមានពិរុទ្ធ ជាបានធ្វើ មុខការខ្លួន ដោយរំលោភ អំណាចនោះ, មានសំអាងថា កាលខ្លួន ប្រព្រឹត្តនោះ, ខ្លួន បានធ្វើ តែ តាមបង្គាប់ ចៅហ្វាយនាយ តាមលំដាប់ថ្នាក់ របស់ខ្លួន ប៉ុណ្ណោះទេ, ហើយម្យ៉ាងទៀត, ថា សេចក្តីបង្គាប់នោះ ក៏មាន កម្មវត្ថុ ត្រូវតាមមុខ អំណាច ចៅហ្វាយនាយនោះដែរ នោះ, ទោស ដែលបានគ្រោងទុក ក្នុងមាត្រា ៦៤០ នេះ ត្រូវអនុវត្ត ទៅលើចៅហ្វាយនាយ ជាម្ចាស់ បង្គាប់ និង អ្នករាជការ, អ្នកតំណាង ដែលទទួលប្រតិបត្តិ បង្គាប់ តាម លក្ខខណ្ឌ ស្តី ពីទទួលខុសត្រូវ ដូចមានសំដែង ក្នុងមាត្រា ១០០ នេះ ។

មាត្រា ៦៦៣– អ្នករាជការ, អ្នកតំណាង អាជ្ញាធរ សាធារណៈ ណា គាត់ខាន មិនបានធ្វើ តាមបង្គាប់តុលាការ ដោយចេតនា, ជាគឺ មន្ត្រីក្រុមព្រះនគរបាលយុត្តិធម៌ មិនយក សាលដីកា, សាលក្រម, ដីកា ឲ្យចាប់ខ្លួន, ឲ្យឃុំខ្លួន, ដីការកោះ. វិធានការ ឲ្យស៊ើបសួរ ក្នុងរឿង

00222291

D99/3/3



ឧក្រិដ្ឋ ទៅប្រតិបត្តិ , អ្នកពជការ, អ្នកតំណាងនោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៤៤ - អ្នកពជការ, អ្នកតំណាង អាជ្ញាធរ សាធារណៈណា គក់ខាន មិនបានទៅ ឬ ប្រកែក មិនទៅពិនិត្យ ឬ ទៅប្ដឹង អាជ្ញាធរ ខាងតុលាការ ពីបទល្មើស ដែលខ្លួន បាន ពត៌មានហើយ, អ្នកពជការ , អ្នកតំណាងនោះៗ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៤៥ - ក្នុងការណ៍ ដែលគេទៅឃើញថា វិរុទ្ធជននោះ បានបំបិទ ឬ បំណាន់ទីបំបិទ ដោយចេតនា នូវបទល្មើស ជាឧក្រិដ្ឋ ឬ មជ្ឈិម ដែលខ្លួន មាន ពត៌មាន ហើយ ឬ មាន តិកតាង ច្បាស់ថា វិរុទ្ធជននោះ បំបាត់ ឬ បំណាន់ ទីបំបាត់ នូវភស្តុតាង នៃបទល្មើស ទាំងនោះ , វិរុទ្ធជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ; លើកមួយតែ ក្នុងករណី ដែលឃើញថា វិរុទ្ធជន មាន សមគំនិត ក្នុងបទល្មើសនោះ ទៀត , នោះទើបត្រូវយក ទោសធ្ងន់ជាងនេះ មកអនុវត្ត ។

អនុទោស ត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋនោះ អាចនឹងយកមក សម្រេចបាន ទៀត ។

មាត្រា ២៤៦– អ្នករាជការ និង អ្នកតំណាង អាជ្ញាធរ សាធារណៈ មិនត្រូវចេញ ប្រកាស, ដីកា ណាមួយ ដែលផ្ទុយ នឹងច្បាប់, ក្រម នឹង ក្រឹត្យ ឬ កំកែ ច្បាប់, ក្រម នឹងក្រឹត្យ ទេ ។ អំពើ ដែល ល្មើស នឹងបទបញ្ញត្តិនេះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៤៧ អ្នករាជការ ខាងតុលាការ មិនត្រូវជ្រៀតជ្រែក ទៅក្នុងកិច្ចការ ដែលជាមុខការ របស់អាជ្ញាធរ ខាងរដ្ឋបាលទេ ។ អ្នករាជការ ខាងរដ្ឋបាល ក៏មិនត្រូវជ្រៀតជ្រែក ទៅក្នុងកិច្ចការ ដែលជាមុខការ របស់អាជ្ញាធរ ខាងតុលាការដែរ ។

កាលណាបើ មាន ការជ្រៀតជ្រែក ដែលអាច បណ្តាល ឲ្យមានព្យសនកម្ម, អ្នកជ្រៀតជ្រែកនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មុខការ ខាងនគរបាល យុត្តិធម៌ ខាងអគ្រានុកូលដ្ឋាន១ ខាងប្រតិបត្តិ សេចក្តីសម្រេច របស់តុលាការ១ ទាំងនេះ ត្រូវទុកថា ជាមុខការរួម របស់អាជ្ញាធរ ខាងរដ្ឋបាល និង ខាងតុលាការ ។

មាត្រា ២៤៨– អ្នករាជការណា, អាជ្ញាធរសាធារណៈណា, មិនមែនជាចៅក្រម មាន សមត្ថកិច្ច ដូចមានក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីទេ, ហើយទៅសម្រេចសេចក្តី ចេញសាលក្រម ឬ

00222293



សាលដីកា ឬ ចេញបង្គាប់ឲ្យឃុំខ្លួន ឬ ឲ្យដោះខ្លួន ជនណាមួយ , អ្នករាជការ ឬ អ្នកតំណាងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៤៩- ចៅក្រមណា ចេញបង្គាប់ ឲ្យឃុំ មនុស្ស ដែលគ្មានត្រូវចោទ ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមសោះ, ឬ មនុស្ស ដែលគ្មានត្រូវទណ្ឌកម្ម ខាងស៊ីវិល នាំឲ្យមានឃុំខ្លួន តាប្រាក់សោះ , ចៅក្រមនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ បើ នឹងសម្រេច អនុទោសត្រង់ស្ថាន បន្ថយសិទ្ធិពលរដ្ឋ ទៀត ក៏បាន ។

មាត្រា ២៥០- នាយក ពន្ធនាគារ ឬ នាយកឃុំណា ទទួលឃុំមនុស្ស ដែលគ្មាន ដីកា របស់តុលាការ ឬ កំណត់ដែសាលក្រម របស់អាជ្ញាធរ ខាងតុលាការសោះ, នាយក ឬ នាយកឃុំនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៥១ - នាយកឃុំណា មិនដោះលែង ដោយចេតនា នូវមនុស្ស ដែលត្រូវដោះលែង តាមច្បាប់តុលាការ ឬ មនុស្ស ដែលបានទទួល ទោសគុក គ្រប់កំណត់ អស់ហើយ , នាយនោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៨២- ក្រោយដែលមាន សេចក្តីព្រមាន របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មក, ចៅក្រមណា ប្រកែក មិនព្រមរក យុត្តិធម៌ ឲ្យគូក្តី ដែលខ្លួន ត្រូវរក ឲ្យគេ, ទោះបី មានលេស ដូចម្តេចក្តី, ក៏ចៅក្រមនោះ ត្រូវមាន ពិរុទ្ធ ក្នុងបទយុត្តិនិសេធ ដែរ, ដូច្នេះ ចៅក្រមនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៨៣- អ្នកកាន់ការណា ឬ អ្នកតំណាង អាជ្ញាធរសាធារណៈណា, កិច្ចការ ខាងរដ្ឋបាល ឬ ខាងតុលាការ ដោយយឺតយូរ ហួស ហេតុ ពេក ពីព្រោះតែធ្វេសប្រហែស ឬ មិនយកចិត្តទុកដាក់; អ្នកកាន់ការណា ឬ អ្នកតំណាងណា ប្រកែក មិនព្រមបង្ហើយ កិច្ចការទាំងនោះ តាមរយៈពេល ដែលនាយចៅហ្វាយខ្លួន ដាក់កំហិត មក, អ្នកទាំងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៨៤- អ្នកកាន់ការណា ឬ អ្នកតំណាង អាជ្ញាធរសាធារណៈណា, ដែលកាន់ការ បានបណ្តេញចេញ ពីមុខងារ ឬ ព្យួរងារ, ផ្លាស់, ដាក់ឲ្យរឺតែក្រត, ឬ មានដាក់គេ មកជំនួសហើយ, នៅតែខំទូបធ្វើការ មុខងារ របស់ខ្លួននោះ តទៅទៀត, ថ្វីបើកាន់ការ បានប្រាប់ឲ្យដើរចេញ ពីមុខងារនោះ ក៏ដោយ, អ្នកកាន់ការនោះ, អ្នកតំ

00222295

D99/3/3



ណាងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៥៥.- អ្នករាជការណា ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈណា, ដោយសំអាងថា ទៅធ្វើការ ក្នុងមុខងារ របស់ខ្លួន ហើយធ្វើអតិក្រម ឬ ប៉ុនប៉ងធ្វើអតិក្រម ទៅក្នុងលំនៅ អ្នកដទៃ, ក្រៅពីករណី ដែលមានគ្រោងទុក ក្នុងច្បាប់, ដោយអ្នកនៅ ក្នុងលំនៅនោះ អ្នកតំណាង ម្ចាស់ផ្ទះនោះ មិនយល់ព្រមផង, អ្នករាជការ ឬ អ្នកតំណាង នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ប្រសិនបើ អតិក្រម ទៅក្នុងលំនៅ អ្នកដទៃនេះ បានប្រើអាការ គំរាម, ដំណាប, ឬ វិហិង្សា ទៅលើអ្នកផ្ទះផង, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ, តែប៉ុន្តែ បើប្រភេទ នៃវិហិង្សានោះ បានប្រព្រឹត្ត ជាទម្ងន់ ទៅលើអ្នករងគ្រោះ ឬ បានប្រព្រឹត្ត ដោយប្រើគ្រឿងអាវុធ ដែលជាហេតុ បណ្តាល ឲ្យមានទោសធ្ងន់ ជាងនេះទៅទៀត, នោះត្រូវយក ទោសធ្ងន់នេះ មកអនុវត្ត វិញ ។

មាត្រា ២៥៦.- ការចូល ក្នុងលំនៅ អ្នកដទៃ ដើម្បីប្រតិបត្តិ សាលដីកា ឬ សាលក្រម ឬ ក្នុងករណី មានឧក្រិដ្ឋកម្ម ឬ ទោសកម្ម ជាក់ស្តែង ហើយធ្វើអង្កេត អំពីបទឧក្រិដ្ឋនោះ ឬ ពុំនោះទ

00222296



មានសម្ពន្ធ៍ ពីខាង ក្នុងផ្ទះ ស្រែកសុំឲ្យជួយ , ទាំងអស់នេះ ត្រូវទុក ជាការចូល ប្រកប ដោយយុត្តិកម្ម ។

មាត្រា ២៥៧.- អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ, ភ្នាក់ងាររាជការឬ អាណត្តិជន អ្នករក្សាឯកសារ ខាងការិយាល័យ ណាម្នាក់ ធ្វើឲ្យបាត់ , បំផ្លាញ, លួច, កែបំបាត់ , ឬ ហូតយកចេញ នូវលិខិតទាំងឡាយ ដែលដាក់ទុក ក្នុងការិយាល័យនោះ , អ្នកទាំងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

បំណង ក្នុងទោសកម្មនេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ទោសកម្មនោះដែរ ។ បើការបំផ្លាញ ឬ ការហូតយកនោះ ប្រព្រឹត្ត ដោយសន្ទិប្បទកម្ម, ឬ ដោយបំបាក់, បំបែក ស្លាក ល័ក្ខ, អ្នកនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២៥៨.- អ្នករាជការ ណា ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈ ណា ក្លែងលិខិត ដែលជាមុខការ របស់ខ្លួន :

ក) ដោយកែខ ឬ ដោយបូម អក្សរ ឬ ហត្ថលេខា ,

ខ) ដោយចេតនា ក្លែង សារជាតិ ឬ កាលៈទេសៈ នៃលិខិតនោះ,

គ) ដោយសម្មតិ បុគ្គល ឬ ដោយអាទេសកម្ម បុគ្គល,

00222297
D99/3/3



អ្នករាជការ ឬ អ្នកតំណាងនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

អ្នករាជការ ដែលក្លែង លិខិត ឬ ដែលបង្គាប់ ឲ្យគេក្លែង ហើយ យកលិខិតនោះ ប្រើ ដោយខ្លួនឯង ត្រូវមាន ទោស ដូចគ្នាដែរ ។

មាត្រា ២៥៩ – ក៏ប៉ុន្តែ បើ ការក្លែង ឬ ការប្រើ លិខិតក្លែង នោះ មិនអាចបណ្ដាល ឲ្យមាន ព្យសនកម្ម អ្វី ទេ, អ្នកមាន ពិរុទ្ធ កម្មបទនេះ ត្រូវមាន ត្រឹមតែ ទោសវិន័យ វិញប៉ុណ្ណោះ ។

មាត្រា២៦០– អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ ណា ចេញ លិខិតទាំងឡាយ ដូចមានរៀបរាប់ ក្នុងមាត្រា ៣១៥ ដល់ បុគ្គលណាម្នាក់ ដទៃ អំពីបុគ្គល ដែលមាន ឈ្មោះ ត្រូវប្រគល់ឲ្យ, ដោយធ្វេសប្រហែស ឬ ដោយគ្មានពិនិត្យពិច័យ, អ្នកទាំងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើចេញឲ្យ ដោយមិនត្រឹមត្រូវនេះ ប្រព្រឹត្ត ដោយចេតនា ឬ ដោយក្លែង តាមរបៀបណា ១ ក្តី, អ្នកនោះត្រូវមានទោស មជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៦១ – អ្នករាជការ ឬ អ្នកតំណាងអាជ្ញាធរ សាធារណៈ

00222298



ណា បានបួល ចេញថ្លៃ ដោយខ្លួនឯងក្តី ឬ ឲ្យគេ ចេញជំនួសក្តី ទិញរបស់ឡាយឡុង ខាងធុណាការ ឬ ខាង រាជការ សាធារណៈ, ចេញផ្សារ ឬ ចេញសហគ្រាហ៍ ដែលនៅ ក្រោមការត្រួតត្រា ឬ ក្រោម អនុរក្ស របស់ខ្លួន, អ្នកនោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

អ្នកទៅជំនួស ព្រមទាំងអ្នកដទៃ ដែលមិនមែន ជាអ្នករាជការទេ បានសមគំនិត ក្នុងបទនេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា២៦២ – អ្នករាជការ, ភ្នាក់ងារ ឬ និយោជិត របស់ រាជការ ណា ធ្វើជំនួញ អ្វីមួយ គឺជាទិញ ដើម្បីលក់ ឬ ទទួលការៈ លក់ឲ្យគេ, ទោះធ្វើជំនួញនោះ ដោយខ្លួនឯងក្តី, ទោះឲ្យអ្នកដទៃ ដូចជា ជន ក្នុងគ្រួសារ ឬ ជន ដែលមិនមែន ក្នុងគ្រួសារ, កាន់កាប់មុខជំនួញ នោះ ជាជំនួសខ្លួនក្តី, អ្នកនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

អ្នកកាន់ការជំនួស ក៏ត្រូវមាន ទោស ដូចគ្នាដែរ ។

បទបញ្ញត្តិនេះ មិនត្រូវយកទៅអនុវត្ត លើអ្នកតំណាង អាជ្ញា សាធារណៈ ដែលមិនមាន គុណភាព ជាអ្នករាជការ ទេ គឺអ្នក នោះ បាន ធ្វើ រាជការ ដោយសារការបោះឆ្នោត ។

មាត្រា ២៦៣ – (ព្រះរាជក្រមលេខ១០៩ប.រ ៤-១១-៦២) អ្នករាជការ,

អ្នកតំណាង អាជ្ញាធរសាធារណៈ ឬ អាណត្តិជន និង ភ្នាក់ងារ របស់អ្នកតំណាងនេះ, ភ្នាក់ងារ និងនិយោជិត របស់រាជការ និង របស់ក្រុមរាជការ ទាហាន ឬ ស៊ីវិល ដែលបញ្ចូលទៅជាទាហាន ទោះបីមានបណ្ដាសក្ដិ និងមាន ប្រភេទ នៃមុខងារដូចម្ដេចក្ដី, អ្នកជំនាញ ដែលអាជ្ញាធរខាងរដ្ឋបាល ឬ ខាងតុលាការ ចាត់តាំងមក, ជន ដែលបានទទួលអាណត្តិ, ទទួលបេសកកម្ម របស់រដ្ឋ ឬ របស់តុលាការ ឬ របស់អង្គការសាធារណៈណាមួយ , អ្នកតំណាងប្រជារាស្ត្រ ដែលបង្កើតឡើង ដោយរដ្ឋធម្មនុញ្ញ, ទៅតឹងទារ, បំណងនឹងតឹងទារ ឬ ទទួល នូវវត្ថុអ្វីមួយ ដែលខ្លួន បានដឹងថា មិនមែនជាវត្ថុជំពាក់ទេ ឬ ទារលើស ពីគេ ជំពាក់រាជការក្ដី, លើសពីគេជំពាក់ភាគី ដែលខ្លួន ត្រូវទារក្ដី លើសពីគេជំពាក់លាភការខ្លួន ដែលមាន ច្បាប់ អនុញ្ញាតឲ្យខ្លួន ជាត្រឹមត្រូវក្ដី , អ្នកតាំងនោះ ត្រូវឲ្យខុស ជាបានប្រព្រឹត្ត វិតិក្រម ។

នាកាលវិរុទ្ធជន តែងដែល បានប្រព្រឹត្ត វិតិក្រម ឬ បំណងប្រព្រឹត្ត វិតិក្រម ច្រើនលើក ផ្សេងៗ គ្នា លើជនតែម្នាក់ ឬ ច្រើននាក់ , វិរុទ្ធជននោះ ត្រូវជាប់ទោស តែមួយបទល្មើសទេ ប៉ុន្តែចំនួនទឹកប្រាក់ទាំងប៉ុន្មាន ដែលតឹងទារ ឬ ដែលទទួលមក ដោយមិនត្រឹមត្រូវនោះ ត្រូវបូកបូលគ្នា ហើយកំណត់ បរិមាណ នៃព្យសនកម្ម ដែលបណ្ដាលមក ពីបទល្មើស នោះ ។

00222300

D99/3/3



មាត្រា ២៦៨.– ( ព្រះរាជក្រមលេខ ១០៩ ន.ស ៤-១០-៦២ ) វិតិក្រម ទិញបំណាច់ ទោសកម្មនេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ , កាលណាបើចំនួនប្រាក់ ដែលគិតទារ ឬ ដែលទទួលនោះ បូកទាំងអស់ទៅ មានចំនួនតិចជាង ឬ ស្មើនឹង ១០ ០០០៛០០; ត្រូវផ្តន្ទាទោសឧក្រិដ្ឋថ្នាក់ទីពីរ,កាលណា បើចំនួនប្រាក់ ដែលបូករួមនេះ លើសពី ១០ ០០០៛ទៅ ។

អនុទោស ត្រង់ស្ថានបន្ថយសិទ្ធិ នៃពលរដ្ឋនោះ ត្រូវមានជានិច្ច, អនុទោសនេះ ទំនងបណ្តាលពេញសិទ្ធិ ឲ្យបណ្តេញ ទោសជននោះចេញ ពីមុខងារសាធារណៈ, ពីមុខងារជាផ្លូវការ ។

ស្ថានក្រាប្រណីទោស, ទោះយ៉ាងណាក៏ដោយ , ក៏មិនអាចបញ្ចុះទោសនោះ ឲ្យតិចជាង ពាក់កណ្តាល អតិបរមា នៃទោសមជ្ឈិមថ្នាក់ទីបី ដែរ ។

ស្ថានបន្ធូរប្រតិបត្តិទោស មិនអាចអនុញ្ញាតិ ឲ្យ ទាល់តែសោះ ។

ប្រាក់ទាំងប៉ុន្មាន ដែលបានទទួលមក ដោយខុសច្បាប់យ៉ាងនេះ ត្រូវតែបញ្ជា ឲ្យប្រគល់ ឲ្យម្ចាស់ប្រាក់វិញ ជាកាតព្វកិច្ច, ទោះបីសាមីខ្លួននេះ មិនបានតាំងខ្លួន ជាភាគីស៊ីវិល ក៏ដោយ ។

មាត្រា ២៦៩– (ព្រះរាជក្រមលេខ ១០៩ ន.ស,៤-១០-៦២) សំណូក មានន័យ ថា «ជូន» ហើយនិង«ទទួល» នូវអត្ថប្រយោជន៍ជាសម្ភារៈ

ក្តីមួយ ដែលមិនមែនជាថ្លៃឈ្នួល ឬ ស្មោន់ ដើម្បីសម្រេច ឬ អនុប្បទាន នូវកិច្ច ណាមួយ ជាផ្លូវការ ដែលមាន លក្ខណៈ ជារដ្ឋបាល, ជាតុលាការ, ជាហេរញ្ញិក, ជាយោធា ឬ ជានីតិបញ្ញត្តិ ហើយកិច្ចការនោះ ត្រូវមុខនៃបុគ្គល ដែលគេ យក ជំនូននោះ មកជូនទៀតផង ។ ពាក្យសន្យាថានឹងជូន ក៏ត្រូវទុកជាជំនូនដែរ ។ កិច្ចការជាផ្លូវការ ដែលត្រូវគេសូកនោះ ទោះបីអ្នកទទួលសំណូក បានបំពេញកិច្ច ត្រឹមតែឲ្យ មតិ ឬឲ្យយោបល់ស្រប ប៉ុណ្ណោះ ហើយឲ្យនោះទៀត ក៏ឲ្យ ដោយយុត្តិធម៌ ក៏ដោយ ក៏ត្រូវទុកជាអង្គមួយនៃសំណូកដែរ ។ ជនអ្នកជូន មាន កំហុសក្នុងបទសំណូកសកម្ម ។ ជននេះ ត្រូវផ្ដន្ទាទោស ជាអ្នកសូក ។ ជនអ្នកទទួល មាន កំហុស ក្នុងបទសំណូកអកម្ម គឺថាជននេះ ត្រូវផ្ដន្ទាទោស ជាអ្នកទទួលសំណូក ។

អ្នកដែលអាចប្រព្រឹត្ត សំណូកអកម្មបាន គឺអ្នករាជការ, ភ្នាក់ងារ ឬនិយោជិតនៃក្រុម នឹងគ្រឹះស្ថានសាធារណៈ នឹង អឌ្ឍសាធារណៈ, អ្នកតំណាងអាជ្ញាធរសាធារណៈ, ទោះបីមានបណ្ណាសក្តិ នឹងមុខងារដូចម្ដេចក្តី ឬ ដោយជន ជាអ្នកទទួល អាណត្តិ ពីអាជ្ញាធរ ខាងរដ្ឋបាល, ខាងតុលាការ, ខាងទាហាន ឬ អ្នកដែលត្រូវបញ្ចូល ជាទាហាន, ទោះបីមានបណ្ណាសក្តិ ឬ មានប្រភេទ នៃមុខងារ ដូចម្ដេចក្តី, អ្នកជំនាញទាំងអស់ដែលអាជ្ញាធរ ខាងរដ្ឋបាល ឬ ខាងតុលាការ តាក់តាំងមក, ជនដែលមាន

មុខងារ ទទួល អាណត្តិ, បេសកកម្ម របស់រដ្ឋ ឬ របស់តុលាការ ឬ របស់អង្គការសាធារណៈ, អ្នកតំណាងប្រជារាស្ត្រ ដែលមានអង្គ បក្ក បង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ។

មាត្រា ២៦៦–( ព្រះរាជក្រមដូចខាងលើ ) សំណូក សកម្ម ឬ អកម្ម ត្រូវមានទោសទណ្ឌ ថ្នាក់ទីមួយ និង អនុទោស ត្រង់ស្ថានបន្ថយសិទ្ធិ នៃពលរដ្ឋ ផង ។ អនុទោសនេះ ទំនងបណ្តាល ឲ្យបណ្តេញទណ្ឌិត នោះ ចេញហូត ពីមុខងារសាធារណៈ, ពីមុខងារជាផ្លូវការ ។

ស្ថានគ្រាប្រណី ទោះយ៉ាងណាក៏ដោយ ក៏មិនអាចបន្ថយទោស នោះ ឲ្យតិចជាង ពាក់កណ្តាល អតិបរមា នៃទោសមធ្យមថ្នាក់ទីបី ដែរ ។

ស្ថានបន្ធូរប្រតិបត្តិទោស មិនអាចអនុញ្ញាតឲ្យ សោះ ។

ម្យ៉ាងទៀត តុលាការ ត្រូវពិន័យ អ្នកសូក ស្មើ នឹងតម្លៃ នៃកស្តុការ សំណូក ហាសិប ដងជានិច្ច ។ តុលាការ ត្រូវពិន័យ អ្នកទទួលសំណូក ស្មើ នឹងតម្លៃ នៃកស្តុការ សំណូក នោះហាសិបដងដែរ ។

មាត្រា ២៦៧–( ព្រះរាជក្រមដូចខាងលើ ) មិនត្រូវមាន ទោស ពីបទ រិតក្រម ឬ ពីបទសំណូកទេ, ជនណា ដែលបានជូនដំណឹង ពីរិតក្រម ឬ សំណូកនោះ ដល់អាជ្ញាធរ រដ្ឋបាល ឬ តុលាការ ឬ ដល់អង្គការសា-

00222303

D99/3/3



ធារណៈណាមួយ មុនមានការចោទប្រកាន់ ។

មាត្រា ២៦៨–( ព្រះរាជក្រមខ្ទួបខាងលើ ) ភស្តុតាងនៃបទសំណូក, ខាងអ្នកសូក ក៏ដូចជាខាង អ្នកទទួលសំណូកដែរ , ត្រូវតែរក គ្រប់វិធី ជាអាទិ៍ត្រូវរក ថាអ្នកនោះ មាន ធនធាន មាន តម្លៃច្រើនលើសលប់ ពីណាមក , សាមីជនអាចជូនសំអាង ដោះសារ ជានិត្យានុកូល ឬទេ ។

ពោះបើ អំពើ របស់សំណូក ដែលជាមូលដ្ឋាន នៃការពិនិត្យ អំពីធនធាននោះ សាមីខ្លួន ដោះសារ ផុតពីបទល្មើស នៃច្បាប់ព្រហ្មទណ្ឌក៏ដោយ ក៏តុលាការ ត្រូវតែកាត់ទោសរឹបអូស គឺរឹបទ្រព្យសម្បត្តិ ដែលបានមក ដោយអនិត្យានុកូល នោះ បានដែរ ។

មាត្រា ២៦៩–( ព្រះរាជក្រមខ្ទួបខាងលើ ) កាលណា បើអ្នកទទួលសំណូក ជាចៅក្រម , ចៅក្រមនោះ ត្រូវមាន ទោសជាអតិបរមា ។

ប្រសិនបើ គេឃើញថា ចៅក្រមណា សម្រេចទោសឧក្រិដ្ឋណាមួយ ដោយអយុត្តិធម៌, ដោយសារសំណូក, ចៅក្រមនេះត្រូវ មានទោស ឧក្រិដ្ឋថ្នាក់ទីពីរ ។ ប្រសិនបើ ទោសដែលសម្រេច ដោយអយុត្តិធម៌ ជាទោសគុកធម្មតា នោះ, ត្រូវអនុវត្តទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២៧០– ( ព្រះរាជក្រមលេខ ១២១-ន ស. ចុះថ្ងៃ ១១-១០ ៥៤ )
អ្នករាជការទាំងឡាយ នៃរាជការសាធារណៈណា ដែលមាន មុខក្រសួង កាន់មូលនិធិ , បានតែបំបាត់ មូលនិធិនោះទាំងអស់ ឬ ខ្លះ , អ្នកនោះ ត្រូវមាន ទោសដូចខាងក្រោមនេះ :

– បើ ប្រាក់ ដែលតែបំបាត់ មានចំនួន តិចជាង ឬ ស្មើនឹង ១០ ០០០ រៀល នោះ, ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីបី ។

– បើ ប្រាក់ ដែលតែបំបាត់ មាន ចំនួន ពី ១០ ០០១រៀល ទៅ ត្រឹម ៥០ ០០០រៀល នោះ, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

– បើ ប្រាក់ ដែលតែបំបាត់ មានចំនួន ពី ៥០ ០០១ រៀល ទៅត្រឹម ១០០ ០០០រៀល នោះ, ត្រូវមាន ទោសឧក្រិដ្ឋថ្នាក់ទីពីរ ។

– បើប្រាក់ ដែលតែបំបាត់ មានចំនួន លើសពី ១០០ ០០០ រៀល ឡើងទៅ នោះ, ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

ម្យ៉ាងទៀត, រីឯជន នឹងត្រូវផ្ដន្ទាទោស ឲ្យបន្ថយសិទ្ធិ សិទ្ធិស៊ីវិក ថែមទៀតផង ។

មាត្រា ២៧១– មូលនិធិ គឺ ប្រាក់, វត្ថុ មានតម្លៃ ជំនួស ប្រាក់, ព្រមទាំង សម្ភារៈ, ស្បៀងអាហារ និងទំនិញ របស់និតិបុគ្គល នៃរាជការសាធារណៈ ដែលទុកដាក់ ក្នុងឃ្លាំងរាជការ ឬ ដែលដំកល់

00222305

D99/3/3



ទុក នៅកន្លែងនានា ដើម្បីជាសេចក្ដីត្រូវការ នៃក្រុមរាជការផ្សេងៗ

វត្ថុតាង និង វត្ថុបង្គួសបណ្ដើរសេីន , ទោះបី មិនទាន់ទុក ជា វត្ថុរឹប ក៏ដោយ ក៏ត្រូវទុកជា " មូលនិធិ " ដែរ ។

មាត្រា ២៧២ – ព្រះរាជក្រម លេខ ១២១ - ន.ស ១១-១០-១៩៥៦)

ទោះបុគ្គលឯណា អាចហ៊ាន នែបំបាត់ នូវវត្ថុ ឬ ប្រាក់ ដែលរាជការ បានប្រគល់ ឲ្យខ្លួន ថែរក្សាទុកជូន រាជការ ឬ ប្រើប្រាស់ មានមុខ ជាកំណត់នោះ , បុគ្គលនោះ ត្រូវធ្វើ ទោស ដូចតទៅនេះ ។

– បើ ប្រាក់ ឬ វត្ថុ ដែលនៃបំបាត់ មានតម្លៃតិចជាង ឬ ស្មើនឹង ១០ ០០០ រៀល , នោះត្រូវធ្វើ ទោស មជ្ឈិម ថ្នាក់ទីពីរ ។

– បើ ប្រាក់ ឬ វត្ថុ ដែលនៃបំបាត់ មានតម្លៃ ជាប្រាក់ ពី ១០ ០០១ រៀល ទៅត្រឹម ៥០ ០០០ រៀល នោះ , ត្រូវធ្វើ ទោសមជ្ឈិម ថ្នាក់ទីបី ។

– បើ ប្រាក់ ឬ វត្ថុ ដែលនៃបំបាត់ មានតម្លៃ ជាប្រាក់ចំនួន ពី ៥០ ០០១ រៀល ទៅត្រឹម ១០០ ០០០ រៀល នោះ , ត្រូវធ្វើ ទោស ទុក្រិដ្ឋថ្នាក់ទីមួយ ។

– ជាទីបំផុត , បើ ប្រាក់ ឬ វត្ថុ ដែលនៃបំបាត់ មានតម្លៃ ជា ប្រាក់ លើសពី ១០០ ០០០ រៀល ឡើងទៅ នោះ , ត្រូវធ្វើទោស

ឧក្រិដ្ឋ ថ្នាក់ទីពីរ ។

ពិរុទ្ធជន នឹងត្រូវផ្តន្ទាទោស ឲ្យបន្ថយសិទ្ធិស៊ីវិកថែមទៀតផង ។

## ចំពូក ប្រាំមួយ

## អំពី បទល្មើស ទាក់ទង ក្នុងការប្រើ សិទ្ធិស៊ីវិក

### Des infractions relatives à l'exercice des droits civiques

មាត្រា ២៧៣ – ជនណា ធ្វើឲ្យសៅហ្មង ដល់សេរីភាព ក្នុងការប្រើ សិទ្ធិបោះឆ្នោត និង សិទ្ធិ ឈរឈ្មោះ ឲ្យគេ បោះឆ្នោត ឬ ធ្វើឲ្យសៅហ្មង ដល់សេចក្តីទៀងទាត់ ក្នុងការបោះឆ្នោត ដោយគំរាម, ដោយរំលោភ លើរូបកាយ ឬ ដោយបង្ខំ មានប្រភេទ យ៉ាងណាៗក្តី, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ, និងត្រូវមាន អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិក ទៀតក៏បាន ។

ទោសកម្មនេះ, បើប្រព្រឹត្ត ដោយជនច្រើននាក់, ត្រូវធ្វើទោស មជ្ឈិម ថ្នាក់ទីពីរ ។

បើ បទល្មើសនេះ ប្រព្រឹត្ត ដោយ មានពួកក្រុម ឬ មានកង មានកាន់អាវុធ ឬ គ្មាន ទេ នោះ, ពិរុទ្ធជន ត្រូវមាន ទោស មជ្ឈិម ថ្នាក់ ទីបី ។ ប្រសិនបើ អំពើនេះ ចូល ជាឧក្រិដ្ឋកម្ម ឬ ជាកុប្បកម្មវិញ, ត្រូវយក ទោស របស់ឧក្រិដ្ឋកម្ម ឬ កុប្បកម្ម មក អនុវត្ត ។

មាត្រា ២៧៤- បើ, ក្នុងពេល ដែលប្រព្រឹត្ត បទល្មើស ដូចស្ដី ខាងលើនេះ, មាន ជនណាម្នាក់ ធ្វើ វិហិង្សា លើរូបកាយគេ, ជននោះ ត្រូវមាន ទោស ជាអតិបរិមា នៃទោស ដែលមានគ្រោងទុក ក្នុងបទវិហិង្សា, ហើយ នឹងត្រូវអនុទោស គ្រង់ស្ថានបន្ថយសិទ្ធិស៊ីវិក ទៀតក៏បាន ។

មាត្រា ២៧៥- បើ បទវិហិង្សានេះ ប្រព្រឹត្ត ដោយមាន អ្នកដៃដល់ ច្រើននាក់នោះ, ទោស, ដែលត្រូវយក ទៅអនុវត្ត, ត្រូវឲ្យមានទម្ងន់ តាមលក្ខណ្ឌ ដូចមានសំដែង ជាពិសេស ក្នុងមាត្រា ៣១៨, ៣៧១ ដល់ ៣៧៦ ដែលស្ដី ពីឃាតកម្ម និង ពីវិហិង្សា លើរូបកាយ អ្នកតំណាង អាជ្ញាសាធារណៈ ។ ជនណា ដែលមាន ពិរុទ្ធ ជាបានចូលរួម ដោយចេតនា ក្នុងទោសកម្ម ដែលធ្វើ ឲ្យរំ-ខាន ដល់សេរីភាព ទាំងអស់គ្នា ក្នុងការប្រើសិទ្ធិ បោះឆ្នោត, ជននោះ ត្រូវទុក ជាអ្នកសមគំនិត ក្នុងបទវិហិង្សា ប្រព្រឹត្ត ក្នុងពេល ដែលមាន ទោសកម្មនេះ ។

មាត្រា ២៧៦- ជនណា មានបំណង នឹងបង្វែង ការបោះឆ្នោត សាកល ឬ បំណង នឹងធ្វើឲ្យមាន អនុប្បវាទ ក្នុងការបោះឆ្នោត ដោយផ្សាយ ដំណឹងកុហក ឬ បរិហារមូលបង្កាច់, ជន

នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៧៧– ជនណា មានពិរុទ្ធ ជាបានធ្វើ ឬ ជាបានបំណង នឹងធ្វើ ឲ្យបាន នូវសំឡេងឆ្នោត ឬ នូវអនុប្បវាទ ដោយប្រើឧបាយកល ទុច្ចរិតក្តី, ដោយឲ្យ ជំនូន ឬ សេចក្តីបេ្តជ្ញា ដូចម្តេចក្តី, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

ជន អ្នកទទួលជំនូន ឬ ទទួលសេចក្តី បេ្តជ្ញា ក៏ត្រូវមាន ទោស ដូចគ្នាដែរ ។ អនុទោស គ្រន់ស្ថាន បន្ថយ សិទ្ធិស៊ីវិក នឹងយកទៅ អនុវត្ត លើពិរុទ្ធជន ទាំងពីរបែបនេះ ក៏បាន ។

មាត្រា ២៧៨ ជនណា មាន ពិរុទ្ធ ជាបានឲ្យ ប្រាក់ ឬ ជាបានទទួល ប្រាក់ ដើម្បីនឹងទៅ ទិញ សំឡេង ក្នុងការបោះឆ្នោត, ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ, ហើយ អាចនឹងត្រូវ អនុ-ទោស គ្រន់ស្ថាន បន្ថយសិទ្ធិស៊ីវិក ទៀត ក៏បាន ។

មាត្រា ២៧៩– ជនណា, ខូច សិទ្ធិបោះឆ្នោតហើយ, ហើយ នៅតែទៅបោះឆ្នោត ព្រោះខ្លួន មានឈ្មោះ ក្នុងបញ្ជី មុនពេល ឬ ក្រោយ ពេល ដែលខ្លួន ខូច សិទ្ធិនេះ, ប៉ុន្តែ ឈ្មោះដែលមាន ក្នុងបញ្ជីនោះ មិនមែនជាហេតុ បណ្តាលមក ពីខ្លួនទេ, ជននោះ ត្រូវមាន ទោស

មជ្ឈិម ថ្នាក់ទីមួយ ។

ប្រសិនបើ ឈ្មោះ របស់ជននោះ មាន ក្នុងបញ្ជី ក្រោយពេល ដែលខ្លួន ខូច សិទ្ធិ, បណ្ដាលហេតុ មក ពីជននោះវិញ, គឺថា មកពីជននោះ ជូន អត្តសញ្ញាណខ្លួន ដោយក្លែងក្លាយក្ដី, ជននោះទាមទារ ឲ្យចុះ ឈ្មោះខ្លួន ក្នុងបញ្ជីបោះឆ្នោត ដោយខ្លួនឯងក្ដី ឬ មិនដោយ ខ្លួនឯងក្ដី ដោយលាក់បំបាំង អសមត្ថភាព របស់ខ្លួនក្ដី, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ២៨០- ជនណា មិនខូច សិទ្ធិស៊ីវិល ទេ, ប៉ុន្តែ ចូលទៅរួមបោះឆ្នោត ដោយប្រើ អត្តសញ្ញាណប័ណ្ណ របស់អ្នកដទៃ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ អនុទោស ត្រង់ស្ដាន បន្ថយ សិទ្ធិស៊ីវិល អាច នឹងយកទៅ អនុវត្ត លើជននោះ បាន ជាដរាប ។

មាត្រា ២៨១- ជនណា បានទទួល ពិន្ទ ពីអនក្ខរជន ដែលពឹង ខ្លួន ឲ្យដាក់ ឈ្មោះ បេក្ខជនណាម្នាក់ ក្នុងសន្លឹកឆ្នោត, ហើយមិនដាក់ តាមអ្នកពឹង, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

00[redacted]2310





មាត្រា ២៨២- ជនណា ជាអ្នកទទួលភារៈ រាប់បើ ហិបឆ្នោត ឬ ត្រួត ហិបឆ្នោត, ហើយដកចេញ, ដាក់បន្ថែម ឬ ផ្លាស់ ប្តូរសន្លឹកឆ្នោតក្តី, ប្រកាស ឈ្មោះផ្សេង ក្រៅពីឈ្មោះ ដែលមាន ក្នុងសន្លឹកឆ្នោតក្តី, ធ្វើកេរ ឬ កែសន្លឹកឆ្នោត, ឬ កែង បំណុច ឈ្មោះក្តី, ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី, ហើយអាច នឹង ត្រូវអនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិក ទៀត ក៏បាន ។

មាត្រា ២៨៣- ជន អ្នកចូលទៅ ក្នុងទី ប្រជុំបោះឆ្នោត មិនត្រូវឲ្យ មានគ្រឿងអាវុធ ទេ ទោះកាន់ឲ្យឃើញក្តី, លាក់បិទបាំងក្តី, អំពីល្មើស នឹងបំរាមនេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។ បើ អាវុធនោះ ជាកាំភ្លើង ហើយអ្នកកាន់នោះ គ្មានច្បាប់ អនុញ្ញាតឲ្យ កាន់ ទេ, អ្នកកាន់នោះ ត្រូវមាន ទោស ពីបទកាន់កាំភ្លើង ឥត ច្បាប់ ថែមទៀត ។

មាត្រា ២៨៤.- ការធ្វើឲ្យវឹកវរ ក្នុងសាលបោះឆ្នោត ដែល ជាហេតុ នាំឲ្យមានកករល្អក់ ដល់សេចក្តីស្ងប់ នៃការិយាល័យ, ត្រូវ ធ្វើ ទោសជាមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ២៨៥.- អ្នកណា ប្រមាថ ដោយវាចា, ដោយអាការៈ

00222311

D99/3/3



ឬ ដោយគំរាម, អ្នកណា ធ្វើវិហិង្សា នឹង រំលោភ លើរូបកាយ សមា-ជិក ក្រុមការិយាល័យ បោះឆ្នោត, អ្នកនោះ ត្រូវមាន ទោស ដូចជា បាន ប្រព្រឹត្ត លើរូបអ្នករាជការ កំពុងធ្វើការ មុខងារ ដូចដែលមាន សម្តែងក្នុង មាត្រា ៣០៦ និង ៣១៨ នៃក្រមនេះដែរ ។

មាត្រា ២៨៦– អ្នកណា ឆក់ដណ្តើម ឬ បំណាង នឹងឆក់ ដណ្តើម ហិប ដែលមាន ឆ្នោត បោះរួចហើយ តែមិនទាន់រាប់, អ្នក នោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។ អ្នក ដែលចូលរួមប្រព្រឹត្ត ផង ដោយចេតនា ទោះប្រព្រឹត្ត ដោយផ្ទាល់ខ្លួនក្តី, មិនផ្ទាល់ក្តី, ត្រូវមាន ទោស ដូចគ្នា ។ បើ ការឆក់ដណ្តើមនេះ ប្រព្រឹត្ត ដោយមាន វិហិង្សាផង នោះ, ត្រូវមាន ទោស ដូចមានសំដែង ក្នុងបញ្ញត្តិនៃ មាត្រា ៣១៨, ៣៧១ ដល់ ៣៧៦ ។

## ចំពូក ប្រាំពីរ

## អំពី បទល្មើស ប្រឆាំង នឹងការរៀបរយ សាធារណៈ

Des infractions contre l'ordre publique

មាត្រា ២៨៧ – ក្រុមហ៊ុនណា រៃ ប្រាក់សាធារណៈជនក្តី, សមាគមណា មាន សមាជិកប៉ុន្មានៗ នាក់ក្តី, ក្រុមហ៊ុនណា មិនរៃ

00222312





ប្រាក់សាធារណៈផងទេ ប៉ុន្តែមាន សមាជិក លើសពីម្ភៃនាក់ ឡើងទៅក្តី, កាលទីតាំងបង្កើតឡើង, ក្រុមហ៊ុន ឬ សមាគមទាំងនោះ ត្រូវប្រតិបត្តិឲ្យស្រប តាមបទបញ្ញា ជាធរមាន ។ បើពុំដូច្នោះទេ, ការផ្តុំគ្នា ជាក្រុមនេះ ត្រូវទុក ជាឥតច្បាប់, ហើយ អ្នក ដែលកឡើង ឬ អ្នក ដែលចូលរួម ក្នុងការនេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ពាក្យថា " ក្រុមហ៊ុន " បានន័យថា ការផ្តុំគ្នា ជាក្រុមមួយ ដើម្បីគោលបំណង ធ្វើ ឲ្យចំរើន ទ្រព្យ, បើ ការនេះ ផ្តើមឡើង ដោយមានហៅ គេ ឲ្យដាក់ហ៊ុន ហើយហ៊ុននោះអាចលក់ ទិញ ដូរ ឲ្យអ្នកដទៃបានតាមចិត្ត, ក្រុមហ៊ុននោះ ឈ្មោះថា ក្រុមហ៊ុន នៃ ប្រាក់សាធារណៈ ។

ពាក្យថា " សមាគម " បានន័យថា ការផ្តុំគ្នា ជាក្រុមមួយ ដើម្បីគោលបំណងមួយ ដែលគ្មានគិត ប្រយោជន៍ ផ្ទាល់ខ្លួន សោះ ។

– (មាត្រានេះ ខ្ទួចជាផ្ទុយបទនឹងរដ្ឋធម្មនុញ្ញ ត្រង់មាត្រា១០ ត្រូវនិរាករ ហើយឬ? ។

មាត្រា ២៨៨– ការផ្តុំគ្នា ឥតច្បាប់, ដែលប្រព្រឹត្តទៅ ដោយលាក់, កំបាំង ឬ ដែលសមាជិកទាំងឡាយ ធ្វើសន្និបាត ដោយលួចលាក់, ត្រូវទុកថា ជាសមាគម ឬ ជាក្រុមហ៊ុន សម្ងាត់ ។ សមាគម ឬ ក្រុមហ៊ុន បែបនេះ ត្រូវតែប្រកាស រំលាយចោល ។ មូលនិធិទាំងឡាយ ព្រមទាំងសម្ភារៈ ទីសង្ហារិម របស់ពួកក្រុមនេះ ត្រូវអូស

00222313

D99/3/3



ជាទ្រព្យបើប ឬ ឯសមាជិកម្នាក់ៗ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីបី ។

អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិល និង ហាមឃាត់លំនៅអាច យកមកសម្រេច លើជនទាំងនោះ គ្រប់ៗគ្នា ទៀត ក៏បាន ។

( មាត្រានេះ ក៏ដូចជាផ្ទុយ និង មាត្រា ១០ នៃរដ្ឋធម្មនុញ្ញដែរ )

មាត្រា ២៨៩– កម្មសិទ្ធិករ, អ្នកជួល ឬ អ្នកកាន់កាប់ គេហដ្ឋានណាមួយ ឲ្យ ដោយចេតនា នូវគេហដ្ឋាន សម្រាប់ធ្វើសន្និបាត នៃសមាគម ឬ ក្រុមហ៊ុន ឥតច្បាប់នេះ ដោយយកថ្លៃក្តី ឬ ដោយ មិនយកថ្លៃក្តី, ជនទាំងនោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើគេហដ្ឋាន ដែលប្រគល់ឲ្យទៅ សមាគម ឬ ក្រុមហ៊ុន សម្ងាត់ ណាមួយ ប្រើប្រាស់ ជាកន្លែង សន្និបាតក្តី ជាទីសំណាក់ការដើម ឬ ជាទីសំណាក់ការ សាខាក្តី, ជនទាំងនោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ, អនុទោស ខាងលើ អាច យកមក អនុវត្ត បានទៀត ។

មាត្រា ២៩០– សន្និបាតណា ដែលមាន រយៈវេលា ប៉ុន្មានក្តី មានចំនួន សមាជិក ប៉ុន្មាននាក់ក្តី ដែលផ្តើមឡើង ដើម្បីនឹងរៀបចំ ឬ ដើម្បីនឹងប្រព្រឹត្ត នូវអំពើល្មើសទាំងឡាយ ជាបទឧក្រិដ្ឋ, សន្និបាតនោះ ត្រូវទុក ថាជាសមាគម នៃជនទុច្ចរិត ។

មេ នៃសមាគមនោះក្តី, អ្នក ក សមាគម ឬ អ្នកដឹកនាំសមាគម

00222314

D99/3/3



នោះក្តី, អ្នកដើរប្រមូលសមាជិកក្តី ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ទីពីរ ; ឯសមាជិក ក្រៅពីនោះ ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ២៩១- ជនណា មានពិរុទ្ធ ជាបានផ្តល់ ឬ ញុំាងគេ ឲ្យផ្តល់, ដោយចេតនា ឬ ដោយដឹងការណ៍, នូវលំនៅ, នូវទីជ្រកពួន ដល់សមាជិកម្នាក់ ឬ ច្រើននាក់ នៃសមាគមទាំងនោះ, ជននោះ ត្រូវ មានទោសទុក្រិដ្ឋ ថ្នាក់ទីមួយ ។

អ្នកផ្តល់ ឬ អ្នក ញុំាងគេ ឲ្យផ្តល់, ដោយចេតនា ឬ ដោយដឹង ការណ៍នេះ ច្បាស់, នូវមធ្យោបាយ សំរាប់ទាក់ទងគ្នា ពីសមាជិកមួយ ទៅសមាជិកមួយ ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ ទីមួយ ដូចគ្នា ។

មាត្រា ២៩២- ក្នុងមាត្រានេះ មានបទល្មើសបី ផ្សេងពីគ្នា គឺ

ក)- ជនណា ចូលរួម ក្នុងសន្និដ្ឋកាត រវាងកូនឈ្នួលនឹងជស្ទៅ ទោះបី សន្និដ្ឋកាតនោះ មានរយៈវេលា ប៉ុន្មានក្តី, មានគ្នាចូលរួមប៉ុន្មាន នាក់ក្តី ដើម្បីនឹងបណ្តាល ឲ្យ ដំឡើង ថ្លៃឈ្នួល ឬ បញ្ចុះថ្លៃឈ្នួល ខុសរបៀប ក្តី, ដើម្បីបញ្ឈប់ ឬ បង្អន់ ល្បឿន ការងារ ក្តី ;

ខ)- នាកាល មាន សន្និដ្ឋកាត រវាងពាណិជជនផងគ្នាក្តី ឬ អ្នកផលិត ផងគ្នាក្តី ដើម្បីនឹងបណ្តាល ឲ្យ កែប្រែ ថ្លៃ ខុសចំនន ដោយដើរ

ប្រមូលទំនិញ ទុក ក្ដី , ដោយទុក សន្និធិ (stock) ច្រើន ហួសហេតុ ក្ដី ឬ ដោយប្រើ ស្នៀត ផ្សេងៗ ទៀត ដែលអាចធ្វើ ឲ្យខូច ប្រៈយោជន៍ សាធារណៈជនក្ដី ;

ត)- ជនណា ស្វែងបណ្ដាលហេតុ ឲ្យមានការ បញ្ឈប់ ឬ ឲ្យមាន ការបន្ទន់ ល្បឿនការងារ ឬ សូកកម្មករ និង និយោជិត ឲ្យឈប់ធ្វើការងារ ដោយសុន្ទរកថា ក្ដី, ដោយសំដីបូផាប់ ក្នុងទីប្រជុំជន ក្ដី, ដោយលាយលក្ខអក្សរ ក្ដី, ដោយកលោបាយ ណាមួយ ក្ដី ។

ជនទាំងអស់នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ, និងត្រូវមាន អនុទោស គ្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិក និង គំហាត់លំនៅ ទៀតក៏បាន ។

បំណាង ក្នុងទោសកម្ម ដូចមានពោល ជាពិសេស ក្នុងមាត្រានេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ទោសកម្ម នោះ ដែរ ។

មាត្រា ២៩៣– អ្នកដេញថ្លៃ ឬ លទ្ធករ ណា បានមត់គ្នា ក្នុងពេល លក់ដេញថ្លៃ និង ក្នុងពេល លក់ឡាយឡុង ដើម្បីនឹងបណ្ដាលឲ្យ ឡើងថ្លៃ ឬ ចុះថ្លៃ ខុសទំនង ដោយកលោបាយ ដែលបានព្រមព្រៀងគ្នា ជាមុន, ជនទាំងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

កម្មករ, និយោជិត, នាយជាងរង (Contre-Maitre) និយោជិត (employé) ណា ដែលមាន ពិរុទ្ធ ជាបានធ្វើ ដោយចេតនា នូវផល នៃ

00222316





ការងារ ដែលខ្លួនធ្វើ ដើម្បីអ្នកដទៃ មិនឲ្យត្រូវ តាមខ្នាត ធ្វើឲ្យខូច ឬ ប្តូរគ្រឿងធាតុដើម ក្តី, ធ្វើឲ្យសៅហ្មង សម្ភារៈ ក្តី, មិនអនុលោម តាមបែបបៀប ដែលធ្លាប់ធ្វើមក ក្តី មិនគោរព តាមបញ្ជា ដែលខ្លួន បានទទួលមក ក្តី, ធ្វើ ឲ្យមានកំហុស បច្ចេកទេស ក្តី, ជនទាំងនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ ប្រសិនបើ ការធ្វើ ឲ្យខុសខ្នាត នោះ បានប្រព្រឹត្តរួចហើយ ឬ បំណងនឹងប្រព្រឹត្ត ដោយសារមានសន្និដ្ឋភាព ជាមួយ គ្នាផង, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

បំណង ក្នុងទោសកម្ម, ដូចមានសម្តែង ជាពិសេស ក្នុងមាត្រានេះ, ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ទោសកម្ម នោះដែរ ។

មាត្រា ២៩៨– ប្រសិនបើ កលោបាយទាំងឡាយ ដែលធ្វើ ដើម្បីឲ្យរំខាន ដល់សេរីភាព ក្នុងការងារ, ដល់សេរីភាពជំនួញ, ដល់សេរីភាពនៃការលក់ឡាយឡុងនោះ មានកំហែង, បន្លំ, គំរាម ឬ វិហិង្សាផង, បទល្មើសនោះ ត្រូវមាន ទោស ជាអតិបរមា ។ ប្រសិន ប្រភេទ នៃវិហិង្សា និង គុណភាព នៃអ្នករងគ្រោះ បណ្តាលឲ្យមាន ទោស ធ្ងន់ជាងនេះ ទៅទៀត នោះ, ទើបត្រូវយក ទោស ធ្ងន់នេះ មកអនុវត្ត ។

មាត្រា ២៩៩– ជនណា ប្រើ សាកាបន្លំ, សាកាគំរាម ឬ

00222317

D99/3/3



វិហិង្សា ដើម្បីប្រព្រឹត្ត តែម្នាក់ឯង នូវអំពើល្មើស ដូចមានសម្តែង ក្នុង មាត្រា ២៩២ និង ២៩៣ នេះ, ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ; វៀរតែ ប្រភេទ នៃវិហិង្សា និង គុណភាព នៃអ្នករងគ្រោះ បណ្តាល ឲ្យមាន ទោសធ្ងន់ ជាងនេះទៅទៀត នោះ, ទើបត្រូវយក ទោសធ្ងន់នេះ មក អនុវត្ត តាមការណ៍ ។

មាត្រា ២៩៦– ជនណា បានផ្សាយ ដំណឹងកុហក ដោយ បំណងថា នឹងបណ្តាល ឲ្យផាក់ថ្លៃ ផ្សេងពីថ្លៃ ដែលគេ បានកំណត់ តាមទម្លាប់ ប្រកួតប្រជែង ដោយសេរី ក្នុងការដើរ, ក្នុងជំនួញ, ក្នុងការលក់ ឡាយឡុង, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បំណង ក្នុងទោស កម្មនេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ទោសកម្ម នោះដែរ ។

មាត្រា ២៩៧– ជនណា ធ្វើឲ្យមាន អហេតុកភ័យ ដល់ប្រជាជន ឬ ធ្វើឲ្យមាន កោលាហល ដល់សាធារណជន ដោយផ្សាយ ដំណឹងកុហក ឬ ដំណឹង វិភេទ ឬ ដំណឹងបំផ្លើស ដោយចេតនា, ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

បំណង ក្នុងទោសកម្មនេះ ក៏ត្រូវមាន ទោស ដូចបានប្រព្រឹត្ត ទោសកម្ម នោះដែរ ។

00222318





មាត្រា ២៩៨- ជនណា ខំធ្វើ ឲ្យប្រជាជន មាន ជំនឿ លើ ខ្លួន ដោយអួតអាងនូវអំណាច ជាឧត្តរិមនុស្សធម្ម ហើយបណ្តាល ឲ្យ មានចលាចល ឬ កោលាហល ដល់សាធារណជន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ ទីមួយ ។

បទបញ្ញត្តិនេះ ត្រូវយកទៅអនុវត្ត លើជន អ្នករៀនធ្មប់, អាបឬ មន្តអាគម ស្នេហ៍ ផង ដែរ ។

បំណង ក្នុងទោសកម្មនេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ទោសកម្មនោះដែរ ។

ការដឹកនាំ ឬ បញ្ចុះបញ្ចូល មនុស្ស តែម្នាក់ ឬ ទាំងហ្វូង ដោយ មធ្យោបាយ យាំងណាក្តី ឲ្យទៅ កាន់កន្លែងទាំងឡាយ នៅ ក្នុងកម្ពុជារដ្ឋ ឬ ក្រៅកម្ពុជារដ្ឋ ដើម្បីទឹងមើល ឬ ចូលរួមធ្វើ បុណ្យ ឬ ប្រជុំ ដែល ធ្វើ ដោយជនជាតិខ្មែរ ឬ ជាតិបរទេស, ប៉ុន្តែមិនមែន ជាបព្វជិត ក្នុង សាសនា របស់រដ្ឋទេ, អំពើទាំងអស់នេះ ត្រូវទុក ថាជាបំណង ទឹង ធ្វើឲ្យចលាចល ដល់សាធារណជន (១) ។

អ្នកទៅ ក្នុងបុណ្យ ឬ ក្នុងប្រជុំនោះ ត្រូវមាន ទោសលហុ(២) ។

---

(១)- បទបញ្ញត្តិ ទាំង ២ វគ្គនេះ ហាក់ដូចជាត្រូវនិរាករណ៍ដោយឯកឯងហើយ ព្រោះជាទាស់ នឹងបទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ មាត្រា ៨ ដែលលើកឲ្យពលរដ្ឋ មានសេរីភាពបរិបូណ៌ ក្នុងជំនឿ ។

00222319





មាត្រា ២៩៩- ជនណា បង្កហេតុ ឬ បំណងនឹងបង្កហេតុ នៅមុខប្រជាជន ដោយពាក្យ ឬ ដោយលាយល័ក្ខអក្សរ , ដោយគំនូរ , រូប ឬ ទស្សន័យភាព , ទោះបី គ្រឿងប្រដាប់ សម្រាប់មើល ឬ សម្រាប់ស្តាប់ ដែលយកមកប្រើ ក្នុងការឃោសនា ដល់ប្រជាជននោះ មានធុនដូចដូចម្តេចក្តី , ទោះបី ភាសា ដែលប្រើនោះ , ជាភាសា ជាតិ ណាៗក្តី ដើម្បីឲ្យមាន ការប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ ទោសកម្ម, ជននោះត្រូវទុក ជាអ្នកសមគំនិត ក្នុងឧក្រិដ្ឋកម្ម ឬ ទោសកម្មនោះ, ប្រសិនបើ បទល្មើសទាំងនោះ បានប្រព្រឹត្តរួចហើយ ឬ មានបំណងនឹងប្រព្រឹត្ត មែនៗ បើ ការបង្កហេតុនេះ គ្មានបាន ផល សោះទេ , វិរុទ្ធជន ត្រូវមាន ទោសមធ្យមថ្នាក់ទីពីរ ។ ក្នុងករណី ទាំងពីរនេះ, វិរុទ្ធជន នឹងត្រូវ អនុទោសគ្រឿងស្លាក បន្ថយសិទ្ធិស៊ីវិក និង ហាមឃាត់លំនៅ ទៀតក៏បាន ។

ការបង្កហេតុ គឺ ការញុះញង់ ដោយផ្ទាល់ ឬ ដោយមិនផ្ទាល់, ឲ្យប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ ទោសកម្ម, បញ្ឆោរ ឬ ចាក់ដើង ជន ដែលបាន ប្រព្រឹត្ត ឬ បំណងនឹងប្រព្រឹត្ត នូវ អំពើល្មើសនោះ ជាដើម ។

( វគ្គ បន្ត ពីវគ្គ ខាងលើនេះ បានត្រូវនិរាករណ៍ហើយ ។ ត្រូវយក មាត្រា ១៩និង២០ នៃ ព្រះរាជក្រម លេខ ៦៣០-នស. ចុះថ្ងៃ ១០-៣-៥១ ដែលមាន សេចក្តីស្រង់ ដូចខាងក្រោមនេះ មកជំនួស វិញ ។ )

មាត្រា ១៩ – ជន អ្នកមានទោស តាម លំដាប់ ដូចខាងក្រោមនេះ,

00222320





ដែលបានប្រព្រឹត្ត បទឧក្រិដ្ឋ និង មជ្ឈិម តាមផ្សាយពត៌មាន , ត្រូវទុកដូច ជាចារី :

១- ចាងហ្វាងផ្សាយដំណឹង ឬអ្នកបោះពុម្ពផ្សាយ (éditeur), បើ ទុកជាមាន ងារ ឬ មានឈ្មោះ ជាអ្វី ក៏ដោយ ។

២- បើ គ្មានជន ខាងលើនេះទេ , ត្រូវយក អ្នកនិពន្ធ ។

៣- បើ គ្មានអ្នកនិពន្ធ ត្រូវយក អ្នកបោះពុម្ព(imprimeur) ។

៤- បើ គ្មានអ្នកបោះពុម្ព, ត្រូវយក អ្នកលក់, អ្នកចែកផ្សាយនិង អ្នកបិទផ្សាយ ។

មាត្រា ២០ - កាលណា ចាងហ្វាងផ្សាយដំណឹង ឬ អ្នកបោះពុម្ពផ្សាយ ត្រូវចោទ ជាអាទិចារី, អ្នកនិពន្ធ នឹងត្រូវចោទ ជាអ្នកសមគំនិត ។ ជន ដែលមានលក្ខណៈ ដូចមានក្នុង មាត្រា ពី៨២ ដល់ ៨៨ នៃក្រមព្រហ្មទណ្ឌនេះ អាចត្រូវមាន ទោស ដូចគ្នា ទាំងអស់ ។

បើ មាន វិក្រឹតជនខ្លះ មាន លក្ខខ្ចិក របស់ខ្លួន ឬ មានហេតុអ្វីផ្សេងទៀត ដែលមិនអាច ឲ្យគេចោទប្រកាន់ បាន ទេនោះ , គេ អាចចោទតែ វិក្រឹតជន ឯទៀត តែម្នាក់ ឬ ច្រើននាក់ ក៏បាន ។

វត្ថុទាំងឡាយ, ជាសម្ភារៈ សម្រាប់ប្រព្រឹត្ត បទល្មើសនោះ ឬ សម្រាប់ផ្សាយ ដល់សាធារណជននោះ, ត្រូវបេក្ខសទុក ។ វត្ថុទាំងឡាយ, ដូចជាពត៌មាន, វិញសារ (Morasse) ម៉ាស៊ីនបោះពុម្ព, ប្រដាប់

00222321

D99/3/3



បញ្ចាំងរូប ឬ ប្រដាប់បំពងសំឡេងជាដើម, ក៏ត្រូវបែកឆ្លុស ដូចគ្នា ៖ ព្រះរាជក្រឹត្យ ដែលមានគណៈរដ្ឋមន្ត្រី បានយល់ព្រម ផង អាចឃាត់ហាមបាន នូវការបោះពុម្ព, ការបោះផ្សាយ ជាសៀវភៅ (édition), ផលិតកម្ម នៃលេខនា សម្រាប់មើល ឬ សម្រាប់ស្តាប់ (reproduction graphique visuelle ou phonique), ការធ្វើទស្សនីយភាព(mise en spectacle ),ការផ្សាយដល់សាធារណៈជន(publication),ការបិទផ្សាយ( affichage), ពិព័ណ៌ ( exposision ), ការបញ្ជូនចុះឡើង (circulation), ការដឹកជញ្ជូន(transport),ការចែកផ្សាយ(distribution),ការលក់(vente) ការផ្សព្វផ្សាយ (diffusion )ដោយរបៀបយ៉ាងណា ៗក្តី នូវលិខិត(écrits) សុន្ទរកថា(disconrs ), គំនូរ (dessins),រូប(image), រូបថត,(photographies ), ទស្សនីយភាព (spectacles),តែផ្សេង ៗ, បដិមរូប (emblèmes) ដែលយល់ថា ជួយ ដឹងសេចក្តីរៀបរយ របស់មហាជន , របស់ទំនៀមទម្លាប់ ឬ ដែលយល់ថា ប៉ះពាល់ ដល់សេចក្តីគោរព ព្រះមហាក្សត្រ, ដល់ព្រះរាជវង្សានុវង្ស, ដល់សាសនា របស់រដ្ឋ , ដល់អាជ្ញាធរ ដែលតែងតាំង ដោយរដ្ឋធម្មនុញ្ញ ។

ព្រះរាជក្រឹត្យ ដែលហាមឃាត់នេះ ត្រូវដាក់ឲ្យប្រតិបត្តិ ភ្លាម ៗ ក្រោយដែលព្រះមហាក្សត្រ ទ្រង់មាន ព្រះរាជឧង្ការ ប្រកាស ឲ្យប្រើ ។

ប្រសិនបើ ការបង្ករហេតុនោះ , ថ្វីបើ មាន ព្រះរាជក្រឹត្យហាមឃាត់

យ៉ាងនេះហើយ , ព្រមទាំងមាន សេចក្ដីប្រកាស ឲ្យប្រើព្រះរាជក្រឹត្យនោះហើយ, ហើយនៅតែបំណង ទឹងប្រព្រឹត្ត ឬ នៅតែប្រព្រឹត្តទៀត, អំពើនោះនឹងត្រូវមានទោស ដល់អតិបរមា , កាលណាបើ ទោសនោះនៅត្រឹមតែទោសមធ្យម ។

មាត្រា ៣០០– ( ព្រះរាជក្រមលេខ ៤១ ន. ស. ចុះថ្ងៃ ២២ - ៩ - ៥៥ )

១.– ជនណា បានផ្សាយ ដោយប្រើ មធ្យោបាយ ណាមួយ បណ្ដា មធ្យោបាយ ទាំងឡាយ ដូចដែលមានសំដែង ក្នុងមាត្រា ២៩៩ ខាងលើនេះ ជាភាសា អ្វីក៏ដោយ ទូរវិទ្ធនិទ្រា ដែលមាន គោលបំណង ជាប្រត្យក្ស ថា ទឹង :

ក) បញ្ឆោតឲ្យប្រាកដ, បង្រៀន ឬ ធ្វើឲ្យជឿច្បាស់ ថា ត្រូវតែផ្ទុះផ្ដួល រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ, អង្គការ នៃអំណាចសាធារណៈ , ច្បាប់ ឬ បទបញ្ញា ខាងរដ្ឋបាល ដោយមធ្យោបាយទាំងឡាយ ផ្សេង ពីមធ្យោបាយ ដែលរដ្ឋធម្មនុញ្ញ ឬ ដែលច្បាប់ អនុញ្ញាត ឲ្យធ្វើ ព្រោះថាការផ្ទុះផ្ដួលនេះ សមស្រប តាមច្បាប់ហើយ ជាចំបាច់ហើយ ឬ សមគួរ ដល់ពេលវេលាហើយ, យ៉ាងនេះក្ដី ។

ខ) ហាមឃាត់, បង្រៀន ឬ ធ្វើឲ្យជឿ ថា ត្រូវតែកែប្រែ រដ្ឋធម្មនុញ្ញ ត្រង់ចំណុច ទាំងឡាយ ដែលរដ្ឋធម្មនុញ្ញ បានហាម មិនឲ្យកែ

00222323





ប្រែ ដោយមធ្យោបាយ, ដែលតាមទំនងក្រៅ, បែប ត្រឹមត្រូវ តាមច្បាប់ ក៏ដោយ, ដោយហេតុថាការកែប្រែនេះ សមរម្យ តាមច្បាប់ហើយ, ជាចាំបាច់ហើយ ឬ សមគួរដល់ពេលវេលាហើយ, យ៉ាងនេះ ក្តី ។

គ) អុជអាល ឲ្យមើលងាយ ឬ ឲ្យស្អប់ រដ្ឋាភិបាលខ្មែរ ឬ ប្រទេស សម្ពន្ធមិត្ត ឬ ជាមិត្ត យ៉ាងនេះ ក្តី ។ ក៏ប៉ុន្តែ ចំពោះបទល្មើស ក្នុងវគ្គនេះ បើរដ្ឋាភិបាល ជាសាមីខ្លួន មិនបានប្តឹង មក ជាមុន ទេ នោះ, ការចោទប្រកាន់ ក៏មិនអាច ធ្វើ បាន ដែរ ។

ឃ) អុជអាល ឲ្យស្អប់ ឬ ឲ្យមើលងាយ រវាងកម្មករ នឹងអ្នកពលការ ក្តី, រវាងវណ្ណៈ ក្តី, រវាងពួក ឬ ជន នៃពលរដ្ឋ នឹងពួក ឬ ជន នៃពលរដ្ឋ ក្តី, រវាងតំបន់ មួយ នឹងតំបន់ មួយ នៃប្រទេសកម្ពុជា ក្តី, រវាងសាសនា នឹង សាសនា ដែលរដ្ឋាភិបាល ទទួលស្គាល់ ក្តី ឬ ប្រឆាំងនឹងសាសនា ណាមួយ បណ្តាសាសនា ទាំងឡាយ នោះ ក្តី ។

ង) អុជអាល មិនឲ្យស្តាប់បង្គាប់, ដោយឲ្យធ្វើតែព្រងើយៗ ក៏ដោយ, នូវច្បាប់, បទបញ្ជា, បទបង្គាប់ តាមច្បាប់ របស់អាជ្ញាធរ ជាធម្មានុរូប ខាងរដ្ឋបាល ឬ ខាងតុលាការ, យ៉ាងនេះ ក្តី ; ប៉ុន្តែ បើការអុជអាល ឲ្យធ្វើ ឧក្រិដ្ឋកម្ម នេះ បានផល របស់វា មែននោះ, ត្រូវយកបទបញ្ញត្តិ ស្តី ពីឧក្រិដ្ឋកម្ម ដែលមាន ទោសធ្ងន់ជាង ទោស នៃបទល្មើស ក្នុងវគ្គនេះ មកអនុវត្ត វិញ ។

ជននោះ ត្រូវផ្តន្ទាទោស ឧក្រិដ្ឋថ្នាក់ទីមួយ ; ប៉ុន្តែទោសនេះគឺមិនជាឧបសគ្គឲ្យខានអនុវត្ត ទោសធ្ងន់ជាងនេះទៅទៀតទេ, ប្រសិនបើមានការណ៍ ត្រូវអនុវត្ត ។

បទបញ្ញត្តិ នៃមាត្រា ២៩៩ ត្រូវយកមក អនុវត្ត អំពីកំណត់ពិរុទ្ធជន, អំពីការទោសប្រកាន់ លើមនុស្ស តែម្នាក់ ឬ ច្រើននាក់ ក្នុងបណ្តា ពិរុទ្ធជនទាំងនោះ, កាលណាបើ មានពិរុទ្ធជន ខ្លះទៀតមិនអាច ត្រូវទោសប្រកាន់បាន, អំពីបន្ធូរ, អំពីបន្ថែម ទម្ងន់ទោស បណ្តាលមក ពីមាន ព្រះរាជក្រឹត្យ ហាមឃាត់ហើយ នៅតែប្រព្រឹត្តទៀត។

២.- ជនណា មានពិរុទ្ធ ជាបានដឹកនាំ, បានចូលរួម ក្នុងការដឹកនាំ, បានក ឬ បានបំណាង ទីឯក នូវបក្សពួក ណាមួយ សម្រាប់ ផ្សាយ នូវវិទ្ធង្សនា ដូចបានពន្យល់ សព្វគ្រប់ ត្រង់កថាខណ្ឌ ទីមួយ នៃមាត្រានេះ, បក្សពួកនោះ ទោះមាន រូបភាព យ៉ាងណា ក៏ដោយ ទោះមាន សារៈ ខាងក្រៅ យ៉ាងណា ក៏ដោយ, ជននោះ ក៏ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរដែរ ។ ទោសនេះ មិនមែន ជាឧបសគ្គ ឲ្យខាន អនុវត្ត នូវទោសធ្ងន់ ជាងនេះ បាន ទេ, ប្រសិនបើ មាន ការណ៍ ត្រូវអនុវត្ត ។

កាលបើ មាន ព្រះរាជក្រឹត្យ ប្រកាស ឲ្យរំលាយ អង្គការ ឬ បក្សពួក ណាមួយហើយ, ជនណា នៅតែខាន បំណង ទីឯបង្កើត ឬ បង្កើត

00222325





នូវអង្គការ ឬ បក្សពួកនោះ ដោយមាន រូបភាព មួយបែបទៀត ឬ មាន ឈ្មោះ មួយទៀត, ជននោះ នឹងត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ដូចគ្នា ទាំងអស់ ដោយឥតបែងចែក ថាអ្នកនេះ ជាអ្នកបង្កើត អ្នកនេះ ជាអ្នកដឹកនាំ អ្នកនេះ ជាសមាជិក ធម្មតា ឡើយ ។

៣.– ក្នុងករណី ទាំងអស់ ដូចមានសំដែង ក្នុងមាត្រានេះ ជន អ្នកត្រូវមួលទោសហើយ នោះ អាចនឹងត្រូវ អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិក និង តំហាត់ លំនៅ ទៀត ក៏បាន ។ (វគ្គនេះប្រហែល ជាត្រូវនិរាករណ៍ ដោយឯកឯងហើយ)

មាត្រា ៣០១– (ព្រះរាជក្រមលេខ ៤១– នស. ចុះថ្ងៃ ២២-៩-៥៥) សេចក្តីជៀលគ្នះ ដល់កិច្ចការ របស់រដ្ឋាភិបាល ចំពោះមុខ ជនានុជន តាមប្រការ ណាមួយ ដែលមានចង្អុល ត្រង់ មាត្រា ២៩៩ ត្រូវធ្វើទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើ សេចក្តីជៀលគ្នះនោះ, មិនមាន ជេរប្រមាថ ទេ, តែមាន គំនិត អាក្រក់ ឬ ចង់ប្រទុស្តរ៉ាយ ជាទីនាំ មតិសាធារណៈជន ឲ្យ បន្ទាប រដ្ឋាភិបាល, តំណែងរាជការ ទាំងនេះ ឬ អ្នក តំណាង រាជការទាំងនេះក្តី, ទំនង ជាទីជំទាស់ ចលកិច្ចការ ខាងរដ្ឋបាល ឬ ខាង តុលាការក្តី នោះ, វិរុទ្ធជន ត្រូវមាន ទោស មជ្ឈិមថ្នាក់ទីមួយ ។

បទបញ្ញត្តិ នៃមាត្រា ២៩៩ ត្រូវយកមក អនុវត្ត ត្រង់ស្ថាន ដូចតទៅនេះ :

00222326



អំពីកំណត់ វិរុទ្ធជន , អំពីការចោទប្រឆាំង លើមនុស្សតែម្នាក់ ឬ ច្រើននាក់ ក្នុងបណ្តា វិរុទ្ធជនទាំងនោះ, កាលណាបើ មាន វិរុទ្ធជន ខ្លះទៀត មិនអាចត្រូវចោទប្រកាន់បាន , អំពីបង្អួស , អំពីបន្ថែម ទម្ងន់ទោស បណ្តាលមក ពីមាន ព្រះរាជក្រឹត្យ ហាមឃាត់ ហើយ នៅតែចេញផ្សាយ ។

មាត្រា ៣០២– ជនណា បំផ្លាញ ឬ ហែកចោល នូវបណ្ណ បិទផ្សាយ ឬ ដំណឹងជាផ្លូវការ ដែលរាជការ បិទផ្សាយ ដល់សាធារណជន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ព្រះរាជក្រម លេខ ៤១ ន ស. ចុះថ្ងៃ ២២-៩-៥៥ បន្ថែម ទៀត ថា. -ជនណា បានចែក , បានដាក់លក់ , បានដាក់តាំង ឲ្យសាធារណជន ឃើញ នូវ ទិតបណ្ណ, ដំទាក្រដាស់ (papillons), បណ្ណបិទផ្សាយ ដែលបានមកពី បរទេស ឬ ដែលដកស្រង់ តាមបរទេស , ជាបណ្ណ មាន កំណើត សម្រាប់ បំផ្លាញ ផលប្រយោជន៍ជាតិ , ជន អ្នកធ្វើនេះ ក៏បានដឹង ច្បាស់ នូវលក្ខណៈ ទុច្ចរិត នៃបណ្ណទាំងនោះដែរ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ; ប៉ុន្តែការណ៍នេះ ត្រូវនាយករដ្ឋាភិបាល ធ្វើពាក្យ ប្តឹង ជាលាយលក្ខអក្សរ ជាមុនសិន ។

គ្រប់ពេល ទាំងពួង ដែលចាប់ កស្តុតាង បាន ថា មូលនិធិ

00222327

D99/3/3



ដែលបានមកពាយព័យ ដើម្បីឲ្យងាយ ប្រព្រឹត្ត ឬ បំណងប្រព្រឹត្ត នូវ ឧក្រិដ្ឋកម្ម ឬ ទោសកម្ម ដូចមានសំដែង ក្នុងមាត្រា ២៦០ ដល់ ២៣៥ ៦៩៩, ៣០០, ៣០១, ៣០៦ នៃក្រមព្រហ្មទណ្ឌនេះ ជាមូលនិធិ បានមក ពីរដ្ឋការបរទេស ឬ ពីអង្គការបរទេស នោះ, ទោស ទាំងឡាយ ដែលគ្រោងទុក ដើម្បីបង្ក្រាប បទល្មើស ទាំងឡាយនោះ ត្រូវ បន្ថែមឲ្យលើស ពីទម្ងន់មុន មួយថ្នាក់ៗទៀត

មាត្រា ៣០៣- ជនណា បង្កហេតុ ឲ្យកើត បលាបល ឬ កោលាហល ដោយចេតនា នៅទីកន្លែង ដែលភ្នាក់ងាររដ្ឋការ ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ បំពេញ កិច្ចការ មុខក្រសួង, ជននោះ ត្រូវផ្តន្ទា ទោស ជាលហុ ។

មាត្រា ៣០៤- ជនណា ជេរបញ្ជោរ, ឈ្លោះ ឬ ធ្វើ វិវាទកម្ម គ្រប់យ៉ាង ដែលបណ្តាល ឲ្យ ភ្រប់ភាស ឬ ឲ្យតឹកតង, នាំ ឲ្យខូច សេចក្តីស្ងប់ស្ងាត់ របស់សាធារណៈ, ជននោះ ត្រូវមាន ទោសជាលហុ ។

មាត្រា ៣០៥- ជនណា ស្រដី ប្រមាថ, មើលងាយ, ប្រគោះ, ព្រហើន ទៅលើ រដ្ឋាភិបាលខ្មែរ ក្នុងទីចំពោះមុខ ជនានុជន, ជននោះ ត្រូវមាន ទោសលហុ ។

មាត្រា ៣០៦– ជនណាប្រមាថ មើលងាយ មន្ត្រី ឬ អ្នកតំណាងអាជ្ញាធរសាធារណៈ, ដែលកំពុងធ្វើការ ឬ ក្នុងវេលា ធ្វើការ មុខក្រសួងនោះដោយពាក្យសំដី, ដោយកាយវិការ, ដោយការកំហែងគំរាម, ដោយលាយលក្ខអក្សរឬក៏ដោយរូបគំនូរ,ជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទី១ ។

មាត្រា ៣០៧ – ព្រះរាជក្រម លេខ ១០៩ ប.រ ចុះថ្ងៃ ៤-១០-៦២ បាននិរាករបញ្ញត្តត្រង់មាត្រានេះចោលហើយ ។

មាត្រា ៣០៨– ជនណា ប្រមាថ ចៅក្រម ឬ ក្រុមប្រឹក្សាតុលាការ ណាម្នាក់ នៅពេល កំពុងជំនុំជំរះក្តី ក្នុងសាលាក្តី ណាមួយ, បណ្តា សាលាក្តី ទាំងឡាយ ក្នុងព្រះរាជអាណាចក្រ, ជននោះ ត្រូវមាន ទោស ដូចមានលើ ដល់អតិបរមា ឯអនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិកនោះ នឹងយកទៅជួន្នា ថែមទៀតក៏បាន ។

មាត្រា ៣០៩– ជនណា បរិហារកេរ្តិ៍ អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ តាមលក្ខខណ្ឌ, ដូចមានសម្តែង ក្នុងមាត្រា ៤១៣, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ៣១០– ជនណា ប្តឹង ពីអ្នករាជការ, អ្នកតំណាង អាជ្ញាធរសាធារណៈ ឬ ភ្នាក់ងាររាជការ, ដែលមានថ្នាក់ ឬ មុខការ ដូច

ម្តេចក៏ដោយ , តាមលក្ខខណ្ឌ ដូចមាន សំដែង ក្នុងមាត្រា ៥១៤, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីបី ។

នាកាល បណ្តឹងក្តីនោះ ប្តឹង ពីកំហុស ក្នុងមុខងារ គឺថា កំហុសនោះ មិនចូល ជាបទមជ្ឈិម ឬ ឧក្រិដ្ឋទេ, អ្នកប្តឹងក្តី ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ។ ប៉ុន្តែ បណ្តឹងបែបនេះ នឹងត្រូវទុកជាក្តីបាន, លុះណាតែ សេចក្តីស៊ើបសួរ ខាងរដ្ឋបាល ឬ ខាងតុលាការ , ដែលបានស៊ើបសួររួចហើយ, ជូន សេចក្តីសន្និដ្ឋាន មកថា បណ្តឹងនោះ មិនពិត ទេ ។

មាត្រា ៣១១– ជនណា ជួញឥទ្ធិពល, ដែលខ្លួន មានមែន ឬ មិនមានសោះ, ហើយទទួល ជំនូន អ្វីមួយ ឬ ទទួល សន្យាណាមួយ ដើម្បីថាទៅគិតគូរ និងអាជ្ញាធរខាងរដ្ឋបាល ឬ ខាងតុលាការ ឲ្យគេអនុគ្រោះ ដល់អ្នក ដែលមកពីខ្លួន ឬ ដល់អ្នក ដែលគេនាំតែ ឈ្មោះ មកពីខ្លួន, ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ វត្ថុ ដែល បានសន្យាថាឲ្យ ឬដែលបានទទួលរួចហើយ, ត្រូវ អូស ជាទ្រព្យរឹប

បទបញ្ញត្តិ នៃមាត្រានេះ ត្រូវយកទៅអនុវត្ត ជាអាទិ៍ លើអ្នករាជការ លើភ្នាក់ងាររាជការ និងក្រុមរាជការ សាធារណៈ គ្រប់ជាន់ថ្នាក់ លើអ្នកតំណាងអាជ្ញាធរ សាធារណៈ , ដែលបានទទួលលាភការ អ្វីមួយ

ដោយផ្ទាល់ខ្លួន ឬ ដោយប្រយោល, ក្នុងវេលា ដែលខ្លួន តែងពាក្យ ឲ្យគេក្តី, ក្នុងវេលា ដែលទៅទាក់ទងគិតគូរ ឲ្យគេ ក្តី, ក្នុងវេលា ដែលខ្លួន សន្យាថា ជួយ ឬ ដែលគេ សុំឲ្យខ្លួន ជួយ ក្តី ។

មាត្រា ៣១២– ជនណា គ្មានបណ្ណសក្តិអ្វីសោះ ហើយជ្រៀតជ្រែក ក្នុងមុខក្រសួងសាធារណៈ ឬ ធ្វើ កិច្ចការអ្វីមួយ ក្នុងមុខក្រសួងនោះ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ បើកិច្ចការ ដែលប្រព្រឹត្តនោះ ចូល ជាអំពើក្លែងផង, ជននោះ ត្រូវមាន ទោស ជាទម្ងន់ជាងនេះ ទៅទៀត ។ អនុទោស ត្រង់ស្ថានបន្ថយ សិទ្ធិស៊ីវិល ក៏អាចយកមកសម្រេច ផងទៀត ក៏បាន ។

បំណង នឹងប្រព្រឹត្ត បទល្មើសនេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត បទល្មើសនេះ ដែរ ។

ឯជន ដែលឥតច្បាប់អនុញ្ញាត ហើយធ្វើកិច្ចការ ឬ បំណង នឹងធ្វើកិច្ចការ ជាមុខក្រសួងមេធាវី ក្នុងសាលាក្តី, ក៏ត្រូវមាន ទោស តាមបទបញ្ញត្តិនេះ ដែរ ។

មាត្រា ៣១៣– ជនណា គ្មានសិទ្ធិ នឹងស្លៀកពាក់ នូវសំលៀកបំពាក់ ជាឯកសណ្ឋាន តាមបទបញ្ជា ណាមួយ ហើយស្លៀកពាក់ នូវសំលៀកបំពាក់ ជាឯកសណ្ឋាននោះ, ជននោះ ត្រូវមាន

00222331





ទោស មជ្ឈិម ថ្នាក់ទីពីរ ។

ជនណា ពាក់សក្តិ ឬ ពាក់គ្រឿងឥស្សរិយយស, ដែលខ្លួន គ្មានសិទ្ធិ ត្រូវពាក់, ជននោះ ក៏ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរដែរ ។

មាត្រា ៣១៤– សំលៀកបំពាក់ ជាឯកសណ្ឋាន តាមបទបញ្ញា ដែលជននោះ គ្មាន សិទ្ធិ ស្លៀកពាក់ គឺៈ

សំលៀកបំពាក់ សម្រាប់អ្នកបួស ក្នុងសាសនា របស់រដ្ឋ ហើយនឹងសំលៀកបំពាក់ សម្រាប់ស៊ីវិល ឬ សម្រាប់ទាហាន ដែលមាន កំណត់ទុក ក្នុងច្បាប់ខ្មែរ ។

សក្តិ គឺជា « បដិមរូប » (emblème) សម្រាប់មន្ត្រី ឬ អ្នកតំណាងអាជ្ញាធរសាធារណៈ ដែលមាន កំណត់ទុក ក្នុងច្បាប់ ។

គ្រឿងឥស្សរិយយស គឺជាប្រដាប់លំអរផ្សេងៗ ដែលរដ្ឋាភិបាលខ្មែរ បានបង្កើត ទទួលស្គាល់ ជាត្រឹមត្រូវ ។

មាត្រា ៣១៥– ជនណា ធ្វើ ឬ ញុំាងគេ ឲ្យធ្វើ នូវសញ្ញាប័ត្រសាកលវិទ្យាល័យ (diplôme universitaire), វិញ្ញាបនប័ត្រនៃការសិក្សាសាធារណៈ ឬ ឯកជន ( certificat de l' enseignement public ou privé), សំបុត្រជំនួស សំបុត្រអត្រានុកូលដ្ឋាន ( acte de notoriété

tenant lieu d'acte d'Etat Civil ), អត្តសញ្ញាណប័ណ្ណ ( carte d'identité ), សំបុត្រឆ្លងដែន (passeport), សំបុត្រអនុញ្ញាតឲ្យនៅ (permis de séjour), កាតពន្ធខ្លួន ( carte d'impôt personnel) , បង្កាន់ដៃការពន្ធ ( quittance d'impôt ) , សំបុត្របញ្ជាក់ពីសាកេរ្តិ៍ (certificat de notoriété), សំបុត្រទុគ៌តភាព (certificat d'indigence), សំបុត្រពិការ (certificat d' imfirmité), សំបុត្រអនុញ្ញាតឲ្យកាន់កាំភ្លើង (permis d'arme), អត្តសញ្ញាណប័ណ្ណសត្វពាហនៈ (carte d' identité des animaux), កាតពន្ធទូក (carte d'immatriculation d'embarcations), សំបុត្រអនុញ្ញាតឲ្យបើកបរ (permis de conduire) , សៀវភៅកម្មករ (carnet d' ouvrier), សៀវភៅអ្នកបើកបរ (carnet de conducteur) , សៀវភៅអនុញ្ញាតបើកបរដល់រថយន្ត (carnet des autorisations de circulation pour véhicules), ស្លាកត្រាពិនិត្យរថយន្ត (plaques de contrôle pour véhicule), និងលិខិតទាំងអស់ ស្ដីពីអត្តសញ្ញាណរបស់បុគ្គល ដែលអាជ្ញាធរខាងរដ្ឋបាលចេញឲ្យ, បញ្ជីការពិនិត្យពន្ធ (contrôle fiscal) ឬ ប៉ូលិសចរាចរ (police de circulation), ហើយដាក់ក្នុងលិខិតដូចរៀបរាប់មកនេះ, ឱ្យសេចក្ដីមិនត្រឹមត្រូវ, សេចក្ដីក្លែង ឬ សេចក្ដីបំភាន់, ជននោះត្រូវមានទោស មជ្ឈិម ថ្នាក់ទីពីរ ។

អ្នក ដែលប្រើ លិខិតមិនត្រឹមត្រូវ, ក្លែង, បំភាន់បែបនេះ ឬ ដែល

ផុតអាយុកាល (prérimés) ឬ ដែលបដិសេធពេលទៅហើយ, ក៏ត្រូវមាន ទោស ដូចគ្នា ដែរ ។

អ្នកណា គ្មានលិខិត ជាត្រឹមត្រូវ តាមបទបញ្ជា ដែលខ្លួន ត្រូវតែ មាន តាមច្បាប់ប៉ូលិសចរាចរសាធារណៈ ហើយទៀតក៏មាន បំភាន់ អំពី អត្តសញ្ញាណរថយន្ត, បំភាន់ អំពីអត្តសញ្ញាណ នៃកម្មសិទ្ធិករ ឬ អ្នក បើកបរ រថយន្ត, បំភាន់ អំពីលំនៅ ឬ អំពីអាសយដ្ឋាន នៃជនទាំងនេះ អ្នកនោះ ត្រូវមាន ទោស ដូចគ្នា ដែរ ។

ជនណា ប្រើប្រាស់ រថយន្ត ដែលមិនទាន់បាន សេចក្ដីអនុញ្ញាត ផ្សេងៗ ឲ្យ ធ្វើចរាចរ និងលិខិតទាំងឡាយ តាមបទបញ្ជា, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ទោសនេះ នឹងត្រូវយក ទៅផ្ដន្ទា ជាអតិបរមា ទៀត, ប្រសិនបើ លិខិត ដែលយកទៅប្រើនោះ មាន ការក្លែង ដល់សម្ភារៈ ។

កម្មសិទ្ធិករ ណា យក រថយន្ត សម្រាប់ប្រើប្រាស់ ផ្ទាល់ខ្លួន ទៅ ដឹកនាំ ទំនិញ ឬ អ្នកដំណើរ យកឈ្នួល, ដែលខ្លួន គ្មានអនុញ្ញាតពិសេស សម្រាប់យកឈ្នួល ដូច្នេះសោះ, ថ្វីបើ ខ្លួន មាន សេចក្ដីអនុញ្ញាត ឲ្យធ្វើ ចរាចរ និងលិខិត ឯទៀត តាមបទបញ្ជា រួចអស់ហើយ ក៏ដោយ ក៏កម្ម សិទ្ធិករនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ដែរ ។

បើអ្នកបើកបរណា យក រថយន្ត បែបនេះ ទៅដឹក យកឈ្នួល មិន

00222334





ឲ្យ កម្មសិទ្ធិករ នៃយានយន្តនេះ ដឹង ផងទេ, អ្នកបើកបរនោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ ទីមួយ ដែរ ។

មាត្រា ៣១៦- ជនណា ប្រើ លិខិត ដូចមាន ខាងលើនេះ ដែលរាជការ ចេញឲ្យ ទៅឈ្មោះដទៃ ផ្សេងពីឈ្មោះខ្លួន, ជននោះ ត្រូវ ទោសមជ្ឈិម ថ្នាក់ ទីមួយ ។

បើលិខិត ដែលប្រើនោះ មានធ្វើកែខ ដើម្បីឲ្យ គេ ជឿថា លិខិត នោះជារបស់ជនម្នាក់ ផ្សេងពីជន ជាម្ចាស់មែនទែន នៃលិខិត, ជននោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ ទីពីរ ។

មាត្រា ៣១៧- កាលណាបើ ការក្លែងលិខិត ឬការប្រើលិខិតក្លែង នោះ ជាលិខិត ក្នុងផ្លូវការ ដែលគ្មានរៀបរាប់ ក្នុងមាត្រា៣១៥ទេ ឬ ក៏ មានរៀបរាប់ ក្នុងមាត្រា ៣១៥ ដែរ, ហើយអំពើក្លែងនោះ មាន រូបរាងច្បាស់ ជាក្លែងដោយប្លម (contrefaçon), ដោយលុប (suppression), ដោយបញ្ចូល adjonction), ដោយកែខ (altération), នូវអក្សរ, ហត្ថលេខាឬត្រា ឬអំពើក្លែងនោះ មាន រូបច្បាស់ ជាក្លែង ដោយការទេសកម្មបុគ្គល (substitution de personne), ឬ ដោយ សម្មតិបុគ្គល (supposition de personne) និងមាន រូបរាងច្បាស់ ជាក្លែង ដោយប្តឹង មិនស្រប តាម ការណ៍សច្ចៈនោះ, ពិរុទ្ធជន ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ ទីមួយ ។

ក៏ប៉ុន្តែ ការក្លែង លិខិតសាធារណៈ , ក្រៅពីលិខិត ដែលមាន គ្រោងទុក ក្នុងមាត្រា ៣១៥ នោះ , នឹងគាប់ត្រូវទោសប្រកាន់បាន ក៏លុះ តែការក្លែង ឬ ការប្រើលិខិតក្លែងនោះ អាចបណ្ដាល ឲ្យមាន ព្យសនកម្ម ដល់សម្ភារៈ ផង ។

មាត្រា ៣១៨– វិហិង្សា ប្រព្រឹត្ត លើរូប អ្នករាជការ , អ្នក តំណាង អាជ្ញាធរសាធារណៈ , និយោជិត និង ភ្នាក់ងារ នៃក្រុម នានា របស់រាជការសាធារណៈ ក្នុងពេល ដែលអ្នកនេះ កំពុងបំពេញ មុខងារ ឬ ក្នុងឱកាស បំពេញមុខងារ របស់ខ្លួន នោះ , វិរុទ្ធជន ត្រូវ មាន ទោស ដូចតទៅ :

បើ វិហិង្សានោះ មិនបណ្ដាល ឲ្យមាន របួស ទេ , ហើយ កាល ប្រព្រឹត្តនោះ ក៏គ្មាន អាវុធ ឬ គ្រឿងអ្វី ជាជំនួសអាវុធដែរ នោះ , វិរុទ្ធ ជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

បើ វិហិង្សានោះ បានបណ្ដាល ឲ្យមានរបួស ឬ កាលប្រព្រឹត្តនោះ មានប្រើ អាវុធ ផង ឬ មានគ្រឿងអ្វីមួយ ជាជំនួស អាវុធ ផង នោះ , វិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

បើ វិហិង្សានោះ បានបណ្ដាល ឲ្យមាន កាយវិកលកម្ម , ពិការជានិច្ច , ស្លាប់អវយវៈ ណាមួយ ជាស្ថាពរ , វិរុទ្ធជននោះ ត្រូវមាន

ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

បើ វិហិង្សានោះ បានប្រព្រឹត្ត ដោយគ្មានចេតនា បង់ឲ្យ អ្នករងអំពើ ស្លាប់ ទេ, ប៉ុន្តែ អំពើនោះ បណ្ដាល ឲ្យស្លាប់ អ្នករងអំពើ វិញ ឬ បើវិហិង្សានោះ មិនបណ្ដាល ឲ្យស្លាប់ អ្នករងអំពើ ទេ, ប៉ុន្តែ ចេតនា របស់វិរុទ្ធជន, កាលប្រព្រឹត្តនោះ, បង់ ឲ្យអ្នករងអំពើ ស្លាប់, វិរុទ្ធនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

(ព្រះរាជប្រកាសលេខ ៨៧ ចុះថ្ងៃ ២០ - ៥ ១៩៤០ ដែលត្រូវដាក់បញ្ចូលក្នុង មាត្រា ៣១៨ នេះ បានត្រូវលើកយកទៅបញ្ចូល ក្នុងក្រមតុលាការសឹក អស់ហើយ)

មាត្រា ៣១៩- ក្នុងបទប្រមាថ ឬ វិហិង្សា និង ក្នុងបទរំលោភ លើរូបកាយ អ្នកតំណាង អាជ្ញាសាធារណៈ ក្នុងពេល កំពុងធ្វើការ មុខងារ ឬ ក្នុងឱកាស ធ្វើការមុខងារនេះ, ជន ដែលត្រូវទុកថា ជា អ្នកតំណាង អាជ្ញាសាធារណៈ បាន គឺជន ដែលទទួលភារៈ ជា មនុស្សជំនួយ ក្រុមរាជការ ណាមួយ, មួយគ្រា, មួយកាល ។

មាត្រា ៣២០- អតិបរមា នៃទោសមធ្យម ដែលបានសម្ដែង ក្នុងមាត្រា ៣១៨ ខាងលើនេះ ត្រូវតែយកទៅ ផ្ទួនា, កាលណាបើ វិហិង្សានោះ បានប្រព្រឹត្ត ទៅលើរូបកាយ ចៅក្រម ឬ សមាជិកប្រឹក្សា ណាម្នាក់ ក្នុងពេល ដែលចៅក្រមនោះ ឬ សមាជិកនោះ កំពុងនៅ ក្នុង

សវនាការ ឬ កំពុងពិភាក្សា ឬ ក៏ កំពុងស៊ើបសួរ ។

មាត្រា ៣២១– ជនណា មិនប្រតិបត្តិ តាមបទបញ្ជាប៉ូលិស, បទបញ្ជាវិថីបាល, និងបទបញ្ជា ចរាចរ ដែលអាជ្ញាធរ ខាងរដ្ឋបាល បានបញ្ញត្តិ ដូច តទៅនេះ, ជននោះ ត្រូវមាន ទោសលហុ :

១.– ជន ដែលដុតផាវ ឬ មៀវគ្រប់យ៉ាង, គ្មានអនុញ្ញាត ពីអាជ្ញាធរ ក្នុងឃុំ ជាមុន ;

២.– ជន ដែលមិនសំអាត លំនៅ របស់ខ្លួន ព្រមទាំងផ្លូវ, ប្រក ល្ហក, ឬ ប្រឡាយទឹក ដែលជាភារៈ លើអ្នកស្រុក, អ្នកភូមិនោះ ;

៣.– ជន ដែលធ្វើឲ្យទើសទែង ផ្លូវសាធារណៈ, ជន ដែលធ្វើ មិនឲ្យមាន ឬ ធ្វើឲ្យបង្អៀតបង្អល់ សេរីភាព ឬ សន្តិសុខ នៃចរាចរ សា-ធារណៈ ដោយឥតមាន ប្រយោជន៍ អ្វីសោះ ; ជនដែលបរ ឬ ប្រើ គេ ឲ្យបរ រទេះ ទឹមសត្វ ហើយមិនបង់ ខ្សែបន្ទោល ខាងឆ្វេង ហើយទឹង ខ្សែរបាំង ពីខាងឆ្វេងសត្វ ។

៣.– ស្ដួន ( ព្រះរាជប្រកាសលេខ ៣២១ ចុះថ្ងៃ ១០–០១–១៩៣៦ ) ត្រូវយក ទោស យ៉ាងធ្ងន់បំផុត មកអនុវត្ត ជាដរាប, ជនណា ប្រព្រឹត្តល្មើស ទីងសេចក្តីបញ្ញត្តិ ដែលស្តី អំពីពន្លឺភ្លើង នៅរទេះ, ស្លាក សម្រាប់ពិនិត្យរទេះ, ទទឹង រទេះ, ទទឹង បន្ទុកទំនិញ ដែលនៅ លើ

រទេះ, ឈរដឹកនាំជាពិសេស, ល្បឿន នៃរថយន្ត, រថអូស និង រទេះ សណ្តោង, ហ្វ្រាំង (Freins) ។

៤.- ជនដែលលែង សត្វព្រៃ ឬ សត្វចង្រៃ ឬ សត្វស្រុក សាហាវ ដែលខ្លួន ចិញ្ចឹម ឲ្យដើរ ពាសកល ពាសកាល, ជន ដែលដោះលែង គោ, ក្របី, សេះ ឲ្យដើរ រហេត រហូត ឬ ឲ្យដើររកស៊ី ឬ ប្រស៊ី នៅ លើផ្លូវសាធារណៈ ឬ ទី ជារណប ផ្លូវសាធារណៈ ឬ ជន ដែលលែង សត្វពាហនៈ ឲ្យដើរ តាមផ្លូវសាធារណៈ ដោយឥតឃ្វាល ;

៥.- ជន ដែលទិញ, ដែលទទួលទុក ឬ ដែលជួល គោ, ក្របី, ដំរី, សេះ ហើយមិនទារ លិខិត ជាត្រឹមត្រូវ ពីម្ចាស់ដើម ឲ្យបាន ច្បាស់ថា អ្នកលក់នោះ ជាកម្មសិទ្ធិករ នៃសត្វទាំងនោះ មែន, ឬ កាល បើ លក់ សត្វទាំងនោះ ទៅវិញ, ក៏ធ្វេសប្រហែស មិនបាន ឲ្យមន្ត្រី ឃុំ បញ្ជាក់ លិខិតនោះ ឲ្យត្រឹមត្រូវ តាមច្បាប់ ;

៦.- ជន ដែលទិញ គោ, ក្របី, ដំរី, សេះ ហើយ ធ្វេស មិន ទៅប្តឹង ពជការ មុខក្រសួង ឲ្យចុះបញ្ជី ក្នុងរយៈវេលា ប្រាំបីថ្ងៃ ;

៧.- ជន ដែលមិនប្រតិបត្តិ តាមបទបញ្ញា ស្តីពីសត្តឃាត និង លក់សាច់ ៗ សាច់ ដែលលក់នោះ ត្រូវរឹបអូស ;

៨.- ជន ដែលប្រើ ជាសាធារណៈ នូវរង្វាស់រង្វាល់ និង ជញ្ជីង ដោយមិនប្រតិបត្តិ តាមបទបញ្ញា ក្នុងរឿងនេះ ៗ ឧបករណ៍ទាំងនេះ

00222339

D99/3/3



ក៏ត្រូវរឹបអូស ដែរ ។

ជនណា ប្រព្រឹត្តល្មើស ឬ មិនស្រប តាមបទបញ្ជា របស់អាជ្ញាធរ ខាងវេជ្ជបាល ដែលស្តីពីសុខភាព នៃសាធារណជន ដូចមានខាងក្រោម នេះ ជាដើម, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ ទីមួយ គឺ :-

១- ជនដែលខានប្តឹង ឬ ប្រកែក មិនព្រមប្តឹង រាជការ អំពីជម្ងឺឆ្លង ដែលកើតមាន ក្នុងស្រុកភូមិ របស់ខ្លួន ;

២- ជនដែលលាក់, ដែលដឹក, ដែលកប់ ឬ ដែលដុត ខ្មោច ដោយឥតសុំ អនុញ្ញាត ជាមុន ។ ករណីនេះស្តី ចំពោះតែសព ដែល មិនចូល ក្នុងបទបញ្ញត្តិ នៃមាត្រា ៣៤១ ប៉ុណ្ណោះ ទេ ;

៣- ជន ដែលបោះចោល ឬ ដាក់ទុក នូវរបស់អ្វីមួយ ដែល អាចបំផ្លាញ សុខភាព សាធារណជន ក្រៅពីកន្លែង ដែលសម្រាប់ ចោល ឬ សម្រាប់ដាក់ទុក របស់នោះ ;

៤- ជន ដែលឥតច្បាប់អនុញ្ញាត ពីរាជការ ជាមុន ហើយបែក ជាឡូត៍ ឬ សង់គ្រឹហស្ថានថ្មី លើដី ដែលរាជការ រៀបចំ, ពង្រីក ឬ ទុក ប្រើការ ជាសាធារណៈ ឬ លើដី ដែលនៅជុំវិញ ដីរាជការនេះ តិចជាង ប្រាំរយម៉ែត្រ ពីព្រំដីរាជការ ;

៥- ជន ដែលបែកដី ដូចមាន ពោលមក ក្នុងកថាខណ្ឌ ខាងលើនេះ ជាឡូត៍ ឬ សង់សំណង់ មិនឲ្យស្រប តាមសេចក្តីអនុញ្ញាត ;

៦- ជន ដែលពកដការ បានដាក់កំហិត ឲ្យកែប្រែហើយ នៅតែ មិនកែប្រែ ឬ ប្រកែក មិនព្រមកែប្រែ, ឲ្យមាន សភាព ដូចដើមវិញ, នូវដី ដែលខ្លួន បែក ជាឡូត៍ ឬ សង់ គេហដ្ឋាន ឥត អនុញ្ញាត ពីពកដការ ជាមុន ឬ ឲ្យខុស ពីសេចក្ដីអនុញ្ញាត ឬ ឲ្យខុស ពីបង្គាប់ ដាក់កំហិត របស់ពកដការនោះ;

៧- ជន ដែលមិនគោរព បរិហារភាព នៃអចលវត្ថុ ដែល ពកដការ អាយ័តមក ដើម្បីជាប្រយោជន៍ ដល់សន្តិសុខ, ដល់អនាម័យ ដល់ចរាចរ ឬ ដល់សោភណភាព;

៨- ជន ដែលធ្វើ ឲ្យខាន ដោយចេតនា ដល់កិច្ចការ របស់ អាជ្ញាធរ ដែលធ្វើ ដើម្បីរក្សា សុខភាព របស់សាធារណជន;

៩- ជន ដែលអាជ្ញាធរ ខាងរដ្ឋបាល ដាក់កំណត់វេលា ឲ្យ រៀបចំ អចលវត្ថុ, គេហដ្ឋាន ទិង លំនៅ របស់ខ្លួន ដើម្បីជាប្រយោជន៍ ដល់សុខភាព តាមយោបល់ របស់គណកម្មការ ខាងសុខភាព ហើយប្រកែក ឬ ខានប្រតិបត្តិ តាមបង្គាប់នេះ ;

១០- ជន ដែលអាជ្ញាធរ ខាងរដ្ឋបាល បានចេញ សេចក្ដីសម្រេច តាមយោបល់ របស់គណកម្មការ ខាងសុខភាព ហាម មិនឲ្យនៅលើ អចលវត្ថុ ឬ គេហដ្ឋាន ជារបស់ខ្លួន ហើយនៅតែនៅ តទៅទៀត ។

ក្នុងករណីទាំងពួងនេះ , សោហ៊ុយ ដែលរៀបចំ ឲ្យមាន ជាសភាព តាមត្រឹមត្រូវទៅវិញនោះ ជាភារៈ របស់ទណ្ឌិត ។

( ព្រះរាជក្រមលេខ ៦-បរ. ចុះថ្ងៃ ១-៣-៦០ បន្ថែមបទបញ្ញត្តិ ដូចតទៅនេះ : )

«ក្នុងករណី មានអន្តរាយ បណ្តាលមក ពីសំណង់ ឥតអនុញ្ញាត ឬ ឥតគោរពបញ្ញាអនាម័យ ឬ សន្តិភាព , កម្មសិទ្ធិករ ឬ ម្ចាស់សំណង់ទាំងនោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ , ប្រសិនបើ អន្តរាយនេះ កើតមក ពីអ្នកជួល សំណង់នោះ ឬ មក ពីអ្នក ដែល នៅ ក្នុងគេហស្ថាន របស់កម្មសិទ្ធិករ និង ម្ចាស់សំណង់នោះ ។

ក្នុងករណី ដែលត្រូវមាន ទោសនោះ , កម្មសិទ្ធិករ និងម្ចាស់សំណង់ ត្រូវទទួលខុសត្រូវ ជាផ្លូវរដ្ឋប្បវេណី រួមរួមគ្នា នឹងអ្នកប្រព្រឹត្ត បទ អន្តរាយ ដែលមាន កំហុសនេះ ទៀត » ។

មាត្រា ៣២២ – ច្បាប់ ហាម មិនឲ្យធ្វើ , មិនឲ្យនាំចូល , មិនឲ្យជួញ , មិនឲ្យចែក នូវកាំភ្លើង , ទោះជាកាំភ្លើង បាញ់ ដោយ កម្លាំងទឹកក្តី , បាញ់ ដោយកម្លាំងខ្យល់ក្តី , នូវគ្រាប់ និង គ្រឿងរំសេវ ឬ ឧបករណ៍ ខាងផ្ទុះ ។

បទល្មើសនេះ ត្រូវផ្តន្ទា ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ក៏ប៉ុន្តែ ការធ្វើ ការុង ឬ គ្រាប់រំសេវ អ្វីមួយ សម្រាប់ប្រើ ផ្ទាល់

00222342





ខ្លួន, អ្នកធ្វើ ត្រូវមានទោស តាមបញ្ញត្តិមាត្រា ៣២៦ ទៅវិញ ។

មាត្រា ៣២៣ - ច្បាប់ហាមមិនឲ្យធ្វើ, មិនឲ្យនាំចូល, មិនឲ្យបែក នូវអាវុធ មានមុខមុត មានប្រភេទដូចអាវុធ អន្ទ័ត, អាវុធសម្ងាត់ ដូចជាដាវស្រោម, កាំបិតបុកគោ, កាំបិតស្នៀត, កាំបិតកៃ, ញៀក, ស្នាប់ដៃ ជាដើម ។ ការប្រព្រឹត្តល្មើស នឹងគំហាត់នេះ ត្រូវផ្តន្ទាទោសមធ្យម ថ្នាក់ទីបី ។

បើនឹងផ្តន្ទាអនុទោស ត្រូវស្ពាន បន្ថយសិទ្ធិស៊ីវិល នឹងគំហាត់លំនៅ ទៀតក៏បាន ។

បើធ្វើអាវុធណាមួយ ដូចខាងលើនេះ សម្រាប់ប្រើផ្ទាល់ខ្លួន, អ្នកធ្វើនោះនឹងត្រូវផ្តន្ទាទោស តាមមាត្រា ៣២៤ ទៅវិញ ។

មាត្រា ៣២៦ - ជនណា មិនមាន សេចក្តីអនុញ្ញាត តាមបទបញ្ញា ដូចមាន លក្ខខណ្ឌ ក្នុងបទបញ្ញា របស់អាជ្ញាធរ សាធារណៈទេ, ជននោះ ត្រូវហាម មិនឲ្យមាន, មិនឲ្យកាន់កាប់, មិនឲ្យរក្សាទុក ឬ កាន់, ស្ពាយ នូវកាំភ្លើងបាញ់ នឹងរំសេវ, បាញ់ នឹងកម្លាំងខ្យល់ ព្រមទាំងគ្រាប់រំសេវទាំងឡាយ ។

ការល្មើសនេះ ត្រូវផ្តន្ទា ទោសមធ្យម ថ្នាក់ទីបី ។

ជនណា មានកំហុស ជាបានលក់, បានធ្វើអនុប្បទាន, បានជួ...

00222343



ឬ បានធ្វើ អាវុធ ឬ គ្រាប់រំសេវ ដែលខ្លួន មានសិទ្ធិ កាន់កាប់ ទៅឲ្យមនុស្ស អ្នកគ្មាន សិទ្ធិអនុញ្ញាត តាមបទបញ្ញា, ជននោះ ត្រូវមានទោស ដូចជាបានសមគំនិត ក្នុងទោសកម្ម ដូចមានសំដែង ជាពិសេស ខាងលើនេះ ដែរ ។

មាត្រា ៣២៥ – ( ព្រះរាជក្រមលេខ ៣៩១–នស.ចុះថ្ងៃ ១២-៥-១៩៥៣) មិនឲ្យកាន់ អាវុធ មានមុខមុត ឬ អាវុធបន្ទប់, ដំបង, ព្រនង់, ផ្គោង, មោង, ស្នាប់ដៃ ហើយនឹងអាវុធ ឯទៀតៗ បែបៗ គ្នា និងមិនឲ្យដឹកនាំនូវគ្រឿងសស្ត្រាវុធ ដូចខាងលើ ដោយឥតហេតុ ជាធម្មានុរូប ។

ជនណា ដើរ តាមផ្លូវសាធារណៈ ហើយមានជាប់ គ្រឿងសស្ត្រាវុធសម្ងាត់ ឬ សម្រាប់ប្រហារ ឬ ដឹកនាំ គ្រឿងសស្ត្រាវុធនោះ, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៣២៦ – អ្នកមានច្បាប់អនុញ្ញាត ឲ្យកាន់ប្រើ កាំភ្លើង ដែលរាជការ បានចេញឲ្យ ឥតបង់ថ្លៃ ឬ មានបង់ថ្លៃ ហើយទិញ ឬ រក គ្រាប់រំសេវ បាន ដោយឥតអនុញ្ញាតច្បាប់, អ្នកនោះត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

មិនតែប៉ុណ្ណោះ នឹងផុតហូតយក ច្បាប់អនុញ្ញាត ឲ្យកាន់កាំភ្លើង

00222344





មកវិញ ទៀត ក៏បាន ។

ក្នុងករណីលក់ ឬ ដូរ កាំភ្លើង មិនបានជូនដឹង រាជការ ជាមុន ក៏ ត្រូវមាន ទោស ដូចគ្នាដែរ ។

មាត្រា ៣២៧- ជនណា ល្មើស នឹងបទបញ្ញត្តិ ស្ដីពីច្បាប់ កាន់ កាំភ្លើង ដែលរាជការ បេញឱ្យ ឥតបង់ថ្លៃ ឬ មានបង់ថ្លៃ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។ មិនតែប៉ុណ្ណោះ បើនឹងដកហូត ច្បាប់អនុញ្ញាត ឱ្យកាន់ប្រើ កាំភ្លើង ទៀតផង ក៏បាន ។

អំពើល្មើស នឹងបទបញ្ញត្តិ ស្ដីពីច្បាប់កាន់ កាំភ្លើងនោះ មានយ៉ាងនេះ ជាដើម: មិន ផ្ដូរ ជាថ្មី នូវច្បាប់ កាន់ កាំភ្លើង, មិនយក ច្បាប់កាំភ្លើង ដែលបេញឱ្យទទេ ឬ បង់ថ្លៃ ទៅចុះ ទិដ្ឋាការ តាមកាលិក, មិនប្ដឹង ពីបាត់កាំភ្លើង គ្រាប់រំសេវ, ច្បាប់ កាន់ កាំភ្លើង; មិនជូន ទៅរាជការ នូវកាំភ្លើង, គ្រាប់, រំសេវ, នឹងច្បាប់ កាន់, កាលណាបើ ច្បាប់នេះ ត្រូវផុត អាយុកាល ឬ ដែលរាជការ ត្រូវដកហូតយកវិញ ឬ ក៏ម្ចាស់ កាំភ្លើង អនិច្ចកម្ម ឬ មួយ បាត់ខ្លួន ។

មាត្រា ៣២៨- ក្រោយពេល ដែលរាជការ ដកហូត ឬ បញ្ឈប់ មិនឱ្យកាន់ប្រើ ច្បាប់កាំភ្លើង ដែលខ្លួន ជាម្ចាស់ច្បាប់ នោះ ទៅហើយៗ សាមីខ្លួន បានទុក កាំភ្លើងនោះ ឱ្យហួស ពីរយៈវេលា

00222345





ប្រាំបីថ្ងៃ ឡើងទៅ សាមីខ្លួននោះ ត្រូវមាន ទោស តាមបទបញ្ញត្តិ ដែលអនុវត្ត ចំពោះអ្នកមាន កាំភ្លើង ឥតច្បាប់ ។

ការមាន កាំភ្លើងច្រើន ហើយមាន ច្បាប់ អនុញ្ញាត តែមួយ ឬ មាន គ្រាប់រំសេវច្រើន លើស ពីចំនួន ដែលច្បាប់ អនុញ្ញាត, ត្រូវ មាន ទោសមធ្យម ថ្នាក់ទីមួយ, ហើយទឹងត្រូវ ដកហូតយក ច្បាប់ អនុញ្ញាត មកវិញ ផង ក៏បាន ។

មាត្រា ៣២៩– ការរើចេញ មិនស្តាប់ បង្គាប់ ជានិត្យានុកូល របស់អាជ្ញាធរ ជាធម្មានុរូប, ប៉ុន្តែ គ្មាន ធ្វើហិង្សា, គ្មានប្រឆាំង ជាសកម្ម ទេ, ត្រូវផ្តន្ទា ទោស ជាលហុ ។

បង្គាប់ ដែលទុក ជានិត្យានុកូលនោះ គឺបង្គាប់ ដែលអ្នកកាជតា ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈ បានបង្គាប់ ក្នុងព្រំដែន នៃ មុខងារ របស់ខ្លួន ដើម្បីការរៀបរយ សាធារណៈ ឬ ដើម្បីបំរើ កិច្ចការសាធារណៈ ដែលខ្លួន អាជ្ញាធរនោះ ត្រូវទទួល ភារៈខុសត្រូវ ឬ ត្រូវជានាយក ឬ ជាអនុរក្ស លើកិច្ចការនោះ ។

មាត្រា ៣៣០– ជនណា មានពិរុទ្ធ ជាមានកំហុស ព្រោះ កៀសខ្លួន, ជននោះ ត្រូវមាន ទោសមធ្យម ថ្នាក់ទីមួយ ។ ដែលហៅ

ជា កំហុស ព្រោះភៀសខ្លួននោះ គឺការរឹងទទឹង មិនព្រមឈប់ តាមបង្គាប់ ដែលឲ្យឈប់ក្តី, មិនប្រាប់ អត្តសញ្ញាណ និង មិនស្ម័គ្រជួយយកអាសា តាមយថាហេតុក្តី, មិនស្ម័គ្រចិត្ត ឋិតឈប់ ទោះតែមានបង្គាប់ឲ្យឈប់ ក៏ដោយក្តី, មិនជំពប កជការ និង មិនយកអាសា ជាយថាហេតុ នៅពេល ដែលមាន គ្រោះថ្នាក់ បណ្តាលឡើង អំពីសត្វពាហនៈ ដែលខ្លួន ដឹកនាំ, ពីយានជំនិះ ដែលខ្លួន បើកបរ, ទោះបីគ្រោះថ្នាក់នោះ គ្មានកំហុស ពីខ្លួនឯង ឬ ពីអ្នកបើកបរ ក៏ដោយ ហើយបើទុកជា គ្រោះថ្នាក់នោះ ខ្លួន មិនត្រូវទទួល ខុសត្រូវ ពីបទព្រហ្មទណ្ឌ ឬ ពីបទស៊ីវិល ក៏ដោយ ។

កាលបើ កំហុសព្រោះភៀសខ្លួននេះ បានប្រព្រឹត្ត បន្ទាប់ពីគ្រោះថ្នាក់ ដែលបណ្តាល ឲ្យស្លាប់មនុស្ស ផងនោះ, វិរុទ្ធជន ត្រូវមានទោសមធ្យម ថ្នាក់ទីពីរ ។

បទបញ្ញត្តិ នៃមាត្រា ៨២ និង ៨៤ អាចយកទៅអនុវត្ត លើជនជានាយចៅហ្វាយ លើអ្នកបើកបរ បាន, ទោះជានាយចៅហ្វាយ ជានិច្ចក្តី, ជានាយចៅហ្វាយ មួយពេល មួយកាលក្តី, មួយខណៈក្តី, កាលណាបើ មានតិកតាងថា ជន ជានាយចៅហ្វាយនោះ បានបង្គាប់ថាមិនឲ្យ អ្នកបើកបរ ឈប់ ។

ទោស ដែលផ្តន្ទា បទកំហុសព្រោះភៀសខ្លួននេះ មិនមែន ជា

00222347

D99/3/3



ឧបសគ្គមួយ នាំឲ្យខានផ្ដន្ទាទោស ពីបទល្មើស ឲ្យមានរបួស និង មនុស្សឃាត ដោយឥតចេតនា ដូចមានសម្ដែង ក្នុងមាត្រា ៤៨៨ និង ៥០២ នោះទេ ។

មាត្រា ៣៣១- ត្រូវផ្ដន្ទាទោសលហុ ជាអតិបរមា ៖

១- ជនណា ដែលអាចជួយបាន ហើយប្រកែក មិនព្រមជួយ តាមសេចក្ដីឈ្លៀស របស់អាជ្ញាធរ ក្នុងពេល អាសន្ន ដូចជាមាន ទឹកជំនន់ធំពេក ក្ដី, អគ្គិភ័យ ក្ដី, នាវា លិច ក្ដី, ចោរលួច ដោយក្លាហាន ក្ដី ឬ ចោរប្លន់ ក្ដី, គ្រោះថ្នាក់យ៉ាងធំ ក្ដី ប្រតិបត្តិ កិច្ចការតុលាការ ឬ ដេញ តាមមនុស្ស ទុច្ចរិតក្ដី ។

២- ជនណា ត្រូវវេន យាមល្បាត ហើយមិនប្រតិបត្តិ តាមកំណែន ដោយឥតហេតុ ជាគប្បី ឲ្យសន្ដោសបាន ។

មាត្រា ៣៣២- មាត្រា ៣៣៣- មាត្រាទាំងពីរនេះ សម្ដែងពីទាហានបោះបង់ ចោល ក្រសួងខ្លួន ។ ប៉ុន្តែមាត្រាទាំងនេះ បានដាក់បញ្ចូល ក្នុងព្រះរាជក្រមលេខ ៤២ ន.ស. ចុះថ្ងៃ ២១ កញ្ញា ១៩៥៥ ដែលជា ក្រមតុលាការសឹកទៅហើយ ។

មាត្រា ៣៣៤- ជនណា មានដីកា កោះហៅ ដោយទៀង ទាត់ ឲ្យទៅធ្វើសាក្សី ចំពោះមុខតុលាការ, ហើយពុំបានទៅ តាមកំ

00222348





ណោះ ក្នុងរឿងនោះ, ជននោះត្រូវមាន ទោសជាលហុ ។

ចៅក្រម ដែលបានកោះហៅ សាក្សីទាំងនោះ អាចនឹងបង្គាប់ ឲ្យ កងកម្លាំង សាធារណៈ នាំ សាក្សីនោះ មកឲ្យខ្លួន ក៏បាន ។ សេចក្ដីសម្រេចនេះ ព្រមទាំងទោសលហុនោះ ត្រូវកាត់សេចក្ដី ដោយដីកា (ordonnance) របស់ចៅក្រម ជាម្ចាស់ដីកាកោះ ដែលសាក្សី មិនប្រតិបត្តិតាមនោះ, ចៅក្រមនេះ មិនចាំបាច់ ប្រើ បែបបៀប ចោទ ប្រកាន់ ផ្សេង ៗ ដូចម្ដេច ទៀតទេ ។ ឯខណ្ឌិត ក៏គ្មានអំណាច នឹង ប្ដឹងតវ៉ា ពីដីកាបង្គាប់នោះ បានដែរ, ប៉ុន្តែ ចៅក្រម នឹងបន្ធូរបន្ថយ ទោស ដែលបានសម្រេច នោះវិញ ក៏បាន, បើសាក្សីនោះ មាន កស្តុតាង គួរសន្ដោស អំពីការយឺតយូរ ឬ ការខានចូលខ្លួនមកនោះ ។

មាត្រា ៣៣៤– សាក្សីទុច្ចរិត ដែលបានឆ្លើយ ជូនតុលាការ ដោយចង់ជួយ មនុស្សត្រូវចោទ ឬ គូភាគី ឬ ក៏ ដោយចង់ ចង់ព្យាបាទ ជនទាំងនេះ, ត្រូវមាន ទោស ដូចតទៅនេះ :

ក្នុងបទឧក្រិដ្ឋ, សាក្សី ទុច្ចរិតនោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។ ប៉ុន្តែ បើ ចោទិតនោះ មាន ទោសធ្ងន់ ជាងនេះ ទៅ ទៀត, សាក្សីទុច្ចរិតនោះ ត្រូវមាន ទោសធ្ងន់ដូចគ្នា នឹងចោទិត ដែរ ។

ក្នុងបទមជ្ឈិម, សាក្សីទុច្ចរិត ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

00222349





ក្នុងបទលហុ, សាក្សីទុច្ចរិត ត្រូវមានទោសមជ្ឈិម ថ្នាក់ទីមួយ ។

ក្នុងបទស៊ីវិល សាក្សីទុច្ចរិត ត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ ។

អាចចាត់ទុក ជាសាក្សី ទុច្ចរិតបាន, សាក្សីណា ដែលបានជូន ពត៌មានខុស ដល់តុលាការ ក្រោយ ដែលបានស្បថរួចហើយ, ប្រសិនបើ ចម្លើយនោះ ពិតជាទុច្ចរិត មែន, ចៅក្រម បានព្រមាន ឲ្យដក ចម្លើយ ទុច្ចរិត ចេញទៀត, តែ សាក្សីនោះ នៅតែប្រកែក មិនព្រមដក ។

ជន ដែលជាប់ ជាញាតិ នឹងចោទក ឬ មនុស្សត្រូវចោទ ដូចមាន កំណត់ ក្នុងលក្ខខណ្ឌ នៃមាត្រា ៣៤០ នោះ នឹងចោទប្រកាន់ ពីបទ ធ្វើសាក្សី ទុច្ចរិត ពុំបានឡើយ, បើកាលណា សក្ខីភាពទុច្ចរិតនោះ ឆ្លើយយោង ចោទក ឬ មនុស្សត្រូវចោទ ដែលជាញាតិនឹងខ្លួន ។

មាត្រា ៣៣៦- បើ មាន ភស្តុតាង ថា សាក្សីទុច្ចរិតនេះ លំអៀង ដោយបាន សំណូក ឬ បានទទួល ពាក្យប្ដេជ្ញា អ្វីមួយនោះ, សាក្សីទុច្ចរិត ហើយនឹង អ្នកបញ្ចុះសាក្សី ត្រូវមាន ទោសមជ្ឈិម ដែល មានបញ្ញត្តិ ក្នុងមាត្រាមុននេះ ដល់អតិបរមា ។

បើ មានភស្តុតាង ថា ជនណាម្នាក់ បានរក ឬ បំណងនឹងរក សាក្សី ឲ្យឆ្លើយយោង ខ្លួន ឬ យោង អ្នកដទៃ, ខ្លួន នឹងឲ្យ សំណូក ឬ ពាក្យប្ដេជ្ញាអ្វីមួយ , ជននោះ ត្រូវមាន ទោសមជ្ឈិម ដូចគ្នាដែរ, ទោះ

បើ សេចក្ដីបំណាច់ ទឹងបញ្ចេះ សាក្សីនោះ មិនបានសម្រេច ក៏ដោយ ។

មាត្រា ៣៣៧– បើសាក្សី បានជូន សំអាងថា ខ្លួន បានធ្វើ សាក្សីខុសពិតនោះ ព្រោះមាន អ្នកដទៃ កំហែងបន្លំ ឬ គំរាមខ្លួន, សាក្សីនោះ ត្រូវមាន ទោសមជ្ឈិម ជាអប្បបរមា ដែលមានចែង ក្នុងច្បាប់នេះ; ឯអ្នក ដែលកំហែងបន្លំ ឬ គំរាម គេ ត្រូវមាន ទោស ជាអតិបរមា ។

មាត្រា ៣៣៨– ជនណា បានឃើញ ហេតុការណ៍ ជាឧក្រិដ្ឋ ឬ ជាមជ្ឈិម ឬ បានដឹង នូវអំពើល្មើស របស់គេ, ហើយមិនឲ្យការណ៍ ដល់ អាជ្ញាធរ ឬ មិនព្រមប្រាប់ ការណ៍ណា ជាចាំបាច់ ដែលខ្លួន បានដឹង ដើម្បីឲ្យបានតាម ឬ ឲ្យឃាត់ ពិនិត្យ បទល្មើស, ឲ្យឃាត់ស៊ើបគេ ឬ ចាប់ខ្លួន, វិរុទ្ធជន ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៣៣៩– បទបញ្ញត្តិ ក្នុងមាត្រាខាងលើនេះ មិនត្រូវយក ទៅអនុវត្ត លើជន ដែលស្ងៀម ព្រោះខ្លួន ជាប់ជាញាតិ នឹងចារី ឬ នឹងអ្នកសមគំនិត ណាមួយទេ, តែលក្ខខណ្ឌ នៃញាតិ នោះ ត្រូវឲ្យ ស្រប តាមជាន់ថ្នាក់ ដូចដែលបានបញ្ជាក់ ត្រង់កថាខណ្ឌទី ២ នៃមាត្រា ៣៤០ នេះផង ។

មាត្រា ៣៤០– ថ្មី (ព្រះរាជក្រមលេខ ៩២១-ន ស ចុះថ្ងៃ ២៣-១២-១៩៥៤)

ត្រូវធ្វើទោសមជ្ឈិម ថ្នាក់ទីពីរ ជនណា ដោយចេតនា បានទទួល ខ្លួនឯងក្តី, ឲ្យអ្នកដទៃ ទទួល ក្តី, នូវមនុស្សណាម្នាក់ ដែលខ្លួនបានដឹងថា មនុស្សនោះ បានប្រព្រឹត្ត បទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

បទបញ្ញត្តិនេះ មិនត្រូវអនុវត្តទៅ លើសហព័ទ្ធទេ ទោះបីសហព័ទ្ធនោះ លែងលះគ្នា ក៏ដោយ, ទៅលើបុព្វញាតិ ឬ បច្ឆាញាតិ មានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម របស់មនុស្សត្រូវចោទទេ, ទៅលើបុព្វញាតិ ឬ បច្ឆាញាតិ មានខាន់ស្លា ឥតខាន់ស្លា, ឬ ចិញ្ចឹម នៃសហព័ទ្ធ របស់មនុស្សត្រូវចោទទេ , ទៅលើបងប្អូនបង្កើត , បងប្អូនរួម ឪពុក , បងប្អូនរួម ម្តាយ ឬ បងប្អូនចិញ្ចឹម របស់មនុស្សត្រូវចោទទេ , ទៅលើមា មីង ទីង ក្មួយរបស់មនុស្សត្រូវចោទ ទេ , ទៅលើសាច់ថ្លៃបង្កើត ឬ ក្មួយថ្លៃ របស់មនុស្សត្រូវចោទ ទេ , ប្រសិនបើ មនុស្សត្រូវចោទនេះ ជាវិរុទ្ធជន ក្នុងបទល្មើស ជាមជ្ឈិម ។

ដែលហៅថា ទទួលមនុស្សទុច្ចរិត គឺទទួល លាក់បំពួន មនុស្ស ឬ អត្តសញ្ញាណ របស់មនុស្សនោះ មិនឲ្យគេស្គាល់ ។

ត្រូវធ្វើទោស ដូចគ្នា ហើយនឹង ត្រូវអនុទោស ត្រង់ស្តាន បន្ថយ សិទ្ធិស៊ីវិល និង គំហាត់លំនៅ ថែមទៀតក៏បាន :

១– ជនណា ចូល ឬ បំណាន់ចូល ក្នុងប្រទេសកម្ពុជា , ជនណា ចេញ ឬ បំណាន់ចេញ ពីប្រទេសកម្ពុជា ឥតមាន លិខិតឆ្លងដែន ដែល

អាជ្ញាធរខ្មែរ បានចុះ ទិដ្ឋាការ ជាត្រឹមត្រូវ តាមមុខក្រសួង ក្តី ឬ ឥតមាន សេចក្តីអនុញ្ញាត ជាត្រឹមត្រូវ ពីអាជ្ញាធរខាងលើនេះក្តី ។

២– ជនណា នាំចូល ឬ បំណងនឹងនាំចូល ក្នុងប្រទេសកម្ពុជា នូវ ឈ្មោះណាម្នាក់ ឬ ច្រើននាក់ ទោះបីឈ្មោះនោះ មានអាយុ និងភេទ ដូចម្តេចក៏ដោយ ដែលគ្មានលិខិត ដូចបានត្រាទុក នៅវគ្គទីមួយនេះទេ ។ ប៉ុន្តែ ជននេះ មិនត្រូវមាន ទោស ទេ, ប្រសិនបើ ឈ្មោះ ដែលខ្លួន នាំចូលមកនោះ ត្រូវជាញាតិ ដូចពណ៌នា ខាងលើនេះ ។

មាត្រា ៣៤១– ជនណា ទទួលទុក ឬ លាក់ សាកសព ដែលស្លាប់ ដោយគេ សម្លាប់, ដោយគេ បំពុល ឬ ដោយគេ ធ្វើ វិហិង្សា, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ, ប្រសិនបើ ជននេះ មិនបាន ត្រូវទោស ពីសមគំនិត ក្នុងបទសម្លាប់នេះទេ ។

ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ដូចគ្នា, ជនណា លាក់ ត្រឹមតែហេតុ ដែលបណ្តាល ឲ្យស្លាប់ ដល់មនុស្ស នោះ ។

មាត្រា ៣៤២– ជនណា បានប្រទះឃើញ ខ្មោចមនុស្ស ហើយ មិនទៅប្តឹង រាជការ, ជននោះ ត្រូវមាន ទោសលហុ ។

មាត្រា ៣៤៣– អ្នកណា មិនប្រតិបត្តិ តាមមាត្រា៥៥ ក្រម

00222353





រដ្ឋប្បវេណី ដែលស្ដី ថាត្រូវតែ ជូន មន្ត្រីអត្រានុកូលដ្ឋាន ជាកានពុំកិច្ច អំពីមរណៈភាព ក្នុងរយៈវេលា បីថ្ងៃ, គិតពីថ្ងៃមរណៈ ឬ ពីថ្ងៃដែលខ្លួន បានប្រទះឃើញ ខ្មោចមនុស្ស, អ្នកនោះ ត្រូវមានទោស ដូចមានសំដែង ក្នុងមាត្រា ខាងលើ ដែរ ។

មាត្រា៣៤៤- អ្នកណា យក សេចក្ដីខុស ទៅជូន មន្ត្រីអត្រានុកូលដ្ឋាន, អ្នកនោះ ត្រូវមាន ទោស តាមបញ្ញត្តិ មាត្រា៤៥ ក្រមរដ្ឋប្បវេណី, ប៉ុន្តែបើ ការបំប្លែង ចាកសេចក្ដីពិតនោះ នាំបណ្ដាល ឲ្យមាន ព្យសនកម្ម ដល់សម្ភារៈផង, អ្នកនោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទី មួយ ដូចមានសំដែង ក្នុងមាត្រា៣១៧ ។

មាត្រា៣៤៥- ជនណា ហែក ដោយចេតនា នូវស្លាកល័ក្ខ ដែលគេ បិទ ជាត្រឹមត្រូវហើយ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។ ប្រសិនបើ ស្លាកល័ក្ខនោះ ហែក ដោយអ្នកបិទមិនចុះប្រសប់ ឬ ដោយ មិន រក់ប្រយ័ត្ន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា៣៤៦- បើមានពិរុទ្ធថា ឆ្មាំ បានហែក, បក ស្លាកល័ក្ខនោះ ដោយខ្លួនឯង, ឆ្មាំនោះ ត្រូវមាន ទោសដូច ខាងលើ ជា អតិបរមា ។

មាត្រា ៣៤៧– ការយកបាត់, ការបំផ្លាញ នូវលិខិតផ្សេងៗ គ្រប់ប្រភេទ ដែលមានទុក ក្នុងឯកសារដ្ឋាន ឬ ក្នុងការិយាល័យរាជការ ក្នុងព្រះរាជអាណាចក្រ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ, រីឯជន ទីង ត្រូវមានទោស ជាទម្ងន់ ជាងនេះ ទៅទៀត ប្រសិនបើ ជននោះ បាន តែបំបាត់ ឬ លួច លិខិតនោះវិញ ។

សេចក្ដីប៉ុណង ក្នុងបទល្មើសនេះ ក៏ត្រូវមាន ទោស ដូចជាបាន ប្រព្រឹត្ត បទល្មើសនេះ ដែរ ។

មាត្រា ៣៤៨– ឯកសារ ហើយនិង វត្ថុតាំងតួង ដែលគេ ទុក ដាក់ ដោយបិទ ស្លាកល័ក្ត ត្រូវទុក ដូចជាលិខិត ដែលគេ ដំកល់ទុក ក្នុងឯកសារដ្ឋាន ដូចដែលមាននិយាយ អំពីការបំផ្លាញ ឬ ការធ្វើ ឲ្យ វត្ថុតាំងនោះ បាត់ ពីកន្លែង នោះដែរ ។

មាត្រា ៣៤៩– ពន្ធិតណា ជាប់ ក្នុងពន្ធនាគារ ព្រោះមាន ទោស ឬ ត្រូវឃុំ ជាបណ្ដោះអាសន្ន ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយ រត់ចេញ ពីពន្ធនាគារ, ពីការដ្ឋាន ឬ ពីទីបណ្ដើរឲ្យធ្វើការ, ពីក្បួន ដឹកនាំ, មនុស្សនោះត្រូវមាន ទោស ដូចខាងក្រោម ។

១– បើមនុស្សរត់នេះ គ្មានកំហែង រំលោភ លើរូបកាយគេ គ្មាន គ្រឿងសស្ត្រាវុធ, គ្មានទំលាយ ពន្ធនាគារ ទេ, មនុស្សនោះ ត្រូវមាន

ទោសគុក ពីបីខែ ទៅដល់ មួយឆ្នាំ ថែម លើទោស ដែលកំពុងរង ។

២– បើមនុស្សរត់ ឬ បំណងនឹងរត់នោះ បានធ្វើហិង្សា លើរូបកាយគេ ក្តី, មានគ្រឿងសស្ត្រាវុធ ក្តី, មានទំលាយ ពន្ធនាគារ ក្តី, ទោសគុក ដែលកំពុងរង ត្រូវបន្ថែម ពីមួយឆ្នាំ ទៅដល់ប្រាំឆ្នាំ ។

ទោសគុក ដែលបានបន្ថែម នោះ ត្រូវមាន ប្រភេទ ជាទោសឧក្រិដ្ឋ ឬ ជាទោសមជ្ឈិម តាមប្រភេទទោសដើម ដែលកំពុងរង ។

ប៉ុន្តែ បើ ទោសគុក ដែលកំពុងរង ជា ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ឬ ថ្នាក់ទីបី ទៅហើយ , ជន ដែលរត់នោះ មិនបាច់ដាក់ខ្លួន ឲ្យតុលាការ ចោទប្រកាន់ ទៀតទេ ។

បើ ពន្ធិត រត់ ពីពន្ធនាគារ ខែត្រណា, ត្រូវតុលាការ ខែត្រនោះ មានសមត្ថកិច្ច ជំរះ រឿងរត់ ពីគុក នោះ , ទោះបីទោសដើម ដែល រា កំពុងទទួល នោះ ជាទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ក៏ដោយ ។

បើចៅក្រម ត្រាប្រណី ដល់មនុស្សរត់ ពីគុក ដែលកំពុងទទួល ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ផងនោះ , ទោសគុក ដែលត្រូវបន្ថែមនេះ ត្រូវស្រូបចូលទៅ ក្នុងទោសឧក្រិដ្ឋ ដែលមិនទាន់បានទទួល នោះ ។

មាត្រា ៣៥០– មនុស្សត្រូវចោទណា បានរត់ពីគុក មុនពេល ដែលតុលាការ សម្រេច ឲ្យរួចខ្លួន ពីបទចោទ , មនុស្សត្រូវចោទ នោះ

00222356



នៅតែ ត្រូវមាន ទោសគុក ដែលមាន រយៈពេល ដូចមានសម្តែង ក្នុង មាត្រា ខាងលើនេះ តាមពិរុទ្ធ របស់មនុស្ស នោះ ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ដដែល ។

មាត្រា ៣៨១– ការគំរាម ឬ ផន្ទាម , ដែលមនុស្សរត់ ពីគុក បានប្រព្រឹត្តនោះ , ត្រូវចាត់ទុកថា ជាវិហិង្សា ។

ប្រសិនបើ បានវាយដំ ផង, មនុស្សរត់ ពីគុក នោះ ត្រូវមាន ទោស ពីបទរត់ ពីគុក ផង ពីបទវាយដំ ផង ។ បើការវាយដំ នោះ ធ្វើឲ្យមាន របួសធ្ងន់ ល្មមបួល ជាបទមជ្ឈិម ឬ ទុក្រិដ្ឋ ឬ បើអ្នករងគ្រោះ នោះ ជា អ្នកពជការ ផង មនុស្សរត់ ពីគុក នោះ ត្រូវមាន ទោស ដល់អតិបរមា នៃបទមជ្ឈិម ឬ បទទុក្រិដ្ឋនោះ ។

មាត្រា ៣៨២– បើមនុស្សរត់ ពីគុក នោះមាន វត្ថុ អ្វីមួយ ដែលអាច យកទៅវាយ គេ ឲ្យមាន របួសស្នាកស្នាម បាន, វត្ថុនោះ ត្រូវចាត់ទុកថា ជាសស្ត្រាវុធ ។

មាត្រា ៣៨៣– ដែលហៅថា ការទំលាយគុក នោះ, គឺអំពើ ដែល ពន្ធិត ធ្វើគុក ឲ្យខូច ឲ្យទៅ ជាប្រកបេញ បានក្តី, គាស់ទំលុះ ទំលាយ កំពែងក្តី, ឬ កាច់បំបាក់ ខ្នោះឃ្នាង ដែលដាក់ ខ្លួនក្តី ។

មាត្រា ៣៨៤– ជនណា ទទួលភារៈ នាំបណ្ដើរ ឬ អនុរក្ស ឬ យាម ពន្ធិត ហើយធ្វេសប្រហែស ឲ្យពន្ធិត ម្នាក់ ឬ ច្រើននាក់ រត់ពីគុក បាន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។ កាលណាបើ មាន សមគំនិត ផង, ជននោះ ត្រូវមាន ទោសមជ្ឈិមថ្នាក់ទីបី ។

បើគ្មាន សមគំនិត រវាងអនុរក្ស និងពន្ធិត ទេ, ប៉ុន្តែ មាន ភស្តុតាង ថា កាលមាន មនុស្ស រត់ ពីគុកនោះ, អនុរក្ស បានដឹងដែរ ហើយ ពុំបានចាត់ វិធានការ ណាមួយ ដើម្បីជៀសវាង ឬ រាំងរា មិនឲ្យរត់ នោះ សោះ, អនុរក្សនោះ ត្រូវចាត់ទុក ជាសមគំនិត ដែរ ។

ក្នុងករណីទាំងអស់នេះ, អនុរក្ស ជាវិរុទ្ធជន នេះ ត្រូវសង ជទទណ្ឌ ដែលបានផ្ដន្ទា លើអ្នករត់ពីគុក ជាជំនួស អ្នករត់នោះ ទាំងអស់ ។

និងទោសប្រកាន់ លើទាហាន ពីបទធ្វេសប្រហែស ឲ្យមនុស្ស រត់ ពីគុក បាន លុះត្រាតែមាន បណ្ដឹង អំពីចៅហ្វាយនាយ របស់ទាហាន នោះ ប្ដឹងមក ផង, ប្រសិនបើ ចៅហ្វាយនាយ នោះ យល់ឃើញ ថា ទណ្ឌកម្ម ជាវិន័យ ដែលត្រូវផ្ដន្ទា លើរូបទាហាន នោះ មិនទាន់ជួន ល្មម ទេ ។

មាត្រា ៣៨៥– កាលណាបើ មាន បទធ្វេសប្រហែស ឬ បទសមគំនិត នោះ ធ្លាក់ លើមនុស្ស ច្រើននាក់ ដែលពធការ ចាត់ឲ្យ

00222358





នាំ ឬ ឲ្យយាម មនុស្ស ដែលខ្លួន បណ្ដោយ ឲ្យរត់នោះ, មនុស្ស ទាំងអស់នេះ ត្រូវមាន ទោស គ្រប់ៗគ្នា ហើយ និងត្រូវ ឲ្យរួបរួម គ្នា សងធនទណ្ឌ ជំនួស មនុស្ស ដែលរត់ នោះទៀត ។

មាត្រា ៣៨៦– បើ បទធ្វេសប្រហែស ឬ បទសមគំនិត នោះ មិនគាប់ និងទោស លើបុគ្គល ម្នាក់ៗ ដែលបណ្ដើរ ឬ ដែលយាម មនុស្ស ដែលរត់នោះ បានទេ, ទោស នេះ ត្រូវធ្លាក់ លើនាយ របស់ បុគ្គល ទាំងនោះ តែម្នាក់ឯង ។

មាត្រា ៣៨៧– ជនណា ទទួលមុខងារ ខាងនាំ ឬ ខាងយាម ពន្ធិត ហើយចូលរួម ដោយចេតនា ក្នុងការរត់ ពីគុក ឬ ក្នុង បំណងរត់ ពីគុក ដោយផ្ទាល់ខ្លួនក្ដី មិនផ្ទាល់ក្ដី, ជននោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៣៨៨– តតិយជន ណា សូកអនុរក្ស ឲ្យព្រមសម គំនិត និងខ្លួន ដើម្បីធ្វើឲ្យ មនុស្ស ដែលនៅ ក្នុងគុក បានរត់ចេញ ពីគុក ដោយងាយស្រួល, តតិយជន នោះ ត្រូវមាន ទោស ប៉ុនគ្នា និង ទោស ដែលត្រូវអនុវត្ត លើអនុរក្ស ដែរ ។

00222359

D99/3/3



មាត្រា ៣៥៩– ជនណា ដោយចេតនា, ទទួលលាក់ បំពួន ឬ បណ្ដាច់ អ្នកដទៃ ឲ្យទទួលលាក់ បំពួន នូវមនុស្ស ដែលខ្លួនបាន ដឹង ថា ជាអ្នករត់ ពីគុក, ដោយឲ្យ ទីជ្រក ឬ ទីពួន, ជននោះ ត្រូវ មានទោស តាមបទបញ្ញត្តិ មាត្រា ៣៥០ ដែលស្ដី ពីទទួល មនុស្ស ទុច្ចរិត នោះ ដែរ ។ ប៉ុន្ដែ ជននោះ អាចនឹងផុត ពីការចោទប្រកាន់ បាន, ប្រសិនបើ ជននោះ ត្រូវជាញាតិសន្ដាន ដូចមាន ក្នុងបទបញ្ញត្តិ ត្រង់កថាខណ្ឌទីបី នៃមាត្រា ដែលចង្អុល ខាងលើនេះ ។

មាត្រា ៣៦០– ជនណា មានអនុទោស ត្រង់ស្ថាន គំហាត់ លំនៅ, កាលបើ បានទទួល ដំណឹង ពីដីកា ស្ដីពីគំហាត់នេះ ហើយ, នៅតែបេះចូលទៅ កាន់កន្លែង ដែលហាមឃាត់ មុនផុត រយៈពេល ដែលដាក់កំហិតនោះ, ដោយគ្មាន សេចក្ដីអនុញ្ញាត អ្វី ជាពិសេស ទេ, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៣៦១– ជនណា បានដឹង ថា មនុស្ស ដែលមាន ទោស គំហាត់លំនៅ ចូលមក ក្នុងកន្លែង ដែលហាមឃាត់ នោះ ហើយ ក៏បាំង ឲ្យ ផ្ទះស្នាក់ ឬ ឲ្យអ្នកដទៃ ទទួលក៏បាំង, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

មិនឲ្យ អនុវត្តន៍ បទបញ្ញត្តិនេះ លើជន ដែលមាន រៀបរាប់ ក្នុង

00222360





មាត្រា ៣៤០ នោះទេ ។

មាត្រា ៣៦២– មនុស្សណា មានភេទជាប្រុស អាយុច្រើនជាង ដប់ប្រាំបីឆ្នាំ និងមាន អាយុ តិចជាង ហុកសិបឆ្នាំ, មានសុពលភាព, មានសតិជា, ល្អ, ហើយមិនមាន ការងារអ្វីមួយ ជាប្រក្រតីសោះ និង មិនមាន សំអាងជា ខ្លួន មាន មធ្យោបាយ អ្វីមួយ ល្មមស៊ីនៅសោះ, មនុស្សនោះ ត្រូវចាត់ទុក ថា ជាពាលអនាថា ហើយ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

ស្ត្រី ដែលមាន លក្ខខណ្ឌ ពីអាយុ និង ពីសុពលភាព ដូចបុរសខាងលើនេះ ដែរ និងត្រូវមាន ទោស ដូចគ្នាបាន, លុះណាតែស្ត្រីនោះបានដើរ សុំ ទានគេ ។

មិនត្រូវ អនុវត្តិ បទបញ្ញត្តិនេះ លើជន ដែលគ្មាន ការងារ និង គ្មានមធ្យោបាយស៊ីនៅ ដោយសារនិកម្មវេលា តាំងបន្តិ នោះទេ ។

ព្រះរាជក្រមលេខ ៣៦៩ ន.ស ចុះថ្ងៃ ១៣ មករា ១៩៦០ ត្រង់កថាខណ្ឌទី ៤ ពន្យល់ថា មិនទុក ជានិកម្មវេលា តាំងបន្តិ ទេ, ជនទាំងឡាយណា ដែលបាន ដំណឹង និង បង្គាប់ ឲ្យទៅធ្វើការ ក្នុងសហគ្រាសណាមួយ ដែលមានត្រាទុក ក្នុងបញ្ជី ដោយប្រកាសរួម របស់ក្រសួងការងារ និងសង្គមកិច្ច ជាត្រឹមត្រូវហើយ មិនព្រមធ្វើការ ដោយគ្មាន

00222361

D99/3/3



សំណងដ៏ សមហេតុសមផល សោះ ។

មាត្រា៣៦៣– មនុស្សត្រូវចោទ ត្រូវរក ភ័ស្តុតាង ជូន តុលា-ការ ថាខ្លួន មានការងារ ជាប្រក្រតី ដើម្បីដោះសារ ការពារខ្លួន ។

ការងារ, ទោះបី មិនបានធ្វើ ជាទៀងទាត់ ក៏ដោយចុះ ឲ្យតែមាន លក្ខណ៍ ច្បាស់ ថា មុខរបរ ដែលមនុស្សត្រូវចោទ បានធ្វើមក នោះ អាច ផ្តល់ ផល ឲ្យមនុស្សត្រូវចោទ ចិញ្ចឹម ជីវិត បាន តាំងពីថ្ងៃ ដែលខ្លួន បានធ្វើ រហូតមក ដល់ថ្ងៃ ដែលខ្លួន ត្រូវចោទនេះ ។

ការងារ ក្នុងអាជីវកម្ម ខុសច្បាប់, ក្នុងជំនួញ ខុសច្បាប់ ឬ ក្នុង ឧស្សាហកម្ម ខុសច្បាប់ មិនទុក ជាការងារ សំរាប់ដោះសារខ្លួន ឲ្យរួច ពីបទពាលអនាថា ទេ ។

មាត្រា៣៦៤– ដើម្បីនឹងរក យុត្តិកម្ម ឲ្យឃើញ ថា មនុស្ស នោះ មាន ឬ មិនមាន មធ្យោបាយ សំរាប់រស់ ទេ, មនុស្សនោះ ត្រូវ ជូនសំអាង អំពីមុខរបរ ខ្លួន ដែលអាចឲ្យ ផល ល្មមចិញ្ចឹម ខ្លួន បាន ។

មុខរបរទាំងឡាយ គឺល្បែង, ស្ទូមពាន, ការបបួលរួម ឧធំពេស្យាការ អ្នកដទៃ, និង មុខរបរ ទាំងឡាយ ខ្ទៅ ដែលជារបរ ធ្វើ ឲ្យសៅហ្មង ដល់សេចក្តីរៀបរយ សាធារណជន, ឬ ដល់ទំនៀមទំលាប់ ដ៏ល្អ របស់រដ្ឋ មិនទុក ជាមុខរបរ ឡើយ ។

00222362



មាត្រា ៣៦៥- ពាលអនាថា គ្មានកាតពន្ធខ្លួន ក្នុងដំបន្ត ត្រូវ ទោសគុក ដែលគ្រោងទុកក្នុង មាត្រា ៣៦៤ ជាអតិបរមា ។

មាត្រា ៣៦៦- ពាលអនាថា ណា ដែលកដករ ចាប់ខ្លួន បានហើយ ឃើញមាន អាវុធ ដូចមាន ន័យ ក្នុងមាត្រា ១៤៦ ឬ ក៏ មាន គ្រឿងប្រដាប់ អ្វី ដែលអាច យកទៅប្រើការ សម្រាប់ចូល ក្នុង លំនៅ គេ ឬ សម្រាប់ប្រព្រឹត្ត សន្ធិប្លូនកម្ម, ជនពាលនោះ ត្រូវមាន ទោស ដល់អតិបរមា នៃទោសគុក ដែលមានគ្រោងទុក ក្នុងមាត្រា ៣៦៤ ហើយអាចនឹងផ្តន្ទា អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិ ស៊ីវិក ឬ តំហាត់លំនៅ ទៀត ក៏បាន ។

មាត្រា ៣៦៧- ជនពាលណា ប្រើ អត្តសញ្ញាណប័ណ្ណ ក្លែង ឬ ជារបស់អ្នកដទៃ, ដើរសូមទានគេ, បំផ្លាញសន្ហារមេ, អសន្ហារមេ ជា កម្មសិទ្ធិ អ្នកដទៃ, ពោល ពាក្យគំរាម, ជេរ ឬ ធ្វើហិង្សា លើរូបបុគ្គល ដទៃ, ជនពាល នោះៗ ត្រូវមាន ទោសមជ្ឈឹម ថ្នាក់ ទីបី ហើយនឹងត្រូវមាន អនុទោសត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិក នឹង តំហាត់លំនៅ ទៀត ក៏បាន ។ មិនតែ ប៉ុណ្ណោះសោត ជនពាលនោះ នឹងមាន ទោស ធ្ងន់ ជាងនេះ ទៅទៀត, ប្រសិនបើប្រភេទ នៃហិង្សា នោះ, ឬ គុណភាព នៃអ្នករងហិង្សា នោះ បណ្តាលឲ្យធ្វើ ទោស

00222363

D99/3/3



យាំងជូន នោះបាន ។

មាត្រា ៣៦៨- ប្រាក់ តាំងពីដប់រៀល ឡើងទៅ ដែលឃើញនៅ លើខ្លួន ជនពាល ត្រូវអូសរឹប ជារបឹប , ប្រសិនបើ ឃើញ ថា ជនពាលនេះ បានប្រាក់នោះ មិន ដោយសុចរិត ទេ ។

មាត្រា ៣៦៩- ១១- ជនណា ផ្លាស់លំនៅ ហើយមិនប្ដឹង រាជការឃុំ ដែលខ្លួន លែងនៅ អំពីការផ្លាស់ លំនៅ នោះទេ, និង មិនប្ដឹង រាជការឃុំ ក្នុងឃុំថ្មី ដែលខ្លួន ចូលទៅនៅ នោះទេ ។

១២- ជនណា ប្រើប្រាស់ មនុស្សបំរើ ឥតមាន កាតពន្ធខ្លួន ក្នុងឆ្នាំបន្ត ទេ ។

១៣- ជន ណា ឲ្យ ទីកន្លែង ជ្រកកាស្រ័យ ដល់មនុស្ស មក ពីឃុំដទៃ ឬ ដល់មនុស្ស ពាលអនាថា ហើយមិនប្ដឹង រាជការឃុំ ឲ្យបាន ដឹង, ជននោះៗ ត្រូវមាន ទោស លហុ ។

មាត្រា ៣៦៩-ស្ទួន (ព្រះរាជក្រមលេខ ៩៣១-ន ស. ចុះថ្ងៃ ១៥-២ ៥៥) ជនណា ដើរសូមទានគេ ជារបរ នៅ លើផ្លូវសាធារណៈ ឬ កន្លែងសាធារណៈ ឬ កន្លែង បើកឲ្យ សាធារណជន , ជននោះ ត្រូវមាន ពិរុទ្ធ ជា បានប្រព្រឹត្ត បទសូមទានគេ ។

ជនណា ជាមនុស្សពិការ ធ្វើការមិនកើត លើសពី ៥០% ហើយ ដើរ សូមទានគេ ក្នុងទីណាមួយ ដូចពោលរៀបរាប់ ខាងលើ, ជននោះ នឹងត្រូវមាន ទោស ជាលហុ, ខ្លួនជននោះ ត្រូវនាំ ទៅឲ្យ គ្រួសារ, ប្រសិនបើមាន បងប្អូន ជាប់កាតព្វកិច្ច អាហារូបត្ថម្ភ នឹងជនពិការ នោះ, តាមន័យ ក្នុងជំពូកទី ១ មាតិកា ទី៦ គត្តិ ទី១ នៃក្រមរដ្ឋប្បវេណី, ហើយអាច ទទួលចិញ្ចឹម បាន, បើពុំដូច្នោះទេ, ខ្លួន មនុស្ស ពិការ នោះ ត្រូវនាំ ទៅឲ្យ គ្រឹះស្ថាន សម្រាប់ទទួល នឹង ថែរក្សា មនុស្សផក ។

បើជន ដែលគេ ចាប់ឃើញ ដើរសូមទាន ពុំមាន អាការរោគ បណ្ដាល ឲ្យធ្វើការ មិនកើត លើសពី ៥០% ទេ, ជននោះនឹងត្រូវ មាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើជន ដែលគេ ចាប់ឃើញ ដើរសូមទាន នោះ ជាមនុស្ស រត់ ពីគ្រឹះស្ថាន សម្រាប់ទទួល និងថែរក្សា ឬ ចាប់ឃើញ ដើរសូមទាន ប្រយោជន៍យកទៅទិញ ស្រាផឹក ឬ យកទៅទិញ អាភៀនជក់ នោះ, ទោះបីជនជាក់ ជាមាន ពិការ លើសពី ៥០% ក៏ដោយ, ក៏ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ដែរ ។

មនុស្សសូមទាន ទោះបីមាន ពិការ លើសពី ៥០% ក៏ដោយ បើ បានចូល ក្នុងផ្ទះ អ្នកដទៃ ដោយឥតអនុញ្ញាត ពីម្ចាស់ផ្ទះ ឬ បានគំរាម ...

ឬ ក្លែងធ្វើ ជាមនុស្ស មានជំងឺ ឬ មានពិការ ឬ ដើរសូមទាន ដោយ មាន គ្នាជាពួកៗ ឬ ក៏ បានប្រើ ក្មេងអាយុ តិចជាង ដប់បីឆ្នាំ ឲ្យ ដើរសូមទាន នឹងត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

ក្នុងករណី ពុំពងចាល, ត្រូវយក ទោស កំរិតយ៉ាងធ្ងន់ មកអនុវត្ត ជាដពប; បើ អ្នកសូមទាន បានក្លែងខ្លួន ជាបព្វជិត ដើម្បីប្រព្រឹត្ត បទ ល្មើស នោះ ក៏ត្រូវអនុវត្ត ទោស ដូចគ្នា ដែរ ។

មាត្រា ៣៦៩-ត្រី(ព្រះរាជក្រមលេខ ៩៣០-នស. ចុះថ្ងៃ ១៥ កុម្ភៈ ១៩៥៥)
បើ ខេត្តណាគ្មាន គ្រឹះស្ថាន សម្រាប់ទទួល និងថែរក្សា ទេ, ស្មូម ដែល មាន ពិការ លើស ពី ៥០% នឹងត្រូវមាន ទោសបាន, លុះតែឃើញ ដើរសូមទាន ជាធម្មតា ។ ស្មូមនេះ, បើគ្មានគ្រួសារ ជាប់អាហារូបត្ថម្ភ ឬ ទទួលបីបាច់រក្សា បាន ទេ, អាចនឹងនាំ ខ្លួន ទៅប្រគល់ ដល់គ្រឹះស្ថាន សម្រាប់ទទួល បីបាច់រក្សា ណា ដែលនៅជិត ជាងគេ បាន ។

មាត្រា ៣៧០- ការប្រហារ , ការរឹងរូស ណា ប្រព្រឹត្តដោយ ហិង្សា ឬ ដោយរំលោភ លើរូបកាយ អ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរសាធារណៈ ដែលកំពុងដាក់ ឲ្យប្រតិបត្តិ ច្បាប់, បទបញ្ជា, សេចក្តីសម្រេចតុលាការ, ដីការតុលាការ (mandat de justice,), សេចក្តីបង្គាប់ ពីកងឈ រដ្ឋបាល, ការប្រហារ, ការរឹងរូស នោះ ឲ្យឈ្មោះថា ឧទ្ទាមកម្ម

មាត្រា ៣៧១– ឧទ្ទាមកម្មណា មានបុគ្គល តែម្នាក់ ឬ ពីរនាក់ ហើយគ្មានកាន់ អាវុធទេ, ឧទ្ទាមកម្មនោះ ត្រូវផ្តន្ទា ទោស មជ្ឈិម ថ្នាក់ទីមួយ ។ ប៉ុន្តែ បណ្តាឧទ្ទាម ទាំងពីរនាក់នេះ, បើឧទ្ទាម ណា, សូម្បីតែម្នាក់, មានកាន់ អាវុធ, ក៏ឧទ្ទាម ទាំងពីរនាក់ នោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ ដែរ ។

មាត្រា ៣៧២– ឧទ្ទាមកម្មណា មានបុគ្គល ពីបីនាក់ ដល់ ម្ភៃនាក់, ហើយគ្មានកាន់ អាវុធទេ, ឧទ្ទាម កម្មនោះ ត្រូវផ្តន្ទា ទោស មជ្ឈិម ថ្នាក់ទីពីរ ។ ឧទ្ទាមកម្មនេះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីបី វិញ, បើ ក្នុងពួកឧទ្ទាមនោះ មានច្រើននាក់ បានកាន់ អាវុធ ។
ព្រះរាជប្រកាស លេខ ៨២ ចុះថ្ងៃទី ២០ – ៥ – ៤០ ដែលបានបញ្ចូលបទបញ្ញត្តិ មក ក្នុង មាត្រា ៣៧២ នេះ បានត្រូវដកទៅបញ្ចូល ក្នុងក្រមតុលាការសឹកហើយ ) ។

មាត្រា ៣៧៣– ឧទ្ទាមកម្មណា មានបុគ្គល លើស ពីម្ភៃនាក់ ឡើងទៅ ហើយគ្មានកាន់ អាវុធទេ, ឧទ្ទាមកម្មនោះ ត្រូវផ្តន្ទា ទោស មជ្ឈិម ថ្នាក់ទីបី ។ ឧទ្ទាមកម្មនេះ ត្រូវផ្តន្ទា ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ វិញ, ប្រសិនបើឧទ្ទាម ច្រើននាក់ មានកាន់អាវុធ ។

មាត្រា ៣៧៤– នាកាលឧទ្ទាមកម្ម ប្រព្រឹត្ត ជាពួក ឬ ជាកង មានកាន់ អាវុធ, អំពើនោះ ត្រូវចោទប្រកាន់ តាមបទបញ្ញត្តិ នៃមាត្រា

00222367





២៣០ ដែលស្តី ពីកុប្បកម្ម វិញ ។ អាស្រ័យហេតុនោះ អ្នកដៃដល់ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ហើយមេដឹកនាំ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា៣៧៥- ដែលហៅថា អាវុធនោះ គឺគ្រឿងប្រដាប់ ដូច ដែលមានសម្តែង ក្នុងមាត្រា ១៤៦ ។

ជនទាំងឡាយ ដែលត្រូវចាប់ ខ្លួនបាន ពីបទឧទ្ទាមកម្ម គ្មានអាវុធ ហើយ, ប៉ុន្តែ កាលបើ គេឃើញថា បណ្តាជនទាំងនោះ មាន ជន ខ្លះ លបបង្កប់ អាវុធ ជាប់នឹងខ្លួន, ជន ដែលមាន អាវុធនោះ តែប៉ុណ្ណោះ ត្រូវមាន ទោស ពីបទចូលរួម ក្នុងឧទ្ទាមកម្ម មាន អាវុធ ។

មាត្រា៣៧៦- បើ ក្នុងវេលា ប្រព្រឹត្ត ឧទ្ទាមកម្ម, ពួកឧទ្ទាម បានធ្វើ វិហិង្សា បណ្តាល ឲ្យមាន របួស, មានជម្ងឺ, មាន អសមត្ថភាព ក្នុងការងារ, មាន ពិការ ឬ ក៏ មានបណ្តាលឲ្យស្លាប់ ជនណាម្នាក់, ពួក ឧទ្ទាមនោះត្រូវមាន ទោស ដូចដែលមានសម្តែង ក្នុងមាត្រា៣១៨, ទោះ បី អ្នករងគ្រោះនោះ មានគុណភាព ដូចម្តេច ក៏ដោយ; មិនតែប៉ុណ្ណោះ សោត បុគ្គលទាំងឡាយ ដែលមាន ភស្តុតាង ជាបានចូលរួម ក្នុងឧទ្ទាម- កម្ម នោះ ក៏ត្រូវចោទប្រកាន់ ជាអ្នកសមគំនិត នឹងអ្នកដៃដល់ នៃអំពើ វិហិង្សា នោះ ឬ មនុស្សឃាត នោះដែរ ។

# ចំពូក ប្រាំបី

## អំពីបទល្មើស លើធនធាន រាជការ សាធារណៈ

## Des infractions contre la fortune publique

មាត្រា ៣៧៧. ថ្មី (ព្រះរាជក្រមលេខ ៩៤ នស ចុះថ្ងៃ ១៧ ឧសភា ១៩៥៦)

វេលាណា មានបទល្មើស ណាមួយ ធ្វើឲ្យអន្តរាយ ដល់សម្ភារៈ របស់ នីតិបុគ្គល ជាសាធារណៈ ឬ នីតិបុគ្គល ឯកជន, ដែលរាជការ បើក ឲ្យមាន ឯកសិទ្ធិ ដោយឡែក ចំពោះមុខការ ណាមួយ ជាប្រយោជន៍ សាធារណៈ, ក្នុងឱកាស បំពេញ មុខការ នេះ, ទៅក្រុម, កាល បើផ្ដន្ទា ទោស ដល់បទល្មើស នេះ ហើយ, ត្រូវតែបញ្ជា ដោយខានមិន បានឲ្យជួសជុល សេចក្ដីខូចខាត នោះ ដោយសម្រេច ឲ្យសងសោហ៊ុយ បង់ខាត, ជម្ងឺចិត្ត តាមការណ៍ ដល់នីតិបុគ្គល ដែលរងគ្រោះ នោះ ដោយមិនបាច់ នីតិបុគ្គល នេះ តាំងខ្លួន ជាភាគីស៊ីវិល ឡើយ ។

មាត្រា ៣៧៨ ថ្មី (ព្រះរាជក្រមលេខ ៩៤ នស ចុះថ្ងៃ ១៧-៥-៥៦)

ក្លែងរូបិយវត្ថុ គឺធ្វើប្រាក់ លោហម័យ ឬធនប័ត្រ ឲ្យដូច ឬ ឲ្យប្រហែលគ្នា នឹងរូបិយវត្ថុ ដែលច្បាប់ បើកឲ្យចាយ ក្ដី, រំកេច ឬ កែប្រែ រូបិយវត្ថុ ដោយរបៀប ណាមួយ ព្រមទាំង ការក្រឡៃពណ៌ ក្ដី ។

ការក្លែង រូបិយវត្ថុ នេះ, សូម្បីតែធាតុ ខាងក្រៅ នៃលោហៈ ឬ ធនប័ត្រ ដែលក្លែងឬដែលរំកេច នោះ, បានបង្ហាញ ហេតុ ជាក់ស្ដែង ទូ

00222369

D99/3/3



កិរិយាកែច្នៃ ឬ នូវវិកេទ , ក៏ត្រូវមាន ទោសដែរ ។

មាត្រា ៣៧៩– ថ្មី (ព្រះរាជក្រម លេខ ៩៤-នស ចុះថ្ងៃ ១៣ ៥-៥៦) នឹងត្រូវតុលាការខ្មែរ ធ្វើទោស តាមច្បាប់ខ្មែរ ការធ្វើតាម , ការកែច្នៃ , ការធ្វើ ឬម ឬ វិកេទ, នៅ ឯបរទេស, នូវរូបិយវត្ថុ ដែលមានអត្ថៈ ជានិត្យានុកូល ក្នុងកម្ពុជរដ្ឋ ទោះបើមិនបានបញ្ចូលមក ក្នុងដែនដីកម្ពុជា នូវ រូបិយវត្ថុ ឬ ធនប័ត្រ ដែលធ្វើតាម, ដែលកែច្នៃ ឬ ដែលវិកេទ ក៏ដោយ ។

មាត្រា ៣៨០– ថ្មី (ព្រះរាជក្រម លេខ៩៤ន.ស. ចុះថ្ងៃ ១៣ - ៥ - ៥៦ ) ដែលហៅ រូបិយវត្ថុ មាន អត្ថៈ ជានិត្យានុកូល នោះ គឺរូបិយវត្ថុ ដែល បោះពុម្ព តាមបាវចនា របស់រដ្ឋ ហើយ ដែលច្បាប់ តម្រូវឲ្យចាយវាយ ជាកាតព្វកិច្ច ក្រោមអាណា របស់រដ្ឋ លើផ្ទៃប្រទេសទាំងមូល , ដរាប ដល់ពេល ដែលរដ្ឋប្រកាសថា ឈប់ចាយ រូបិយវត្ថុ នោះហើយ ។

រតនាគារ មានមុខងារ ខាងបោះពុម្ព ផ្សាយ នូវរូបិយវត្ថុ ជាលោហម័យ, ឯធនប័ត្រ ត្រូវ ធនាគារ ដែលមាន ឯកសិទ្ធិ ខាងបោះពុម្ព, ជាអ្នកបោះ ។

មាត្រា ៣៨១– ការកែច្នៃ រូបិយវត្ថុ ជាសាច់ប្រាក់ ឬ មាស ដែល មាន អត្ថៈ ជានិត្យានុកូល ក្នុងកម្ពុជរដ្ឋ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់

ទីពីរ , បើ ក្លែង រូបិយវត្ថុ ជាលោហម័យ ដទៃ ទៀត ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៣៨២– ថ្មី ( ព្រះរាជក្រម លេខ ៩៤ - នស ចុះថ្ងៃ ១៣-៥-៥៦) ការក្លែង ដោយធ្វើគ្រាប់, ដោយបូម ឬ ដោយវិកេទ នូវរូបិយវត្ថុ បរទេស ដែលមាន អត្ថ ជានិត្យានុកូល ក្នុងប្រទេស នោះ នឹងត្រូវផ្តន្ទា ទោស ជាឧក្រិដ្ឋ ថ្នាក់ទីមួយ , ប្រសិនបើ រូបិយវត្ថុ ក្លែង នោះ ជាធនប័ត្រ ឬ ជារូបិយវត្ថុ ធ្វើ ពីមាស ឬ ពី ប្រាក់, ត្រូវមាន ទោសមធ្យម ថ្នាក់ទីបី វិញ, បើ រូបិយវត្ថុ នោះ ធ្វើ ពីលោហធាតុ ផ្សេង ពីមាស ឬ ពីប្រាក់ ។

មាត្រា ៣៨៣ – មាត្រានេះ ព្រះរាជក្រម លេខ ៩៤ ន ស ចុះថ្ងៃ ១៣-៥-៥៦ បានប្រកាសលុបចោល ហើយ ឥតមាន ដាក់ ជំនួស វិញ ឡើយ ។

មាត្រា ៣៨៤ ថ្មី ( ព្រះរាជក្រម លេខ ៩៤ ន. ស. ចុះថ្ងៃ ១៣-៥-៥៦) ការក្លែង ដោយធ្វើបូម, ដោយធ្វើគ្រាប់ ឬ ដោយវិកេទ នូវឆនុភាព នៃប្រាក់ ធនាគារ សាធារណៈ ហើយនិង ធនប័ត្រ ដែលមាន អត្ថៈ ក្នុងកម្ពុជរដ្ឋ នឹងត្រូវផ្តន្ទា ទោស ជាឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ៣៨៥ – ព្រះរាជក្រម លេខ៩៤ – ន. ស ចុះថ្ងៃទី ១៣-៥-៥៦ ប្រកាសឲ្យលុបចោល ហើយ ឥតមាន ដាក់ជំនួស វិញឡើយ ។

00222371





មាត្រា ៣៨៦– ការនាំចូល, ការបោះពុម្ពផ្សាយ, ការដាក់តាំង
ក្នុងដែនដី នៃកម្ពុជរដ្ឋ នូវរូបិយវត្ថុ ក្លែង ជាលោហម័យ ឬ ជាធនប័ត្រ នោះ
ត្រូវផ្ដន្ទា ទោស ដូចគ្នា នឹងទោស ដែលត្រូវផ្ដន្ទា ពីបទក្លែង នោះដែរ ។

មាត្រា ៣៨៧– បុគ្គល ណា បានទទួល រូបិយវត្ថុ ក្លែង ជាលោហ
ម័យ ឬ ជាធនប័ត្រ ដោយសម្គាល់ ថា ជារូបិយវត្ថុ ត្រឹមត្រូវ ដោយចិត្ត
ជាសុចរិត ហើយ បានចាយ ដោយសុចរិត ទៀត, បុគ្គល នោះ មិនត្រូវ
ទុក ជាអ្នកប្រមូលគំនិត ក្នុងការបោះពុម្ពផ្សាយ នូវរូបិយវត្ថុ ក្លែង នេះ ទេ ។
ក៏ប៉ុន្តែ បើ មាន សំគាល់ ថា បុគ្គល នោះ បានដឹង ថា រូបិយវត្ថុ នោះ ជា
របស់ក្លែង ហើយ នៅតែ យកទៅ ចាយ ទៀត, បុគ្គល នោះ ត្រូវមាន
ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៣៨៨– ការធ្វើ ឬ ការរក្សាទុក នូវគ្រឿងយន្ត, ឧបករណ៍
និងប្រដាប់ សំរាប់ បោះពុម្ព ឬ ធ្លាក់ នូវរូបិយវត្ថុ ផលប័ត្រ ឬ ធនប័ត្រ
ដែលក្លែងបន្លំ, អំពើ ទាំងអស់ នេះ, ត្រូវចាត់ទុក ជាចំណាង នឹងក្លែង
បន្លំ ហើយ នឹងត្រូវផ្ដន្ទា ទោស តាមបទបញ្ញត្តិ ទាំងឡាយ ដែលបាន
សំដែង ក្នុងមាត្រា ខាងលើ បាន ។

មាត្រា ៣៨៩– ជនណា មិនព្រម ទទួល ស្គាល់ រូបិយវត្ថុ

00222372

D99/3/3



និង ធនប័ត្រ ដែលមាន អត្ថៈ ជាទិតក្ខុកូល ក្នុងកម្ពុជរដ្ឋ, កាល បើ រូបិយវត្ថុ និង ធនប័ត្រ ទាំងនោះ ជាវត្ថុបរិសុទ្ធ មិនមែនក្លែងក្លាយ ទេ, ជននោះ ត្រូវមាន ទោសមធ្យម ថ្នាក់ទីមួយ ។

មាត្រា ៣៩០– ការក្លែងបន្លំ តែម សារពើពន្ធ និង តែម ប្រៃសនីយ៍, ការបោះពុម្ពផ្សាយ ឬ ការនាំ តែម ទាំងនោះ ចូលមកផ្សាយ ក្នុងដែនដី កម្ពុជា, ត្រូវតុលាការ (បារាំងសែស) ជំនុំជំរះ ព្រោះជាអំពើ លើស នឹងច្បាប់បារាំងសែស ។ បើ ប្រើ តែម ទាំងនោះ ដោយដឹង ច្បាស់ថា ជាវត្ថុក្លែង ឬ តែមបរិសុទ្ធ ដែលប្រើរួចហើយ ក៏ត្រូវតុលាការ បារាំង ជំនុំជំរះ ដែរ ។ (មាត្រានេះ ពិតមែនតែ ពុំទាន់បានកែប្រែ ឬមិនទាន់បាន លុបចោល ក៏ទុកដូចជាលុបចោលដែរ ពីព្រោះតុលាការបារាំង ត្រូវបាត់បង់ ពីដែនដីកម្ពុជា តាំងពីថ្ងៃ ២៤ សីហា ១៩៥៣ មក គឺថ្ងៃ ដែលរាជការបារាំង ផ្ទេរ សមត្ថកិច្ច តុលាការខ្លួន ទៅប្រទេសខ្មែរ មកជូន ព្រះរាជរដ្ឋាភិបាល ខ្មែរ នោះ ។

មាត្រា ៣៩១– បទក្លែង សញ្ញា (Marque) ដែលបោះ ក្នុង នាម នៃក្រុមរដ្ឋការសាធារណៈ ក្នុងផលប្រយោជន៍ នៃរតនវត្ថុ របស់រដ្ឋ ត្រូវតុលាការបារាំង ជំនុំជំរះ ។ អ្នកយក សញ្ញាបរិសុទ្ធ ទៅប្រើ មិន តាមទំនង ដែលត្រូវប្រើ ហើយបណ្តាលឲ្យមាន ព្យសនកម្ម ដល់រតនវត្ថុ របស់រដ្ឋ ក៏ត្រូវ សាលាក្តី បារាំង ជំនុំជំរះដែរ ។ (មាត្រានេះ ទុកដូចជាត្រូវ លប់ចោល ដោយហេតុដូច ខាងលើនេះដែរ )

00222373

D99/3/3



មាត្រា ៣៩២—ស្ដីពីល្មើស នឹងបញ្ញត្តិ រាជការគយ។ មាត្រានេះ ត្រូវនិរាករណ៍ ដោយឯងៗ ដោយអំណាច ព្រះរាជក្រម លេខ២២៤-នស ចុះថ្ងៃទី ៩-៩-៤៦ និងលេខ ៦៦០ នស ចុះថ្ងៃ ២៩ មិថុនា ១៩៥១ ។

មាត្រា ៣៩៣- ការបង្ខូច ឬ បំផ្លាញ ដោយចេតនា ឲ្យមាន ព្យសនកម្ម, ដោយរបៀប ណាមួយ, ដល់សង្ហារិម ឬ អសង្ហារិម ជាសម្បត្តិ នៃបុគ្គលសាធារណៈ, ត្រូវផ្ដន្ទា ទោសមជ្ឈិម ថ្នាក់ទីពីរ ។

អំពើ ណា បណ្ដាលឲ្យខូច ដោយចេតនា នូវបរិសុទ្ធភាព នៃទឹក ជាអាហារសាធារណៈ ប្រព្រឹត្ត ដោយវិធី ណាមួយ ទោះបីមិនបានបំផ្លាញ បង្ខូច ឬ ឲ្យសៅហ្មង នូវការ (Ouvrage) នោះ ក៏ដោយ, ក៏ត្រូវមាន ទោស ដូចបានសំដែង ខាងលើ នេះ ដែរ ។

ការបំផ្លាញ បង្ខូច ឬ ធ្វើឲ្យសៅហ្មង ដោយអចេតនា ព្រមទាំង អំពើ ធ្វេសប្រហែស និង មិនថែរក្សា នាំឲ្យខូច បរិសុទ្ធភាពនៃទឹក ជាអាហារសាធារណៈ ទាំងអស់នេះ ត្រូវផ្ដន្ទា ទោស ជាលហុ ។

បើ ការបំផ្លាញ នោះ បានសម្រេច ឬ បំណង នឹងឲ្យសម្រេច ដោយ យក ភ្លើង ទៅដុត, អំពើនោះ នឹងត្រូវផ្ដន្ទា ទោស តាមបញ្ញត្តិ មាត្រា ៤៣៧ និង ៤៣៨ ។ អតិបរមា នៃទោសមជ្ឈិម ដែលមានសំដែង ក្នុង មាត្រា ៤៣៨ ក៏ត្រូវតែយកមក ផ្ដន្ទា ដែរ ។

មាត្រា ៣៩៤– វត្ថុ គ្រប់យ៉ាង ឯណា ដែលបានសង់ ឬ ដែល

បានទុកដាក់ តាមបង្គាប់ ឬតាមសេចក្ដីអនុញ្ញាត របស់អាជ្ញាធរ សាធារណៈ ដើម្បីសេចក្ដីត្រូវការ របស់ក្រុមពលករសាធារណៈ ឬ របស់សមូហភាព ពលករ, ប៉ុន្តែទ្រព្យទាំងនេះ មិនមែន ជាទ្រព្យពលករទេ និង មិនមែនជាទ្រព្យ របស់ឯកជនទេ, តែ គ្រប់យ៉ាងនោះ ត្រូវរាប់ ថា ជាទ្រព្យរបស់ នីតិបុគ្គល សាធារណៈ ។

ប្រាសាទបុរាណ និង បុរាណវត្ថុ ឬ វត្ថុ ដែលទាក់ទង នឹងប្រវត្តិសាស្ត្រ ព្រមទាំងរមណីយស្ថាន ដែលពលករ បានយកបញ្ចូលរួចហើយ ត្រូវរាប់បញ្ចូល ជាទ្រព្យ ពលករ ដែរ ។

មាត្រា ៣៩៨-ការជ្រៀតជ្រែក យក ផ្លូវសាធារណៈ, ការធ្វើឲ្យខូច ផ្លូវសាធារណៈ និងអំពើទាំងឡាយ ទូទៅ, ដែលបណ្ដាល ឬដែលមានទំនង នឹងបណ្ដាល ឲ្យប៉ះពាល់ ដល់សម្បូរណភាព នៃផ្លូវសាធារណៈ, ដែលមានទំនងនឹងកែប្រែ ឋិតភាព នៃផ្លូវសាធារណៈ, ដែលមានទំនងនឹងឲ្យវិនាស ផ្លូវសាធារណៈក្ដី, អំពើ មិនគោរព នូវបរិហារភាព ជាសាធារណៈប្រយោជន៍ ដែលពលករ តាក់តែងឡើង ដើម្បីជាប្រយោជន៍ដល់ផ្លូវ, ដល់បរិការផ្លូវ, ដល់បរិវេណផ្លូវ ក្ដី, អំពើល្មើស នឹងបទបញ្ជារបស់អាជ្ញាធរ ដែលបញ្ញត្តិ ដើម្បីឲ្យផ្លូវ បានឋិតថេរ ចិរកាល ក៏ដោយ ក្ដី អំពើ ទាំងអស់នេះ ត្រូវមានទោសលហុ ។ នាកាល បទល្មើសនេះ

00222375

D99/3/3



បានប្រព្រឹត្ត ឡើងហើយ, អាជ្ញាធរ អាចទៅពិនិត្យ អំពើល្មើស ទាំងអស់ នេះ នៅ ថ្ងៃ ណា ខែ ណា ឆ្នាំ ណា ក៏បាន ។

ប្រសិនបើ បទល្មើស នេះ ផុត អាជ្ញាយុកាល ហើយ, ចារី នៃបទល្មើសនេះ មិនត្រូវមាន ទោស ទេ ដូចដែលមានបញ្ញត្តិ ក្នុងមាត្រា ១០៩ នៃក្រមនេះ, ក៏ប៉ុន្តែ ចារី នៃបទល្មើស និង អ្នកទទួលខុសត្រូវ ខាងស៊ីវិល អាចត្រូវទទួល ទណ្ឌកម្ម ឲ្យជួសជុល សេចក្តីខូចខាត នោះ, ឲ្យបង្វិល ដីដែលជ្រៀតជ្រែក នោះ, ឲ្យរុះរើ វត្ថុទាំងប៉ុន្មាន ដែលបានធ្វើ រួចហើយ ឬ ដែលកំពុងធ្វើ, បើនឹងឲ្យសង សោហ៊ុយ និង ប្រាក់ចំណាយ ដែលរាជការ យកទៅជួសជុល ផ្លូវបកបរ ឲ្យបាន ដូចដើមវិញ ឬ ដើម្បីនឹងរៀបចំ កន្លែងនោះ ឲ្យមាន សភាព ដូចដើមវិញ ទៀត ក៏បាន ទោះបីថ្ងៃដែលប្រព្រឹត្ត បទល្មើស នោះ យូរយារ ណាស់ មកហើយ ក្តី ។

បើ ការពិនិត្យ បទល្មើស នោះ បានទៅធ្វើ ក្នុងពេល ដែលចារី កំពុងតែប្រកប ការងារ មាន ទំនង ឲ្យវិនាសខូច ឬ បណ្តាលឲ្យ សៅហ្មង ដល់សម្បូរណភាព នៃផ្លូវសាធារណៈ បរិករផ្លូវ និង បរិវេណផ្លូវ នោះ, សាលាក្តី ដែលទទួល ដំណឹង ត្រូវជំនុំជំរះ ភ្លាម កុំបង្អែរបង្អង់ ឡើយ, បើ នឹងចេញ ដីកាបង្គាប់ ដោយឯង ៗ ឲ្យបញ្ឈប់ ការងារ នោះ មួយរំពេច ក៏បាន, ចុះ សេចក្តីបង្គាប់ នោះ លើបណ្តឹង ដែលមាន អធិប្បាយ ក្នុងកំណត់ហេតុ ក៏បាន ចុះ សេចក្តីបង្គាប់ លើបណ្តឹង

ដែលប្ដឹងសុំជាក្រោយក៏បាន ។

សាលាក្ដី ដែលត្រូវទទួលបណ្ដឹងក្នុងរឿងនេះ គឺសាលាក្ដីជា នាទី ដែលមានបទល្មើសនេះ ។ សាលាក្ដីត្រូវកោះជនអ្នកល្មើសនោះ យ៉ាងយូរណាស់ត្រឹមដប់ថ្ងៃ ។ ឯអ្នកតែងកំណត់ហេតុ និងអ្នកជំនាញណាមួយ ដែលចៅក្រមបានចាត់ ក៏ត្រូវកោះឲ្យចូលមកព្រមគ្នា ក្នុងថ្ងៃនោះដែរ ។

តុលាការ អាចបង្គាប់ឲ្យបញ្ឈប់កិច្ចការ ទាំងនោះភ្លាម រហូតដល់មានសេចក្ដីសម្រេច អំពីបទល្មើសនោះជាស្ថាពរ បាន ។ សេចក្ដីសម្រេចនេះ ត្រូវប្រតិបត្តិ ក្នុងពេលជំរះរួចភ្លាម , ឬ ក្នុងពេលឲ្យដំណឹង ពីសេចក្ដីសម្រេចដល់សាមីខ្លួន, ប្រសិនបើ សាលក្រមនោះ ជាសាលក្រមដាច់ណាត់ , ទោះបីសាលក្រម នោះ នៅក្នុងអំណាចឧទ្ធរណ៍ ក៏ដោយ , ហើយ រាជការ អាចប្រើមធ្យោបាយ បង្ខិតបង្ខំយ៉ាងណា ដើម្បីឲ្យ សាលក្រមនោះ ត្រូវគេទទួលប្រតិបត្តិ តាមភ្លាមៗ ។

មាត្រា ៣៩៦ – ស្ដីពីបទល្មើស ប្រព្រឹត្ត លើបទបញ្ជា ខាងគង្គា និងរុក្ខា ។

មាត្រានេះ បានត្រូវនិរាករ ដោយព្រះរាជក្រម លេខ ១៩៧ ន. ស. ចុះថ្ងៃ ២៦ –៦– ៤៦ ។

(ចំពោះបទបញ្ជា ខាងក្រុមគង្គានិងរុក្ខា , ត្រូវមើលច្បាប់ដូចតទៅនេះ :

ព្រះរាជប្រកាស លេខ ៩ ចុះថ្ងៃ ១១ - ១ - ១៩៣៧ ; ព្រះរាជក្រម លេខ ១៩៧ ន ស. ចុះថ្ងៃ ២៦-៦-៣៦ ; ដេក្រេ ចុះថ្ងៃ ២-១.៣១ ។ ព្រះរាជក្រម លេខ ៣៣៨ ន ស ចុះថ្ងៃ

00222377

D99/3/3



៩-៧-៤៩; លេខ ៥២០ នស. ចុះថ្ងៃ ២១-៧-៤៩; លេខ ៥៥៧ នស. ចុះថ្ងៃ ២០-១២-៤៩ ។

បទបញ្ជា ស្តី អំពីប្រមាញ់ ត្រូវមើល ព្រះរាជប្រកាស លេខ ៥២ ចុះថ្ងៃ ១៧-៣-៣៩ ព្រះរាជក្រម លេខ ៥៦២ នស. ចុះថ្ងៃ ៣១-១២-៤៩; ដេក្រេ ចុះថ្ងៃ ៧ ៤-២៧ ។

បទបញ្ជា ស្តីពីនេសាទ ត្រូវមើល ព្រះរាជក្រម លេខ ៨៧-នស. ចុះថ្ងៃ២៣ ៤.៥៦ ។

មាត្រា ៣៩៧- ការបង់ដោយយឺតយូរ ឥតសមហេតុ នូវប្រាក់ពន្ធ ដែលជំពាក់ រាជការ ដូចជាពន្ធអាករ ឬ វិភាគទាន ផ្សេងៗ ត្រូវមាន ទោសលហុ ។

ការប្រកែក មិនព្រមបង់ ប្រាក់នោះ ដោយឥតសមហេតុ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។ បើ ការប្រកែកនេះ ធ្វើព្រមគ្នា ច្រើន នាក់ លើស ពីពីរនាក់ ឡើងទៅ ដោយសទ្ធិភាព រវាងគ្នា និងគ្នា នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ បើ ការប្រកែក នោះ ធ្វើ ដោយ វិហិង្សា ឬ ដោយការរំលោភ លើរូបកាយ នោះ, ត្រូវសម្រេច តាមបទ បញ្ញត្តិ នៃមាត្រា ៣៧០ ដែលស្តី ពីឧទ្ទាមកម្ម វិញ ។

ដំណើរយឺតយូរ និងការប្រកែកប្រណាំង ទាំងនោះ ត្រូវទុកជាសមហេតុ តែក្នុងករណី មាន ជម្ងឺ, មាន បន្ទុក គ្រួសារ ច្រើន លើសលុបពេក, មាន និក្ខមវេលា ទាំងបន្ទុំ, មាន គ្រោះថ្នាក់, មាន ចុបគ្រោះ, មាន ខូចខាតដំណាំ, មាន ចោរលួច, មាន អន្តរាយ, ហើយ ជាទុកលំទូទៅ, មាន ហេតុ ដែលមិនមែនកើតឡើង ពីឆន្ទៈ នៃអ្នកជាប់ពន្ធទេ ហើយ

និង ហេតុ ដែលបណ្តាលឲ្យខ្លួន ដល់នូវអសាធនភាព នេះ ។

អ្នកតំណាង អាជ្ញាធរសាធារណៈ ដែលមាន មុខងារ ជាអ្នកពិនិត្យ ត្រូវកត់ ដំណើរ យឺនយូរ និង ការប្រកែកប្រណាំង នេះ ក្នុងកំណត់ ហេតុ ដោយឡែកៗ ពីគ្នា ក្រោយដែលបានដាក់ កំហិត ដល់មនុស្ស ម្នាក់ៗ នោះ ឬ ដល់ពួកក្រុម នោះ ជាមុនសិន ព្រមទាំង បានកំណត់ រយៈវេលា ដែលត្រូវបង់ ប្រាក់ នោះ ផង ។

កំណត់ហេតុ មួយច្បាប់ ៗ ដោយឡែក ៗ ពីគ្នា នោះ ត្រូវចុះ ហេតុ ដែលអ្នកជាប់ពន្ធ អាង ដើម្បីនឹងរក យុត្តិកម្ម ក្នុងដំណើរយឺតយូរ និង ការប្រកែកប្រណាំង នេះ ឲ្យ ។

ចៅក្រម ត្រូវកំណត់ ចំនួន ទឹកប្រាក់ ដែលអ្នកជាប់ពន្ធ នៅជំពាក់ ហើយនិង ដាក់ ទណ្ឌកម្ម ឲ្យបង់ ប្រាក់ នោះ ដោយកំណត់ រយៈវេលា ដែលត្រូវដាក់គុកបន្ទោរ ប្រាក់ នោះ តាមមាត្រា ៣៧៧ និង តាមមាត្រា ១០ ដល់ មាត្រា១៣ ផង ។

មាត្រា ៣៩៨– ជនណា បានចូល មក ធ្វើការ បំរើ ម្ចាស់ផែនដី ឬ នីតិបុគ្គល ខាងរាជការសាធារណៈ បានទទួល បៀវត្សរ៍ ជាថ្នូរ ការ ពីមូលនិធិ នៃថវិកា ហើយ ហើយឈប់ ធ្វើការ នោះ ដោយឥត សមហេតុ, គៀស ខ្លួន បាត់, ព្រមទាំង បំបាត់ ប្រាក់ ដែលបានបើកមុន,

ហើយដែលឈ្មោះនេះ នៅជំពាក់ប្រាក់នោះ នៅឡើយ , ជននោះត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៣៩៩-( មាត្រានេះ បានដកយក ទៅបញ្ចូល ក្នុងក្រមតុលាការសឹកត្រង់មាត្រា ២៩៧ ហើយ ។

## ចំពូកប្រាំបួន
## អំពីបទល្មើស និងសីលធម៌ សាធារណៈ
### Des infractions contre la moralité publique

មាត្រា ៤០០- ការដាំ ឬ ផ្សំ កញ្ឆា ដើម្បីបរិភោគ ឬ ធ្វើជំនួញ ដំណាំកញ្ឆា នេះ ត្រូវហាមឃាត់ ។ ការប្រព្រឹត្ត ល្មើស នឹងបញ្ញត្តិ នេះ ត្រូវផ្ដន្ទា ទោស ជាមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៤០១- ជនណា ជក់ ឬ លេប, ឲ្យអ្នកដទៃ ជក់ ឬ លេបនូវកញ្ឆា ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៤០២- ជនណា ផ្ដល់ កញ្ឆា ឬ អាភៀន ដល់មនុស្សអាយុ តិចជាង ដប់ប្រាំបីឆ្នាំ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

អំពីអាភៀន, ត្រូវមើល ព្រះរាជក្រម លេខ ១០ ន.ស. ចុះថ្ងៃ ៣០-៥-៥៥ ដែលមាន នៅ ខាងចុង នៃសៀវភៅ នេះ ទៀតផង ។

00222380



មាត្រា ៤០៣– ប្រើប្រាស់ ក្មេង មិនទាន់ប្រការ ក្នុងផ្ទះ លក់ អាភៀន ត្រូវនិរាករដោយអនុភាព ព្រះរាជក្រមលេខ ១០-នស. ចុះថ្ងៃទី ៣០-៥-៥៥ ។

មាត្រា ៤០៤-ជនណា សំដែង អាកប្បកិរិយា ឲ្យគេ ឃើញជាក់ស្តែង នូវភាពស្រវឹងស្រា ក្នុងទីសាធារណៈ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៤០៥– ជនណា ផ្តល់ នូវទឹកស្រវឹង ដល់អនីតិជនអាយុ តិចជាង ដប់ប្រាំបីឆ្នាំ ឬ ផ្តល់ ដល់បុគ្គល កំពុងស្រវឹង, ទោះឲ្យផឹក នៅទី ដែលផ្តល់ នោះ ក្តី ទោះយកទៅឲ្យ ដល់ផ្ទះ ក្តី, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

(អំពីទឹកស្រវឹងនេះ, ត្រូវមើលព្រះរាជប្រកាសលេខ៧៨ ចុះថ្ងៃ២៨-៤-៤០ និងព្រះរាជក្រមលេខ ១៧៥ ន.ស– ចុះថ្ងៃ ៣០-១០-៤៧ ) ។

មាត្រា ៤០៦– ជនណា លេងល្បែង ស៊ីសង ជាប្រាក់ នៅផ្លូវធ្លាសាធារណៈ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

(អំពីល្បែង ស៊ីសង, មើលព្រះរាជក្រម លេខ ៥១ ន.ស. ចុះថ្ងៃ ទី ២៦-១០-៥៥ ដែលមាន ខាងចុង សៀវភៅ នេះ ។

មាត្រា ៤០៧ · ថ្មី (ព្រះរាជប្រកាសលេខ៣៦ចុះថ្ងៃ២៨-១០-៤០ ) ត្រូវធ្វើទោស ដាក់គុក ជាបទមជ្ឈិម ថ្នាក់ទីពីរ, ខ្មួយ ជាតិ និងពិន័យ

00222381



ជាបទមជ្ឈិម ថ្នាក់ទីបី, គុណមួយ ជាបី, ពោះជនណា តាំងឲ្យលេង ល្បែង ស៊ីសង ជាប្រាក់ នៅទីកន្លែងណា, ដោយយក ថ្លៃ ពីអ្នកចូល ទៅលេងក្តី, ដោយហូត ទឹកប្រាក់ ដែលលេងឈ្នះ ឬ ទឹកប្រាក់ ដែល ដាក់ទុកក្តី, ឬ ដោយអ្នកលេង ហៃគ្នា ឲ្យ ឬ ឲ្យ ប្រាក់ ផ្ទាល់ខ្លួនក្តី ។

សេចក្តី បញ្ញត្តិ នេះ ក៏ត្រូវសម្រេច លើជនណា ដែលទទួល ប្រាក់ ដាក់ ទុក ឲ្យអ្នកជាវ ក្នុងល្បែង ស៊ីសង នេះក្តី, លើជនណា បង្កើត ល្បែង ភ្នាល់ឥតអនុញ្ញាត គឺបរសត្វ, ប្រជល់សត្វ, បំបាប់ មនុស្ស, ល្បែងកំឡា ក្តី, លើជន ដែលពុំបាន អនុញ្ញាត ហើយ ហានរៃ ប្រាក់, ធ្វើ ឆ្នោតប្រាក់, ឆ្នោតវត្ថុក្តី ឬ លើជនណា ដែលគ្មាន អនុញ្ញាត ហើយ ដើររៃអង្គាស ប្រាក់ ឬ របស់ អ្វីនីមួយ ៗ ដើម្បីយកទៅ ធ្វើ ជាការកុសល ឬ ជាការសប្បុរស អ្វីក្តី, លើជនណា ដែលគ្មាន សិទ្ធិ អនុញ្ញាត ជាត្រឹមត្រូវ ហើយ ទទួល ប្រាក់កំណាន់, ទទួលអំណោយ ជាប្រាក់, ជារបស់ អ្វីក្តី, ដើម្បីយកទៅ ដាក់ ក្នុងល្បែង តាំងពួន ដែលពជការ បានអនុញ្ញាត ឲ្យលេង ឬ ដើម្បីយកទៅ ចូល បុណ្យ ផ្សេង ៗ ដែលពជការ បានយល់ព្រម ថា ជាប្រយោជន៍ សាធារណៈក្តី ។

វិរុទ្ធជន ទាំងឡាយ ដែលបានទទួល ទោស គ្រប់កំណត់ហើយ មិន ត្រូវអនុទោស គ្រង់ មាត្រា ៤៩ ក្នុងក្រមនេះ ចំនួន ប្រាំ ឆ្នាំ យ៉ាងតិច

ដប់ ឆ្នាំ យ៉ាងច្រើន តាមបញ្ញត្តិ ថែមទៀត ក៏បាន ហើយទិង គំហាត់ លំនៅ តាមកំណត់ ឆ្នាំ ខាងលើ នេះ ក៏បាន ។

បើ មិនកង់ពាលទេ ចៅក្រម នឹងត្រាប្រណី ទោស តាមបញ្ញត្តិ មាត្រា ក្រមព្រហ្មទណ្ឌ នោះ ពុំបាន ឡើយ ។

មាត្រា ៤០៨– អ្នកម្ចាស់ផ្ទះ ឬ អ្នកកាន់កាប់ ទីកន្លែង លេងល្បែង ហើយនិង ការទទួលធានា រ៉ាប់រង ក្នាល់ ដាក់ប្រាក់, អ្នក រៀបចំ ហើយនិងមេ ព្រមទាំង ភ្នាក់ងារ ស៊ីសង ទាំងប៉ុន្មាន ត្រូវមាន ទោស ជាមួយគ្នា ដូចខាងលើ ដែរ ។

មាត្រា ៤០៩– កាលណាបើ ក្នុងក្រុម អ្នកលេងល្បែង ឬ អ្នក មើល ល្បែង នោះ, មាន មនុស្ស អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ម្នាក់ ឬ ច្រើន នាក់ នៅរួម ជាមួយ ផង នោះ, អតិបរមា នៃទោស ដែល បានគ្រោងទុកមក នោះ ត្រូវយកមក ផ្ទួន ដែរ ។

មាត្រា ៤១០– ទោះក្នុងករណី ណា ក៏ដោយ, ប្រាក់ ដែលដាក់ ក្នុងល្បែង, ប្រាក់ ដែលមាននៅ ទឹងខ្លួន អ្នកចាត់ចែង , បង្កើតល្បែង, នៅ ទឹងខ្លួន មេល្បែង, នៅ ទឹងខ្លួន ភ្នាក់ងារល្បែង , នៅ ទឹងពួកអ្នក ជួយ ស៊ីសង ក្នុងល្បែង, នៅ ទឹងអ្នកទទួលភារៈ ខាងគណនេយ្យ

00222383





ហើយទិននៅ លើខ្លួន អន្តរការី ត្រូវរឹបអូស ទាំងអស់, កាលបើ ជនទាំង នោះ មាន អាយុ លើស ពីដប់ប្រាំបី ឆ្នាំ ឡើងទៅ ។ ឯសម្ភារៈ និង សង្ហារិម ដែលដាក់តាំង នៅ កន្លែង សម្រាប់ពីបង់ ល្បែង នោះ ក៏ ត្រូវអូសទុក ហើយរឹបយក ជាទ្រព្យរឹប ទាំងអស់ ។

មាត្រា ៤១១- ថ្មី (ព្រះរាជប្រកាស លេខ ៦៣ ចុះថ្ងៃ ២៨.៣.១៩៥០) ជនណា មាន អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ ហើយមាន ពិរុទ្ធ ជាបានលេង ល្បែង នៅ ទីកន្លែង ទាំងនោះ, ជននោះ ត្រូវមាន ទោស គុក ជាបឋមជ្ឈិម ថ្នាក់ ទីមួយ គុណមួយ ជាបី និង ពិន័យ ជាមជ្ឈិម ថ្នាក់ទីបី, បើ មិនកាន់តាលទេ និងត្រាប្រណី តាមបញ្ញត្តិ មាត្រា ក្រម ព្រហ្មទណ្ឌ ដែលបន្ធូរបន្ថយ ទោស នោះ ពុំបាន ឡើយ ។

មាត្រា ៤១២- បទបញ្ញត្តិ ទាំងឡាយ ដែលមានសំដែង ក្នុង មាត្រា ខាងលើ មិនត្រូវយកទៅ អនុវត្ត លើឆ្នោត ជាប្រាក់ និង ល្បែង ស៊ីសង ដែលពជការ មុខក្រសួង អនុញ្ញាត ឲ្យលេង ជាត្រឹមត្រូវ ក្នុង ពេល មួយដង មួយកាល នោះឡើយ ។

មាត្រា ៤១៣- ថ្មី (ព្រះរាជប្រកាស លេខ ៩ ចុះថ្ងៃ ១៥-១- ៣៨) បើ កាលណា បងការ ប្រាក់ ឬ បណ្ដាក់ ទំនិញ តាមដើមកំពង់ ហើយ កម្ម.

00222384





ដែលរាជការកំណត់ថ្លៃឲ្យលក់ ឬដោយធ្វើតាមតម្លៃជើងកំពង់, ដោយបានព្រមព្រៀងគ្នា តាមច្បាប់ដប្បវេណី ហើយ តែយក ការប្រាក់ ហួសពីអត្រា (taux) ដែលមានបញ្ញត្តិ ក្នុងព្រះរាជប្រកាស លេខ១៩៩ ចុះថ្ងៃ១៩ ខែកក្កដា ឆ្នាំ ១៩៣៤ នោះ, ប្រាក់ ដែលយក ហួស ទាំងប៉ុន្មាន ត្រូវយកមក កាត់សង ការប្រាក់ តាមអត្រា ធម្មតា ដែលជំពាក់ ពេញច្បាប់, រួចពីនោះ ត្រូវយកមក កាត់សង ប្រាក់ដើម ដែលជំពាក់នេះ ទៀត ។ បើ កាត់សង បំណុល នោះ ទាំងដើមទាំងការរួចស្រេចហើយ ហើយឃើញ ថា នៅសល់ ប្រាក់ ដែលទារ ជាការ នោះ ទៀត, ម្ចាស់បំណុល ត្រូវសង ប្រាក់ ដែលទារ លើស នោះ វិញ ព្រមទាំងការនៃប្រាក់លើស នេះ គិតតាំង ពីថ្ងៃ ដែលខ្លួន បានទទួលប្រាក់ នោះ រៀងមក ថែមទៀតផង ។

ក្នុងជំនួញ ក៏ត្រូវបញ្ញត្តិ ដូចគ្នា ដែរ, បើកាលណា គូសញ្ញា ព្រមព្រៀងគ្នា បង់ការប្រាក់ យកទៅធ្វើ ជំនួញ តែខាងម្ខាង ឬ ទាំងសងខាងក្តី មិនត្រូវឲ្យយក ការប្រាក់ លើស ពីអត្រាមធ្យម ត្រឹមត្រូវ ទៀងទាត់ ហើយ ថែម ពាក់កណ្ដាល នៃអត្រា នោះ ទៀតទេ ។ អត្រាមធ្យម គឺអត្រា ដែលអ្នក ម្ចាស់ប្រាក់ សុចរិត ធ្លាប់ ឲ្យខ្ចី ហើយយក ធ្លោះបង្ការគ្រោះថ្នាក់ ដូចស្ថាន ដែលឲ្យខ្ចី ប្រាក់នោះ ដែរ ។

អ្នកបង់ការ ប្រាក់ ទាំងឡាយ ដែលល្មើស ទំនងសេចក្តី បញ្ញត្តិ

ទាំងពីរស្ថាន ដូចមានសំដែង ខាងលើនេះ ត្រូវ ពិន័យ ជា មជ្ឈិម ថ្នាក់ទីពីរ; បើមាន ស្ថាន ពុំកងហាល ផង ត្រូវផ្ដន្ទា ទោសគុក ថ្នាក់ ទីពីរ ដដែល ហើយ ថែមទាំងពិន័យ ថ្នាក់ ដដែល នោះ ទៀតផង ។

ក៏ប៉ុន្តែ បទបញ្ញត្តិ នៃព្រះរាជប្រកាស លេខ ៩៩ ចុះថ្ងៃ ១៧ ខែ មិថុនា ឆ្នាំ ១៩៣៥ នេះ មិនត្រូវ អនុវត្ត លើធនាគារ បនការ ឲ្យ កសិករ ទេ ។

មាត្រា ៤១៤– ជនណា មាន ទម្លាប់ តែងទទួលបញ្ចាំ ចលវត្ថុ ដោយឥតមាន អនុញ្ញាត ពីរាជការ ជាមុន ទេ, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

បើ អំពើ ទទួលបញ្ចាំ នេះ យក អត្រា តាមសេចក្ដីព្រមព្រៀងគ្នា ឲ្យលើស ពីអត្រា ដែលច្បាប់ បានអនុញ្ញាត នោះ, ត្រូវយក ទោស ដែលមានសំដែង ក្នុងមាត្រា មុននេះ មកផ្ដន្ទា ជាអតិបរមា ។

មាត្រា ៤១៥– អំពើទទួលបញ្ចាំ ចលវត្ថុ នេះ នឹងត្រូវទុក ជា ជា ទម្លាប់បាន លុះណាតែ មាន ភស្តុតាង ថា ក្នុងរយៈវេលា មួយ ឆ្នាំ មាន មនុស្សច្រើន នាក់ បានមកបញ្ចាំ នឹងអ្នកទទួលបញ្ចាំ តែម្នាក់ នេះ មែនៗ

មាត្រា ៤១៦– ជនណា ប្រព្រឹត្តរំលោភ លើទំនុកចិត្ត, លើ

00222386

D99/3/3



សតិទន់ខ្សោយ, លើសេចក្ដីត្រូវការ ឬ លើពាល្យ នៃអនីតិជន អាយុ តិចជាង ម្ភៃមួយ ឆ្នាំ ហើយ ញ៉ាំងអនីតិជន នោះ ឲ្យប្រគល់ ដល់ខ្លួន នូវមូលនិធិ ឬ វត្ថុ មាន តម្លៃ ក្ដី, ឲ្យស្ម័គ្រដាក់ធានា, ឲ្យចុះហត្ថលេខា ក្រោមកិច្ចសន្យាតាំងខ្សោយ ក្ដី, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

វត្ថុ ដែលអនីតិជន បានប្រគល់ ទាំងប៉ុន្មាន, ទៅក្រម ត្រូវបង្គាប់ឲ្យប្រគល់ឲ្យ វិញ, ដោយមិនចាំបាច់ ឲ្យមាន តាំងខ្លួន ជាភាគីស៊ីវិល ទេ ។ កិច្ចសន្យា ដែលអនីតិជន ចុះហត្ថលេខា នោះ ត្រូវទុក ជាមោឃៈ ។

មាត្រា ៤១៧– ជនណា បញ្ចាំ ឬ ទទួលបញ្ចាំ តតិយជន ដើម្បីឲ្យផុតលេត ភាតព្វកិច្ច ណាមួយ ឬ ដើម្បីហេតុ អ្វីមួយ, ជននោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីមួយ ។

ប៉ុន្ដែ បទបញ្ញត្តិនេះ មិនត្រូវយកទៅ អនុវត្ត លើកិច្ចសន្យា ព្រមព្រៀង រវាងនិយោជក និង ឪពុកម្ដាយ នៃនិយោជិត ជាអនីតិជន អាយុ តិចជាង ម្ភៃមួយ ឆ្នាំ នោះ ឡើយ, ប្រសិនបើ ប្រាក់ឈ្នួល ដែលបានបើក មុន នោះ មិនទាន់លើស ពីថ្លៃឈ្នួល ពីរ ឆ្នាំ ទេ, ហើយមួយវិញទៀត បើប្រាក់ជំពាក់ នោះ ពុំមានគិត ការ ផងទេ ។

មាត្រា ៤១៨– ជនណា ទិញ ឬ លក់ មនុស្ស ទោះជាភេទ អ្វីក្ដី, អាយុ ប៉ុន្មាន ក្ដី, ឬ មាន សញ្ជាតិ អ្វីក្ដី, ទោះបី ទុក អំណាច ឲ្យលោះ

វិញ ក៏ដោយ, ក៏ជននោះ ត្រូវមានទោស មធ្យម ថ្នាក់ទីបី ដែរ ។

ល្គឹកណាបើ មនុស្ស ដែលជាកម្មវត្ថុ នៃកិច្ចសន្យា លក់ទិញ នោះ ជាអនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ វិញ អតិបរមា នៃទោស ដែលក្រោងទុក នោះ ត្រូវយកមក ផ្ទួន ជាដកប ។

ក្នុងករណីទាំងអស់នេះ, អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិ ស៊ីវិល និងតំហាត់លំនៅ នឹងយកមក អនុវត្ត លើវុទ្ធជន នោះ ផងក៏បាន ។

ក្នុងបទ នេះ, បំណង ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត ដែរ ។

មាត្រា ៤១៩– ជនណា ជួញ មនុស្ស គឺថាមាន ទម្លាប់ នៃទិញ ឬ ស្វែងរក មនុស្ស មកលក់, ជននោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ដែលហៅថា ទម្លាប់ នោះ គឺកាលណា មាន សំអាង ថា មនុស្ស រូបដដែល ម្នាក់ ឬ ច្រើននាក់ ចូលហ៊ុនគ្នា ធ្វើ ជំនួញ នេះ បានទិញ, បានរក, បានប្រមូល, បានលក់ មនុស្ស ជាច្រើន នាក់ ហើយ ។

មាត្រា ៤២០– ជនណា ពង្រត់, លួច, បង្វែះ នូវអនីតិជន អាយុ តិចជាង ដប់បី ឆ្នាំ ឲ្យបាត់ ពីកន្លែង ដែលអ្នកព្យាបាល ឬ អនុរក្ស អនីតិជន នោះ ទុកដាក់, ជននោះ ត្រូវមានទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

បទបញ្ញត្តិ ក្នុងមាត្រានេះ មិនត្រូវយកទៅ សម្រេច លើបុព្វញាតិ

00222388

D99/3/3



មាន ខាន់ស្លា , ឥត ខាន់ស្លា , ចិញ្ចឹម នៃអនីតិជន នោះ ទេ , ទោះបី បុព្វញាតិ នោះ អស់ អំណាចមេបា ក៏ដោយ ។

មាត្រា ៤២១ - អំពីពង្រត់ ឬ បំណង នឹងពង្រត់ អនីតិជន អាយុ តិចជាង ម្ភៃមួយ ឆ្នាំ តែច្រើនជាង ដប់បី ឆ្នាំ ត្រូវផ្តន្ទា ទោស មជ្ឈិម ថ្នាក់ទីមួយ , ប្រសិនបើ អនីតិជន នោះ ទៅ តាមអ្នកពង្រត់ ដោយស្ម័គ្រចិត្ត , ក្នុងករណីនេះ , អយ្យការ នឹងចោទប្រកាន់បាន តែ លុះតែមាន បណ្តឹង ពីបុគ្គល ដែលមាន អំណាច ត្រឹមត្រូវ តាមច្បាប់ លើអនីតិជន នោះ បានប្តឹង ជាមុន ផង ។

ប្រសិនបើ អនីតិជន នោះ អាយុ ច្រើនជាង ដប់បី ឆ្នាំ ត្រូវ គេ ពង្រត់ ដោយគ្មាន សេចក្តីស្ម័គ្រ ពីវា ទេ , ដោយការបោកបញ្ឆោត ឬ ដោយវិហិង្សា , អំពើពង្រត់ នេះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៤២២ - អំពើ ពង្រត់ មនុស្ស នីតិភាព ដោយមធ្យោ-បាយ បោកបញ្ឆោត ឬ ដោយវិហិង្សា ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៤២២ «ស្ទួន» ព្រះរាជក្រមលេខ ៣១០ ន.ស ចុះថ្ងៃ ១១-៣-៥៩

កាលបើ មាន បទមនុស្សគ្រាហ ដូចមានចែង ក្នុងមាត្រា៤២០ , ៤២១ វគ្គទី២ និងមាត្រា៤២២នៃក្រមព្រហ្មទណ្ឌ បានប្រព្រឹត្តឬប្រុង នឹងប្រព្រឹត្ត

00222389

D99/3/3



ដោយប្រើមធ្យោបាយ ណា ក្តី ក្នុងគោលបំណង នឹងបង្ខិតបង្ខំ ឲ្យធ្វើ នូវអំពើ ណា មួយ ឬ ឲ្យបង់ប្រាក់ ឬ វត្ថុមានតម្លៃ ឬ ឲ្យព្រម ចុះកិច្ចសន្យា អ្វីមួយ នោះ, ចារី ទាំងឡាយ និង អ្នកសមគំនិត ទាំងឡាយ ក្នុងបទមនុស្សគ្រាហ ឬ ក្នុងបំណងនៃបទមនុស្សគ្រាហ នេះ ត្រូវ ទោស ឧក្រិដ្ឋ ថ្នាក់ទីបី ។

ស្ថានត្រាប្រណីទាំងឡាយ មិនអាច អនុញ្ញាត ឲ្យបាន ឡើយ កាលបើ ជនដែលអំពើ ទាំងនោះ ជាអនីតិជន ឬ កាលបើ បទមនុស្សគ្រាហ នេះ បណ្តាលឲ្យ ស្លាប់ ដល់អ្នករងគ្រោះ នោះ ។

កាលបើ បទមនុស្សគ្រាហ ដែលមានចែង ក្នុងមាត្រា ៤២២ នៃក្រមព្រហ្មទណ្ឌ នោះ បានបម្រុង នឹងប្រព្រឹត្ត ឬ បានប្រព្រឹត្ត ចំពោះមនុស្ស គ្រប់គ្នា ក្នុងគោលបំណង ដែលមានចែង ក្នុងវគ្គទី១ ខាងលើនេះ ចារីទាំងឡាយ ក្នុងបទមនុស្សគ្រាហ នេះ ឬ ក្នុងការបំណង ត្រូវទទួល ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

ជនទាំងឡាយ ដែលបានយក ប្រយោជន៍ ឬ ដែលត្រូវទទួលប្រយោជន៍ ក្នុងមនុស្សគ្រាហ , ទោះបី មិនបានចូលរួម ក្នុងបទមនុស្សគ្រាហ ដូចមានចែង ក្នុងមាត្រានេះ ក៏ដោយ , ក៏ត្រូវធ្វើទោស ដូចអ្នកសមគំនិត ដែរ ។

មាត្រា៤២៣– ខាកាល ស្ត្រី ដែលគេ ពង្រត់ នោះ បានត្រូវគេ លក់ ឬ ឲ្យធ្វើ ជាពេស្យា នោះ, ពិរុទ្ធជន ត្រូវមានទោស ទក្រិដ្ឋ ថ្នាក់ទីពីរ ។

កាលណាបើ មាន សេវនកិច្ច ដោយកំហែងបង្ខំ ឬ មាន ការបៀតបៀន កើតទាស ក្នុងលក្ខខណ្ឌ ដូចមានសម្ដែង ក្នុងមាត្រា ៤៤២ លើរូបស្ត្រី ដែលពង្រត់ នោះ, មុនពេល ពង្រត់ក្ដី, ក្នុងពេល កំពុងពង្រត់ ក្ដី ឬ ក្រោយពេល ពង្រត់ ក្ដី, អ្នកដែលដល់ ក្នុងអំពើពង្រត់ នេះ ឬ អ្នកសមគំនិត ត្រូវមាន ទោស តែមួយ ដូចគ្នា ក្នុងឱកាស ដែលបទល្មើស នោះ បានប្រព្រឹត្ត រួចហើយ; បណ្ដាទោស នៃបទល្មើស ទាំងនេះ ទោសណា ធ្ងន់ជាងគេ ត្រូវយក ទោស នោះ មកសម្រេច ។

មាត្រា ៤២៤– (បទបញ្ញត្តិ ទាំងឡាយណា នៃមាត្រា ពី ៤២៤ ដល់ ៤៣៦ ដែលទាក់ទង នឹងពេស្យាការ ហើយ មាន សេចក្ដីផ្ទុយ នឹងបទបញ្ញត្តិ ទាំងឡាយ ក្នុងព្រះរាជក្រមលេខ ៦០ –ប រ. ចុះថ្ងៃ ១៦-១១-៦១ ដែលមាននៅ ខាងចុងសៀវភៅ នេះ, បទបញ្ញត្តិទាំងឡាយនោះ ត្រូវទុក ជាមោឃៈ) ។

ជនណា បើក បនពេស្យា ឥតអនុញ្ញាត ពីរដ្ឋការ ជាមុន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា៤២៥– ត្រូវទុក ជាមេ បនពេស្យា :

១– ជនណា បានទទួល ស្ត្រីជាមាស ម្នាក់ ឬ ច្រើននាក់ ទុកនៅ

00222391

D99/3/3



ក្នុងផ្ទះ របស់ខ្លួន ដើម្បីនឹងធ្វើ ជំនួញ នេះ ដល់ជន ដទៃ ។

២– ជនណា ចាំចារ ថៃចូល ពីអចិតជន របស់ស្ត្រីពេស្យា ,

ជនណា ដកយក គុណ ពីប្រាក់ចំណូល នៃពេស្យាការ នេះ ។

មាត្រា៤២៦– កាលណាបើ ស្ត្រីផ្កាមាស ដដែល នៅតែនឹង ផ្ទះណាមួយ ជាលំនៅក្តី, នៅ មាន កំណត់ ពេលម៉ោងក្តី ឬ ពុំនោះ សោតទេ, កាលណាបើ ស្ត្រីផ្កាមាស នោះ មកនៅ ទីផ្ទះ នោះ ដោយ ព្រមៗគ្នា ឬ ដោយបន្តបន្ទាប់គ្នា ដែលមាន លក្ខណៈ ដូចៗគ្នា, ផ្ទះ នោះ ត្រូវទុកជា ជាផ្ទះ ផ្តល់ ស្ត្រីពេស្យា ជាធម្មតា ។

មាត្រា៤២៧– ស្ត្រីណា បានប្រគល់ ខ្លួន ទៅ ក្នុងពេស្យាការ ជាធម្មតា, ស្ត្រីនោះ ត្រូវទុក ជាស្ត្រីផ្កាមាស ។ កាលណាបើស្ត្រី នោះ គ្មានមុខរបរ គ្មានវិជ្ជាជីវៈ និង គ្មានធនធាន អ្វី ឲ្យឃើញថា គួរល្មម នឹងចិញ្ចឹម ជីវិត បានទេ នេះម្យ៉ាង, ម្យ៉ាងទៀត, កាលណាបើ ឃើញថា ស្ត្រីនោះ បានទទួល ប្រុសៗដទៃ មកនៅ ទីផ្ទះ ខ្លួន, ហើយ បណ្តាប្រុស ទាំងនោះ, គ្មានប្រុស ណាម្នាក់ ឆ្លើយទទួល ជាព្រម ផ្គត់ផ្គង់ និង ចិញ្ចឹម ស្ត្រីនោះ សោះ ឬ ប្រុសនោះ គ្មានមធ្យោបាយ អ្វី គាប់ នឹងផ្គត់ផ្គង់ ចិញ្ចឹម ស្ត្រី នោះទេ, អំពើគ្មានទីពឹង នេះ ត្រូវទុក ជា ភស្តុតាង នៃរបរពេស្យា បាន ។

ជនណា មិនបានបំពេញ លក្ខខណ្ឌ ជាញាតិលោហិត ឬ ញាតិពន្ធ នឹងស្ត្រីពេស្យា ដូចមានកំណត់ទុក ក្នុងមាត្រា ១១៨ ដល់ ១២០ នៃក្រមរដ្ឋប្បវេណី ទេ, ជននោះត្រូវទុក ជាអ្នកដទៃ នឹងស្ត្រីពេស្យា ។

មាត្រា ៤២៨– ស្ត្រីផ្កាមាស ដែលមិនធ្វើ តាមបទបញ្ជាពេទ្យស្តីពីពេស្យាការ ត្រូវមាន ទោសលហុ (ព្រះរាជក្រមលេខ១៩៥– ន ស. ចុះថ្ងៃ ៣០–៤–៥៧ ឲ្យតម្លើងទោសលហុ ទៅ ជាទោសមជ្ឈិម ថ្នាក់ទីមួយ វិញ ), ប៉ុន្តែការបន្ទា ទោសនេះ មិនជាឧបសគ្គ ធ្វើឲ្យខកខាន អនុវត្ត លើស្ត្រីនោះ នូវបទបញ្ជា ស្តី ពីឲ្យស្ត្រី នោះ ទៅព្យាបាល ខ្លួន តាមវិធីបង្ការរោគ នោះទេ ។

មាត្រា ៤២៩– មេបន នៃពេស្យាការ ណា បានទទួលទុក ក្នុងបន របស់ខ្លួន នូវស្ត្រីផ្កាមាស ដែលមិនប្រតិបត្តិ តាមបទបញ្ញត្តិ នៃមាត្រា ខាងលើនេះ, មេបននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើបន នៃពេស្យាការ នោះ ជាផ្ទះ លួចលាក់ ទៀត, មេបន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ដល់អតិបរមា ។

មាត្រា ៤៣០– ស្ត្រីផ្កាមាស ណា មាន ពិរុទ្ធ ជាបានហៅ អ្នកដំណើរ នៅ លើផ្លូវសាធារណៈ ឬ នៅ ក្នុងកន្លែង ប្រជុំជន, ស្ត្រីផ្កាមាស នោះ ត្រូវមាន ទោសលហុ (ព្រះរាជក្រម លេខ ១៩៥ ន.ស. ចុះថ្ងៃទី៣០-៤-៥៧ តម្លើង ទោស នេះ ទៅ ជាទោសមជ្ឈិម ថ្នាក់ទីមួយ វិញ ) ។

មាត្រា៤៣១– មេបនពេស្យាឃារណា ទទួលស្ត្រីផ្កាមាស ជាអនីតិជន ឲ្យនៅក្នុងបនរបស់ខ្លួន, មេបននោះត្រូវទៅប្តឹង ការជ្រាជរ ក្នុងឃុំ អំពីការទទួល នេះ ភ្លាម ។

បើ ស្ត្រីផ្កាមាស ដែលមេបន បានទទួល នោះ មាន អាយុ តិចជាង ម្ភៃមួយ ឆ្នាំ, ការជ្រាជរ ក្នុងឃុំ ត្រូវឲ្យ មេបន នេះ បេញសោហ៊ុយ នាំស្ត្រី នោះ ទៅប្រគល់ឲ្យ គ្រួសារវិញ ជាការតព្វកិច្ច, កាលបើ ស្ត្រី នោះ គ្មានគ្រួសារ ទេ ឬ ក៏គ្រួសារ នោះ មិនព្រមទទួល រាប់រក ទេ, មេបន ត្រូវយក ស្ត្រីនោះ ទៅផ្ញើ ទីក្រុមកែ តម្រង់ សីលធម៌ ឬ ក៏ផ្ញើ ទីជន ដែលចាំងហ្វាត បេញដីកា (ordonnance) ចាត់មក ។ ជន ដែលសាលា ចាត់មកនោះ, ត្រូវមាន ការធានា គ្រប់យ៉ាង ថា ខ្លួន មាន សីលធម៌ សមល្មម មែន ហើយ ត្រូវសន្យា ជាមាំមួន ថា ខ្លួន ទីនថែ ចាំរក្សា ស្ត្រីបញ្ញើ នេះ ឲ្យបានល្អ ។

បទបញ្ញត្តិ ទាំងឡាយ នេះ ត្រូវយកទៅ អនុវត្ត លើស្ត្រី អនីតិភាព អាយុ ច្រើនជាង ដប់ប្រាំបី ឆ្នាំ ដែលបានប្តឹង រកការឃុំ ថា ខ្លួន មិនព្រមនៅ ជាពេស្យាការ ទេ នោះ បាន ដែរ ។

មេបន ទាំងឡាយ ដែលល្មើស ទីនឹងការតព្វកិច្ច នេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

អនុទោស៖ គ្រឿងស្ពានបន្ទាយសិទ្ធិស៊ីវិល និង ការហាត់លំនៅ ការប

យកទៅផ្ដន្ទា លើមេបន ទាំងនេះ ទៀត ក៏បាន ។ បើ មេបន នោះ ជាមេ លបលាក់, ទោស នេះ ត្រូវអនុវត្ត ឲ្យដល់ អតិបរមា ។

មាត្រា ៤៣២– មេបន ណា បង្ខាំង ឬ បំណាង ទីងបង្ខាំង ស្ត្រីផ្កាមាស ដែលមិនព្រមទៅ ឲ្យនៅ ក្នុងបនខ្លួន, មេបន នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី , ទោះបី ការ បង្ខាំង នេះ ដោយអាង ហេតុ ថា ស្ត្រីពេស្យា នោះជំពាក់ ប្រាក់ ខ្លួន ក្តី, ដោយអាង ហេតុ ដទៃទៀត ដែលតម្រូវ ឲ្យបង្ខាំង ស្ត្រីផ្កាមាស នោះ ក្តី, ឬ ដោយមាន ហេតុ ដែល ស្ត្រីផ្កាមាស នោះ ព្រមព្រៀងផង ក្តី ។

ទោះបី ជំពាក់ធ្លាក់ ដូម្តេច ក៏ដោយ, ក៏មេបន នោះ មិនអាចប្តឹង ឲ្យដាក់គុកបង្ខំទារ ប្រាក់ ដូចមានសំដែង ក្នុងក្រមរដ្ឋប្បវេណី នោះ បានទេ ។

បើស្ត្រី ដែលមេបន បង្ខាំង នោះ ឬដែលមេបនបំណាង ទឹង បង្ខាំង នោះ មានអាយុ តិចជាង ដប់ប្រាំបី ឆ្នាំ , ទោសទាំងឡាយខាងលើ នេះ ត្រូវយកមក ផ្ដន្ទា ជាអតិបរមា ។

ឯអនុទោស គ្រឿងស្ថាន បន្ថយសិទ្ធិស៊ីវិល និង គំហាត់លំនៅ អាច យកមក ផ្ដន្ទា ទៀតបាន ។

មាត្រា ៤៣៣– ជនណា ចែក ប្រាក់ គ្នា ដោយបានដឹងច្បាស់ ថា ប្រាក់ នេះ បានមក ពីពេស្យាការ នៃអ្នកដទៃ ឬ ជនណា ជួយ ឲ្យ

00222395



អ្នកដទៃ ធ្វើ ពេស្យាការ នៅ ផ្លូវសាធារណៈ, ជននោះត្រូវមានទោស មជ្ឈិមថ្នាក់ទីបី និងត្រូវមាន អនុទោស ត្រង់ស្ថានបន្ទុយ សិទ្ធិស៊ីវិល និង តំហាក់លំនៅ ទៀតផង ។

មាត្រា ៤៣៤– ជនណា មានរបរ រស់នៅ ដោយសារតែការ ជ្រើសរើស ស្ត្រីផ្កាមាស ឲ្យ បនពេស្យា, ជននោះ ត្រូវមាន ទោស ដូចគ្នា ។

ទោសទាំងនោះ ត្រូវយកទៅ ផ្តន្ទា ដល់អតិបរមា លើរូបជន ដែលជ្រើសរើស ស្ត្រីផ្កាមាស ដើម្បីបនពេស្យា ដោយលបលាក់ ។

មាត្រា ៤៣៥– ជនណា ដើរជៀវ ស្ត្រី ដែលនៅ ក្នុងអនីតិភាព អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឲ្យទៅធ្វើ ជាពេស្យា, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ហើយ អាច ត្រូវមាន អនុទោស ត្រង់ស្ថាន បន្ទុយ សិទ្ធិស៊ីវិល និង តំហាក់លំនៅ ទៀត ក៏បាន ។

បំណង ក្នុងបទល្មើស នេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត បទល្មើស នោះដែរ ។

មាត្រា៤៣៦– អ្នកណា ដឹកនាំ ឬ បំណង ទំនងដឹកនាំ ស្ត្រី អនីតិភាព អាយុ ក្រោមជាង ដប់ប្រាំបី ឆ្នាំ ឲ្យជាប់ចិត្ត ធ្វើ ជាស្ត្រីពេស្យា

00222396





ដោយ វិហិង្សា ឬ ដោយគំរាម ក្តី, ដោយឧបាយកល ទុច្ចរិត ក្តី, ជននោះ ត្រូវ មាន ទោស ដូចមានសំដែងមក ខាងលើ នេះ ។

ទោស នេះ ត្រូវ ផ្ទួន ជាអតិបរមា , ប្រសិនបើ ស្ត្រី ដែលគេនាំ ឲ្យធ្វើ ជាពេស្យា នោះ មាន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ។

មាត្រា ៤៣៧– អ្នកណា ជំរុញ ក្មេង ប្រុស ក្តី ស្រី ក្តី អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឲ្យលុះ ក្នុងផ្លូវអនាចារ, អ្នកនោះ ត្រូវមាន ទោសមធ្យម ថ្នាក់ ទីពីរ ។

មាត្រា ៤៣៨- ជនណា ធ្វើ ឲ្យអ្នកដទៃ អៀនខ្មាស ព្រោះ សម្រាត់ ខ្លួនឯង ដោយចេតនា ក្តី, ព្រោះលើកអាស ដោយអាការៈ ឬ ដោយអំពើ ណាមួយ ក្តី, ជននោះ មាន តិរុទ្ធ ជាបាបធ្វើ ឲ្យអាស្រូវកាស ដល់សាធារណជន , ហើយ ត្រូវមាន ទោសមធ្យម ថ្នាក់ទីមួយ ។

ទោស នេះ ត្រូវផ្ទួន ជាអតិបរមា លើជនណា ដែលបង្ខំ ឲ្យគេ ស្រាត កណ្តាលប្រជុំជន ឬ ដែលសម្រាត ខោអាវ គេ ឲ្យគេ អាក្រាត ក្រាំង កណ្តាល ប្រជុំជន ។

មាត្រា ៤៣៩– បទអាស្រូវកាស នេះ ទីទុក ជាប្រព្រឹត្ត ក្នុងទីសាធារណៈ , កាលណាបើ បទនេះ បានប្រព្រឹត្ត ក្នុងទី ចំពោះ

00222397

D99/3/3



មុខជនច្រើននាក់ ដែលមិនស្ម័គ្រ ផង ឬ ក៏ប្រព្រឹត្ត ក្នុងកន្លែង ណាមួយ ដែលប្រជាជន អាច មើលទៅ ឃើញ បាន ។

បទអាស្រូវកាស នេះ ទីទុក ជាសាធារណៈ ដែរ, កាលណា បើ អំពើ នេះ បានប្រព្រឹត្ត ក្នុងទី ចំពោះមុខ នៃអនីតិជន អាយុ តិច ជាង ដប់បី ឆ្នាំ, ទោះបីក្មេង នោះ ស្ម័គ្រ ជាមួយផង ក៏ដោយ ។ ប៉ុន្តែ បើ វា មិនស្ម័គ្រ ជាមួយផង ទេ, ទោស នោះ ត្រូវផ្ទួនទ្វេ ដល់អតិបរមា ។

មាត្រា ៤៨០- ជនណា ពោល ពាក្យ អាសគ្រាម ខុសទំនៀម ទំលាប់ ក្នុងទីសាធារណ, ជននោះ ត្រូវមាន ទោស លហុ ៖ ។

មាត្រា ៤៨១- ជនណា លក់ក្តី, ធ្វើអនុប្បទានក្តី, ឲ្យក្តី, ឬ ផ្ញើ ក្តី, ទាំង អនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ នូវវត្ថុ, គំនូរ, រូប, រូបថត, លិខិតអាសគ្រាម, ឬ ដែលធ្វើ ឲ្យសៅហ្មង ដល់ ទំនៀមទំលាប់, ជនណា បែកផ្សាយ ឬ ដាក់តាំង ដល់សាធារណជន នូវរបស់ ដូចខាងលើ នេះ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ជនណា ផ្សាយ ដល់សាធារណជន នូវសុន្ទរកថា, គំនូរ, លិខិត ឬ ទស្សនីយភាព អ្វីមួយ មាន ប្រភេទ ដូចខាងលើ នេះ, ដោយគ្រឿង បំពងសូរស័ព្ទ ក្តី, ដោយគ្រឿង បញ្ចាំងរូប ក្តី, ជននោះ ត្រូវមាន ទោសដូចគ្នា, តែប៉ុន្តែ បើ អំពើ ដែលបានពោលមក នេះ បានប្រព្រឹត្ត

00222398



ក្រោយ ដែលមាន ព្រះរាជក្រឹត្យ ហាមឃាត់ ដូចមានសំដែង ក្នុងមាត្រា ២៩៩ ហើយ, ជន អ្នកប្រព្រឹត្ត នោះ ត្រូវមាន ទោស តាមបទបញ្ញត្តិ នៃមាត្រា ២៩៩ នោះ វិញ ។

មាត្រា ៤៤២– ជនណា ស្ទាបអង្អែល កេរ្តិ៍ខ្មាស អ្នកដទៃ ឬ បង្ខំ អ្នកដទៃ ឲ្យធ្វើ អំពើ ឥតអៀនខ្មាស នេះ ដល់រូបខ្លួន វិញ, ជន នោះ ត្រូវមាន ពិរុទ្ធ ជាបានប្រព្រឹត្ត បទប្រទូស្ត កេរ្តិ៍ខ្មាស ។

អំពើ ប្រទូស្ត កេរ្តិ៍ខ្មាស ប្រព្រឹត្ត ដោយគ្មានវិហិង្សា, គ្មានឧបាយកល ទុច្ចរិត, លើបុគ្គល អនីតិភាព អាយុ តិចជាង ដប់បីឆ្នាំ ទេ, អំពើ នោះ ត្រូវផ្តន្ទា ទោសមជ្ឈិម ថ្នាក់ទីបី ។ បើ មាន ប្រើ វិហិង្សា ឬ ឧបាយកល ទុច្ចរិត ផង, អំពើ នោះ ត្រូវផ្តន្ទា ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ក្នុងករណី ទាំងអស់ ខាងលើ នេះ, អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិល និង តំហាត់លំនៅ អាច យកទៅ អនុវត្ត ទៀត ក៏បាន ។

ជនណា ស្ទាបអង្អែល ខ្លួនបុគ្គល ណាម្នាក់ ដោយតម្រេក ក្រៅ ពីគន្លងជាតិ នៃបុគ្គល នេះ មិនស្ម័គ្រ ផង, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ ទីមួយ, បើមួយនៃ ការស្ទាបអង្អែល នោះ ប្រព្រឹត្ត ដោយ វិហិង្សា, ទើបអំពើល្មើស នោះ ត្រូវផ្តន្ទា ទោស ដូចមានសំដែង ក្នុង មាត្រា ៤៩៥ និង តទៅ ។

00222399

D99/3/3



មាត្រា ៤៤៣- ជនណា បញ្ចូល ឬ បង់ ទឹងបញ្ចូល តាំងបន្ទុំ ឬ តាំងតម្រោម ទូវអង្គជាតិ របស់ខ្លួន ទៅ ក្នុងអង្គជាតិ នៃស្ត្រី ដែល ប្រកែក មិនព្រមស្ម័គ្រ ផង, ជននោះ ត្រូវទុក ជាមាន ពិរុទ្ធ ក្នុងបទ កំហែង រួមមេវណី ដល់ទីជម្រៅ ។

បើស្ត្រីរងគ្រោះ មាន អាយុ តិចជាង ដប់បី ឆ្នាំ វិរុទ្ធជន ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ ទីមួយ ។

បើ ស្ត្រី រងគ្រោះ មាន អាយុ ច្រើន ជាង ដប់បី ឆ្នាំ, វិរុទ្ធជន ត្រូវមាន ទោស មជ្ឈិម ថ្នាក់ ទីបី ។

មាត្រា ៤៤៤- បើ សេវនកិច្ច នោះ ប្រព្រឹត្ត លើស្ត្រី អនីតិជន អាយុ តិចជាង ដប់បី ឆ្នាំ ដោយមាន សេចក្តីស្ម័គ្រ ពីស្ត្រី នោះផង, គ្មាន ការបង្ខំ, គ្មានហិង្សា ឬ គ្មានឧបាយកល ទុច្ចរិត ទេ នោះ, វិរុទ្ធជន ត្រូវ មាន ទោស ឧក្រិដ្ឋ ថ្នាក់ ទីមួយ ។

មាត្រា ៤៤៥- ជនណា រំលោភ រួមមេវណី លើរូបស្ត្រី ដោយ ប្រើ ថ្នាំសណ្តំ ឬ ប្រើ ឧបករណ៍ អ្វី តាំងពួង ដែលនាំ ឲ្យបាត់ ស្មារតី ឬ មនុស្សណ្តំ, ជននោះ ត្រូវទាន ទោស ដូចគ្នា នឹងទោស កំហែង រួមមេវណី ដល់ទីជម្រៅ ដែរ ។

ត្រូវមាន ទោស ដូចគ្នាដែរ, ជនណា ឡើងលប ស្ត្រី ដែលគេ

00222400



កំពុងដេកលក់ ដើម្បីសេពសន្ថវៈ ឬ បំណង សេពសន្ថវៈ ។

មាត្រា៤៤៦– ទោសមជ្ឈិម ខាងលើនេះ នឹងត្រូវយកទៅ ផ្តន្ទាជាអតិបរមា, កាលណាបើ បទកំហែង រួមវេណី នោះ ចូល ក្នុងករណី ដូចតទៅនេះ :

១– បើ ស្ត្រី ដែលត្រូវគេ កំហែងរួមវេណី នោះ ជាស្ត្រីក្រមុំព្រហ្មចារី,

២– បើ ស្ត្រីរងគ្រោះ នោះ ជាស្ត្រីបញ្ញើ ឬ នៅក្រោមអំណាច, ក្រោមការត្រួតត្រា, ការឃោមល្បាត ឬ ការថែរក្សា នៃចារី ដែលកំហែងរួមវេណី ឬ នៃអ្នកសមគំនិត នឹងចារីនេះ,

៣– បើ ស្ត្រីរងគ្រោះ នោះ មានជាប់ ជាញាតិលោហិត ឬ ញាតិពន្ធ នឹងចារី ឬ នឹងអ្នកសមគំនិត ណាម្នាក់ ត្រឹមថ្នាក់ទីបី ជាកំណត់,

៤– បើ ស្ត្រី ដែលគេ កំហែងរួមវេណី នោះ ជាប្រពន្ធ របស់គេមានខាន់ស្លា,

៥– បើ ស្ត្រី នោះ ត្រូវចារី ច្រើន នាក់ រួមវេណី បន្តៗ គ្នា,

៦– បើ បទកំហែងរួមវេណី នេះ មាន អ្នកសមគំនិត, អ្នកជួយទំនុកបំរុង ផង ។

មាត្រា ៤៤៧– បុរស និង ស្ត្រី ណា ជាប់ ជាញាតិលោហិត

ឬ ញាតិពន្ធ នឹងគ្នា ដូចមានចែង ក្នុងច្បាប់ ហើយសេពសន្ថវៈ ទាំងគ្នា, បុរស, ស្ត្រី នោះ ត្រូវមាន កំហុស ជាសន្មត់; បទល្មើស នេះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ៤៤៨- ត្រូវទុក ជាសន្មត់, សេវនកិច្ច រវាងបុព្វញាតិ នឹងបច្ឆាញាតិ មាន ខាន់ស្លា, ឥត ខាន់ស្លា ឬ ចិញ្ចឹម, រវាងបុព្វញាតិ នឹងបច្ឆាញាតិ ខាងសហព័ន្ធ, មាន ខាន់ស្លា, ឥត ខាន់ស្លា ឬ ចិញ្ចឹម, រវាង បងប្អូន បង្កើត, រួមលោហិត, រួមឧទរ ឬ ចិញ្ចឹម, រវាងមា មីង នឹងក្មួយ, រវាងបងថ្លៃនឹង ប្អូនថ្លៃ នឹង រវាងមា មីងក្មេក នឹងក្មួយថ្លៃ ។

មាត្រា ៤៤៩- ប្រពន្ធ មាន ខាន់ស្លា ណា, ទោះជាថ្នាក់ទី ប៉ុន្មានៗ ក្ដី បានរួម សេវនកិច្ច ដោយចេតនា ជាមួយ នឹងបុរស ដទៃ, ក្រៅពីប្ដីខ្លួន, ក្នុងពេល ដែលខ្លួន នៅមាន អាពាហ៍ពិពាហ៍ នៅឡើយ ប្រពន្ធ មាន ខាន់ស្លា នោះ ត្រូវមាន ពិរុទ្ធ ជាបានផិត, ហើយ ត្រូវ មាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ ឯអ្នកសមគំនិត ត្រូវមាន ទោស ដូចគ្នា ដែរ, លើកលែងតែ អ្នកសមគំនិត នេះ ជាមនុស្ស ពុំកងចាល, ទើប ជន នេះ ត្រូវមាន ទោស ធ្ងន់ជាង ស្ត្រី នោះ បាន ។

កាលណាបើ បុរស រួមសេវនកិច្ច នឹងស្ត្រីផិត នេះ មាន សំអាង ថា ខ្លួន មិនបានដឹងថា ស្ត្រី នោះ មាន ប្ដី មាន ខាន់ស្លា ទេ, ប្រុស

00222402

D99/3/3



នោះ មិនទុក ជាសមគំនិត ក្នុងបទផិត ឡើយ ។

បទផិត ត្រូវឲ្យមាន កត្តាណាមួយ ដូចខាងក្រោម នេះ :

១- វិវេចន ទទួលសារភាព,

២- ប្រុស ឬ ស្រី បានផ្ញើ លិខិតឆ្លើយឆ្លង គ្នា, ហើយ លិខិត នេះ លាតត្រដាង យ៉ាងច្បាស់ នូវការផិត នោះ,

៣- ការប្រទះឃើញ ប្រុស និងស្រី កំពុងផិត ដោយជាក់ស្តែង មិនអាច ឲ្យមាន មន្ទិលសង្ស័យ ក្នុងសេវនកិច្ច នេះ ឡើយ ។

មាត្រា ៤៥០- ត្រូវទុក ជាមាន ពិរុទ្ធ ក្នុងបទទ្វេពន្ធភាព :

១- បុរសណា មាន អាពាហ៍ពិពាហ៍ ខាន់ស្លា ទីមួយ, មិនទាន់ ដាច់ នៅឡើយ, ហើយរៀប អាពាហ៍ពិពាហ៍ ខាន់ស្លា ទីមួយ ទៀត ។

២- ស្ត្រី ដែលមាន ខាន់ស្លា ទីមួយ ឬ ទីពីរ មិនទាន់ដាច់ នៅឡើយ, ហើយ រៀប អាពាហ៍ពិពាហ៍ ទីមួយ ឬ ទីពីរ ទៀត ។

អំពើ ល្មើសនេះ ត្រូវផ្តន្ទាទោសមជ្ឈិម ថ្នាក់ទីពីរ ។

ក្នុងបទទ្វេពន្ធភាពនេះ, អយ្យការ អាចចោទ ដោយចិត្តឯង ក៏បាន, ចោទ តាមបណ្តឹង របស់ប្តី ឬ ប្រពន្ធ ក៏បាន ។ ក្នុងករណី ដែលអយ្យការ ចោទប្រកាន់ ប្រពន្ធ តាមបណ្តឹង របស់ប្តី មុននោះ, បទបញ្ញត្តិ ត្រង់បទផិត ដែលស្តី ពីឈប់ប្តឹង ឬ ពីបោះបង់ បណ្តឹង ពេលក្តី, ដែលស្តី ពីទោស ដែលត្រូវផ្តន្ទា ក្តី, មិនត្រូវយកមក អនុវត្ត ឡើយ,

00222403



ប៉ុន្តែ អយ្យការ អាចចោទប្រកាន់ ប្តី ក្រោយនេះ ពីបទសមគំនិត ក្នុងបទទ្វេពន្ធភាព បាន, ប្រសិនបើ មាន សំអាង ច្បាស់ ថា ប្តី ក្រោយ នេះ បានដឹង ដែរ ថា ប្តីមុន និង ប្រពន្ធ ដែលខ្លួន ការ នេះ មាន អាពាហ៍ពិពាហ៍នឹងគ្នា មិនទាន់ ដាច់ នៅឡើយ ទេ ។

ជនទាំងឡាយ ដូចខាងក្រោម នេះ ត្រូវជាប់ចោទ ពីបទសមគំនិត ក្នុងបទទ្វេពន្ធភាព ដែរ :

ស្ត្រី ដែលការ ជាមួយ នឹងប្រុសទ្វេពន្ធ , ឪពុកម្តាយ នៃទ្វេពន្ធ, ជន អ្នកបានព្រមព្រៀង ឲ្យរៀប អាពាហ៍ពិពាហ៍ បណ្តាលឲ្យមាន ទ្វេពន្ធភាព នេះ , អ្នកមហា , អ្នកបែបួរ និង សាក្សី , កាលណាបើមាន ពិរុទ្ធ ថា ជនទាំងនេះ មិនមែន ជាមិនដឹង ថា បំណង អាពាហ៍ពិពាហ៍ មុន នោះ នៅ មិនទាន់ ដាច់ នៅឡើយ ។

មន្ត្រី អត្រានុកូលដ្ឋាន ដែលទទួល បណ្តឹង និង ចុះ បញ្ជីអាពាហ៍ពិពាហ៍ នោះ ក៏ត្រូវមាន ទោស ដូចគ្នា ដែរ ។

នាកាលបើ មន្ត្រី អត្រានុកូលដ្ឋាន ដែលចុះបញ្ជី អាពាហ៍ពិពាហ៍ នោះ បានដឹង ថា បំណង អាពាហ៍ពិពាហ៍ មុន របស់ប្តី ឬ ប្រពន្ធនោះ នៅ មិនទាន់ ដាច់ ទេ, មន្ត្រីនេះ មិនត្រូវមាន ទោស ពីសមគំនិត ក្នុងបទទ្វេពន្ធភាព នោះ ទេ , គឺត្រូវមាន ទោស ដូចមានសម្តែង ក្នុងវគ្គទី ១ នៃ មាត្រា ២៦០ នៃក្រមនេះ វិញ ។

00222404





អាពាហ៍ពិពាហ៍ ដែលរៀបលើកមុន នោះ នឹងទុក ជាមោឃៈ បាន លុះណាតែ មាន សំអាង លើលិខិតមរណភាព របស់សហព័ទ្ធ ដែល ការមុន ឬ មាន សំអាង លើសេចក្ដីសម្រេច ជាស្ថាពរ របស់តុលាការ ដែលកាត់ ឲ្យអាពាហ៍ពិពាហ៍ មុន ដាច់ស្រឡះហើយ ឬក៏មាន សំអាង លើបណ្ដឹង ពីអវត្តមាន នៃសហព័ទ្ធ តាមល័ក្ខខ័ណ្ឌ ដូចមានសម្ដែង ក្នុង មាត្រា ៨៧ និង តទៅ នៃក្រមរដ្ឋប្បវេណី ។

សេចក្ដីសម្រេច របស់តុលាការ ដែលកាត់ ពីបទ ទ្វេពន្ធភាព ត្រូវ តែនិយាយ ជាដរាប ថា ត្រូវបដិសេធចោល ឬ ត្រូវទុក អាពាហ៍ពិពាហ៍ ដែលគេ ប្ដឹង ពីទ្វេពន្ធភាព នេះ ផង ។

មាត្រា ៤៨១ - ប្ដីណា នាំ ស្ត្រី ផ្កាមាស ឬ សហាយ ទៅនៅ ក្នុងផ្ទះ ជាលំនៅ របស់ប្រពន្ធ, ទោះបីប្រពន្ធ ព្រមព្រៀងផង ក៏ដោយ, ក៏ ប្ដីនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ដែរ ។ បើ ផ្ទះនោះ មាន កូន ក្មួយ ១ នៅ ជាមួយ ដែរ, ទោស នោះ ត្រូវផ្ដន្ទា ដល់អតិបរមា ។

មាត្រា ៤៨២ - ប្រពន្ធទីមួយ ឬ ទីពីរ ណា បានរត់ចោល លំនៅ សង្វាស, ហើយ មេឃុំ បានដាក់ កំហិត ជាទៀងទាត់ ឲ្យវិលទៅ លំនៅ សង្វាស វិញ, ប្រពន្ធ នោះ នៅតែប្រកែក មិនព្រម វិល ទៅ នៅ វិញ ទេ, ដោយឥតហេតុ ដ៏គួរ តាមច្បាប់, ប្រពន្ធនោះ ត្រូវមាន ទោស

00222405





មជ្ឈិម ថ្នាក់ទីមួយ ។

មេឃុំ ខាងលំនៅ ដែលប្រពន្ធ នោះ នៅ សំណាក់ ត្រូវតែដាក់ កំហិត, កាលណាបើ ប្ដីខាងនោះ បានប្ដឹង ជាលាយលក្ខអក្សរ សុំឲ្យដាក់ កំហិត នោះ ដល់ប្រពន្ធគេ, ដល់ម្ចាស់ផ្ទះ ឬ ដល់នាយគ្រួសារ ដែល ប្រពន្ធ នោះ នៅនៅជាមួយ ។

ហេតុ ជំនួរ ទទឹងច្បាប់ ដែលប្រពន្ធនោះ អាងមក ត្រូវចៅក្រម ថ្លឹង មើល ដោយបរិមានុភាព; បណ្ដឹង សុំលែង គ្នា ត្រូវទុក ជាហេតុ ជំនួរ ទទឹង ច្បាប់ បាន ពីត្រឹម ថ្ងៃ ប្ដឹង ដរាប ដល់ថ្ងៃ មាន សេចក្ដីសម្រេច របស់តុ-លាការ ជាស្ថាពរ តាមទីតិវិធី ។

បើប្រពន្ធ នោះ នៅនៅ ផ្ទះ អ្នកដទៃ, អ្នក ទទួលឲ្យនៅ នេះ, ទោះបើ បានទទួល កំហិត ហើយ, ហើយ នៅតែរង ឲ្យនៅ, ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ, កាលណាបើ សេចក្ដីប្រកែក នោះ គ្មាន ហេតុអ្វី ជាយុត្តិកម្ម សោះ ។

ប្រពន្ធ និង ជន អ្នកឲ្យផ្ទះនៅ មិនអាច ត្រូវចៅក្រម យកទៅ ដាក់ ឃុំឃាំង ជាបណ្ដោះអាសន្ន បាន ទេ ។

មាត្រា ៤៨៣ – បទល្មើស ដែលមានសំដែង ក្នុងមាត្រា ៤៤៩ ៤៨១, និង ៤៨២, ទឹងយកទៅ ចោទ បាន, លុះណាតែ មាន បណ្ដឹង ពីសហព័ទ្ធ ជាមុនសិន ។ អ្នកនោះ អាច ឈប់ប្ដឹង វិញ បាន ជា

ដកប ។ អ្នកនេះ អាចសុំ ឲ្យតុលាការ ដោះ ទណ្ឌិត នោះ ឲ្យនៅ ក្រៅឃុំ បានដែរ ។

ក្នុងបទផិត ឬ បទបោះបង់ លំនៅសហវាស, កាលបើ ប្តី សុំ ឈប់ប្តឹង ឬ សុំ ឲ្យប្រពន្ធ ជាទណ្ឌិត នោះ នៅ ក្រៅឃុំ, អ្នកសមគំនិត ក្នុងបទផិត នេះ ព្រមទាំង អ្នកឲ្យផ្ទះ ដល់ប្រពន្ធ ដែលរត់ នេះ នៅ ក៏ត្រូវបាន រួច ខ្លួន ដូចគ្នា ដែរ ។

មាត្រា ៤៥៤– បើក្រោយ ពីប្រពន្ធ ត្រូវទណ្ឌកម្ម មក ឬ ក្រោយ ពីប្តី បានប្តឹង ពីបទផិត មក, ប្តី ត្រឡប់ មកនៅ រួមរស់ ជាមួយ នឹងប្រពន្ធ មាន ទោស ឬ ជាប់ចោទ នោះ វិញ, នាអនាគត ប្តី នេះ គ្មានសិទ្ធិ នឹងប្តឹង ពីប្រពន្ធខ្លួន ពីបទផិត ទៀត ឡើយ ។

មាត្រា ៤៥៥– ជនណា ធ្វើ ឬ ប៉ន់ នឹងធ្វើ ដោយប្រការយ៉ាង ណា ក្តី ឲ្យស្ត្រី មានផ្ទៃ រលូត កូន, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ, ប្រសិនបើ ការរលូត នោះ បានធ្វើ ឬ បានបំណង នឹង ធ្វើ ដោយគ្មាន សុគ្រចិត្ត ពីស្ត្រី នោះ ផងទេ; ផ្ទុយ ទៅវិញ, បើស្ត្រី នោះ ព្រមផង, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ហើយ ស្ត្រី មានផ្ទៃ ដែលព្រម ឲ្យគេ រំលូត ឬ បំណង រំលូត នោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ។

00222407

D99/3/3



មាត្រា ៤៩៦- ស្ត្រី មានផ្ទៃ ណា បានប្រើ វិធី រំលូត ដើម្បី រំលូត ខ្លួនឯង, ស្ត្រី នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។ ទោស នេះ ត្រូវផ្ទួនា ជាអតិបរមា លើជន អ្នកសមគំនិត ។

មាត្រា ៤៩៧- ក្នុងករណី ដែលរំលូត ឬ បំណងរំលូត នេះ បណ្តាល ឲ្យមាន ពិការ ជានិច្ច ឬ ឲ្យដល់ នូវមរណៈ លើរូបស្ត្រី មានផ្ទៃនោះ, ជន អ្នកប្រើ ឧបាយ រំលូត នេះ, អ្នកប្រាប់ វិធី រំលូត ដល់ស្រី ផើគ្រោះនោះ ដោយដឹង ថា ស្ត្រីនោះ មុខតែ ប្រើ វិធីទាំង នោះ ជាមិនខាន ឬ អ្នកផ្តល់ ឧបករណ៍ ឬ ថ្នាំ ដល់ស្ត្រី នោះ ដោយដឹងថា វត្ថុ ទាំង នោះ សម្រាប់យកទៅ រំលូត, ជននោះ ត្រូវមាន ទោស, តាមការណ៍, ជាអ្នក ដៃដល់ ឬ ជាអ្នកសមគំនិត ក្នុងបទឧក្រិដ្ឋ ដូចមានសំដែង និង ឲ្យផ្ទួនា ទោស តាមមាត្រា ៤៩៤, ៤៩៨ និង ៥០៣ ។

មាត្រា ៤៩៨- កាលបើ មានសំគាល់ ថា ក្រោយ ពីរំលូត មក ទារក បានកើតមក រស់ ហើយអាច រស់ តទៅបាន, ប៉ុន្តែក៏ត្រឡប់ ជាស្លាប់ ទៅវិញ ព្រោះខ្វះ ការថែទាំ ឬ ព្រោះមធ្យោបាយ ណាមួយ ផ្សេង ទៀត, អ្នកទទួលខុសត្រូវ ចំពោះការរំលូត និង មរណៈ នៃទារក នោះ ត្រូវជាប់ទោស ពីបទទារកឃាត ។

មាត្រា ៤៥៩- ការរំលូត មិនត្រូវមាន ទោស ទេ, កាលណា បើអំពើ នេះ ជាមធ្យោបាយ ចាំបាច់ មួយ ដើម្បីស្រោចស្រង់ ជីវិត ម្តាយ ទារក នោះ ឲ្យរួច ពីគ្រោះថ្នាក់ ហើយ ក្នុងការរំលូត នោះ, មាន គ្រូពេទ្យ ទទួល ខុសត្រូវ និង មាន គុណភាព មកជួយ រំលូត ផង ព្រមទាំង បានឲ្យ ដំណឹង ដល់អាជ្ញាធរ ក្នុងឃុំ ជាមុនទៀត ។

មាត្រា ៤៦០- ទារកឃាត គឺឃាតកម្ម លើរូបទារក ដែលទើបនឹងកើត ។ អ្នកដៃដល់ និងអ្នកសមគំនិត ក្នុងបទនេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។ ឯម្តាយ ទារក ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ៤៦១ - (ព្រះរាជក្រម លេខ ៣២៩ ន.ស ចុះថ្ងៃ១១ - ៣ - ៥២) ជនណា មាន កាតព្វកិច្ច ត្រូវប្តឹង អំពីកំណើត ហើយធ្វេសប្រហែស មិនបានប្តឹង ឬ មិនព្រម ប្រតិបត្តិ តាមសេចក្តីបញ្ញត្តិ មាត្រា ៤៩, ៥០ និង៥៣ នៃក្រមរដ្ឋប្បវេណី, ជននោះ ត្រូវមាន ទោសលហុ ។

មាត្រា ៤៦២- ជនណា បានឃើញ ទារក ទើបនឹងកើត ដែលគេ បោះបង់ចោល, ជននោះ ត្រូវតែយក ទារក នោះ ទៅប្រគល់ ដល់ មន្ត្រី អត្រានុកូលដ្ឋាន ក្នុងឃុំ ព្រមទាំង សំលៀកបំពាក់ ដែលជាប់ នឹងខ្លួនទារក ហើយនិង ឲ្យការណ៍សព្វគ្រប់ អំពីកាលៈទេសៈ, ពេល

វេលា និង ទីកន្លែង ដែលខ្លួន ប្រទះឃើញ ទារក នោះ ផង, បើពុំ ធ្វើ ដូច្នោះ ទេ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា៤៦៣- ជនណា យក ក្មេង អាយុ តិចជាង ប្រាំពីរ ឆ្នាំ, ទៅប្រោសចោល ក្នុងកន្លែង ណាមួយ ឆ្ងាយ ដាច់សន្លែង ពីលំនៅ អ្នកស្រុក, ស្រែកហៅ មិនឮ, ជននោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីពីរ ។

បើ បំណង ប្រោសចោល ឬ បានប្រោសចោល ក្មេង នោះ នៅទីជិតលំនៅ អ្នកស្រុក, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី វិញ ។

មួយទៀត ជននោះ នឹងត្រូវផ្តន្ទា អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិល ព្រមទាំងដកអំណាច មេបា ទៀត ក៏បាន ។

មាត្រា៤៦៤- នាកាល ក្មេង បព្រោស នោះ មាន អាយុច្រើន ជាង ប្រាំពីរ ឆ្នាំ តែតិចជាង ដប់បី ឆ្នាំ, អ្នកយកទៅប្រោសចោល ត្រូវ មាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ, ប្រសិនបើ អំពើនោះ បានសម្រេច ហើយ ឬ នឹងបានសម្រេច តាមលក្ខខណ្ឌ ទាំងឡាយ ដែល មាន លក្ខខណ្ឌ ដែលធ្វើឲ្យក្មេង នោះ មិនអាច រស់នៅ តទៅ ដោយ មធ្យោបាយ របស់វា បាន ជាដើម ។

ជននោះ ត្រូវដក អំណាច មេបា ចេញ ទៀត ។

មាត្រា៤២៥– ជនណា ទទួល ខុសត្រូវ លើរូបកុមារ អាយុ តិចជាង ដប់បី ឆ្នាំ ហើយ មិនព្រមយក កុមារ នោះ មកបង្ហាញ អាជ្ញាធរ ក្តី, មកបង្ហាញ បុគ្គល ដែលមាន គុណភាព ក្នុងការទារ កុមារនោះ មកមើល ក្តី, ដោយមិនអាចជូន ភស្តុតាង ថា ក្មេង នោះ បាត់ខ្លួន ដោយ ហេតុ អ្វី ទេ, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៤២៦ - ជនណា មានពិរុទ្ធ ជាបានពង្រត់ ឬ ទទួល បំពួន នូវទារក ទើបនឹងប្រសូត ឬ ក៏ ផ្ដូរ រូប ទារក ម្នាក់ នឹងទារកម្នាក់ ទៀត, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ក្នុងករណីដែលយក ទារក ណាមួយ ទៅក្លែងថា ជាកូន របស់ ស្ត្រី ដែលពុំមែន ជាម្តាយ នោះ, ពិរុទ្ធជន ត្រូវមាន ទោស ដូចគ្នា ។

មាត្រា ៤២៧– ជនណា ធ្វើបាប ដោយចេតនា នូវក្មេង អាយុ តិចជាង ដប់បី ឆ្នាំ ដោយបង្អត់ អាហារ ឬ មិនឲ្យមាន ការថែទាំ ជាចាំបាច់ តាមអាយុវា ទេ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី, ជននោះ នឹងត្រូវ អនុទោស ត្រង់ស្ថាន បន្ទាបសិទ្ធិស៊ីវិល ព្រមទាំងដក អំណាច មេបា ផង ទៀត ក៏បាន ។

មាត្រា ៤២៨– ជនណា បង្ខំ អនីតិជន អាយុ តិចជាង ដប់ប្រាំបី ឆ្នាំ ឲ្យធ្វើការ ហត់នឿយ ហួសកម្លាំង ឬ ក៏បង្ខំប្រើ ឲ្យយូរ ហួស កំណត់

00222411

D99/3/3



វេលាធ្វើការ, ជននោះត្រូវមានទោសមធ្យមថ្នាក់ទីពីរ ។

ត្រូវមានទោសដូចគ្នា, បើជនណាប្រើអនីតិជននោះឲ្យធ្វើការងារណាដែលនាំឲ្យមានព្យសនកម្មដល់សុខភាពឬដែលផ្ទុយនឹងការធាត់ធំនៃរូបកាយអនីតិជននោះ ។

មាត្រា ៤៦៩- ជនណាមានអំណាចមេបាលើកុមារដែលមានអាយុល្មមរៀនសូត្របាន ហើយគាត់ខានឬប្រកែកមិនព្រមឲ្យកុមារនោះរៀនសូត្រជាទៀងទាត់ ដោយគ្មានហេតុជាសំខាន់សោះ, ជននោះត្រូវមានទោសមធ្យមថ្នាក់ទីមួយ ។

អាយុដែលល្មមរៀនសូត្របាននោះគឺអាយុប្រាំពីរឆ្នាំ ។

ហេតុដែលជាសំខាន់នោះគឺ: - កុមារនោះមានសុខភាពមិនល្អ, - ទីលំនៅឆ្ងាយពីសាលារៀនហួសពេក, - គ្រួសារទីទាល់ក្រខ្លាំងពេក,

មាត្រា ៤៧០- ជនណាជេរ, ប្រមាថ ឬគំរាមបុព្វញាតិមានខាន់ស្លាក្តី, ឥតខាន់ស្លាក្តី ឬបញ្ចឹមក្តីរបស់ខ្លួន ឬជេរ, ប្រមាថ, គំរាមបុព្វញាតិមានខាន់ស្លាក្តី, ឥតខាន់ស្លាក្តី ឬបញ្ចឹមក្តីរបស់សហព័ទ្ធខ្លួន ជននោះត្រូវមានទោសមធ្យមថ្នាក់ទីបី ។

ជនណាជេរ, ប្រមាថ ឬគំរាមសហព័ទ្ធចុងរបស់បុព្វញាតិ

00222412



មានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម របស់ខ្លួន, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

ក្នុងករណី ទាំងអស់ នេះ តុលាការ គាប់យក អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិ ស៊ីវិល មកផ្ទួន បាន ដែរ ។

អយ្យការ នឹងចោទ ពីបទ នេះ បាន, លុះត្រាតែមាន បណ្តឹង ពីបុព្វញាតិ ឬ ពីសហព័ទ្ធ នៃបុព្វញាតិ ដែលរងគ្រោះ នោះ ប្តឹង ជាមុន សិន ។

អយ្យការ ត្រូវឈប់ ចោទ ទៅវិញ ភ្លាម, កាលណាបើ អ្នករងគ្រោះ នេះ សុំ ឲ្យឈប់ ចោទ, ទោះបីរឿង នោះ បានចាត់ការ ដល់ណា ក៏ដោយ, សូម្បីតែតុលាការ បានកាត់ ទោស មនុស្សត្រូវចោទ នោះ ក៏ ដោយចុះ ក៏ចាងហ្វាង ដែលបានទទួល រឿង នេះ ត្រូវដោះ ទណ្ឌិត នោះ ភ្លាម ក្នុងពេល ដែលអយ្យការ បានសុំ ឲ្យដោះ ។

មាត្រា ៤៧១ ជនណា ហ៊ាន ប្រព្រឹត្ត នូវវិហិង្សា ឬ រំលោភ លើរូបកាយ បុព្វញាតិណា ម្នាក់ ដែលមាន ខាន់ស្លា ក្តី, ឥតខាន់ស្លា ក្តី ចិញ្ចឹម ក្តី របស់ខ្លួន ជននោះ ត្រូវមាន ទោស ដូចតទៅ :

បើ វិហិង្សា នោះ មិនបានបណ្តាល ឲ្យមាន របួស ទេ និង មិនមាន កម្មវិបាក មក លើសុខភាព នៃអ្នករងគ្រោះ ទេ , វិរុទ្ធជន នោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

បើ វិហិង្សា នោះ បានបណ្តាល ឲ្យមាន របួស និង មាន កម្មវិបាក

00222413

D99/3/3



លើសុខភាព នៃអ្នករងគ្រោះ, វិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

បើ វិហិង្សា នោះ បានបណ្តាល ឲ្យមាន ការវិកលកម្ម , ឲ្យមាន ពិការ ជានិច្ច , ឲ្យស្លាប់ អវយវៈ ណាមួយ ជាស្ថាពរ, ឲ្យបាត់បង់ នូវ អវយវៈ ឬ វិញ្ញាណ ណាមួយ, ឬ ប្រសិនបើ, កាលប្រព្រឹត្ត នោះ, គ្មាន ចេតនា ចង់ឲ្យ ស្លាប់ទេ, ប៉ុន្តែ វិហិង្សា នោះ ខ្លាំងពេក បណ្តាលឲ្យ ស្លាប់, វិរុទ្ធជន នោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

បើ សេចក្តីស្លាប់ បណ្តាលមក ពីអាការ ឃោរឃៅ ខ្លាំងពេក ឬ បើ វិហិង្សា នោះ បានប្រព្រឹត្ត ក្នុងបំណង ថា ចង់សម្លាប់ មែន, ថ្វីបើអ្នករង អំពើ នោះ មិនស្លាប់ , វិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី, ទោះបី មាន សេចក្តីត្រាប្រណី ដូចម្តេច ក្តី, ក៏តុលាការ មិនអាច បន្ថយ ទោស នេះ ឲ្យចុះក្រោម អតិបរមា នៃទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ដែរ ។

កាលណា វិហិង្សា នេះ បានប្រព្រឹត្ត ទៅ លើសហព័ទ្ធ ពុក មាន ខាន់ស្លា របស់បុព្វញាតិ ខ្លួន ដែលមានខាន់ស្លា , ឥតខាន់ស្លា ឬ ចិញ្ចឹម នោះ, វិរុទ្ធជន ត្រូវមាន ទោសមធ្យម ដល់អតិបរមា នៃទោស របស់ បទល្មើស ដែលមាន ប្រភេទ ដូចគ្នា ហើយ ដែលបានប្រព្រឹត្ត លើ ជន មិនមែន ជាញាតិ លោហិត ឬ ជាញាតិពន្ធទេ ។ បើ បទល្មើស នោះ ត្រូវផ្តន្ទា ដល់ទោសឧក្រិដ្ឋ, ទោះបី ត្រាប្រណីដូចម្តេច ក្តី ក៏តុលាការ មិនអាច បន្ថយ ទោស នេះ ឲ្យ តិចជាង ទោស ឧក្រិដ្ឋ ថ្នាក់ក្រោម

00222414





បន្ទាប់នោះ ដែរ ឬ មិនឲ្យក្រោម អតិបរមា នៃទោសគុកមធ្យម ថ្នាក់ទីបី ដែរ, ប្រសិនបើ ទោសឧក្រិដ្ឋនោះ ជាឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៤៩២– ជនណា បង្ក ឬ ប៉ង ប៉ុនបង្ក ឲ្យមានជម្ងឺ ដោយសារថ្នាំពុល នាំឲ្យខូច សុខភាព, តែមិនដល់ ស្លាប់ ទេ, ហើយការ ឲ្យ ថ្នាំ នោះ ក៏ឲ្យ ដោយចេតនា ដែរ, ទោះឲ្យ ដោយរបៀប យ៉ាងណា ក៏ដោយ, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ, ប្រសិនបើ ជន ធ្វើ អំពើល្មើស នោះ ជាបុព្វញាតិ របស់ខ្លួន មានខាន់ស្លា ឥតខាន់ស្លា ឬ ចិញ្ចឹម ឬ ជាបុព្វញាតិ មានខាន់ស្លា ឥតខាន់ស្លា ឬ ចិញ្ចឹម របស់សហព័ទ្ធ ខ្លួន ។ ជននោះ ត្រូវមាន ទោសមធ្យម ថ្នាក់ ទីបី ជា អតិបរមា ហើយ ត្រូវ អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិល និង គំហាត់លំនៅ ថែមទៀត ក៏បាន, ប្រសិនបើ អ្នកធ្វើអំពើ ល្មើស ឬ អ្នកធ្វើបំណង៍នេះ ជាសហព័ទ្ធ ឬ មានខាន់ស្លា របស់បុព្វញាតិ ខ្លួន ដែលមានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម ។

នាកាល ថ្នាំ ដែលឲ្យ ដោយចេតនា នោះ មានពិស ដល់ស្លាប់ តែថ្នាំ នោះ មិនបានបណ្ដាល ឲ្យស្លាប់ ក៏ដោយ ក្ដី ឬ បើថ្នាំ នោះ មាន ពិស មិនដល់ស្លាប់ ទេ, ប៉ុន្តែ វា បណ្ដាល ឲ្យស្លាប់ នោះ, វិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។ ទោស នេះ មិនអាច បន្ថយ, ដោយ សារមាន សេចក្ដីត្រាប្រណី, ឲ្យ តិចជាង ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ បាន

១, ប្រសិនបើ អ្នកធ្វើអំពើ នោះ ជាបុព្វញាតិ មានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម របស់ចារី នោះ, ជាបុព្វញាតិ មានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម របស់សហព័ន្ធខ្លួន ឬ មិនអាច នឹង បន្ថយ ឱ្យ តិចជាង អតិបរមា នៃទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។ ២, ប្រសិនបើ អ្នកធ្វើអំពើ នោះ ជាសហព័ន្ធចុង របស់បុព្វញាតិ ខ្លួន ដែលមានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម ។

មាត្រា ៤៧៣ - បទល្មើសទាំងឡាយ ដូចខាងលើ, បើ ចារី ជាព្យាបាលិក ប្រព្រឹត្តទៅ លើអ្នកព្យាបាល ឬ អ្នកអតីត ព្យាបាល របស់ខ្លួន, សិស្ស, សាវ័ក ប្រព្រឹត្ត ទៅ លើសាស្ត្រាចារ្យ ឬ គ្រូ របស់ខ្លួន ទៅ លើ អតីតសាស្ត្រាចារ្យ ឬ អតីតគ្រូ ដែលបានអប់រំ សីលធម៌ ឬ ចំណេះវិជ្ជា ដល់ខ្លួន, បទល្មើស នោះ ត្រូវទុកដូច ជាបទល្មើស ប្រព្រឹត្ត ទៅលើបុព្វញាតិ មានខាន់ស្លា, ឥតខាន់ស្លា ឬ ចិញ្ចឹម ដូចដែលមានសំដែង ក្នុង មាត្រា ៤៧០, ៤៧១ និង ៤៧២ ដែរ ។

មាត្រា ៤៧៤ - ជនណា ប្រកែក មិនព្រម ផ្គត់ផ្គង់ ញាតិ ដែល ធ្វើការ មិនកើត ដោយសារជរា ឬ ពិការ ហើយ គ្មានធនធាន, គ្មាន ស្បៀងអាហារ សម្រាប់ ទ្រទ្រង់ ជីវិត, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ។

បទបញ្ញត្តិ នេះ ត្រូវអនុវត្ត លើញាតិម្នាក់ៗ គ្រប់រូប ដែលមាន

00222416



ពិរុទ្ធ ក្នុងបទ នេះ ។

ត្រូវទុក ជាញាតិ, ជនណា ដែលជាប់ ជាញាតិលោហិត ឬ ញាតិពន្ធ ដូចមាន រៀបរាប់ ក្នុងមាត្រា ៤៤៨ នៃក្រមព្រហ្មទណ្ឌនេះ ព្រម ទាំងសហព័ទ្ធ ដែលមិនទាន់ដាច់គ្នា ផង ។

ព្រះរាជប្រកាស លេខ ១៩៣ ចុះថ្ងៃទី ៣ . ៩ - ៣៣ បន្ថែម បទបញ្ញត្តិ ដូចខាងក្រោមនេះ ។

ឈ្មោះណា ដែលមាន សាលក្រម ជំនុំជំរះ កាត់សេចក្ដី ជាស្ថាពរ ហើយ ឬ ជាបណ្ដោះអាសន្ន ថា ឲ្យចេញថ្លៃ អាហារ ចិញ្ចឹម ប្រពន្ធ និង កូន អាយុ មិនទាន់គ្រប់ការ ឬ ញាតិលោហិត ក្នុងគ្រួសារ ដូច មានបទបញ្ញត្តិ ក្នុងមាត្រា ១៩៣, ៣៥៦, ៤៨០, ៤៨១, ៤៨២ ក្រម រដ្ឋប្បវេណី ហើយ ទុក ឲ្យហួស កំណត់ ជាង បីខែ ដោយចេតនា មិន បានចេញ ថ្លៃ អាហារ ទេ, ឈ្មោះនោះត្រូវទុក ជាបាន បោះបង់ ចោល គ្រួសារ ហើយ ត្រូវផ្ដន្ទា ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើ មិនកំណត់ទេ ចៅក្រម ត្រូវយក ទោសគុក មកផ្ដន្ទា ជា ដាច់ ថ្វីបើ ផ្ទុយ នឹងបញ្ញត្តិ មាត្រា ១៥៨ ក្រមព្រហ្មទណ្ឌ នឹងយក អនុទោស បន្ថយសិទ្ធិស៊ីវិល និងបញ្ឈប់ មិនឲ្យធ្វើ ជាអ្នកព្យាបាល មក ផ្ដន្ទា លើប្រពន្ធ ឬ ម្ដាយ ណាដែលមាន ទោស ពីបោះបង់ចោលគ្រួសារ ថែមទៀត ក៏បាន ។

ឯចៅក្រម ដែលត្រូវសម្រេច រឿង នេះ, បើកាល ណា រកទៅឃើញ

00222417





ថា មនុស្ស ជាប់ចោទ បាន ដោះសារ ដោយជូន សំអាង ត្រឹមត្រូវ ហាក់បី គួរឲ្យជឿបាន ថា មនុស្សនោះ និយម ធ្វើ តាមសេចក្ដីបង្គាប់ នោះដែរ តែធ្វើ មិនបាន សោះ , ត្រូវតែកាត់សេចក្ដី ឲ្យមនុស្ស ជាប់ចោទ រួចខ្លួន ។

មាត្រា ៤៧៥–ជនណា សម្លាប់ គោ, ក្របី, សេះ ឬ ដំរី ដោយចេតនា, ឥតមាន ត្រូវការធ្វើ ជាប្រយោជន៍ សោះ, ជននោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ, ទោះបី សត្វ ទាំងនេះ ជារបស់ខ្លួន ក៏ដោយ ។

មាត្រា ៤៧៦– ជនណា ធ្វើ ទារុណកម្ម ឬ ប្រព្រឹត្ត អំពើយង់ឃ្នង លើសត្វ ពាហនៈ ឬ ធ្វើឲ្យរបួស ដល់សត្វ ទាំងនោះ ដោយចិត្តអសប្បុ-រស, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ទោះបី សត្វ ទាំងនោះ ជារបស់ខ្លួន ក៏ដោយ ។

មាត្រា ៤៧៧– ជនណា ធ្វើ ទារុណកម្ម ឬ ធ្វើ អំពើយង់ឃ្នង លើសត្វ តិរច្ឆាន សាហាវ, ចង្រៃ ដូចម្ដេច ក៏ដោយ, ក៏ជននោះ ត្រូវមានទោសជាលហុ ដែរ ។

# មាតិកា ពីរ

## អំពីបទល្មើស ប្រព្រឹត្ត លើជន សាមញ្ញ

## DES INFRACTIONS CONTRE LES PARTICULIERS

### ជំពូក មួយ

### អំពីបទល្មើស ប្រព្រឹត្ត លើរូបកាយ ជន សាមញ្ញ

### Des infractions contre la personne des particuliers

មាត្រា ៤៧៨– អំពើគំរាម គឺជាពាក្យ ព្រមាន របស់ជន ណាម្នាក់ ដែលពោល ទៅ កាន់បុគ្គល ណាម្នាក់ ថា ខ្លួន សម្រេចចិត្ត នឹងប្រព្រឹត្ត ឬ នឹង ញុំាងគេ ឲ្យប្រព្រឹត្ត នូវបទល្មើស ណាមួយ ដើម្បីឲ្យមាន ព្យសនកម្ម ដល់រូប បុគ្គល នោះ ។

បើ ពាក្យគំរាម នេះ បរិហារ ដោយកំហឹង ក្នុងពេល ដែលអ្នកពោល នោះ ត្រូវ ក្ដៅទោសៈ ឆាបឆេះ មួយឆាវ យ៉ាងជាក់ស្ដែង ព្រោះមាន ការជជែក វែកញែក ជាមួយ នឹងអ្នករង ពាក្យគំរាម ឬ នឹងជន ជាញាតិ នៃអ្នករង ពាក្យគំរាម នោះ, សំដីគំរាម នេះ ត្រូវទុក ជាសំដីជេរ ឬ មើលងាយ ទៅវិញ ។ អាស្រ័យហេតុនេះ, សំដី នោះ ត្រូវផ្ដន្ទាទោស តាមបទបញ្ញត្តិ នៃមាត្រា ៨១១ ឬ ៣០៤ តាមករណី គួរ ។

ប្រសិនបើ, ពេល ក្រោយមក, បទល្មើស ដូចដែលជន អ្នកគំរាម បានពោល នោះ បានកើតមាន មែន ឬ ប្រុង នឹងកើតមាន មែន, ពាក្យគំរាម នោះ អាច រើសយកមក ធ្វើ ជាមូលវិចារណ៍ មួយ គ្រប់គ្រាន់

00222419





សម្រាប់រក យុត្តិកម្ម អំពីការ ដែលគួរឃុំ ផង ដែលបានពោល ពាក្យគំរាមនោះ ថា ជាបានប្រព្រឹត្ត ឬ បានបំណង នឹងប្រព្រឹត្ត បទល្មើសនោះ ក្នុងឋានៈ ជាការី, ជាសហការី ឬ ជាអ្នកចូល គំនិត បាន ។

ផ្នែក អំពីករណី ដែលទុក សេចក្តីគំរាម ថា ជាពាក្យជេរ នោះមក, អំពើគំរាម នេះត្រូវផ្តន្ទាទោស ទៅ តាមដំណើរ ដែល ពាក្យ គំរាម នោះពោល ដោយវាចា ឬ ដោយអក្សរ, និង ទៅ តាម ប្រភេទ នៃ ពាក្យគំរាម នោះ ថា នឹងប្រព្រឹត្ត បទមជ្ឈិម ឬ ទុក្រិដ្ឋ ។

មាត្រា៤៧៩- កាលណា ពាក្យគំរាម នោះ បានពោល ថា នឹងធ្វើ អំពើ អ្វីមួយ ដែលជាអំពើ គួរផ្តន្ទា ដល់ទោសទុក្រិដ្ឋ, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើ អំពើគំរាម នោះ មាន សេចក្តី ជាអក្សរ, ជាសំបុត្រ នាមិក ឬ អនាមិក, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា៤៨០- កាលណា ពាក្យគំរាម នោះ បានពោល ថា នឹងធ្វើ អំពើ អ្វីមួយ ដែលជាអំពើ គួរផ្តន្ទា ត្រឹម ទោសមជ្ឈិម, វិរុទ្ធជន ត្រូវ មាន ទោសលហុ ។

បើ អំពើគំរាម នោះ មានសេចក្តី ជាអក្សរ, ជាសំបុត្រនាមិក ឬ អនាមិក, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

00222420





មាត្រា ៤៨១- បើ កាលណា អំពើគំរាម នោះ ប្រាប់ តែមាត់ ទទេ ឬ មាន ទំនុក ជាអក្សរ ថា ឲ្យ ជន អ្នកទទួលពាក្យ គំរាម បំពេញ នូវកាតព្វកិច្ច ណាមួយ នោះ, បទបញ្ញត្តិ នៃមាត្រា ខាងលើ នេះ មិនត្រូវ អនុវត្ត ទេ, គឺត្រូវ អនុវត្ត បទបញ្ញត្តិ នៃមាត្រា ៥៦២ វិញ ។

មាត្រា ៤៨២- ជនណា គ្មាន បានទទួល បង្គាប់ ពីអាជ្ញាធរ ជាធម្មានុរូប សោះ និង ក្រៅ ពីករណី នៃបទល្មើស មជ្ឈិម ឬ ទុក្ករិដ្ឋ ជាក់ស្តែង ទៀត, ហើយ ចាប់, ឃុំ, និង ឃាត់ទុក នូវបុគ្គល ណាម្នាក់ ក្នុង រយៈវេលា មិនលើស ពីដប់ ថ្ងៃ ទេ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

ក្នុងករណី ផ្ទុយទៅវិញ, គឺថា លើស ពីដប់ ថ្ងៃ ឡើងទៅ, ជន នោះ ត្រូវមានទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៤៨៣- ជនណា ដែលបានចាប់, ឃុំ, និង ឃាត់ គេ ទុក ហើយ ធ្វើ វិហិង្សា លើរូបកាយ គេ ទៀត ក្តី, ធ្វើ ទុក្ខបុកម្នេញ ក្តី, បង្អត់ អាហារ គេ ក្តី, ជននោះ ត្រូវផ្តន្ទា ដល់អតិបរមា នៃទោស ដែល ពោល ខាងលើនេះ ។ ប៉ុន្តែបើ វិហិង្សា ឬ ការធ្វើទុក្ខបុកម្នេញ ឬ ការ បង្អត់អាហារ នោះ បណ្តាល ឲ្យមាន កម្លាំបាក ជាទម្ងន់ លើរូប ពន្ធិត

00222421





ថែមទៀត, ចៅក្រម ត្រូវផ្ដន្ទាទោស ដែល ធ្ងន់ ជាងនេះវិញ ។

មាត្រា ៤៨៤– ក្នុងបទវិសណ្ឋានកម្ម នេះ ចៅក្រម នឹងយក អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិល និង ដំហាក់លំនៅ មកផ្ដន្ទា ទៀត ក៏បាន ។

មាត្រា ៤៨៥– ប្រសិនបើ ជន អ្នកចាប់ ឬ អ្នកធ្វើ វិសណ្ឋាន-កម្ម នោះ បានក្លែង ឈ្មោះ, ក្លែង គុណភាព, ក្លែង មុខងារ ឬ ប្រើ សំលៀកបំពាក់ ឯកសណ្ឋាន ដែលខ្លួន គ្មានសិទ្ធិប្រើ, ជននោះ ត្រូវមាន ទោស ដូចខាងលើ ដល់អតិបរមា ។ ក៏ប៉ុន្តែ ទោស នេះ មិនមែន ជាឧបសគ្គ នាំ ឲ្យមាន ផ្ដន្ទា ទោសធ្ងន់ ទៅ ទៀត ទេ, ប្រសិនបើ អំពើនេះបានប្រព្រឹត្ត ក្នុងករណីទាំងឡាយ មាន ក្លែង លិខិត សាធារណៈ ឬ ប្រើ លិខិត សាធារណៈក្លែង ជាដើម ។

មាត្រា ៤៨៦– ជនណា, កាលបានដឹង រឿង នេះ ហើយ, ក៏ឲ្យ ផ្ទះ ឥតយកឈ្នួល ដល់អ្នកនោះ ដើម្បីធ្វើ ជាកន្លែង វិសណ្ឋានកម្ម, ជននោះ ត្រូវមាន ទោស ដូចជាចារី នៃវិសណ្ឋានកម្ម ដែរ ។

មាត្រា ៤៨៧– (ព្រះរាជប្រកាស ចុះថ្ងៃ ១០ វិច្ឆិកា ១៩៣៧) ជនណា ធ្វើ ឲ្យអ្នកដទៃ មាន របួស, មាន ជម្ងឺ ឬ ពិការ ដល់ ទៅ ភាក់ខាន

ធ្វើ ការ ងារ មួយគ្រា ៗ , ដោយមិនប្រុងប្រយ័ត្ន , មិនប្រសប់ ឬ ដោយធ្វេសប្រហែស, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បើ បុព្វហេតុ នៃរបួស ឬពិការ ខកខាន ធ្វើ ការ នោះ បណ្ដាល មក ពីមិនប្រតិបត្តិ តាមបទបញ្ញា ទាំងឡាយ , ជននោះ ត្រូវមាន ទោស ដូចខាងលើនេះ ជាអតិបរមា ។

កាលណាបើ មានបណ្ដាល ឲ្យពិការ ជាទិច្ច, ឲ្យស្លាប់ កាយ គ្រឿង ណាមួយ ជាទិច្ចក្តី, ដូច ភ្នែក , ត្រចៀក, ច្រមុះ, អណ្ដាត, កាយ ជាដើម, តារនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ បើ បុព្វហេតុ នៃគ្រោះថ្នាក់ នោះ បណ្ដាលមក ពីមិនប្រតិបត្តិ តាមបទបញ្ញា ផង, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ជាអតិបរមា ។

(ព្រះរាជប្រកាសលេខ ១៣៩ ចុះថ្ងៃ ១០ វិច្ឆិកា ១៩៣៦) កាលណាបើ របួស ឬ ពិការ ខាតខាន ធ្វើ ការ នោះ, បណ្ដាល មក ពីការ បើក បរ រថយន្ត , តុលាការ នឹងកាត់ សេចក្តី ឲ្យដកហូត ច្បាប់ ដែល ឲ្យ អំណាច បើកបរ រថយន្ត នោះ ទុក ក្នុងកំណត់មិនឲ្យលើស ពីបី ឆ្នាំ បានទៀត, ក្រៅ អំពីទោស ដែលបានបញ្ញត្តិ ក្នុងមាត្រា នេះ មក ត្រូវ ឲ្យ កត់ត្រា សេចក្តី ដែលដកហូត យ៉ាងដូច្នេះ ក្នុងបញ្ជី ថ្កោល ទោស ទៀតផង ។

អ្នកបើករថយន្ត ណា, បានទទួល ដំណឹង អំពីសេចក្តី សម្រេច

00222423





របស់ពទ្យការ វេជ្ជបាល ឬអធិការសាលក្រម របស់សាលាដំបូង សំរេចសេចក្ដីឲ្យដកហូត សំបុត្រអនុញ្ញាត ឲ្យបើកបរ នោះ ហើយ, អាចហាម ទៅបើកបរ រថយន្ត ទៀត ឬបំណងទីងសុំ សំបុត្រអនុញ្ញាត បើកបរ មួយ ថ្មីទៀត ដោយធ្វើ ពាក្យសុំ កែក្លែងក្លាយ, អ្នកបើកបរ នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ៤៨៨– ជនណា គ្មានសញ្ញាប័ត្រ ដែលអនុញ្ញាត ឲ្យ ធ្វើ ពេទ្យ ឬធ្វើ ធ្មេញ ហើយ ធ្វើ ឬ បំណងធ្វើ នូវសល្យកម្ម លើរូប បុគ្គល ណាម្នាក់, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៤៨៩– សល្យកម្ម គឺការ វាត់, កាត់, វះ ខាងក្នុងខ្លួន នៃមនុស្ស ឬ ខាងក្នុង នៃសាច់ ក្ដី, ក្នុងសរីរាង្គ ខាងខួរក្បាល ឬ ខាង លិង្គ ក្ដី ។ ការដោះ ចណ្ដុះ ឆុតព្រៃ គឺទុក ជាសល្យកម្ម ដែរ ។

មាត្រា ៤៩០– បើសល្យកម្ម ឬ បំណង នៃសល្យកម្ម នោះ បានបណ្ដាល ឲ្យស្លាប់, ទោស នៃអំពើ នេះ ត្រូវផ្ដន្ទា ដូចគ្នា នឹងទោស នៃមនុស្សឃាត ឥតចេតនា ប្រព្រឹត្ត ដោយមិនប្រតិបត្តិ តាមបទ បញ្ជា នោះ ដែរ ។

មាត្រា ៤៩១– បើ សល្យកម្ម នោះ បណ្ដាល ឲ្យពិការ ជាទិច្ច,

តុលាការ ត្រូវយក ទោស ដែលមាន បញ្ញត្តិ ត្រង់កថាខ័ណ្ឌ ខាងចុង នៃ មាត្រា ៤៨៧ មក ផ្តន្ទា ។

បើសល្យកម្ម បណ្តាល ឲ្យមាន ជម្ងឺ ឬ បណ្តាល ឲ្យខកខាន ធ្វើ ការងារ តែកន្លងមួយកាល ទេ, តុលាការ ត្រូវយក ទោស ដែល មានបញ្ញត្តិ ត្រង់កថាខ័ណ្ឌ ទី ២ នៃមាត្រា ៤៨៧ មកផ្តន្ទា វិញ ។

មាត្រា ៤៩២– ជនណា គ្មានសេចក្តីអនុញ្ញាត តាមបទបញ្ជា សោះ ហើយ លក់, ធ្វើ អនុប្បទាន ឬ ឲ្យ ថ្នាំ លាយ ដោយគ្រឿងពុល ណាមួយ ដើម្បីឲ្យ គេ យកទៅ ប្រើប្រាស់ កែ រោគ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

មាត្រា ៤៩៣– អ្នក ណាមួយ លក់, ដាក់លក់, ធ្វើ អនុប្បទាន នូវភេសជ្ជៈ ឬ ចំណីអាហារ ដែលខ្លួន បានដឹង ថា វត្ថុនោះ មិនឲ្យសុខ, ឬ វត្ថុ ស្អុយ រលួយ ឬ វត្ថុ បំផ្លាញ ដល់សុខភាព, អ្នកនោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ៤៩៤– អ្នកណា បង្កហេតុ ដោយចេតនា ឲ្យគេ មាន ជម្ងឺ ឬ ឲ្យ គេ ធ្វើការ មិនកើត អាន កំណត់ កាល ដោយដាក់ ថ្នាំ បំផ្លាញ សុខភាព គេ តែមិន ដល់ស្លាប់ ទេ, ទោះបី ដាក់ ដោយរបៀប ណាក៏

00222425

D99/3/3



ដោយ, អ្នកនោះ ក៏ត្រូវមាន ទោសមធ្យម ថ្នាក់ទីបី ដែរ ។

កាលណាបើ ថ្នាំនោះ បណ្ដាល ឲ្យសរីរាង្គ តាំងមូល ឬ ភាគខ្លះ ពិការ ជានិច្ច, ឲ្យស្លាប់ អវយវៈ ណាមួយ ជាស្ថាពរ, ឲ្យមាន កាយវិកលកម្ម ឲ្យបាត់បង់ អវយវៈ ណាមួយ ឬ វិញ្ញាណ ណាមួយ, ឲ្យវិបត្តិស្មារតី, ឲ្យលេលា, ឲ្យគ្រុនឡើក ខួរក្បាល ជាស្ថាពរ, ឲ្យស្ត្រី មានផ្ទៃ រលូត កូន, វិវុទ្ធជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៤៩៥– វិហិង្សា ធ្វើ ដោយចេតនា លើរូប អ្នកដទៃ ត្រូវផ្ដន្ទា ទោស ។ ប៉ុន្តែ ទម្ងន់ នៃទោស នេះ ត្រូវ ទៅ តាមកម្មវិបាក នៃអំពើ នោះ ដែលធ្វើ ឲ្យខូច សុខភាព នៃអ្នករងគ្រោះ ហើយ នឹងត្រូវ ទៅ តាមបទល្មើស, កាលប្រព្រឹត្ត នោះ, មាន ប្រើ អាវុធ ឬ គ្មាន ប្រើ អាវុធ ។

ត្រូវទុក ជាមាន ប្រើ អាវុធ, គ្រាណា ដែលវិហិង្សា នោះ បាន ប្រព្រឹត្ត ដោយមាន ប្រើ វត្ថុអ្វីមួយ សម្រាប់វាយ ឬ សម្រាប់ធ្វើ ឲ្យសៅ-ហ្មង ដល់អ្នករងគ្រោះ ។

បំណង ក្នុងបទ នេះ ក៏ត្រូវមាន ទោស ដែរ, កាលណាបើ វិហិង្សា នោះ បានប្រព្រឹត្ត ហើយ, តែអ្នករងអំពើ ចៀសផុត មិនបានត្រូវ ទេ ។

មាត្រា ៤៩៦– កាលណាបើ វិហិង្សា នោះ មិនបណ្ដាលឲ្យ

មាន ស្នាកស្នាម, មិនបណ្ដាល ឲ្យមាន កម្មវិបាក ដល់សុខភាព នៃអ្នករងគ្រោះ ទេ, បើបទល្មើស នោះ បានប្រព្រឹត្ត ដោយគ្មាន ប្រើ អាវុធ ទេ, វិរុទ្ធជន នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។ បើ បទល្មើស នោះ បានប្រព្រឹត្ត ដោយមាន ប្រើ អាវុធ ផង, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា ៤៩៧– កាលណាបើ វិហិង្សា ប្រព្រឹត្ត ដោយចេតនា នោះ បានបណ្ដាល ឲ្យមាន ស្នាកស្នាម, បានបណ្ដាល ឲ្យមាន កម្មវិបាក ដល់សុខភាព នៃអ្នករងគ្រោះ, បើបទល្មើស នោះ បានប្រព្រឹត្ត ដោយគ្មាន ប្រើ អាវុធ ទេ, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ; បើមាន ប្រើ អាវុធ ផង, វិរុទ្ធជន ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៤៩៨.–( ព្រះរាជប្រកាសលេខ ៨៨ ចុះថ្ងៃ ២០-៥-៤០ ) កាលបើ វិហិង្សា នោះ បានបណ្ដាល ឲ្យ សរីរាង្គ តាំងមូល ឬ ភាគខ្លះ ពិការ ជាដាច់, ឲ្យស្លាប់ អវៈយវៈ ណាមួយ ជាស្ថាពរ, ឲ្យមាន កាយវិកលកម្ម, ឲ្យបាត់បង់ នូវអវៈយវៈ ណាមួយ ឬ វិញ្ញាណ ណាមួយ, ឲ្យវិបត្តិស្មារតី, ឲ្យលេលា ឬ ឲ្យក្រឡុក ខួរក្បាល ជាស្ថាពរ, ឲ្យស្ត្រីមានផ្ទៃ រលូត កូន, វិរុទ្ធជន នោះ ត្រូវមាន ទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ទាហាន កងរាជអង្គរក្ស ក្ដី, ទាហាន កងស្រុកអាយ ក្ដី

00222427

D99/3/3



ដែលបានប្រព្រឹត្ត ដោយចេតនា លើកាយរបស់ខ្លួន នូវវិហិង្សា ដើម្បីឲ្យ ខ្លួន ធ្វើការ រាជការ មិនកើត មាន កំណត់ កាល ក្តី, ជានិច្ច ក្តី ឬ ធ្វើ ខ្លួន ឲ្យពិការ ដោយចេតនា ដើម្បី គេច ឲ្យផុត ពីកាតព្វកិច្ច ដែលព្រះរាជប្រកាស ឬ បទបញ្ជា ជាធរមាន បានតម្រូវមក ។

កថាខណ្ឌ នេះ បានដកចេញ ពីក្រមព្រហ្មទណ្ឌហើយ ហើយយកទៅបញ្ចូល ក្នុងមាត្រា ២០៣ នៃក្រមតុលាការសឹក វិញ ។

ត្រូវមាន ទោស គុកមធ្យម ថ្នាក់ទីពីរ ដូចគ្នា យុវជន ណា មាន ពិរុទ្ធ ក្នុងទោសកម្ម ដូចគ្នានេះ ក្រោយ ថ្ងៃ ដែល បានសំបុត្រ ហៅខ្លួន ឲ្យធ្វើ ទាហាន ជាដំបូង ឬ ហៅ ឲ្យធ្វើ ទាហាន ម្តងទៀត តែមុន ថ្ងៃ ដែលត្រូវចូល ខ្លួន ក្នុងកងយោធពល ។

មាត្រា ៤៩៩.– ជនណា គ្មានចេតនា ខំសម្លាប់ គេ ទេ, ប៉ុន្តែ បានធ្វើ ឬ មាន បំណងនឹងធ្វើ ដោយចេតនា, ឲ្យអ្នកដទៃ មាន គ្រោះថ្នាក់ មិនដល់ស្លាប់ ដោយពន្លះ សត្វ ក្តី, ដោយធ្វើ កលឧបាយ ដូចម្តេច ក្តី ឬ ដោយប្រើ វិធី យ៉ាងណា ៗ ក្តី, ជននោះ ត្រូវទុក ដូចជា បានធ្វើ វិហិង្សា ដោយចេតនា ប្រព្រឹត្ត ដោយមានប្រើ អាវុធ ដែរ ។

មាត្រា ៥០០– ជនណា ធ្វើ ទារុណកម្ម អ្នកដទៃ ដើម្បីឲ្យ អ្នក នោះ ឈឺ ជាខ្លាំង ហើយឲ្យប្រាប់ ពត៌មាន ផ្សេង ៗ ដែលមានប្រយោជន៍ ដល់ការប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ មជ្ឈិមកម្ម ណាមួយ ក្តី, ដើម្បីសងសឹក ឬ ដោយអំពើ ចិត្តព្រៃ របស់ខ្លួន ក្តី, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

00222428





**មាត្រា ៥០១.-** ជនណា ធ្វើឲ្យគេ ស្លាប់, ជននោះ មានពិរុទ្ធ ក្នុងបទមនុស្សឃាត ។ បើ ស្លាប់នោះ បណ្ដាល មក ពីអំពើ ឥតចេតនា ទេ, អំពើ នោះ ឈ្មោះថា មនុស្សឃាត ដោយអចេតនា ។

បើ ស្លាប់ បណ្ដាលមក ពីអំពើ ប្រកប ដោយចេតនា បង់សម្លាប់គេ, អំពើនោះ ឈ្មោះថា មនុស្សឃាត ដោយចេតនា ។

**មាត្រា ៥០២.-** មនុស្សឃាត ដោយអចេតនា ណា បណ្ដាលមក ពីកំហុសទាំងឡាយ គឺមិនប្រយ័ត្ន, មិនប្រសប់, ធ្វេសប្រហែស ឬ មិនគោរព តាមបទបញ្ញា, មនុស្សឃាត ដោយអចេតនា នោះ ត្រូវមាន ទោស [illegible]ទៅ តាមប្រភេទ នៃកំហុស របស់វា ផ្សេង ៗ គ្នា យ៉ាងនេះ:

មនុស្សឃាត ព្រោះមិនប្រយ័ត្ន, មិនប្រសប់ ឬ ធ្វេសប្រហែស ត្រូវផ្ដន្ទា ទោសមធ្យម ថ្នាក់ទីពីរ ,

មនុស្សឃាត ព្រោះមិនគោរព តាមបទបញ្ញា ត្រូវផ្ដន្ទា ទោស មធ្យម ថ្នាក់ទីបី ។

កាលបើ មនុស្សឃាត ដោយអចេតនា បណ្ដាលមក ពីដាក់ ថ្នាំពុល, ដោយមិនប្រយ័ត្ន, មិនប្រសប់, ដោយធ្វេសប្រហែស ឬ មិនគោរព តាមបទបញ្ញា, មនុស្សឃាតនោះ ត្រូវផ្ដន្ទា ទោស ដូចគ្នា ដោយវែកញែក តាមរបៀប ខាងលើ នេះ ដែរ ។

ព្រះរាជប្រកាស លេខ ១៧៩ ចុះថ្ងៃ ១០-១១-៣៦ បានបន្ថែមថា :

បទបញ្ញត្តិទាំងឡាយ ដែលមានត្រាទុក ក្នុងវគ្គទី ៦ និង ទី ៤ នៃ មាត្រា ៤៨៧ ក៏ត្រូវយកមក អនុវត្តក្នុងមាត្រានេះដែរ ។

មាត្រា ៥០៣- កាលបើ មនុស្សឃាត បណ្ដាលមក ពីអំពើ ដែលប្រព្រឹត្ត ដោយចេតនា ត្រឹមតែចង់ ឲ្យឈឺ រូបកាយ បុគ្គល ណាម្នាក់ ប៉ុណ្ណោះទេ មិនចង់ ឲ្យបុគ្គល នោះស្លាប់ទេ, ប៉ុន្តែ អំពើ នោះបណ្ដាល ឲ្យ ស្លាប់ បុគ្គល នោះ ទៅវិញ, មនុស្សឃាតនេះ ត្រូវទុក ជាបទ មនុស្សឃាត គ្មាន មរណចេតនា ទេ ។

អ្នកមាន ពិរុទ្ធ ក្នុងបទ នេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៥០៤- កាលបើ មនុស្សឃាត បណ្ដាលមក ឬ អាច បណ្ដាលមក ពីចិត្ត ដែលស្ទុះឡើង ភ្លាម ៗ , ចង់ឲ្យស្លាប់ , មនុស្សឃាត នេះ ឲ្យឈ្មោះថា ឃាតកម្ម ឬ បំណងឃាតកម្ម ។

អ្នក មាន ពិរុទ្ធ ក្នុងបទ នេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា ៥០៥.- ចៅក្រម អាច សន្និដ្ឋាន ថាឃាតករ មាន មរណចេតនា បាន កាលណាបើ ឃាតករ បានប្រើ សស្ត្រាវុធ គួរដល់ស្លាប់, កាលណាបើឃាតករ ប្រហារ យ៉ាង ពេញ ទំហឹង, កាលណាបើ មាន មុខរបួស មុតស៊ាំ លើខ្លួន អ្នកស្លាប់, កាលណាបើ ឃើញថា ឃាតករ

បានកើសកេ ការខូចដំណាំ នៅលើខ្លួន អ្នកស្លាប់ គួរដល់ស្លាប់ មែន ។

មាត្រា ៤០៦– កាលណាបើ មនុស្សឃាត បណ្ដាលមក ឬ អាច បណ្ដាលមក ពីអំពើ ដោយចេតនា ឬ ពីបំណង ដោយ ចេតនា, ហើយ ចេតនា នោះ បានសម្រេច ជាប់ខាត ជាមុន ផង, មនុស្សឃាត នេះ ឲ្យឈ្មោះថា ឃាតកម្ម ឬ បំណង នៃឃាតកម្ម ។

អ្នក មាន ពិរុទ្ធ ក្នុងបទ នេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

មាត្រា ៤០៧– កាលណាបើ មនុស្សឃាត បណ្ដាលមក ឬ អាច បណ្ដាលមក ពីវត្ថុ មាន ជាតិពុល ដល់ស្លាប់ ដែលជន ណាម្នាក់ ដាក់ ដោយចេតនា បង់ បំពុល មែន, មនុស្សឃាត នេះ ឲ្យឈ្មោះ ថា បទបំពុល ឬ បំណង ក្នុងបទបំពុល ។

អ្នក មាន ពិរុទ្ធ ក្នុងបទ នេះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី ។

នាកាល វត្ថុ ដែលដាក់ ដោយចេតនា នោះ មិនមែន ជាវត្ថុ មាន ជាតិពុល ដល់ស្លាប់ ទេ គឺមាន ជាតិពុល ត្រឹមតែ បង្ខូច សុខភាព ប៉ុណ្ណោះ, ហើយ ក៏ស្រាប់តែ បណ្ដាល ឲ្យ ស្លាប់, វិរុទ្ធជន ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ៤០៨– វត្ថុ មាន ជាតិពុល នោះ, ទោះមាន ប្រភេទដូច ម្ដេច ក្ដី, ទោះមាន វិធី ដែលដាក់ នោះ ដូចម្ដេច ក្ដី, ទោះរយៈពេល

00222431

D99/3/3



ដែលត្រូវពុលស្លាប់ នោះ មាន កំណត់ ប៉ុន្មាន ៗ ក្តី, ក៏ត្រូវទុក ជាថ្នាំនោះ មានជាតិពុល ដល់ស្លាប់ ដែរ ។

មាត្រា ៥០៩- ជនណា ប្រើ ដោយចេតនា នូវវិធី បញ្ឆោត ចិត្ត ក្តី, ឬ ឧបាយកល សាស្រ្ត ណាមួយ ឲ្យអ្នក ណាម្នាក់ ដាច់ចិត្ត សម្លាប់ខ្លួនឯង, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

## ចំពូកពីរ

## អំពី បទល្មើស ប្រព្រឹត្ត លើកេរ្តិ៍ឈ្មោះ ជន សាមញ្ញ

## Des infractions contre la réputation des particuliers

មាត្រា ៥១០- គ្រូពេទ្យ, សល្យពេទ្យ, គិលានុបដ្ឋាក, ឆ្មប ជម្ងឺ មេធាវី និង ជន ទាំងឡាយណា ជាអ្នក មាន មុខការ ខាងទទួល ទុក នូវអាថ៌កំបាំង ដែលគេ ផ្ញើ ទីងខ្លួន ឬ នូវពត៌មាន សម្ងាត់ ដែលគេ ប្រាប់ខ្លួន ក្នុងពេល ដែលខ្លួន ទៅយក ការណ៍ នោះ ហើយមាន ពិរុទ្ធ ជាបាន ខ្ចាយ នូវអាថ៌កំបាំង ឬ ពត៌មាន សម្ងាត់ នោះ, ជន ដូចរៀបរាប់ មក នេះ, ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ក៏ប៉ុន្តែ ថា បើ អាថ៌កំបាំង ឬ ពត៌មាន សម្ងាត់ នោះ ជារឿង បទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិម ហើយ ជននោះ ក្លាយ ប្តឹង ដល់អាជ្ញាធរ ណាមួយ ឬ ក៏ អាជ្ញាធរ ខាងតុលាការ បង្គាប់ ឲ្យខ្ចាយ នូវអាថ៌កំបាំង ឬ ពត៌មាន

00222432





សម្ងាត់នោះ, ជននោះ មិនត្រូវមាន ទោស ទេ ។

មាត្រា ៥១១ ជនណា ជេរ ឬ ពោល មើលងាយ ជនដទៃ ក្នុងទីសាធារណៈ ឬ ឲ្យសាធារណជនឮ, ជននោះ ត្រូវមាន ទោសលហុ ។

បើ ជេរ ទៅវិញ ទៅមក, ត្រូវមាន ទោស តាមមាត្រា ៣០៤ ។

មាត្រា ៥១២– ជនណា ជេរ ឬ ដាក់ពាក្យ មើលងាយ ក្នុងសំបុត្រ អនាមិក ឬ ក្នុងសំបុត្រ នាមិក ទៅឲ្យ ជន ម្នាក់ទៀត, ជននោះ ត្រូវមាន ទោស លហុ ។

បើ សំបុត្រ នោះ បានផ្សាយ ដល់សាធារណជន, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ វិញ ។

សំបុត្រ ដែលសរសេរ ឲ្យទៅ ជន តែម្នាក់ ក៏ទុកដូច ជាផ្សាយ ដល់សាធារណជន ដែរ ។

មាត្រា ៥១៣ និង ៥១៤ – ព្រះរាជក្រមលេខ ១១០ ប រ ចុះថ្ងៃទី ៤.១០-៦២

មាត្រា១.– ជនណា បរិហារ ក្រោមកសណ្ឋាន អនាមិក ពីអ្នករាជការ អ្នកតំណាងអាជ្ញាធរសាធារណៈ ឬ ជន ដែលទុក ជាអ្នករាជការ ដោយនិត្យានុកូល ឲ្យដំណឹង ដល់សាធារណៈជន នូវអំពើ ដែលមាន ប្រភេទ ឲ្យ សៅហ្មង ដល់កិត្តិយស ឬ កេរ្តិ៍ឈ្មោះ អ្នកទាំងនោះ ដោយពាក្យ, ដោយ

លិខិត ដោយគំនូរ, ដោយរូប ឬ ដោយមធ្យោបាយ ណាមួយ ប៉ុន្តែអំពើនោះ មិនចូល ជាបទឧក្រិដ្ឋ ឬ មជ្ឈិម ទេ, ជននោះ មាន ពិរុទ្ធពីបទបរិហារកេរ្តិ៍ អក្កអនាមិក នោះ បើរកមុខឃើញ ទឹងត្រូវមានទោស ឧក្រិដ្ឋ ថ្នាក់ទីមួយ ។

ជនណា ដែលបានឮ សំដីបរិហារកេរ្តិ៍ នោះ ហើយ យក សំដី នោះ ទៅនិយាយ ដល់ជន ដទៃ គេទៅ ទៀត, ជនណា ដែលបានលិខិត, គំនូរ ឬ គ្រឿង ប្រដាប់ ដទៃទៀត ជាអនាមិក សំរាប់ បរិហារកេរ្តិ៍ នោះ ហើយ បញ្ជូនទៅឱ្យជន ដទៃ ទៀត សម្បីតែម្នាក់ ក៏ដោយ ក៏ជន នោះ ត្រូវមានទោស មជ្ឈិមថ្នាក់ទី បី ដែរ ។ ទោសនេះ ត្រូវតែ យកទៅ ផ្តន្ទាដែរ ទោះបី ជននោះ គ្មានបំណង ទឹងបង្ខូច ជន ដែលត្រូវគេ បរិហារនោះក៏ដោយ ។ ការអនុវត្ត នៃបទបញ្ញត្តិ នេះ ត្រូវវៀរចេញ បាន តែកាលណា ឈរបញ្ជូន គ្រឿងប្រដាប់ ជាអនាមិក នោះ ធ្វើតាមបង្គាប់ដែលត្រូវធ្វើ ជាចាំបាច់ ក្នុងកិច្ចការ តុលាការខាងបទព្រហ្មទណ្ឌ ។

មាត្រា២.– កាលណាបើ ការបរិហារកេរ្តិ៍ ដោយមធ្យោបាយ អនាមិក ប្រព្រឹត្តឱ្យមានសនិត្យកម្មដល់ជនណាម្នាក់ទៀត ដទៃពីជនដែលបង្អុលក្នុងនោះ មាត្រា ១ ខាងលើនេះ, ហើយ ដែល គេ រក មុខឃើញ ត្រូវមានទោសមជ្ឈិម ថ្នាក់ទី បី

ក្នុងករណី ដូចគ្នា នេះ ជន អ្នកចាប់ផ្សាយ ទូវមធ្យោបាយ សំរាប់

00222434





បរិហារកេរ្តិ៍ ដោយអនាមិក ដែលមក ដល់ខ្លួន តាមលក្ខខណ្ឌ ក្នុងកថាខណ្ឌទី២ នៃមាត្រា ១ ខាងលើ នេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

មាត្រា៣.– ជនណា ប្ដឹង បង្កាច់ ឬ ហែកហួ ក្នុងទីសាធារណៈ នូវអំពើដែលមាន ប្រភេទ នាំ ឲ្យមាន ការពោលប្រកាន់ ពីបទមជ្ឈិម ឬ ទុក្រិដ្ឋ លើជន ណាម្នាក់ ជាកំណត់ ដែលមាន គុណភាព ជាអ្នករាជការ ឬ ជាអ្នកតំណាង អាជ្ញាធរ សាធារណ ឬដែលទុក ជាអ្នករាជការ ឬ អ្នកតំណាង អាជ្ញាធរ សាធារណៈ ជានិត្យានុកូល , ជននោះ ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ទីពីរ , កាលណាបើ ពាក្យប្ដឹង ឬ សំដីហែកហួនោះ ធ្វើ ដោយមធ្យោបាយ អនាមិក ។

ជនអ្នកជួយ បញ្ជូន ឬ ផ្សាយ នូវពាក្យប្ដឹង ឬ សំដី ហែកហួ យ៉ាងនេះ ដែលខ្លួន បានដឹង ថា ការនោះ បានធ្វើ ក្រោមសណ្ឋាន អនាមិកមែន , ត្រូវមាន ទោសទុក្រិដ្ឋ ថ្នាក់ទីមួយ ។

មាត្រា៤.– នាកាលអំពើ ដែលបានប្ដឹង ឬ ដែលបានហែកហួ នោះ គួរដល់ការពោលប្រកាន់ ជាបទអាជ្ញា មែនហើយ តែបណ្ដឹង ឬ សំដីនេះ នឹងមានលក្ខណៈ ជាក្លែងបង្កាច់ បាន លុះណាតែ តុលាការ បានឃាត់ សេចក្ដី ឲ្យរួចខ្លួន ឬ លើកលែង ទោសប្រកាន់ ជន ដែលគេ ប្ដឹងនោះ ជាមុនសិន ។ ការចាំបាច់មួយទៀត តម្រូវ ឲ្យអ្នកម្ចាស់ ពាក្យ ឬ ម្ចាស់សំដី នោះ បានប្ដឹង ឬ បាននិយាយ ដោយចេតនាទុច្ចរិត ដ៏ក្នុងបំណង បង់បង្ខូច

គេ ផង ទើបទុក ជាប្តឹង បង្កាច់បាន ។ ចេតនា និង បំណង នេះ ត្រូវទុក ជាទុច្ចរិត និង បង់បង្ខូច ជាដាច់ខាត, មិនអាច យក ភស្តុតាង ផ្សេង ណា មួយ មក ជារបាំង បាន ឡើយ កាលណាបើ អ្នកនោះ ប្រព្រឹត្ត ក្រោម កាសនដ្ឋាន អនាមិក ។ ចំពោះជន ដែលរាប់ផ្សាយ នូវពាក្យបណ្តឹង ឬ សំដីហែកហួ ដោយអនាមិក នេះ ក៏ត្រូវ តែចាត់ទុក ថា ជននោះ មាន ចេតនាទុច្ចរិត និង មាន បំណង បង់បង្ខូច ដែរ កាលណាបើ ជននោះ បានដឹង នូវលក្ខណៈអនាមិក នៃពាក្យប្តឹងនិងសំដី ហែកហួ នេះ ដែរ ប៉ុន្តែត្រង់នេះក៏ស្តុតាងផ្សេង គ្រប់យ៉ាង ត្រូវតែទទួលបាន ។

មាត្រា៨.– នាពេលពាក្យប្តឹង ឬ សំដីហែកហួអនាមិក នោះ កើត បង្កាច់ ថា គេ ធ្វេសប្រហែស ក្នុងវិជ្ជាជីវៈ ទៅវិញ, មិនចូល ក្នុងជាតុ នៃបទ ល្មើស គាថា ទេ, ទោសដែលត្រូវអនុវត្ត នោះ គឺទោសមជ្ឈឹម ថ្នាក់ទីបី ប្រសិនបើ ជនរងគ្រោះ ពីព្រោះពាក្យប្តឹង ឬ សំដីហែកហួ នោះ ជាជន ណាម្នាក់ ក្នុងពួកជន ដែលមានចែង ក្នុងមាត្រា១ វគ្គទី១ ខាងលើនេះ ។

នាពេលជន ដែលត្រូវ គេ ប្តឹងបង្កាច់ ឬ គេ ហែកហួ នោះ ជាជន សាមញ្ញ វិញ, ទោស ដែលត្រូវផ្តន្ទានោះ គឺទោសទណ្ឌ ថ្នាក់ទីមួយ ។

ត្រូវយក សេចក្តីសន្និដ្ឋាន របស់រដ្ឋបាល ឬ តុលាការ ដែលបាន ស៊ើបសួររឿងនេះ ទុក ជាភស្តុតាង ថា បណ្តឹង ឬ សំដីនោះជារបស់កើត មែន ឬ មិនមែន ។

00222436



មាត្រា៦.– នាកាលអំពើ ដែលប្ដឹង ឬហែកហូ ដោយក្មេង និងដោយអនាមិក នោះ គួរឲ្យតុលាការ ជាន់ខ្ពស់ ពោទប្រកាន់ ហើយ វជ្វសកា សំរេច ថា មិនជូនទៅ តុលាការ ជាន់ខ្ពស់ ឲ្យពោទប្រកាន់ ទេ ឬ សំរេច ឲ្យប្រួមខ្លួន ឬ លើកលែង ពោទប្រកាន់ សេចក្ដី សំរេច នេះត្រូវ ទុកជាកស្ដុតាង ។

មាត្រា៧.– ការពោទប្រកាន់ ដែលទាក់ទង ដល់អំពើ មាន ថែច យ៉ាង ដូច បានអធិប្បាយ ក្នុងច្បាប់ នេះ ទិងគប ពោទប្រកាន់ បាន លុះត្រាតែ មាន ពាក្យ ពីអ្នករងគ្រោះ សិន ដែរ ។

កំប៉ុន្ដែថា បើ ការបរិហារកេរ្ដិ៍ និងពាក្យប្ដឹង ក្មេងបង្កាប់ ឬ សំដីក្មេង មួលបង្កាប់ បានធ្វើ ដោយមធ្យោបាយ អនាមិក តម្រង់ទៅរក អ្នកកាជការ អ្នកតំណាង អាជ្ញាធរ សាធារណៈ ឬ ជន ណាម្នាក់ ដែលទុក ជាអ្នកកាជការ ដោយទិត្យានុកូល ក្នុងឱកាស ដែលអ្នក ទាំងនេះ កំពុងទទួលបន្ទុក មុខងារ របស់ខ្លួន , អយ្យការពោទ គាប ពោទ តាមធម្មតាបាន ទោះបី គ្មាន ពាក្យប្ដឹង ពីជន ដែលត្រូវអនាមិកជន ប្ដឹងមក ក៏ដោយ ។

## ចំពូក បី

## អំពី បទល្មើស ប្រព្រឹត្ត លើធនធាន ជនសាមញ្ញ

## Des infractions contre la fortune des particuliers

មាត្រា៥១៥.– ជនណា ធ្វើ ឲ្យវិនាស ធនធាន អ្នកដទៃ ដោយ

00222437

D99/3/3



ចោរកម្មក្តី, ដោយរំលោភលើទំនុកចិត្តគេក្តី, ដោយឆបោកក្តី ឬ ដោយលួចលក់ ឬ លួចបញ្ចាំ អចលវត្ថុក្តី, ជននោះត្រូវមានទោស មជ្ឈិម ថ្នាក់ទីបី ហើយ តាមទីត្រូវ អនុទោស ត្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិល ព្រមទាំង តំហាត់លំនៅ ទៀត ក៏បាន ។ ដែលហៅថា៖

១-ចោរកម្ម គឺកិរិយាកាន់យក ឬ បំណាន់ និងកាន់យក ជារបស់ខ្លួន, ដោយចេតនា ទុច្ចរិត, នូវវត្ថុ អ្វីមួយ ដែលខ្លួន គ្មានសិទ្ធិ និងកាន់យក និងមិនមែន ជារបស់ខ្លួន;

២-- រំលោភ លើទំនុក ចិត្ត គឺកិរិយាកែបំបាត់ ឬ ស៊ីឡប ជាប្រយោជន៍ខ្លួន ឬ ជាប្រយោជន៍ តតិយជន ណាម្នាក់ នូវវត្ថុ អ្វីមួយ ដែលគេ ប្រគល់ ការៈ ឲ្យខ្លួន រក្សាទុកក្តី, ឲ្យដាក់តាំង ក្តី ឬ ឲ្យយក វត្ថុ នោះ ទៅប្រើប្រាស់ មាន មុខការ ជាក់ណាត់ ក្តី,

៣- ឆបោក គឺកិរិយាប្រើ ឧបាយកល ទុច្ចរិត ដើម្បីញុំាងគេ ឬ បំណាន់ និងញុំាងគេ ឲ្យប្រគល់ ទ្រព្យគេ ទាំងអស់ ឬ ខ្លះ មក ឲ្យខ្លួន ។

៤- លួចលក់ ឬ លួចបញ្ចាំ អចលវត្ថុ គឺលក់ ឬ បញ្ចាំ ដោយប្រាប់ ថា ជារបស់ខ្លួន នូវអចលវត្ថុ ដែលខ្លួន បានដឹង ថា មិនមែន ជារបស់ខ្លួន សោះ ឬ ដោយប្រាប់ ថា អចលវត្ថុ នោះ នៅទំនេរ ឥតមាន ពាក់ព័ន្ធ អ្វីទេ, ប៉ុន្តែ តាមសេចក្តីពិត, ខ្លួន បានដឹង ថា អចលវត្ថុ នោះ មាន ជាប់ ពាក់ព័ន្ធ នឹងគេ រួចទៅហើយ ។

00222438





មាត្រា ៨១៦– បទបញ្ញត្តិ ទាំងឡាយ នៃមាត្រា ខាងលើនេះ ត្រូវអនុវត្ត បាន ជាដរាប, ទោះបី វត្ថុ ដែលវិនាស ដោយបទល្មើស នោះ មានប្រភេទ យ៉ាងណា ។ ក៏ដោយ, ទោះបី វត្ថុ នោះ មិនមាន រូបធាតុ សោះ ក្តី, មិនមែន ជាទ្រព្យ អាស្រ័យនៅ នឹងវត្ថុ មានរូប ក្តី ។ គួរយ៉ាង: កម្លាំងយន្ត, ទឹក និង បរន្ត អគ្គិសនី ដែលបែក ឲ្យតែ ជន ដទៃ ក្តី, ដូចជា ការប្រើ សិទ្ធិប្រមាញ់, និង នេសាទ ក្នុងទី កន្លែង ដែលជាសិទ្ធិ របស់អ្នកដទៃ ឬ ដែលសិទ្ធិ នោះ ទុកឲ្យ អ្នកដទៃ ទៅ ហើយ ក្តី, ដូចជាផលិតកម្ម នៃការសិល្ប, អក្សរសាស្ត្រ, តន្ត្រី ឬ វិទ្យាសាស្ត្រ ដើម្បីផ្សាយ ដល់ជន ទាំងពួង ដោយគ្មាន អនុញ្ញាត ពី ម្ចាស់ នៃការ នោះ ក្តី, សូម្បី ការកែសម្រួល តែសេចក្តីក្រៅ ដើម្បី បបាត់ ប្រភព នៃការ នោះក៏ដោយ ក្តី ។

មាត្រា ៨១៧– បទបញ្ញត្តិ នៃមាត្រា ៨១៨ មិនត្រូវ អនុវត្ត ទេ ក្នុងករណី ទាំងឡាយ ដូចតទៅនេះ :

១– កាលណាបើ បទល្មើស នោះ ប្រព្រឹត្ត ឡើងក្នុង រវាង សហព័ទ្ធ និង សហព័ទ្ធ, រវាង សហាយ និង សហាយ, រវាង បុព្វញាតិ និង បច្ឆាញាតិ ខាងខាន់ស្មា, ឥតខាន់ស្មា ឬ ចំពុំម, ព្រមទាំងបុព្វញាតិ របស់សហព័ទ្ធ ឬ របស់សហាយ, រវាង បច្ឆាញាតិ និង សហព័ទ្ធ សហាយ របស់ បុព្វញាតិ ;

២– កាលណាបើ បទល្មើស នោះប្រព្រឹត្ត លើអចលវត្ថុ ពីកំណើត ដូចមានសម្តែង ក្នុងមាត្រា ៦៣១ ក្រមរដ្ឋប្បវេណី កុំឲ្យតែការ មកយក ជាទ្រព្យ ខ្លួន នោះ ដោយវិហិង្សា ឬ កុំឲ្យតែ អំពើ នោះ ចូល ជាទោសកម្ម លួចលក់ ឬ លួចបញ្ចាំ ;

៣– កាលណាបើ អំពើល្មើស នោះ ចូល ជារឿង កូនបំណុល មិនព្រម ប្រតិបត្តិ តាមកាតព្វកិច្ច ដែលកើតមក ពីកិច្ចសន្យាលក់, កិច្ចសន្យា ខ្ចី ទៅបរិភោគ ឬ កិច្ចសន្យា ជួល ការងារ; ក្នុងករណីនេះ ត្រូវ យក មាត្រា ៤២១ និង ៤២៨ ទៅ អនុវត្ត វិញ ប្រសិនបើ អំពើ នោះ ប្រព្រឹត្ត គ្រប់លក្ខខណ្ឌ ទាំងអស់ របស់មាត្រា ទាំងនេះ;

៤– កាលណាបើ អំពើល្មើស នេះ ចូល ក្នុងរឿង កិច្ចសន្យា ធ្វើ មិនស្រប តាមច្បាប់ ឬ ធ្វើ ជាមួយ នឹងជន គ្មានសមត្ថភាព ឬ ពុំនោះ ទេ កិច្ចសន្យា នោះ ពិតមែនតែ ធ្វើស្រប នឹងច្បាប់, ហើយទុក ជាបានការ តាមច្បាប់ តែកិច្ចសន្យា នេះ មាន កម្មវត្ថុ ស្តី ពីការវិវាទ រវាង ម្ចាស់បំណុល និង កូនបំណុល អំពីអត្ថិភាព នៃកិច្ចសន្យា ក្តី, អំពីប្រភេទ នៃកាតព្វកិច្ច ដែលបានព្រមព្រៀង គ្នា ក្តី, អំពីការប្រតិបត្តិ នៃកិច្ចសន្យា នេះ ក្តី ។

មាត្រា៤១៨– នាកាល បទល្មើស គឺ ចោរកម្ម ដូចដែល មានសំដែង ដោយឡែក ក្នុងមាត្រា ៤១៥ កថាខណ្ឌទី ១ នោះ លួច

00222440

D99/3/3



ដំរី, សេះ, ក្របី ឬ គោ ក្តី, លួច រថ សម្រាប់ ដឹក មនុស្ស, ដឹក ទំនិញ ឬ សម្រាប់ ជិះ ផ្ទាល់ខ្លួន ក្តី, លួច គ្រឿង ប្រដាប់ សម្រាប់ ធ្វើ ដំណាំ ឬ ឧបករណ៍ កសិកម្ម ឬ ឧស្សាហកម្ម ក្តី, លួច នាវា ឬ នេសាទុបករណ៍ ក្តី, អំពើ នោះ ត្រូវធ្វើ ទោស ជា អតិបរមា នៃ ទោស មជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៨១៩– ចោរកម្ម ឯណា ប្រព្រឹត្ត លើផល ដំណាំ ដែល មិនទាន់ ច្រូតកាត់ ឬ ច្រូតកាត់ហើយ ប៉ុន្តែ បិតនៅ លើស្រែ, ចំការ នៅឡើយ, ចោរកម្ម នោះ ត្រូវផ្តន្ទា ទោស ជាអតិបរមា ដូចគ្នា ។ ប៉ុន្តែ អំពើ ដែលលួច ផ្លែឈើ ដើម្បីគ្រាន់តែ បរិភោគ ទីកន្លែង ដែលលួច ឬ ដើររើស កួរស្រូវ ក្នុងស្រែ ដែលច្រូតកាត់ រួចហើយ គ្មាន អនុញ្ញាត ពីម្ចាស់ស្រែ នោះ ត្រូវមាន ទោស ជាលហុ វិញ ។

មាត្រា ៨២០– ជនណា បានដឹង ថា ខ្លួន គ្មាន ប្រាក់ ទេ ហើយ ហៅ ភោជន ឬ ភេសជ្ជៈ មក បរិភោគ នៅ ទីលក់ អាហារ នោះ, ជន នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ជនណា ជួល ឬ បំណាង ទីជួលយាន គេ ជិះ ដើម្បីធ្វើ ដំណើរ តាមផ្លូវគោក, តាមទន្លេ, តាមសមុទ្រ ឬ តាមអាកាស, ហើយ គ្មាន ប្រាក់ឈ្នួល ឲ្យ គេ, ជននោះ ក៏ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ដូច

គ្នា ដែរ ។ ក៏ប៉ុន្តែ បើ ជននោះ ជួល ដឹក វត្ថុ ឬ ទំនិញ វិញ, ជននេះ មិនត្រូវមាន ទោស បាន, លុះណាតែ របស់ ដែលដឹក នោះ លក់សង ថ្លៃឈ្នួល ដឹក នោះ មិនគ្រាន់ ។ អាស្រ័យហេតុនេះ, តុលាការ ត្រូវ អូស របស់ ដែលដឹក នោះ ទុកបណ្ដារ ហើយ បង្គាប់ ឲ្យលក់ របស់ តាមពាក្យសុំ នៃអ្នកម្ចាស់ យាន ។

មាត្រា៤២១ ជនណា លក់, ធ្វើ អនុប្បទាន, ឲ្យ ឬ ធ្វើ ឲ្យបាត់ ដោយទុច្ចរិត នូវរបស់ ដែលខ្លួន ទិញជឿ ពីគេ មក, មិនទាន់ឲ្យ ថ្លៃ អស់, មិនទាន់សង បង្គ្រប់ នូវថ្លៃ ដែលនៅ ជំពាក់ នៅឡើយ ឬ មិនបាន ប្រគល់ របស់ ជាកម្មវត្ថុ នៃកិច្ចសន្យា ទិញជឿ នោះ ទៅ ម្ចាស់របស់ វិញ ទេ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

ក៏ប៉ុន្តែ បើ វត្ថុ ដែលទិញជឿ នោះ ជាស្បៀងអាហារ ដែលជន ជាកូនបំណុល នោះ ទិញ ដើម្បីលៀង ជីវិតខ្លួន តែប៉ុណ្ណោះ, មិនមែន ដើម្បី ធ្វើ ជំនួញ ទេ, បទបញ្ញត្តិ ខាងលើនេះ មិនត្រូវអនុវត្ត ឡើយ ។

មាត្រា ៤២២– ជនណា បន្លំ ឬ ប៉ង នឹងបន្លំ ឈ្មោះណាម្នាក់ ដោយវោហាស្ត្រ ឬ ដោយគំរាម ឲ្យបំពេញ នូវកាតព្វកិច្ច អ្វីមួយ ដូចមាន សម្ដែង ក្នុងមាត្រា ៧៨៩ ក្រមរដ្ឋប្បវេណី, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីបី ។ អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិល និង គំហាត់

លំនៅ, អាច នឹងអនុវត្ត លើជននោះទៀត ក៏បាន ។

ការបកកេរ្តិ៍ ឬ ផ្តោលទោស ជា យថាហេតុ ដោយលាយលក្ស អក្សរ ឬ ដោយវាចា ពីអំពើ ទាំងឡាយ ដែលមាន ពិត ឬ ក្លែងក្លាយ ហើយ ដែលមានប្រភេទ នាំឲ្យសៅហ្មង ដល់កិត្តិយស ឬ កេរ្តិ៍ឈ្មោះ របស់អ្នកដទៃ ត្រូវទុក ថា ជាសេចក្តីគម្រាម ។

« សេចក្តីគម្រាម » អាចមាន ការណ៍ យ៉ាងនេះ ជាអាទិ៍:

១- ខ្ចាយ នូវអាថ៌កំបាំង ក្នុងវិជ្ជាជីវៈ ដូចមានសម្តែង ក្នុង មាត្រា ៤១០ ;

២- បង្ខំ ជន ណាម្នាក់ ឲ្យសន្យា ឬ ឲ្យប្រគល់ ប្រាក់ មាន ចំនួន ប៉ុណ្ណេះ ឬ ប៉ុណ្ណោះ មក ឲ្យខ្លួន ដើម្បីចៀសវាង កុំឲ្យ ខ្លួន ប្តឹង ពី ជននោះ ឬ ពីតតិយជន ណាម្នាក់ ទៀត , ក្នុងឱកាស ដែលមាន បទ ល្មើស ណាមួយ កើតឡើង , ទោះបី អ្នក ដែលទទួល ពាក្យសន្យា ឬ ទទួល ប្រាក់ នោះ ជាអ្នករងគ្រោះ ក្នុងបទល្មើស នោះ ក៏ដោយ ។

« កាតព្វកិច្ច » អាច មាន ន័យ ថា ពាក្យសន្យា ឬ ពាក្យប្តេជ្ញា តែប៉ុណ្ណោះ ក៏បាន ទោះបី ពាក្យ នោះ គ្មានអ្វី ជាប្រាកដ ក៏ដោយ ។

មាត្រា ៤២៣- ជនណា បានក្លែង លិខិត ឯកជន ដោយ របៀប ណាមួយ ដូចមានរៀបរាប់ ក្នុងមាត្រា ៣១៧ ឬ ប្រើ លិខិត ក្លែង

នោះ ដោយ ដឹង ថាក្លែង ដែរ , ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។ អនុទោស ត្រង់ស្ថាន បន្ថយសិទ្ធិស៊ីវិល តាម ន័យ អនុវត្ត លើជននោះទៀត ក៏បាន ។

សេចក្ដីបំណង ក្នុងបទល្មើស នេះ ក៏ត្រូវមាន ទោស ដូចជាបានប្រព្រឹត្ត បទល្មើស នោះ ដែរ ។

ក៏ប៉ុន្តែ ការក្លែង ឬ ការប្រើ ដោយក្លែង នូវលិខិត ឯកជន នេះមិន ត្រូវចោទប្រកាន់ ទេ , បើ អំពើ នោះ មិនអាច បណ្ដាល ឲ្យមានព្យសនកម្ម អ្វីមួយ សោះ ទេ ។

មាត្រា ១២៤ ជនណា ប្រើ ជញ្ជីង ចុង , ជញ្ជីងខ្សែ , ប្រើខ្នាត សម្រាប់ វាល់ , ថ្លឹង , វាស់ ជាខ្នាត ក្លែង , ជនណា បន្លំ ឬបំណង ទីងបន្លំ អ្នកដទៃ អំពីគុណភាព នៃរបស់ ជាកម្មវត្ថុ នៃកិច្ចសន្យាណាមួយ , ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើ ជន , អ្នកប្រព្រឹត្ត ទោសកម្ម នេះ , ជាពាណិជ ឬ ជាអ្នកលក់ដូរ ដល់សាធារណជន , ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

ក្នុងករណី ទាំងអស់នេះ , គ្រឿងឧបករណ៍ ក្លែងក្លាយ សម្រាប់ថ្លឹង , វាស់ ឬ វាល់ ត្រូវអូសរឹប និង ឲ្យបំផ្លាញ ចោល ទាំងអស់ ។

ពាណិជ ឬ អ្នកលក់ដូរ ណា មាន កូនជញ្ជីង ក្លែង , ខ្នាតក្លែង ,

ជញ្ជីងប៉ុង ក្លែង, ជញ្ជីង ខ្សែ ក្លែង, ពាណិជ្ជ ឬ អ្នកលក់ដូរ នោះ ត្រូវ មាន កំហុស ជាមាន បំណង ទីងប្រព្រឹត្ត នូវទោសកម្ម ដូចមាន សម្តែង ជាពិសេស ខាងលើនេះ ។

មាត្រា ៤២៥– ពាណិជ គឺជន ដែលមាន ប៉ាតង់ ឬ គ្មាន ប៉ាតង់ ទិញមក ដើម្បីលក់ ជូន សាធារណៈជន ក្នុងនាមផ្ទាល់ របស់ ខ្លួន ក្តី ដើម្បីជាប្រយោជន៍ អ្នកដទៃ ក្តី ។

អ្នកលក់ដូរ ជូន សាធារណៈជន គឺជន ដែលលក់ ក្នុងទីផ្សារ ក្តី, តាមផ្លូវសាធារណៈ ក្តី, ក្នុងហាង ក្តី, ឬ ស្ពាយ, ទូល ក្តី ដែលសាធា-រណៈជន អាច ទិញដូរ បាន ដោយសេរី ។

ឧបករណ៍ ក្លែង គឺឧបករណ៍ សម្រាប់ថ្លឹង ឬ វាស់, វាល់, ដែល មាន កូនជញ្ជីង, មាន មាឌ, មាន ទំហំ មិនស្រប តាមការពិតដែលខ្លួន ត្រូវថ្លឹង វាល់ ឬ វាស់ ឲ្យអ្នកទិញ ។

មាត្រា ៤២៦– ជនអ្នក បន្លំ ឬ ប៉ង់ ទីងថ្លឹ អ្នកដទៃ នូវអត្ត សញ្ញាណ, ប្រភេទ, គុណភាព ឬ ដើមកំណើត នៃរបស់ ដែលជា កម្មវត្ថុ ក្នុងកិច្ចសន្យា ណាមួយ, ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើ ចារី នេះ ជាពាណិជ ឬ ជាអ្នកលក់ដូរ ជូនសាធារណជន, ចារី នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា៤២៧- នាកាលឧបាយកល ដែលប្រើ ដើម្បីបន្លំ ឬ ប៉ុនប៉ងបន្លំ ពីប្រភេទ, អត្តសញ្ញាណ, គុណភាព ឬ ដើមកំណើត ជាឧបាយកល ធ្វើ ដោយក្លែងក្លាយ ឬ ដោយវិភេទ យ៉ាងណាៗ ដើម្បីទីងក្រឡៃកែ សំបកក្រៅក្តី, ដើម្បីទីងក្រឡៃ ដល់សារជាតិនៃរបស់ នោះក្តី ឬ ដើមកំណើត និង សញ្ញាការដ្ឋាន (marque de fabrique) នៃ របស់ នោះក្តី, អំពើ ក្លែង បន្លំ ដូចមានសំដែង ក្នុងមាត្រា ៤២៦ នោះ ត្រូវ ផ្តន្ទាទោស ជាអតិបរមា តាមថ្នាក់ ទោស របស់ ពារី នោះ ជាពាណិជ, ជាអ្នកលក់ដូរ ឬ មិនមែន ជាពាណិជ, មិនមែន ជាអ្នកលក់ដូរ ៗ អំពើនេះ អាចនឹងត្រូវផ្តន្ទា អនុទោស គ្រង់ស្ថាន បន្ថយ សិទ្ធិស៊ីវិក និង គំហាត់លំនៅ ទៀតក៏បាន ៗ ចៅក្រម ត្រូវបង្គាប់ ឲ្យអូសរឹប របស់ ដែលក្លែង ឬ ដែលវិភេទ នោះ ព្រមទាំង ឲ្យអូសរឹប របស់ក្លែង ដូចគ្នា ដទៃទៀត ដែលនៅ ក្នុងដៃ ឬ ដែលជារបស់ ពារី នោះ ៗ ចំពោះរបស់ ដែលអូសរឹប នេះ, ចៅក្រម ត្រូវអូសទុក ជាទ្រព្យរបប ឬ ត្រូវបំផ្លាញ ចោល តាមគួរ ដល់ការណ៍ ៗ

មាត្រា៤២៨- ជនណា, កាលបានព្រមព្រៀង ចុះ កិច្ចសន្យា ដោយសេរី និង ដោយទៀងទាត់ នៅ ចំពោះមុខ អាជ្ញាធរ ក្នុងឃុំ ថា នឹងស៊ីឈ្នួល ធ្វើការ ឲ្យគេ ហើយ មិន ធ្វើការ ឲ្យគ្រប់ ថ្ងៃឈ្នួល ដែល ខ្លួន បានបើកយក ជាមុន នោះ ព្រមទាំង តែបាត់ មិន បានសង ថ្ងៃឈ្នួល

ដែលនៅសល់ ជំពាក់គេ នោះ ទៀត ផង, ជននោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ។

នឹងទុក ថា ជាថ្លៃឈ្នួល បើកមុន បាន វត្ថុ ទាំងឡាយ ជាប្រាក់ក្តី, ស្បៀងអាហារ ឬ ទំនិញ ផ្សេងៗក្តី, ឧបករណ៍ សម្រាប់ធ្វើការងារ ឬ សត្វពាហនៈក្តី; កាលបើ មាន ភស្តុតាង ថា មនុស្សឈ្នួល ដែលរត់ នេះ បានធ្វើ អនុប្បទាន, បានលក់, បានឲ្យ ឬ បានធ្វើ ឲ្យបាត់ នូវទំនិញ, ស្បៀង, ឧបករណ៍ ឬ សត្វ ដែលខ្លួន បានទទួលមក-នោះ, មនុស្សឈ្នួល នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

ក្នុងរឿងនេះ, ចៅក្រម មិនបាច់ តឹងទារ ម្ចាស់ឈ្នួល ឲ្យជូន កិច្ចសន្យា នោះ ទេ, កាលណាបើ មាន ករណី ដូចតទៅ នេះ:

១ - ឈ្នួល នោះ រត់បាត់ ឬ រក ឃើញមក វិញ ,

២ - ឈ្នួលនោះ មិន គាំ ពីប្រភេទ នៃកិច្ចសន្យា នោះ ទេ , មិន គាំ ពីថ្លៃឈ្នួល ដែលខ្លួន បានបើក មុន នោះ ទេ , មិន គាំ ពីការ ដែលខ្លួន ឈប់ ធ្វើការ មុន កំណត់កាល នឹង ដោយចេតនា ទេ ។

បទបញ្ញត្តិ ទាំងឡាយ ក្នុងមាត្រា នេះ មិន ត្រូវអនុវត្ត ទេ, កាលណាបើ និយោជក នោះ មិនបានរត់ សោះ ឬ មិនមានបំណង នឹងរត់ សោះ ទេ, កាលណាបើ និយោជិត នោះ គាំ អំពីប្រាក់ ដែលម្ចាស់ឈ្នួល នោះ តឹងទារ ឬ និយោជិត នោះ បានគាំ ថា ខ្លួនបាននៅ បំរើ -

00222447





គ្រប់ ប្រាក់ឈ្នួល ហើយ ។

នាកាល កិច្ចសន្យា ជួល ការងារ នេះ មាន សេចក្ដី ថា ជួល ជន ម្នាក់ នេះ មក ធ្វើការ, តែដល់បើក ថ្លៃឈ្នួល, ម្ចាស់ប្រាក់ បើក ឲ្យទៅ ជនដទៃ ក្រៅ ពីជន ដែលធ្វើការ នោះ ទៅវិញ, បទបញ្ញត្តិ នៃមាត្រា នេះ ក៏មិនត្រូវ អនុវត្ត ដែរ ។

ព្រះរាជក្រម លេខ ២៣២ ប រ ចុះថ្ងៃទី ៣-២-៦៥ បន្ថែម ថា និយោជកណា ដោយការទុច្ចរិត មិនបើក ប្រាក់ឈ្នួល ដែលខ្លួន ជំពាក់ ឲ្យទៅ និយោជិត ខ្លួន តាមកាលបរិច្ឆេទ និង តាមចំនួន ដូចបានព្រមព្រៀង ទេ, និយោជក នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ ការហាមប្រាម ចំពោះនិយោជក មិនធ្វើទៅបាន លុះណាតែ តុលាការ រដ្ឋបាល ណា មួយ បាន ដាក់ កំហិត និយោជក ឲ្យសង តាមបណ្ដឹង របស់និយោជិត នោះរួចហើយ ។ និយោជិត អាច ជូន ភស្តុតាង តាមបែបបទ ណា ក៏បាន ដើម្បីបញ្ជាក់ អំពីឥណទេយ្យ ខ្លួន ។

មាត្រា ៥២៩– ឥណាយិ ( កូនបំណុល ) ណា មាន ពិរុទ្ធ ថា បានធ្វើ ឲ្យបាត់ ឬ បំណង នឹងធ្វើ ឲ្យបាត់ ដោយចេតនា នូវបេតិកភណ្ឌ ខ្លួន ទាំងអស់ ឬ ភាគខ្លះ ដើម្បីបង្ខូច សិទ្ធិ ឥណទាយក ( ម្ចាស់បំណុល ) ខ្លួន , ឥណាយិ នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ

00222448





ពាយាទ (អ្នកត្រូវទទួលមរតក) ណា លាក់ បិតបាំង មរតក ទាំងអស់ ឬ ភាគ ខ្លះ ដើម្បីកុំឲ្យបានទៅ សហពាយាទ (អ្នកត្រូវទទួលមរតក ជាមួយគ្នា), ពាយាទ នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ដែរ ។

មាត្រា ៨៣០– អ្នកណា ប្រព្រឹត្ត នូវទោសកម្ម ដែលមាន សម្តែង ក្នុងមាត្រា ១៦៧១ ក្រមរដ្ឋប្បវេណី ស្តី ពីនៃបំបាត់ ទ្រព្យអំ-ណូស, អ្នកនោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី ។

មាត្រា ៨៣១– ស្តី អំពី សមត្ថកិច្ច តុលាការ ក្នុងរឿង អ្នកជំនួញ ជាតិខ្មែរ ត្រូវ និរាករណ៍ ដោយឯកឯង ដោយអំណាច ព្រះរាជក្រម លេខ ៥៧៨ ន.ស. ១៣–៣–៥០

មាត្រា ៨៣២– ជនណា មិន បានប្រព្រឹត្ត ជាមួយ, ដោយផ្ទាល់ឬដោយប្រយោល, នូវអំពើល្មើស ណាមួយ ដែលបណ្តាលឲ្យមាន ព្យសនកម្ម ដល់ធនធាន អ្នកដទៃ ទេ, ប៉ុន្តែ បានទទួល ដោយចេតនា ឬ ដោយដឹងច្បាស់, នូវផល នៃអំពើល្មើស នោះ ទាំងអស់ ឬ ភាគខ្លះ, ឬ បានជួយ សម្រួល ឬ ជួយខ្នះខ្នែង ក្នុងការចែណ្តារ ផល នៃអំពើល្មើស នោះ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីបី, ជននោះ អាច នឹងត្រូវមាន អនុទោស ត្រង់ឃ្លាន បន្ថយសិទ្ធិស៊ីវិក និង គំហាត់លំនៅ ទៀត ក៏បាន ។

សេចក្តីប៉ុនប៉ង ក្នុងបទល្មើស នេះ ក៏ត្រូវមាន ទោស ដូចបាន

00222449





ប្រព្រឹត្ត បទល្មើស នោះ ដែរ ។ មើលព្រះរាជប្រកាស ស្តីអំពីលក់ចេញទិញចូល
នៅ ខាងចុង សៀវភៅ នេះ ទៀត ។

មាត្រា ៤៣៣– កាលណា វត្ថុ ដែលគេ លួចទៅ, គេ បំបាត់ទៅ ឬ គេ យកបាន ដោយសារគេ ប្រព្រឹត្ត បទឧក្រិដ្ឋ ឬ មជ្ឈិម នោះ, បានគេ ឃើញ មកវិញ ហើយ, អ្នករងអំពើល្មើស អាច សុំឲ្យ ចៅក្រម បញ្ជា ឲ្យបង្វិល វត្ថុ នោះមក ឲ្យខ្លួន វិញ បាន, ចៅក្រម ក៏ត្រូវតែ អនុញ្ញាត តាមសុំ ជាដរាប, ប្រសិនបើ ចៅក្រម បានឆូស របស់ នោះពីដៃ នៃអ្នក ទទួល ផល ចោរកម្ម មក ។ កាលណាបើ លទ្ធករ ដោយសុចរិត មិនអាច ជូន សំគាល់ បាន ថា វត្ថុនោះ ខ្លួន បានទិញ ក្នុងផ្សារសាធារណៈ, ក្នុង ផ្ទះរបស់ពាណិជ, ក្នុងផ្ទះ អ្នកលក់ដូរ ជូនសាធារណជន, ពីតំណាង នៃ អ្នកលក់ដូរ ជូនសាធារណជន ឬ ពីតំណាង នៃជន ណាម្នាក់ ដែល សាធារណជន បានស្គាល់ ថា ជននោះ ធ្លាប់ ធ្វើ ជំនួញ ទូវវត្ថុ បែប នេះ ទេ ឬ ក្នុងកន្លែង ដែលវត្ថុ នោះ ដាក់តាំង ដល់សាធារណជន ទេ ចៅក្រម ក៏ត្រូវតែ បញ្ជា ឲ្យបង្វិល វត្ថុ នោះ ឲ្យម្ចាស់ វត្ថុ ដែលជាអ្នក រង អំពើល្មើស នោះ ដែរ ។

សូម្បី វត្ថុ នោះ ចាស់ រិចរិល, ខូចខាត, បាត់ខ្លះ, នៅ ខ្លះ មិនគ្រប់សព្វ, ឬ ដែលទិញមក ថោកគេក៏ដោយ, ក៏បើ វត្ថុ នោះ បានទិញមក ពីអ្នកលក់ដូរ ជូនសាធារណជន, ឬ ក្នុងទីសាធារណៈ ក៏

ដោយ ឲ្យតែក្រៅ ពីគ្រឹះស្ថាន ដែលរាជការ ត្រួតពិនិត្យ, ក៏ត្រូវតែ តុលាការ បង្វិលទៅឲ្យ អ្នកធ្វើអំពើល្មើស វិញ ដែរ ។ ថ្លៃ ដែលត្រូវទុក ថាថោក ពេក នោះ គឺថ្លៃ ដែលតិចជាង ពាក់កណ្ដាល នៃថ្លៃ ទិញ នោះ ។

ក៏ប៉ុន្តែ ចៅក្រម មិន ត្រូវបង្វិល វត្ថុ ដែលបានមក ដោយសារបទ ល្មើស ទៅឲ្យម្ចាស់វត្ថុ នោះវិញទេ កាលណាបើ បណ្ដឹង អាជ្ញា ត្រូវ លត់ ដោយសារផុត អាជ្ញាយុកាល ទៅហើយ ។

មាត្រា ៥៣៦– ជនណា ធ្វើ ឲ្យអន្តរាយ, ដោយចេតនា នូវ ចលវត្ថុ ឬ អចលវត្ថុ ជាកម្មសិទ្ធិ របស់អ្នកដទៃ , ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

អ្នកណា ធ្វើ ឬ បំណង ទីងធ្វើ ឲ្យវិនាស អន្តរាយ ដោយចេតនា , នូវចលវត្ថុ ជាកម្មសិទ្ធិ របស់អ្នកដទៃ ដោយបង្កហេតុ ឲ្យមាន គ្រោះថ្នាក់ ជាសម្ភារៈ ដល់ជន អ្នកប្រើប្រាស់ ផ្លូវសាធារណៈ, អ្នកនោះ ក៏ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ដែរ ។

អ្នកណា ធ្វើ អំពើ ទាំងឡាយ មានដាក់ លើផ្លូវសាធារណៈ នូវដែក គោល, បន្ទះ, កំទិច លោហម័យ ឬរបស់ផ្សេង ដែលនាំ ឲ្យមុត ផ្ទុះ ជាដើម, អ្នកនោះ ត្រូវមាន ទោស ដូចគ្នា ដែរ ។

មាត្រា ៥៣៧– ជនណា បំផ្លាញ, ដោយចេតនា, ឲ្យវិនាស

អន្តរាយ ដំណាំ ឬ ផលដំណាំ ដែលបិតនៅ ក្នុងស្រែ, ចំការ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។

បើ សេចក្តីអន្តរាយ នេះ បណ្តាលមក ពីការលែង សត្វ ឲ្យដើរ ជាន់ ឬ ឲ្យស៊ី, អ្នកលែង សត្វ នេះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

បទបញ្ញត្តិ ទាំងពីរ បទ នេះ ត្រូវអនុវត្ត ដែរ, កាលណាបើ ជន ណាម្នាក់ ដោយអួតអាង ថា ខ្លួន មានសិទ្ធិ លើដី ដែលតតិយជន បាន ដាំ ដំណាំ រួចទៅហើយ, ហើយ ទៅធ្វើ ឲ្យវិនាសអន្តរាយ ដល់ដំណាំ នោះ, ទោះបី ពីថ្ងៃមុន ខ្លួនបានបណ្តេញ តតិយជន ឲ្យរុះរើ ដំណាំ នោះ ចេញ ដែរ តែ តតិយជន មិនព្រមធ្វើតាម ក៏ដោយ, ទោះបីខ្លួន កំពុង ក្តីក្តាំ ទាមទារ សិទ្ធិ ដី នោះ ក៏ដោយ ។

មាត្រា ៤៣៦ – ជនណា បំផ្លាញ ដោយរបៀប ទាំងឡាយ ណា មួយ មានបំផ្លាញ ដោយអគ្យន្តរាយ ជាដើម ឲ្យវិនាស ព្រៃឈើ,ដំណាំ ឬ ផលដំណាំ ដែលកំពុងដុះ ឬ ដែលដក, ច្រូត ហើយ, ជននោះ ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ៤៣៧ – ថ្មី ( ព្រះរាជក្រមលេខ៦– បរ ចុះថ្ងៃ ១–៤–៦០ )

ជនណា បង្ហិន, បំផ្លាញ ដោយភ្លើង ឬ ដោយបែបបទ ដទៃ ទៀត នូវគេហស្ថាន ជាលំនៅ, ទូក, នាវ ទាំងឡាយ, ជននោះ ត្រូវមាន

00222452

D99/3/3



ទោសទណ្ឌក្រិដ្ឋ ថ្នាក់ទីបី ។

បើ ការបង្ហិន បំផ្លាញ គេហស្ថាន ដែលមិន សម្រាប់នៅ, ដូចជា បរិវេណ, ក្រោលសត្វ, រោង រថ ឬ សត្វ, រោងធ្វើការ, ជង្រុក ទិន ក្រង់, ត្រូវធ្វើ ទោសទណ្ឌក្រិដ្ឋ ថ្នាក់ទីពីរ ។

មាត្រា ៥៣៨–(ក្រមលេខ ៦–បរ ចុះថ្ងៃ ១–៩–៦០) អគ្គិភ័យណា, ការបំផ្លាញ ឬ ការបង្ខូច ណា ដែលកើតឡើង ដោយអចេតនា, តែមាន ភ័ស្តុតាង ថា អ្នកប្រព្រឹត្ត នូវអំពើល្មើស នោះ មិន ប្រយ័ត្ន, មិនប្រសប់, ដោយធ្វេសប្រហែស, វិរុទ្ធជន នោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីពីរ ។ ប្រសិនបើ អំពើ ទាំងនោះ បានកើតឡើងដោយ ចារី មិនគោរព តាមបទបញ្ជា, វិរុទ្ធជន នោះ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីពីរ ដល់អតិបរមា ។

មាត្រា ៥៣៩ - ជនណា បង្ខិត គោល, រើ ស្លាក ជាតសិណា, រំលើងចេញកូនឈើ ឬ ដើមឈើ ដុះជាព្រំ, បំផ្លាញ របង, ឈូស រំលើង ភ្លឺ, លប់ គូ ដែលព័ទ្ធ អចលវត្ថុ ជាកម្មសិទ្ធិ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

សូម្បី ចារី នោះ ជាអ្នក បានដាំ ដើមឈើ នោះ, បានបោះ គោល ឬ ស្លាក នោះ, បានលើក ភ្លឺ នោះ, បានជីក គូ នោះ ដោយខ្លួនឯង ក្តី,

00222453

D99/3/3



នាកាល របស់ ពាំងអស់នេះ កើត ជារបស់សម្រាប់ បង្ហាញ, ប្រាប់ ព្រំប្រទល់ ដី ណាមួយ ដែល នៅជាប់ គ្នា ទៅហើយ, ហើយ ខូច ទៅ បង្ខិត ឬ បំផ្លាញ មិន ឲ្យ អ្នកនៅ លើដី ជាប់គ្នា នោះ ឬ កម្មសិទ្ធិករ នៃដី ជាប់គ្នា នោះ យល់ព្រម ជាមុន ទេ, ការី នោះ ក៏ ត្រូវមាន ទោស មជ្ឈិម ថ្នាក់ទីមួយ ដែរ ។

មាត្រា៥៤០– ជនណា ចូល ឬ ចំណាន ទំងចូល ក្នុងលំនៅ អ្នកដទៃ ដោយអ្នកនៅ ផ្ទះ នោះ ឬ អ្នកមាន គុណភាព ជាតំណាង ម្ចាស់ ផ្ទះ នោះ មិនព្រមព្រៀង ផង ឬ មិនបានដឹង សោះ, ជននោះ ត្រូវមាន ទោសមជ្ឈិម ថ្នាក់ទីមួយ ។

ចប់ក្រមព្រហ្មទណ្ឌ

00222454



# ច្បាប់ស្ដីពីលក់ចេញ ទិញចូល

ព្រះរាជប្រកាស លេខ ៧១ ចុះថ្ងៃ ទី ៨ កើតខែចេត្រ ឆ្នាំ ច ឆស័ក ព.ស. ២៤៧៧ ត្រូវនឹងថ្ងៃទី ១១ ខែមេសា ឆ្នាំ ១៩៣៨

ប្រការមួយ– អ្នកលក់ចេញ ទិញចូលណា ទិញសង្ហារិម ចាស់ៗ, សំពត់ គ្រឿងសំលៀកបំពាក់, គ្រឿងមាសប្រាក់, ចាន ក្បាន, គ្រឿងសស្ត្រាវុធ, គ្រឿងលោហធាតុ គ្រឿងដែកចាស់ៗ របស់ឯទៀត ទិញទំនិញ ផ្សេងសំណាង ដើម្បីនឹងលក់ ទៅវិញ ឬ ទិញ ទំនិញ ថ្មីៗ អំពីជន ឯណា ក្រៅ ពីអ្នក ដែលធ្វើ របស់ នោះ ឬ ក្រៅ ពីអ្នក ដែលធ្វើជំនួញ របស់ ទាំងនោះ អ្នកលក់ចេញទិញចូល នោះ ត្រូវ ប្រតិបត្តិតាមសេចក្ដីបញ្ញត្តិ ដូចមានខាងក្រោយ នេះ ។

ប្រការ២– ជំនួញ គ្រឿងសស្ត្រាវុធ ដែលអ្នកលក់ចេញទិញ ចូល បានអនុញ្ញាត ឲ្យធ្វើ នោះ នឹង អាចទិញ ឬ លក់បាន តែគ្រឿង សស្ត្រាវុធ ចាស់ៗ ហើយ ដែលប្រើការ មិនកើត ។

ប្រការ៣– ជនណា ចង់ធ្វើ ជា អ្នកលក់ចេញទិញចូល ត្រូវសុំ ចុះ ឈ្មោះ ក្នុងបញ្ជីសម្រាប់កត់ អ្នកជំនួញ បែបនេះ នៅមន្ទីរ រ៉េស៊ីដង់ មែរី ជាមុន បើខ្លួន នៅភ្នំពេញ ; បើ នៅ ខែត្រក្រៅ ត្រូវសុំចុះ ឈ្មោះ ក្នុងបញ្ជី ដែលបើក សម្រាប់ ឲ្យចុះ នៅប៉ុយរ៉ូ រ៉េស៊ីដង់ ទីរួមខែត្រ ។

ដែលនឹងប្តឹងសុំ ចុះឈ្មោះ នោះ ត្រូវធ្វើ ពាក្យ បំពែម មួយច្បាប់ ព្រមទាំងបញ្ជីថ្កោលទោស ខ្លួន មួយច្បាប់, អត្តសញ្ញាបណ្ណ មួយច្បាប់ រូបថត ៦ សន្លឹក ជាប់ ជាមួយ ផង, រូបថត ១ សន្លឹក សម្រាប់បិទ ក្នុងបញ្ជី ដូចមានសំដែង ខាងលើ នេះ, ១ សន្លឹកទៀត សម្រាប់បិទ ក្នុងកំណត់ ចុះឈ្មោះ ដែលត្រូវឲ្យ សាមីខ្លួន ។

ពាក្យនោះ ត្រូវប្រាប់ កន្លែង ដែលត្រូវធ្វើ ជំនួញ ព្រមទាំង ចំនួន បន្ទប់ ដែលត្រូវធ្វើ ជាកន្លែង ដំកល់ ឬ ជាឃ្លាំង ដាក់ របស់ ។ ថ្ងៃក្រោយ បើ នឹងយក បន្ទប់ ណា ធ្វើ ជាកន្លែង ដំកល់ ឬ ជាឃ្លាំង ដាក់ របស់ នោះ ត្រូវសុំអនុញ្ញាត ជាមុន, បើឥត អនុញ្ញាត ពីរាជការ មុខក្រសួង ទេ នឹងធ្វើពុំបាន ។ មួយទៀត បន្ទប់ ទាំងនោះ ត្រូវទុក សម្រាប់តែធ្វើជំនួញ លក់ចេញទិញចូល ប៉ុណ្ណោះឯង ។ អ្នករាជការ ដែលទទួលភារៈ ខាងពិនិត្យ ត្រួតត្រា នោះ អាចនឹងពិនិត្យ ឲ្យដឹង ថា សេចក្តីបញ្ញត្តិទាំងនោះ បានប្រតិបត្តិ តាម ត្រឹមត្រូវ ឬ ទេ គឺត្រូវពិនិត្យ គ្រប់បន្ទប់ ក្នុងផ្ទះ ដែលធ្វើជំនួញ នោះ បាន តាមត្រូវការ ។

មួយទៀត ពាក្យនោះ ត្រូវចុះ ឲ្យដឹង ថា សាមីខ្លួន ចូលចិត្តរបរទិញចូល លក់ចេញ ជាដុំកល់ទុកទៅ ឬ មួយ រើសមុខ, មិន មានទិញនិង លក់ គ្រឿងមាស ប្រាក់ ឬ គ្រឿង ដែលធ្វើ អំពីលោហធាតុ ដែលមាន តម្លៃ ទេ ។ លុះរាជការ បានឆ្លើយតប នឹងពាក្យប្តឹងសុំ របស់ខ្លួន

ហើយ សាមីខ្លួន ត្រូវបង់ ប៉ាតង់ តាមបញ្ញត្តិ របស់ច្បាប់ ។ ត មក រដ
ការ ទឹងចេញ ប៉ុល្លិតាំងមួយ សន្លឹក ឲ្យ សាមីខ្លួន ទុក បង្ហាញ រដការ
នៅវេលាណា ដែលរដការ មក ឆែកឆេរ ហើយ នៅវេលា ដែលមក
ត្រួតម្តង ៗ , អ្នករដការ ត្រូវបញ្ជាក់ ថា បានពិនិត្យ គ្រប់បន្ទប់ផង ។

ប្រការ៤- ឃុំង, កន្លែង ដំកល់ របស់ ដែលបានប្តឹង រដការ
តាមសេចក្តីបញ្ញត្តិ ត្រង់ប្រការ ៣ ត្រូវតាំង ទូ រៀប ទំនិញ របស់អ្នក
លក់ចេញទំនិញចូល នោះ ត្រូវនៅ ក្រោមសេចក្តីត្រួតត្រា អ្នកឡើរស៊ី-
ដង់ត៍ មែរក្រុងភ្នំពេញ, រេស៊ីដង់ត៍ ចំរូមខេត្រ ចៅហ្វាយខេត្រ និងចៅ
ហ្វាយស្រុក នៅគ្រប់ដំបន់ ដែលមាន តាំងឃុំង, កន្លែង ដំកល់ របស់
និង ទូ រៀប ទំនិញ នោះ ។

មន្ត្រីទាំងនោះ នឹងមាន អំណាច ឲ្យយក បញ្ជី ដូចមាន សំដែង
ត្រង់ប្រការ៦ ខាងក្រោយនេះ មកជូន ខ្លួន ពិនិត្យមើល នៅវេលាណា
ក៏បាន ។ បើកាលណា បញ្ជី ទាំងនោះ រដការត្រូវ ជូស ធ្វើជារបស់
គាំង, រដការ ត្រូវចេញ បង្កាន់ដៃ ឲ្យ ជា សំគាល់ ថា បានជូសទុក
ជារបស់គាំង , ហើយ អ្នក លក់ចេញ ទំនិញចូល ត្រូវធ្វើ បញ្ជី មួយ
ក្បាល ទៀត ជាបណ្ដោះអាសន្ន ។ បញ្ជី បណ្ដោះអាសន្ន នេះ ត្រូវ
មានចុះ លេខ និង ហត្ថលេខា សង្ខេប មួយពេច ហើយ ត្រូវទុក

00222457

D99/3/3



ប្រើ ឈរ ទំព័រ ពដការ បន្ទុល បញ្ជីចាស់ មកឲ្យ វិញ ។

ប្រការ ៥– បើកាលណា ត្រូវ ផ្លាស់ លំនៅ, អ្នក លក់ចេញ ទិញចូល ត្រូវធ្វើ ពាក្យ មួយច្បាប់ ចុះ សេចក្ដី តាមលក្ខណៈ ដូចមាន បញ្ញត្តិ ត្រង់ប្រការ ៣ នៃព្រះរាជប្រកាស នេះ ប្ដឹងទៅ អាជ្ញាធរ ដែល មាន គុណភាព ត្រូវទទួល បណ្ដឹង មុននោះ គឺ អាជ្ញាធរ ខាងកន្លែង ដែលខ្លួន ចេញទៅ និង អាជ្ញាធរ ខាងកន្លែង ដែលខ្លួន តាំង លំនៅ ថ្មី ។

ប្រការ៦– អ្នក លក់ចេញ ទិញចូល ត្រូវកាន់ បញ្ជី ដែលអ្នក ស៊ើបដង់ត៍ ម៉ែរី ក្រុងភ្នំពេញ, ឬ ស៊ើបដង់ត៍ ទីរួមខេត្ត ចុះ លេខ និងហត្ថលេខា សង្ខេប នោះ ឲ្យរៀបរយ រាល់ថ្ងៃ កុំឲ្យមាន រំលង ទំព័រ ឲ្យសល់ ទទេ ឥតសរសេរ, កុំឲ្យមាន ឆ្នូតលុប ឬ កុំឲ្យមានជ្រៀត ហើយ បញ្ជី នោះ ត្រូវមានចុះ សេចក្ដី ដូចមាន ខាងក្រោម នេះ:

១.– លេខរៀង ;

២.– ថ្ងៃ – ខែ – ឆ្នាំ ;

៣.– ប្រភេទនៃប្រតិបត្តិការ ( ទិញ ឬ លក់ ) ,

៤.– នាមត្រកូល, នាមខ្លួន និង នាមក្រៅ របស់ភ្ញៀវ (អ្នកលក់ ឬ អ្នកទិញ) និង លេខ, ថ្ងៃ – ខែ អត្តសញ្ញាណប័ណ្ណ ផង បើមាន ;

៥.– បេរគេស៊ី ឬ គុណភាព ;

៦.– លំនៅ ;

00222458



៧.- ឈ្មោះរបស់ដែលទិញ ឬ ដែលលក់ ប្រភេទនិងគុណភាព ;

៨.-- ថ្លៃទិញ ឬ ថ្លៃលក់របស់នោះ ,

៩.- ក្នុងករណីដែលភ្ញៀវ (អ្នកលក់ ឬ អ្នកទិញ) គ្មានអត្តសញ្ញាណប័ណ្ណទេ អ្នកលក់បេញទិញចូល ត្រូវកត់ នាម, ត្រកូល, លេខអត្តសញ្ញាណប័ណ្ណ ឬ កាតរបស់សាក្សី ដែលជូនភ្ញៀវនោះមក ឲ្យសាក្សីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយឲ្យចុះហត្ថលេខាផង ។

១០.-នៅក្នុងបញ្ជីទិញ, អ្នកលក់បេញទិញចូល ត្រូវចុះលេខរៀង, ថ្ងៃ-ខែ ដែលលក់របស់ ដូចដែលបានចុះក្នុងបញ្ជីនោះ (សេចក្តីនេះត្រូវចុះក្នុងវេលា ដែលលក់របស់នោះទៅវិញ) ។

- នៅក្នុងបញ្ជីលក់ អ្នកលក់បេញទិញចូល ត្រូវចុះលេខរៀង, ថ្ងៃ-ខែ ដែលទិញរបស់ ដូចបានចុះក្នុងបញ្ជីទិញ ;

១១.- សេចក្តីផ្សេងៗ ;

របស់ដែលទិញ ពីការលក់ឡាយឡុង មក, អ្នកលក់បេញទិញចូល ត្រូវចុះក្នុងបញ្ជីទិញ; អំពើដែលបានល្មើស នឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្តន្ទាជាទោសលហុ ។

ប្រការ៧- ហាមជាពិសេស ដល់បុគ្គលដូចមានសំដែងក្នុងប្រការមួយនោះ មិនឲ្យទិញសង្ហារឹម, គ្រឿងសំលៀកបំពាក់, សំពត់, គ្រឿងមាសប្រាក់, សៀវភៅមើល, លោហធាតុ, ចានក្បាន, បរិយាយ

តែមួយនាក់ គឺចលនវត្ថុ ណាមួយ ដែលជារបស់ ឬ ដែលនៅ ក្នុង
កណ្តាប់ដៃ អនីតិជន ដែលឥតអនុញ្ញាត យល់ព្រម ជាជាក់ស្តែង ដោយ
សំបុត្រ ពីជន ដែលក្មេង នោះ នៅ ក្នុងអាណាព្យាបាល តាមបញ្ញត្តិ
ច្បាប់ ៗ មួយវិញ ទៀត, មិនឲ្យទិញ ពីជន ឯណា ដែលខ្លួន មិនស្គាល់
ឈ្មោះនិងទីលំនៅ, លើកតែ បើកាលណា មាន សាក្សី ២ នាក់ ដែលខ្លួន
ស្គាល់ មកបញ្ជាក់ អំពីសារតាជាតិ ជននោះ ហើយ ចុះហត្ថលេខា ក្នុង
បញ្ជី នោះ ផង ទើបទិញ បាន ។

អំពើ ដែលបានល្មើស នឹងបទបញ្ញត្តិ ខាងលើនេះ ត្រូវធ្វើទណ្ឌកម្ម
ជាបទមជ្ឈិម ថ្នាក់លេខមួយ ។

ប្រការ៨– អ្នក លក់ចេញ ទិញចូល ដែលគ្មានតាំងផ្ទះ ក៏ត្រូវ
ប្រតិបត្តិ តាមសេចក្តីបញ្ញត្តិ នេះ ដូចគ្នាដែរ ហើយ ត្រូវធ្វើទណ្ឌកម្ម ដូច
គ្នា បើកាលណា ប្រព្រឹត្តល្មើស លើសេចក្តីបញ្ញត្តិ ដូចមាន សម្តែងមក
ខាងលើ នេះ ។ អ្នក លក់ចេញ ទិញចូល នោះ ត្រូវពាក់ មេដាយ
ឲ្យគេឃើញច្បាស់ ហើយត្រូវ បង្ហាញ មេដាយ នោះ នៅវេលា ដែល
រាជការ ត្រូវតែឆែកមើល ។ នៅ លើមេដាយ នោះ មានចុះ នាម ត្រ
កូល និងលេខបញ្ជី ផង ។

មេដាយ នោះ ជាដែកស្ពាន់ មួយ មូល ទ្រវែង, ទំហំ ដប់ សង់ទីម៉ែត្រ
បណ្តោយ, ប្រាំមួយសង់ទីម៉ែត្រ ទទឹង ។ មេដាយ នោះ ត្រូវ សាក់ខ្លួន

00222460

D99/3/3



គេដោយសោហ៊ុយរបស់ខ្លួន ៗ មេដាយនោះត្រូវរាជការកយក្រា ឲ្យសិន មុននឹងចេញប៉ាតង់ឲ្យ ហើយត្រូវឲ្យរក្សា មេដាយនោះ ឲ្យស្អាត ឲ្យមើលច្បាស់ជានិច្ច ៗ

មួយទៀត អ្នកលក់ចេញទិញចូល ដោយគ្រាប់ផ្កាត់ នោះត្រូវប្រតិបត្តិ តាមសេចក្តីបញ្ញត្តិ គ្រប់ជំពូក ក្នុងប្រកាស ឃរ៉ែតេ រាជការក្រុមមឿង នឹងសេចក្តីសំរេច របស់រាជការ រ៉េស៊ីដង់ ដែលស្តីពីរបៀបថែទាំផ្ការ ៗ

ប្តឹកណាក៏ ប្រព្រឹត្តល្មើស នឹងសេចក្តីបញ្ញត្តិ ក្នុងប្រការនេះ នឹងត្រូវធ្វើទណ្ឌកម្ម ដែលមានសំដែង ត្រង់ប្រការ ៧ និង ៨ នេះ ៗ

ប្រការ៩– អ្នកលក់ចេញទិញចូល ដែលបានធ្វើរបរនេះពីមុនមក រហូតដល់សព្វថ្ងៃនេះ ត្រូវប្រតិបត្តិ តាមសេចក្តី ដែលមានបញ្ញត្តិ ក្នុងព្រះរាជប្រកាសនេះ ក្នុងកំណត់ ៦ ខែ គិត តាំងពីថ្ងៃ ដែលចេញព្រះរាជប្រកាសនេះតទៅ គឺត្រូវធ្វើពាក្យប្តឹង ទៅរាជការ មុខក្រសួង ព្រមទាំងលិខិត ដូចមាន បញ្ញត្តិត្រង់ប្រការ ៣ នោះផង ៗ

ឯអ្នកលក់ចេញទិញចូលណា ដែលនឹងធ្វើជំនួញនេះ តាំងពីថ្ងៃចេញព្រះរាជប្រកាសនេះតទៅ, ត្រូវប្រតិបត្តិ តាមបទបញ្ញត្តិនេះភ្លាម ឥតគ្មានទុកពេលឲ្យទៀតទេ ៗ

# ច្បាប់ភុងទីន

ព្រះរាជក្រមលេខ ៥៦៥ – ន ស. ចុះថ្ងៃ ២៧-៥-៥៤

មាត្រា មួយ – ព្រះរាជក្រមនេះ មាន គោលបំណង នឹងបន្ថែម សេចក្តីដែលគ្មាន ក្នុងអនុសញ្ញា នៃភាគី ទុកសម្រាប់ ជំរះនូវ វិវាទកម្ម ដែលអាច នឹងកើតឡើង បាន នៅវេលា ដែលភុងទីន កំពុងនៅរស់ ឬ ដែលត្រូវជំរះ ភុងទីន ឲ្យជ្រះស្រឡះ ។ ភាគី មាន សេរីភាព នឹងធ្វើ អនុសញ្ញា ណាមួយ ផ្សេង ពីបទបញ្ញត្តិ នៃព្រះរាជក្រម នេះក៏បាន ។

មាត្រា ២ – មាត្រា ១៥, ១៦, ២២, ២៧, និង ២៨ នៃព្រះរាជក្រម នេះ អធិប្បាយ ពីបទល្មើស ជាអាជ្ញា ដែលគួរ ឲ្យផ្តន្ទាទោស បណ្តាល មក ពីភុងទីន នេះ ។

មាត្រា ៣ – ភុងទីន ជាកិច្ចសន្យា មួយ ដែលចង មេភុងទីន នឹង សមាជិក ភុងទីន ពី ២ រូប ឡើងទៅ មេភុងទីន និង កូនភុងទីនម្នាក់ ៗ ត្រូវមាន ហ៊ុន ឬ ចំណែក យ៉ាងតិច មួយ ហ៊ុន ម្នាក់ ។

ហ៊ុន និមួយ ៗ ត្រូវមាន តម្លៃ ស្មើគ្នា ជាដាច់ខាត ។ កូនភុងទីន ម្នាក់ ៗ ព្រមទាំង មេភុងទីន អាច មាន ហ៊ុន ច្រើន បាន ។

មាត្រា ៤ – តម្លៃ ហ៊ុន មួយ គុណ នឹងចំនួន ហ៊ុនទាំងអស់ បាន ជាទុន នៃភុងទីន ។ ហ៊ុន និមួយ ៗ ដកយក ទុន បាន តែម្តង ទេ ។

00222462





ហេតុនេះ ឬ ការដេញ តុងទីន ត្រូវដេញ ច្រើនដង ស្មើនឹងចំនួន ហ៊ុន ។

មាត្រា ៥– កិច្ចសន្យា នៃតុងទីន មាន កំណត់យ៉ាងនេះ :

១– ឈ្មោះ មេតុងទីន

២– ឈ្មោះ កូនតុងទីន

៣– ចំនួន ហ៊ុន

៤– ថ្លៃ ហ៊ុន និមួយៗ ព្រមទាំង ថ្លៃ ទុន នៃតុងទីន

៥– ចំនួន ដេញ ត្រូវឲ្យស្មើ នឹងចំនួន ហ៊ុន

៦– កាលបរិច្ឆេទ ត្រូវដេញ , ទីកន្លែង ត្រូវធ្វើ ព្រមទាំង បែបបទ ទាំងឡាយ ។

មាត្រា ៦– ទំរង់ និងសេចក្តី នៃកិច្ចសន្យា ត្រូវទុក ជាភស្តុតាង តាមច្បាប់ សាធារណៈ ។

មាត្រា ៧– អ្នកមាន ហ៊ុន មួយៗ ដែល ដេញ តុងទីន បាន ម្តងហៅថា « អ្នកដេញបាន » ។

ទិចក្ខការ នៃតុងទីន

មាត្រា ៨– នៅវេលា ដេញ ម្តង ៗ កូនតុងទីន ត្រូវមាន ប្រាក់ ស្មើ នឹងចំនួន ហ៊ុន ដែល ខ្លួន លេង ទុកប្រគល់ឲ្យ មេតុងទីន ។ បេស-ជកម្ម នៃមេតុងទីន ត្រូវប្រមូល ទុន , ចាត់ចែង ឲ្យដេញ និងប្រគល់

00222463



ប្រាក់ឲ្យទៅ អ្នកដេញបាន ។

មាត្រា ៩– មេតុងទីន មានសិទ្ធិត្រូវដក ទុន នៅឱកាស ដេញ លើកដំបូង ហើយត្រូវបាន ទុនទាំងមូល , កាលបើមាន ហ៊ុន ច្រើន មេតុងទីន នឹងទៅ ជាអ្នកដេញបាន គ្រប់ៗ ពេល តាមដែលខ្លួន នៅមាន ហ៊ុន មិនទាន់ ដេញ បាន នៅ ឡើយ ។

មាត្រា ១០– ពេល ដេញ ជាបន្ទាប់ មកទៀត អ្នក ដែលមាន ហ៊ុន ហើយ មិនទាន់ ដេញ បាន នៅឡើយ ត្រូវបូលដេញ ; អ្នក ដែល មាន ហ៊ុន មួយ ឬ ហ៊ុន ច្រើន ហើយ ដេញ បាន អស់ហើយ មិនត្រូវ បូល ដេញ ទៀត ឡើយ ។

មាត្រា ១១– អំពីការបូលដេញ, អ្នក ដែលមាន ហ៊ុន ហើយ មិនទាន់ ដេញ បាន នៅឡើយ ត្រូវសុំ ឲ្យ ការ ដល់កូនតុងទីន ឯទៀតៗ

អ្នកដេញ នោះ សុំយកទុន ដោយកាត់ ការ ចេញ តែប៉ុណ្ណោះ តាមទន្ទាប់ ៗ នរណា ដែលដាក់ ការ ច្រើនជាង គេ អ្នកនោះ ទុក ជា អ្នក ដេញបាន ។ បើគ្មាន សន្យា គ្នា អ្វីផ្សេង ទៅទៀត ទេ កូនតុងទីន ម្នាក់ៗ ត្រូវប្រគល់ ក្រដាស បិទស្រោមឲ្យជិត មួយ ចុះ ទឹកប្រាក់ ការ ដែលខ្លួន ព្រមឲ្យ នោះ ទៅ មេតុងទីន ។ មេតុងទីនត្រូវ «បើកស្រោម» នៅ ចំពោះមុខ កូនតុងទីន ទាំងអស់ ។

មាត្រា ១២– កាលបើ នៅសល់ ហ៊ុន តែ មួយ មិនទាន់ដេញ

បាន នោះ, អ្នក នេះ មានសិទ្ធិ បាន ទុន ទាំងមូល មិនចាំបាច់ សុំ ឲ្យ ការ ទៀត; តុងទីន ក៏ត្រូវផុត ត្រឹមនេះដែរ ។

ភារកិច្ច របស់មេតុងទីន

មាត្រា ១៣– មេតុងទីន ដែលជាអ្នកកណ្តាល រវាង កូនតុងទីន ទាំងអស់ ត្រូវទទួលខុសត្រូវ ក្នុងការប្រព្រឹត្តទៅ នៃតុងទីន ។ ដូច្នេះ មេតុងទីន ត្រូវតែបង់ ចេញជួស កូនដែលក្ស័យ មិនព្រម ចេញ ប្រាក់ តាមចំណែកខ្លួន ដោយហេតុ ណាមួយ ក៏ដោយ ។

មាត្រា ១៤– ជួនកាលខ្លះ កូនតុងទីន ឈប់សង ប្រាក់ ច្រើនគ្នា នាំ ឲ្យមេតុងទីន រំលាយ តុងទីន មុន អាយុ តុងទីន ។

ក្នុងរឿង បែបនេះ សិទ្ធិ របស់មេ និង កូនតុងទីន ត្រូវសំរេច ដូច មានចែង ក្នុងមាត្រា ២៣ និង តទៅ នៃព្រះរាជក្រមនេះ ។

មាត្រា ១៥– ត្រូវទុក ជាបាន ល្មើស ទំនឹងបញ្ញត្តិ នៃមាត្រា ៥១៥ វគ្គទី២ នៃក្រមព្រហ្មទណ្ឌ (នៃបំបាត់ លើទំនុកចិត្ត), មេតុងទីន ណា បំបាត់យក ជាប្រយោជន៍ ខ្លួន ឬ ប្រយោជន៍ អ្នកដទៃ នូវប្រាក់ ដែល ប្រមូល បាន នៅពេល ដេញ ណាមួយ ហើយមិនប្រគល់ ឲ្យទៅ អ្នក ដែលដេញបាន ។ អ្នកដទៃ ដែលទទួលយក ប្រាក់ នោះ ដោយទុច្ចរិត ត្រូវទុក ជាបានល្មើស ទំនឹងបញ្ញត្តិ មាត្រា ៥៣៦ នៃក្រមព្រហ្មទណ្ឌ ។

មាត្រា ១៦– ត្រូវទុក ជាបានល្មើស ទំនឹងបញ្ញត្តិ នៃមាត្រា ៥១៨

00222465





វគ្គទី ៣ នៃក្រមព្រហ្មទណ្ឌ (ឆបោក) មេតុងទីន ណា ធ្វើ ឲ្យកូនតុងទីន ជឿជាក់ ថា,ជាតុងទីន មួយ ត្រឹមត្រូវ,ឬតុងទីន ដែលសមាជិក ភាគច្រើន គ្មានរូបសោះ ឬ មិនបានចូល ក្នុងតុងទីន នោះសោះ ៗ ក្នុងរឿង បែបនេះ អ្នកធ្វើបាន ជាដំបូងទាំងឡាយ គឺជាមនុស្សទុច្ចរិត សមគំនិត នឹងមេតុងទីន ក្នុងការប្រើ ឧបាយកល ឲ្យគេ ជឿ ថា មាន តុងទីន ខ្មោច មួយមែន, មនុស្សនោះ ត្រូវមាន ទោស , កាលបើ គំនិតទុច្ចរិត មាន ភស្តុតាង ច្បាស់ ថាមនុស្សនោះ សមគំនិត ក្នុងបទឆបោក ដោយប្រើ ឧបាយកល ដែលមាន មេតុងទីន ជាដារី ៗ

ភារកិច្ច របស់កូនតុងទីន

មាត្រា ១៧– កូនតុងទីន ត្រូវតាមមើល ការវិវត្ត របស់តុងទីន, ជាពិសេស ត្រូវមើល របៀបដេញ, ដាក់ ការ ជាដើម ៗ កូនតុងទីន មិន ដាក់ការ នៅពេល ដេញ ណាមួយ ត្រូវទុក ជាបោះបង់ចោល សិទ្ធិ របស់ខ្លួន ជាអ្នកដេញ នៅពេល ដេញ នោះ ៗ សេចក្តីនេះ មិនត្រូវ ឲ្យ មានព្យសនកម្ម ដល់ការដេញ ក្រោយបង្អស់ ដូចមានលក្ខខណ្ឌ ដែល មានបញ្ញត្តិ ក្នុងមាត្រា ១៦ ដែលស្តីថា ត្រូវបាន ប្រាក់ទុន ទាំងមូល ឥតចាំបាច់ ខាត ការ បន្តិច នោះឡើយ ៗ

មាត្រា ១៨– កូនតុងទីន ដែលមិនយក ប្រាក់ ហ៊ុន តាមចំនួន ដែលខ្លួន លេង ទៅប្រគល់ ឲ្យមេតុងទីន នៅពេល ដេញ ម្តង ៗ ទេ

ត្រូវទុក ជាកៀសខ្លួន ។

មាត្រា ១៩– បើអ្នក កៀសខ្លួន មិនទាន់ដេញ បាន ទេ អ្នក នោះត្រូវបាត់ អំណាច ជាសមាជិក ក្នុងតុងទីន ព្រមទាំងគ្មាន សិទ្ធិ នឹង តាមទារប្រាក់ ដែលខ្លួន បានបង់ រួចមកហើយ នោះ ផង ។

អ្នកជំនួស អ្នកកៀសខ្លួន, តាមគោលការណ៍, មេតុងទីន ឬ កូនតុងទីន ណាម្នាក់ ដែលបានព្រមព្រៀង ជាមួយ នឹងមេតុងទីន ឬ អ្នកដទៃ ដែលមេតុងទីន នាំមកចូល នោះ, អ្នកនោះ ត្រូវ ទទួល ហ៊ុន ទាំងអស់ របស់អ្នកកៀសខ្លួន បានពេញ ច្បាប់ ហើយត្រូវបេញ ហ៊ុន បន្ត ពីពេល កៀសនោះ ទៅ ។ អ្នកជំនួស នោះ អាច ដេញ បាន គ្រប់ តែ ហ៊ុន របស់អ្នកកៀសខ្លួន ដែល មិនទាន់ដេញ ក្នុងពេលកៀសនោះ ។

មាត្រា ២០– កូនតុងទីន អាច លក់ ហ៊ុន របស់ខ្លួន មួយហ៊ុន ឬ ទាំងអស់ ឲ្យទៅ កូនតុងទីន ម្នាក់ទៀត ឬ ឲ្យទៅ ជនដទៃ បាន គ្រប់ពេល ទាំងអស់ តែត្រូវ ឲ្យមាន សេចក្តីព្រមព្រៀង យ៉ាងជាក់ច្បាស់ ពីមេតុងទីន ផង ។

មាត្រា ២១– អ្នកកៀសខ្លួន ដែលបានដេញ រួចហើយ, ត្រូវតែ សង ទៅ មេតុងទីន ឬ ទៅ អ្នក ដែលជំនួស ខ្លួន, នូវប្រាក់ ដែល គេ បានបេញ ជំនួសខ្លួន ឥតទាន់គិត ដោយដល់ជម្ងឺចិត្ត ដែលអាច មាន ឡើង បាន ផងឡើយ ។

មាត្រា ២២– កូនតុងទីន ណា ដេញ តុងទីន បាន ដោយឲ្យការច្រើន ហួសហេតុ ហើយក្រោយមក ឈប់បង់ ប្រាក់ ចំណែកខ្លួន ទៅ, កូនតុងទីន នោះ ត្រូវទុក ជាបាន ល្មើស នឹងមាត្រា ៥១៥ វគ្គទី៣នៃក្រមព្រហ្មទណ្ឌ (ឆបោក) ។ ទោសនេះ មិនមែន ជាឧបសគ្គ ឲ្យខាន អនុវត្ត បទបញ្ញត្តិ នៃមាត្រា ២១ ខាងលើ នេះ ទេ ។

មាត្រា ២៣– ក្នុងរឿង រំលាយ តុងទីន មុនអាយុ ដូចមាន បញ្ញត្តិ ក្នុងមាត្រា ១៤ នៃព្រះរាជក្រម នេះ, សិទ្ធិ របស់មេតុងទីន និង កូនតុងទីន ត្រូវសម្រេច ដូចមានពោល ខាងក្រោម នេះ ។

មាត្រា ២៤– សិទ្ធិ របស់មេតុងទីន ចំពោះកូនតុងទីន ដែល កៀសខ្លួនចាំងឆ្ងាយ ត្រូវសម្រេច តាមមាត្រា ១៨ , ១៩ , ២១ ហើយ និងមាត្រា ២២ នៃព្រះរាជក្រម នេះ ផង ដែរ ។

មាត្រា ២៥– អ្នកមិនកៀសខ្លួនចាំងឆ្ងាយ ដែលជាអ្នកដេញ បាន ត្រូវប្រគល់ ប្រាក់ ឲ្យមេតុងទីន តាមចំណែក របស់ខ្លួន ដែលមាន ចែង ក្នុង មាត្រា ៣ នៃព្រះរាជក្រម នេះ គុណ នឹងចំនួន ពេលដេញ ដែលមិនទាន់បានដេញ ។ ឯប្រាក់ នេះ តម្រូវ ឲ្យចេញ តាំងពីថ្ងៃ រលាយ តុងទីន មក ។

មាត្រា ២៦–មេតុងទីន ត្រូវសង ទៅ កូនតុងទីន ដែលមិនកៀស ខ្លួន ហើយពុំមែន ជាអ្នកដេញបាន នូវប្រាក់ តាមចំណែក ដែលអ្នកនោះ

បានបង់ ទាំងប៉ុន្មាន ឲ្យគ្រប់ ចំនួន ទៀតផងតែ មេតុងទីន បានទទួល ពីកូន តុងទីន ដែលជាអ្នកដេញបាន ដូចមានពោល ក្នុងមាត្រា មុន នេះ ។

មាត្រា២៧ – ត្រូវទុក ជាបានលើស នឹងបញ្ញត្តិ មាត្រា ៤១៥. វគ្គ ទី២ នៃក្រមព្រហ្មទណ្ឌ (គៃបំបាត់ លើទំនុកចិត្ត) មេតុងទីនណា គៃបំបាត់ ជាប្រយោជន៍ខ្លួន ឬ ប្រយោជន៍អ្នកដទៃ នូវប្រាក់ ដែលកូនតុងទីន អ្នក ដេញបាន ពីលើកមុន បានប្រគល់ មកឲ្យ ខ្លួន តាមមាត្រា ២៥ នៃព្រះរាជ ក្រមនេះ , មិនប្រគល់ ទៅឲ្យ កូនតុងទីន ដែលមិនទាន់ដេញបាន តាម ចំនួន ប្រាក់ ដែលអ្នក ទាំងនោះ បានបង់ ចំណែក រៀងៗ ខ្លួន ។

មាត្រា ២៨ – ត្រូវទុក ជាបានឆបោក ដោយប្រើ ឧបាយកល ទុច្ចរិត ដែលមានបញ្ញត្តិ ក្នុងមាត្រា ៤១៩ នៃក្រមព្រហ្មទណ្ឌ, មេតុងទីន ណា កុហក កូនតុងទីនណាម្នាក់ ដែលជាអ្នកដេញបាន ក្នុងតុងទីន ឯណា មួយ ដោយថ្លែង ថា តុងទីន នោះ រលាយបាត់ មុនអាយុ ទៅហើយ ដើម្បី ឲ្យ កូនតុងទីន នោះ ប្រគល់ ប្រាក់ មកឲ្យខ្លួន តាមមាត្រា ២៥ ។

មាត្រា ២៩ – មេតុងទីន ដែលរំលាយ តុងទីន មុនអាយុ ហើយ គ្មានប្រាក់ សង ដល់កូនតុងទីន តាមសុំ ដោយខ្លួនឯង ឬ ក៏ កូនតុងទីន សុំឲ្យ បិទទ្វារឡាយឡុង ប្រសិនបើ ខ្លួន ជាអ្នកជំនួញ ។

មាត្រា ៣០ – កូនតុងទីន ជាអ្នកជំនួញ ហើយឈប់បង់ តុងទីនណា មួយ ដែលបង្កើតឡើង ជាត្រឹមត្រូវ តាមច្បាប់ ក៏ត្រូវបិទទ្វារ ឡាយឡុង ដែរ

ព្រះរាជក្រម លេខ ២២៣ បរ ចុះថ្ងៃ ១៤-១-៦៥ បានបន្ថែមថា

មាត្រា មួយ.– បទបញ្ញត្តិ នៃព្រះរាជក្រ លេខ ៨៦៥-នស ចុះថ្ងៃទី ២៧ ឧសភា ១៩៥៤ ត្រូវបំពេញដូចតទៅ :

មាត្រា ២.– កិច្ចសន្យាតុងទីន ដែលមានចែង ក្នុងមាត្រា ៩ និង ៦ នៃព្រះរាជក្រម លេខ ៨៦៥-នស ចុះថ្ងៃទី ២៧ ឧសភា ត្រូវធ្វើជា លិខិត លាយលក្ខណ៍អក្សរ មានចុះហត្ថលេខា តួសញ្ញា មានបិទ តែម និង ប្រថាប់ត្រា លើបន្ទុក ប្រធានតុងទីន ។ ទំរង់ការ នេះ បើពុំបាន បំពេញ ទេ កិច្ចសន្យា ត្រូវទុក ជាមោឃៈ ជាដាច់ខាត ។ ការមិនប្រតិបត្តិ តាមទំរង់ការ នេះ ប្រធាន ត្រូវមាន ទោស ជាមជ្ឈិម ថ្នាក់ទីពីរ ដោយមិន គិត ដល់ទោស ក្នុងក្រមតែម និង ប្រថាប់ត្រា ដែលអាច ឲ្យមាន បាន ទៀត ផង ។

មាត្រា ៣.– ក្រៅអំពីបទល្មើស ឆបោក និង នៃបំបាត់ ដែល មានចែង ក្នុងមាត្រា ១៤-១៦-២២.២៧ និង ២៨ នៃព្រះរាជក្រម លេខ ៨៦៥.នស ចុះថ្ងៃទី ២៧ ឧសភា ១៩៥៤ :

១– ត្រូវមានទោស មជ្ឈិម ថ្នាក់ទីពីរ :

ប្រធានតុងទីន ឬ អ្នកជំនួសណា ដែលប្រធាន ផ្ទេរឈ្មោះ ទៅឲ្យ ដោយហេតុអ្វី ក៏ដោយ ដែលមិនបង់ប្រាក់ ជំនួសសមាជិក ណា ដែលមិន បានបំពេញកិច្ច នេះ ឬ មិនបង់ ប្រាក់ ទៅសមាជិក ណា ដែលបានបង់

00222470





តាមចំណែក មកខ្លួន ហើយ ។

២- ត្រូវមានទោស ដូចគ្នា ។

សមាជិក ឬ អ្នកជំនួស ណា ដែលសមាជិក នោះ ផ្ទេរឈ្មោះ ទៅឲ្យ ដែលមិនបង់ ប្រាក់ ចំណែកខ្លួន ឬ មិនសងទៅ ប្រធាន វិញ នូវប្រាក់ ដែលខ្លួន ត្រូវនៅជំពាក់ ប្រធាន ។

មាត្រា ៤ .- ការសុំអនុញ្ញាត ចោទប្រកាន់ លើអ្នកក្តី ដែលមានបុព្វសិទ្ធិ មិនជាការចាំបាច់ ទេ វៀរលែងតែមាន បទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ ដែលផ្ទុយ នឹងច្បាប់ នេះ ។

មាត្រា ៥ .- ដោយបញ្ញត្តិផ្ទុយ នឹង មាត្រា ២០៦ ក្រមពិការក្ស-ព្រហ្មទណ្ឌ ហើយទោះក្នុងស្ថានការណា ក៏ដោយ ក្នុងបទគុនីទននេះ , ការដាក់ឃុំឃាំង មនុស្សត្រូវចោទ ជាការចាំបាច់ ហើយការដោះ ឲ្យនៅក្រៅឃុំ ត្រូវទុកជាសិទ្ធិ របស់មនុស្សត្រូវចោទ បើកាលណា មនុស្សត្រូវចោទ បានដាក់ ប្រាក់ធានា គ្រប់ចំនួន តាមទឹកប្រាក់ ដែលជំពាក់ នៅ មន្ទីរក្រឡាបញ្ជី នៃសាលាសមត្ថកិច្ច ជំនុំជំរះ ហើយ ។

មាត្រា ៦ .- បទបញ្ញត្តិ ទាំងឡាយ ក្នុងព្រះរាជក្រម លេខ ៨៦៩ នស ចុះថ្ងៃទី ២៧ ឧសភា ១៩៥៤ ដែលផ្ទុយ ឬ មិន ចុះសម្រុង នឹងបទបញ្ញត្តិ នៃច្បាប់ នេះ ត្រូវនិរាករណ៍ ។

00222471



# ច្បាប់ស្ដីពីហាមឃាត់អាភៀន

ព្រះរាជក្រមលេខ ១០-នស ចុះថ្ងៃ ៣០ ឧសភា ១៩៥៨

មាត្រា មួយ - ដំណាំអាភៀន ជាដើមឈើមានជាតិស្រវឹង ដែលឈ្មោះគេហៅថា : ( Papaver somniférum, papaver album, papaver glabrum, papaver sétigérum, papaver somniférum nigrum ) ត្រូវហាមឃាត់មិនឲ្យដាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា បើទុកណាជា មានបំណងអ្វីផ្សេង ឬ ដោយកិច្ចកល យ៉ាងណាក៏ដោយ ។

មាត្រា ២ - ការដឹកនាំចូល, ការដឹកនាំចេញ ពីកន្លែងមួយ ទៅកន្លែងមួយទៀត, ការទុកក្នុងកន្លែងសំរាប់ជំនួញ នូវអាភៀនសាច់ ព្រមទាំងការលួចនាំចេញពីស្រុក នូវដើមសំណាប ឬ គ្រាប់អាភៀនដែលមានជាតិស្រវឹង ត្រូវហាមឃាត់ទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ - ការដឹកនាំចូលមកក្នុងស្រុក, ការដឹកនាំចេញ, ការដំកល់ទុក, ការបង្កើតជារបរ, ការទិញ, ការលក់, ការនាំចេញក្រៅស្រុក, ការទុកក្នុងកន្លែងសំរាប់ជំនួញ , ការលួចនាំចេញក្រៅស្រុក ការប្រើប្រាស់ ព្រមទាំងការទុកបំរុងប្រើប្រាស់ ផ្ទាល់ខ្លួននូវចន្ទូ ហៅអាភៀនសំរាប់ជក់ ត្រូវហាមឃាត់ទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា បើទុកណាជា មានបែបបទយ៉ាងណា ឬ ដោយកលល្បិចយ៉ាងណាក៏ដោយ ។

00222472





មាត្រា ៤– បទល្មើសទី៍មាត្រា១–២ និង៣ នៃព្រះរាជក្រមនេះ នឹងត្រូវបញ្ញត្តិ ហើយតោងប្រកាន់ទៅតាមច្បាប់ធម្មតា ។

សេចក្តីកត់ហេតុទាំងឡាយ ដែលភ្នាក់ងារគយ និងរដ្ឋាករបានបង្កើត មក និងតាក់តែងជាបានការ មកទល់នឹងមានការបះ សេចក្តីក្លែង នាំឈាល សេចក្តីកត់ហេតុនោះ បានធ្វើទៅតាមបញ្ញត្តិច្បាប់ និងបទបញ្ជាជាធរមាន ដើម្បីឲ្យមានទំរង់ទុកពេញលក្ខណៈបែបនេះ ពុំមានផ្លាស់ប្តូរឡើយ ត្រង់សិទ្ធិរបស់ភ្នាក់ងារគយ ក្នុងការចូលទៅឆែកឆេរដល់ទីលំនៅក៏ប៉ុន្តែ រាជ-ការគយ និងរដ្ឋាករគោរពបាត់នូវអំណាច ត្រង់សម្រួលក្នុងរឿងដែលមានបទល្មើស ដូចមានសំដែងក្នុងព្រះរាជក្រមនេះ ។

មាត្រា ៥– នឹងត្រូវផ្តន្ទាទោស ជាបទមជ្ឈិមថ្នាក់ទីពីរ បទល្មើសទាំងឡាយ និងមាត្រា១-២និង៣ នៃព្រះរាជក្រមនេះ បើចូលក្នុងស្ថាន ពុំកងចាល ត្រូវយកទោសគុក មានកំណត់យ៉ាងតិចត្រឹមពាក់កណ្តាល នៃកំណត់យ៉ាងធ្ងន់បំផុត នៃទោសគុកមជ្ឈិមថ្នាក់ទី២ យកមកសំរេចជាដាច់ ហើយមិនត្រូវព្យួរទោសនោះទេ ។

មាត្រា ៦– ក្នុងករណីនេះ ជនណាប្រាកដជាបានឲ្យ, បានចែក, បាននាំនូវបទខ្លួន ហៅអាភៀនសំរាប់ជក់ឲ្យទៅជន នៅក្មេងពុំទាន់គ្រប់ការ ទោះជាភេទប្រុស ឬ ស្រីក៏ដោយ ដែលមានអាយុតិចជាង២១ ឆ្នាំ នឹងត្រូវផ្តន្ទាទោសគុកដោយឥតព្យួរយ៉ាងតិចត្រឹមមួយឆ្នាំ ហើយយ៉ាង

ច្រើនត្រឹម៥ឆ្នាំ ជាដរាប តាំងពីជននោះ ប្រព្រឹត្តបទល្មើសជាដំបូង ។ ឯទោសនេះ ត្រូវសម្រេច ដោយឥតគិតទោសពិន័យ ពី ១០.០០០ រៀល ទៅ ៥០ ០០០ រៀល ដែលយកមកផ្ដន្ទាបន្ថែម លើទោសគុក ហើយដែលទឹងព្យួរ ឬ ទឹងត្រាប្រណីពុំបាន ។

មាត្រា ៧- ត្រូវផ្ដន្ទាទោសគុកជាមធ្យម ថ្នាក់ទី៣ ទោះជនណា ដែលបើកបនអាភៀន ឯទោសនេះមិនត្រូវព្យួរ ឬ យកស្ថានត្រាប្រណីមកសំរេចឡើយ ,

ឯទោសគុកនេះ ទឹងអាចទ្វេឡើងជា២ដង ទៅលើកំណត់យ៉ាងធ្ងន់បំផុត នៃទោសគុក ជាមធ្យម ថ្នាក់ទី៣ បើកាលណា ក្នុងបណ្ដាជនដែលម្ចាស់បន ទទួលឲ្យចូលជក់នោះមានអាយុមិនទាន់គ្រប់ការ ភេទប្រុស ឬ ភេទស្រីមួយនាក់ ដែលមានអាយុតិចជាង ២១ឆ្នាំ ប្រព្រឹត្តជាមួយផង ។

ដែលទុកជាបនអាភៀន គឺអស់តាំងកន្លែងដែលម្ចាស់បន ឬ អ្នកចាំបននោះ បានទទួលជនឯណាមួយ ដែលមិនមែនជាមេបា ឬ ជាជំណាផ្ទាល់ ឬ ត្រូវជាប្ដីប្រពន្ធ ទទួលឲ្យជក់អាភៀន បទល្មើសទុកជាមានពិរុទ្ធ ទោះបើអ្នកជក់មួយនាក់ ឬ ច្រើននាក់ បានយកអាភៀនទឹងប្រដាប់សំរាប់ជក់របស់ខ្លួន ដើម្បីទឹងជក់ក៏ដោយ ។

មាត្រា ៨- ការធ្វើខ្សៀសំរាប់ជក់ត្រូវហាមឃាត់ បទល្មើសនឹងមាត្រានេះ ត្រូវផ្ដន្ទាទោសគុក ជាមធ្យមថ្នាក់ទីមួយ ។

00222474





មាត្រា ៩– អ្នកប្រើខ្សែកាកៀន ឬម្ចាស់ខ្សែកាកៀន មុនវេលាផុតកំណត់ ដែលមានបញ្ញត្តិនៅមាត្រា១២ ខាងក្រោមនេះត្រូវបំផ្លាញខ្សែរបស់ខ្លួនចោល ឬកំបាក់សំណចោលក្នុងខ្សែ ដែលភ្នាក់ងារនេយទឹង រដ្ឋការត្រូវបោះត្រា ។

ការទុកខ្សែកាកៀន ដែលខ្លួនពុំបានបាក់សំណបិទទេ នឹងត្រូវផ្តន្ទាទោសពិន័យជាមធ្យមថ្នាក់ទី២ ខ្សែកាកៀននឹងត្រូវរឹបអូស ឬបំផ្លាញចោលតាមផ្លូវច្បាប់, បើបូលក្នុងស្ថានពុំកងចាលផង នោះទោសគុកកំណត់ស្មើនឹងកំរិតយ៉ាងធ្ងន់ នៃទោសគុក ជាមធ្យម ថ្នាក់ទី២ ត្រូវយកមកសំរេបជាដកប ហើយទោសគុកនេះ មិនត្រូវព្យួរទេ ។

មាត្រា ១០– ដើម្បីរកបទល្មើស នឹងព្រះរាជក្រម បច្ចុប្បន្ននេះ លើកលែងបទល្មើសដែលមានបញ្ញត្តិ នៅមាត្រា៩ក្នុងស្ថាននេះ ការឆែកឆេរក្នុងទីលំនៅ នឹងធ្វើឡើងបានទ ៗ តែក្នុងពេលថ្ងៃ នោះក្រុមប៉ូលិសអាចទទួលនូវសិទ្ធិ នឹងចូលឆែកឆេរក្នុងផ្ទះនិមួយ ៗ ក្នុងពេលថ្ងៃ ឬ យប់ វេលាស្មើម៉ានបាន ឲ្យតែការឆែកឆេរ បានធ្វើឡើង ប្រកបដោយមានយ៉ាងតិច ភ្នាក់ងារក្រុមព្រះនគរបាលតុលាការ១នាក់ បានប្រព្រឹត្តដោយគ្មានដីកាពីសុភាចារបុរស តែតាមបណ្តឹងយ៉ាងជាក់ស្តែង ដែលមានអ្នកស្រុកយ៉ាងតិច២នាក់ ចុះហត្ថលេខាលើបណ្តឹងនោះផង ។

00222475



មាត្រា ១១- គ្រប់តែបទល្មើសនឹងព្រះរាជក្រមបច្ចុប្បន្ននេះ នោះការកៀនដែលចាប់បានត្រូវរឹបអូស ឬ បំផ្លាញតាមច្បាប់ គ្រឿងសម្ភារៈដែលបានប្រើដឹកនាំគេនយ ក៏ត្រូវរឹបអូសបាន បើកាលណាគេឃើញថាអ្នកនាំមានបំណងទុច្ចរិត ។

មាត្រា ១២- អត្ថបទទាំងស្រុងនៃព្រះរាជក្រមនេះ នឹងចាប់អនុវត្តន៍ក្នុងកំណត់៩០ថ្ងៃគត់ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខា ។ អ្នកជាប់ការកៀនទាំងឡាយ ត្រូវចាត់ចែងយ៉ាងណា ដើម្បីនឹងលែងការកៀនទៀតទាន់មុនផុតកំណត់ ដែលមានបញ្ញត្តិខាងលើនេះ ។

---

# ច្បាប់ស្តីពីបង្ក្រាបល្បែងស៊ីសង

ព្រះរាជក្រមលេខ៨១-ន ស-ចុះថ្ងៃ២៦ តុលា ១៩៥៥

មាត្រា មួយ – ត្រូវហាមឃាត់ជាដាច់ខាត មិនឲ្យលេងនូវល្បែង បៀ និងបៀក្ដុក គ្រប់ប្រភេទ ព្រមទាំងល្បែងស៊ីសងទាំងឡាយដទៃ ទៀត ។

មាត្រា ២ – ត្រូវផ្ដន្ទាទោសដូចខាងក្រោមនេះ ដោយពុំគិតដល់ ការអនុវត្តន៍ នៃមាត្រា ៤០៦ ដល់ ៤១១ ក្រមព្រហ្មទណ្ឌ ៖

១– ជាទោសមជ្ឈិមថ្នាក់ទី៣ លើជនឯណា ដែលបើកឲ្យលេង ល្បែងស៊ីសង ដូចបានពណ៌នាខាងលើនេះ ទោះបីរៀបចំបើកឲ្យលេង មួយគ្រាៗ ក្ដី ហើយដោយពុំមានយកកំរៃស៊ីក៏ដោយ ។

២– ជាទោសមជ្ឈិមថ្នាក់ទី ២ លើជនឯណាដែលបានប្រព្រឹត្តលេង ល្បែងស៊ីសង ដូចបានរៀបរាប់ក្នុងមាត្រាមួយខាងលើនេះ ។

ក្នុងករណីណាក៏ដោយ ឧបករណ៍នៃល្បែងស៊ីសង ត្រូវតែរឹបអូស តាមផ្លូវច្បាប់ ។ បើបូលជាស្ភានពុំរាងចាល ទោសពិន័យនោះត្រូវទ្វេ ជា ២ ហើយនឹងទោសគុកទ្វេបានដូចគ្នា ។

មាត្រា ៣– ការដែលនាំចូលមក ក្នុងព្រះរាជាណាចក្រ, ការ ដាក់តាំង , ការលក់ , ការចែក , ការដើរលក់ , ការកាន់កាប់ទុក

00222477



ដាក់ នៅទីកន្លែងសាធារណៈក្តី ឯកជនក្តី នូវបៀ ឬ បៀក្លុកនោះ ត្រូវផ្តន្ទាទោសពិន័យ ជាមធ្យម ថ្នាក់ទី១ ហើយត្រូវរឹបអូសឧបករណ៍នៃល្បែងស៊ីសង ។ បើចូលជាស្ពានពុំកនតាល ត្រូវយកទោសពិន័យជាមធ្យមថ្នាក់ទី ២ មកសំរេច ។

មាត្រា ៤– អត្ថបទឯណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជាមោឃៈ ។

មាត្រា ៥–ច្បាប់នេះ ត្រូវប្រកាសឲ្យប្រើជាប្រញាប់ ។ ចប់ ។

00222478



# ច្បាប់ស្តីអំពីការបិទផ្ទះបនស្រីពេស្យា

ព្រះរាជក្រមលេខ ៦០ - ប ក · ចុះថ្ងៃ ១៦ វិច្ឆិកា ១៩៦២

មាត្រា មួយ — ក្រោយ ៦ ខែ គិតពីថ្ងៃប្រកាសឲ្យប្រើច្បាប់នេះ ត្រូវហាមមិនឲ្យ មានបនស្ត្រីពេស្យា នៅក្នុងផែនដីព្រះរាជាណាចក្រ ហើយការប្រើប្រាស់ប័ណ្ណ «កាត» ដល់ស្ត្រីពេស្យា ក៏ត្រូវមិនឲ្យមានតាំងតែពីពេលនេះទៅដែរ ។

ផ្ទះបនស្ត្រីពេស្យា ដែលមានតាំងប៉ុន្មានមកទល់ពេលនេះ ត្រូវបិទតាំងអស់ ហើយលិខិតផ្សេង ៗ ដែលសំគាល់ពីការដែលបានអនុញ្ញាតឲ្យបើកបនស្ត្រីពេស្យា ពីមុនមកនោះ ក៏ត្រូវដកហូតលែងឲ្យប្រើដែរ ដោយគ្មានចេញប្រាក់បំណាយអ្វីឡើយ ។ នៅក្នុងគ្រឹះស្ថានដដែលនេះ ក៏ត្រូវហាមដាច់ មិនឲ្យគេបើណា ដែលគេអាចសំគាល់បាន ជាបនស្ត្រីពេស្យា ។

មាត្រា ២ — ផុតពីពេលដែលបានកម្រិត ក្នុងមាត្រា១ខាងលើនេះ កិច្ចសន្យាតាំងប៉ុន្មាន ដែលបានធ្វើមក ក្នុងរបៀបតាំងផ្ទះបនស្ត្រីពេស្យានេះ ត្រូវបដិសេធចោលទាំងអស់ ដូចជាកិច្ចសន្យារវាងស្ត្រីពេស្យា និងថៅកែរបស់ខ្លួន ឬ កិច្ចការអតិថិជន, កិច្ចសន្យាពីរៀបជួលគ្រឹះស្ថាន សម្រាប់យកទៅធ្វើផ្ទះបន ទោះជាកិច្ចសន្យានេះបានធ្វើមក រវាងកូនឈ្នួលក្តី អ្នក

ផ្តល់អ្វីៗគឺ អ្នកឲ្យប្រាក់ខ្ចី ទីដីអ្នកជួលផ្ទះឲ្យគេ ឬ ទិញមុខរបរជំនួញ ធ្វើស្ត្រីពេស្យាក្តី ។

ចំពោះការបដិសេធនេះ ឥតមានបញ្ញត្តិឲ្យបញ្ចេញសោហ៊ុយ ដាច់ខាតអ្វីឡើយ ហើយគ្មានបញ្ញត្តិឲ្យសងគ្រឿងសម្ភារៈទាំងឡាយ ដែលបានទទួលពីថ្ងៃមុន ឬ កំប្រាក់ការសអ្វី ដែលគេបានប្រគល់ឲ្យពីថ្ងៃមុន ឬ កំសងប្រាក់ខ្ចីដែលគេបានឲ្យខ្ចី ។

មាត្រា ៣– ការប្រព្រឹត្តិល្មើសនឹងច្បាប់នេះ ត្រូវផ្តន្ទាទោសជាបទមជ្ឈិមថ្នាក់ទី ២ ។

មាត្រា ៤– បទបញ្ញត្តិ ទាំងឡាយណា ដែលមានពីពេលមុនមក ហើយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជាមោឃៈ ។ចប់ ។

---

00222480



# សទ្ទានុក្រម

—ក—

កថាខណ្ឌ= ចំណែក និមួយៗនៃមាត្រាមួយ paragraphe ។

កម្មវិបាក= ផលដែលអំពើណាមួយ ហុចផលឲ្យ, conséquance

កម្មសិទ្ធិ= សិទ្ធិ ដែលមានពេញទី លើចលវត្ថុ ឬ អចលវត្ថុ, propriété ។ មើលមាត្រា ៦៤៤ និងតទៅ នៃក្រមរដ្ឋប្បវេណីផង ។

កម្មសិទ្ធិករ= ម្ចាស់កម្មសិទ្ធិឬអ្នកមានកម្មសិទ្ធិ: propriétaire

ករណី= ហេតុរឿង , ហេតុ , រឿង , កាលៈទេសៈ ឬ ឱកាសពិសេស : cas ។

កាតព្វកិច្ច= កិច្ច ដែលត្រូវធ្វើ ខានមិនបាន ។ ចំណងរបស់ច្បាប់ ដែលចង ជនដែលបានចុះ កិច្ចសន្យា នឹងជនដទៃ ឲ្យបំពេញកិច្ចទាំងឡាយ ដូចមាន ក្នុងកិច្ចសន្យា ទោះជូន ជនដទៃនេះ : obligation ។ មើលមាត្រា ៧៨៤ និងតទៅនៃក្រមរដ្ឋប្បវេណី ទៀតផង ។

កាយវិកលកម្ម= ការធ្វើឲ្យពិការ, ផ្តាច់បង់ នូវអវយវៈណាមួយ ឬ ភាគណាមួយ នៃកាយ : mutilation ។

កាលៈទេសៈ= ហេតុការណ៍ ក្តីមួយ ដែលកើតមក ជាមួយនឹងអំពើ ណាមួយ : circonstance ។ កាលៈទេសៈ ធ្ងរធ្ងន់ = (circonstances aggravantes) ហេតុការណ៍ ដែលកើត ជាមួ

00222481

D99/3/3



មួយនឹង បទល្មើសណាមួយ នាំឲ្យបទល្មើសនោះ មានទោស ធ្ងន់តែធ្ងន់ថែមទៀត ។ កាលៈទេសៈ ឲ្យប្រណី circonstances atténuantes= កាលៈទេសៈ ដែលនាំឲ្យបទល្មើសនោះ មានទោស ស្រាលជាងកំណត់ទោស ដែលត្រូវផ្ដន្ទា ។

កាលិក=ដែលកើតមានមួយពេល,មួយកាល temporaire ។

កាលិកបត្រ= សារពត៌មាន ដែលចេញផ្សាយ តាមកំណត់កាល គឺចេញផ្សាយរាល់ថ្ងៃ ឬ រាល់ថ្ងៃណាមួយ បណ្ដាថ្ងៃទាំងប្រាំពីរ ក្នុងសប្ដាហ៍ ឬ ចេញរាល់ខែ ឬ រាល់ត្រីមាស périodipue ។

កុប្បកម្ម= ការបះបោរ ដែលមនុស្សច្រើននាក់ លើកគ្នា មកប្រឆាំង នឹង អំណាច អាជ្ញាធរសាធារណៈ : sèdition ។

កិត្តិយស (គ្រឿង) = អលង្ការ ដែលរដ្ឋការ បង្កើតឡើង ដើម្បីទុកឲ្យ ជនដែលបានធ្វើការ បំរើ រដ្ឋ ដោយប្រពៃ ពាក់ជាកិត្តិយស : insignes honorifiques ។

កោសលវិច័យ= ប្រតិបត្តិការ របស់អ្នកជំនាញ មានពេទ្យជាដើម ដែលចៅក្រម ឬ ភាគី ឬ ច្បាប់ ចាត់តាំង ឲ្យទៅពិនិត្យ, ពិចារ-ណា , វាយតម្លៃរបស់ ឬ កិច្ចការអ្វីមួយ ; អ្នកជំនាញ នេះ , ក្រោយដែលបានស្បថ រួច , ក៏ចុះ សេចក្ដីពិនិត្យ , ពិចារណា , វាយតម្លៃនោះ ក្នុងកំណត់ហេតុមួយ ; រួច មក កំណត់ហេតុនេះ ត្រូវយកទៅជូន

00222482





តុលាការ : expertise ។

កោលាហល = ការកករល្អក់ នៃសង្គម , ការរំជើបរំជួលក្នុងសង្គម désordre ។

កំណាត់ដៃ = សេចក្ដីស្រង់ យកតែ គោលសំខាន់ ពីសាលក្រម ឬ សាលដីកា : extrait ។ សេចក្ដីស្រង់ ពីសាលក្រម ហៅជាកំណាត់ដៃ សាលក្រម : extrait du jugement , សេចក្ដីស្រង់ ពីសាលដីកា ហៅជា កំណាត់ដៃ សាលដីកា : extrait d'arrêt ។

ក្រុមប្រឹក្សាញាតិ = សន្និបាត ដែលមាន មេឃុំ ជាប្រធាន និង មានញាតិ ឬ មិត្ត របស់មាតាបិតា នៃអនីតិជន មានខាងស្ពាប្រាំមួយនាក់ជាសមាជិក ដែលតាំងឡើង ដើម្បីជ្រើសរើស ជនណាម្នាក់ឲ្យធ្វើ ជាអ្នកអាណាព្យាបាល លើអនីតិជននោះ , ដើម្បីដកហូតអំណាច ពីជនអ្នកអាណាព្យាបាល លែងឲ្យព្យាបាល តទៅទៀត , ដើម្បីត្រួតពិនិត្យ កិច្ចការ របស់អ្នកអាណាព្យាបាល ឬ ដើម្បីអនុញ្ញាត ដល់អ្នកអាណាព្យាបាល ឲ្យធ្វើកិច្ចការអ្វីមួយ ជាប្រយោជន៍ដល់អាណាព្យាបាលិក :conseil de famille ។ មើលមាត្រា ៣៨០ និងតទៅក្នុងក្រមរដ្ឋប្បវេណីផង ។

ក្រុមប្រឹក្សា តុលាការ = ជនដែលតុលាការ តាក់តាំងឲ្យធ្វើ ជាហិតុប្បត្ថម្ភក៍ របស់ជន ដែលគ្មានសមត្ថភាព ដើម្បីឲ្យជួយធ្វើ កិច្ចការទាំងពួង របស់ជន អសមត្ថភាពនោះ នៅក្នុងតុលាការ ឬ ទីនថ្លឹង

00222483

D99/3/3



ដល់តុលាការ ជាជំនួស ជនអសមត្ថភាពនោះៗ : conseil judiciaire ។

គ្រាន = ផ្ទះសម្បែង , គ្រួសារ, មនុស្សមួយក្រុម ដែលរស់នៅ ក្នុងលំនៅ ជាមួយគ្នា : foyer ។ នាយគ្រាន = ជនអ្នកមានការៈ គ្រប់គ្រង គ្រាន ឬ គ្រប់គ្រង មនុស្ស ក្នុងគ្រាន : chef de foyer ។

–ខ–

ខាន់ស្លា = សំដៅសេចក្ដីថា ប្រុសស្រ្ដីបានយកគ្នា ជាប្ដីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ ។ បុព្វញាតិមានខាន់ស្លា = ឪពុកម្ដាយ, ជីដូន ជីតា បានយកគ្នាជាប្ដីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ : ascendants légitimes ។

–គ–

គណនេយ្យ = បញ្ជីកត់ត្រា លុយកាក់ សព្វសារពើ comptabilité ។

គុណភាព = ភាពនៃមនុស្ស ឬ ភាពនៃវត្ថុ ដែលមានលក្ខណៈ, មានបែបបទ ល្អ, អាក្រក់ ជាដើម qualité ។ គុណភាពនៃ អ្នករងគ្រោះ = អ្នកនៃគ្រោះ មានភាព ជាក្មេង, ជាចាស់ ជាបព្វជិត ជាអ្នករាជការ ឬ ជាជនសាមញ្ញ: qualité de la victime ។

គុណវុឌ្ឍិ = សេចក្ដីចំរើន ដោយគុណ, ដំណើរចំរើន ដោយ សេចក្ដីល្អ qualifié ។ ពាក្យដែលមានគុណវុឌ្ឍិ : ពាក្យដែល

00222484

D99/3/3



បំណាច់បំនួន ក្នុងមុខ ពេទ្យសាស្ត្រ, médecin qualifié ។ បុគ្គលអ្នកមានគុណវុឌ្ឍិ= បុគ្គលអ្នកមានឥស្សរិយ៍, មានសណ្ដាប់ធ្នាប់ជាអ្នកត្រឹមត្រូវ : personne qualifiée ។

គោលច្បាប់= ខ សំខាន់, ខដើម របស់ច្បាប់ : principe ។

កំហាត់ជានិត្យានុកូល= មើលសេចក្ដីពន្យល់ ក្នុងមាត្រា ៥៤, ៥៥, ៥៦ : interdiction légale ។ ពាក្យបុរាណថា : ហាមឃាត់តាមច្បាប់ ។

កំហាត់លំនៅ= មើលសេចក្ដីពន្យល់ ក្នុងមាត្រា ៥៩ រហូតដល់ ៦៤ : interdiction de séjour ។ ពាក្យបូរាណថា ហាមឃាត់មិនឲ្យទៅនៅ ក្នុងទីកន្លែងឯណាមួយ ។

-ឃ-

ឃាតកម្ម= ( ឃាត = សម្លាប់ + កម្ម = អំពើ ) អំពើសម្លាប់មនុស្ស ( មាត្រា ៥០៤ ) meurtre ។

-ច-

ចរន្ត = ដំណើរ ប្រព្រឹត្តទៅ courant ។ ឆ្នាំចរន្ត = ឆ្នាំដែលមាន ថ្ងៃ.ខែ កំពុងតែកន្លងទៅ មិនទាន់គ្រប់ដប់ពីរខែ ឬ បីរយហុកសិបប្រាំ ថ្ងៃ : Année courante ។

00222485



ចលាចល= ការសៅហ្មង ដល់សេចក្ដីរៀបរយ របស់សង្គមមនុស្ស trouble ។

ចារី= អ្នកប្រព្រឹត្ត , អ្នកធ្វើដល់ auteur ។

ចំពូក= ចំណែកមួយ នៃមាតិកា chapitre ។ ក្រមព្រហ្មទណ្ឌនេះ ចែកជាប្រាំគន្ថី ។ គន្ថីមួយ ៗ ចែកជាច្រើន មាតិកា ។ មាតិកា មួយ ៗ ចែកជាច្រើនចំពូក ។

ច្បាប់= អក្សរ ដែលរដ្ឋសភា បានអនុម័ត ហើយ ដែលព្រះមហាក្សត្រ មានព្រះបរមរាជឱង្ការ ប្រកាសឲ្យប្រើ Loi ។

## -ដ-

ដីកា= លិខិត របស់ចៅក្រម សម្រាប់កោះហៅសាក្សី , មនុស្សត្រូវចោទ ។ ឧ. ដីកាកោះ , ដីកាឲ្យចូលខ្លួន , ដីកាបង្គាប់ឲ្យចាប់ខ្លួន ។ សេចក្ដីសម្រេច របស់ចៅក្រមនៃម្នាក់ អនុញ្ញាត ឬ បង្គាប់ឲ្យធ្វើកិច្ចការអ្វីមួយ ។ « ដីកា » ត្រូវគ្នានឹងពាក្យបារាំងថា citation, mandat de justiee, ordonnance, réquisitoire ។

ដំណាប= លិខិតដែលតប ទៅនឹងលិខិត ដែលគេបានផ្ញើមកឲ្យ ។

## -ឋ-

ឋិតិភាព= ការកំណត់ ឲ្យជាក់ច្បាស់នូវមូលដ្ឋានអ្វីមួយ ដែលត្រូវបំពេញនូវកិច្ចការខ្លះ ៗ assiette ។ ឋិតិភាព នៃផ្លូវសាធារ-

00222486





ណា:= មូលដ្ឋានជាទីបិតនៅ នៃថ្នល់សាធារណៈ: assiette de la route ( មាត្រា ៣៩៨ ) បរិកាព នៃពន្ធ= មូលដ្ឋាន ដែលត្រូវកំណត់ ពីគុណភាព ពីចំនួន ពីមុខការដូចម្ដេច ដោយត្រូវជាប់ពន្ធ assiette de l'imqot ។

## -ត-

តតិយជន= ជនទីបី ឬ ជនដែលមិនមែនជាភាគី, ជនដែលមិនមានឈ្មោះ ក្នុងកិច្ចសន្យា ឬ ក្នុងសាលក្រម ។ Les tiers ou la tierce - personne ។

តតិយជន= ( ក្នុងមាត្រា ៣៤៨ ) = ជនដែលមិនមែនជាអ្នកជាប់គុកនឹងមិនមែន ជាអនុរក្ស ។

តតិយជន= ( ក្នុងមាត្រា ៦១៧ ) = ជនដែលគេដឹកយកមកបញ្ចាំ, មកលក់ ។

តតិយជន= ( ក្នុងមាត្រា ៤១៣ ) = ជនដែលបានឮ គេបរិហារកេរ្តិ៍ របស់មនុស្ស ណាម្នាក់ ។

តម្រួត= ដាក់ត្រួតលើគ្នា cumuler ។

ការតម្រួតទោស= ការបូករួម ទោស នៃបទល្មើស ច្រើនបទ បញ្ចូលគ្នា cumul des peines : ១-ទណ្ឌិត មាន ទោស គុកពីបទលួចពីឆ្នាំ, ទោសគុកពីបទឆបោកមួយឆ្នាំ ។ ទណ្ឌិតត្រូវទទួល

00222487





រង់ទោស ចាំអស់ បញ្ចាំ ។ មាត្រា ១៤ ដល់ ១៩

-ទ-

ទណ្ឌកម្ម= សេចក្ដីតុលាការវិនិច្ឆ័យ សម្រេចទោសដល់ពីរ លហុកម្ម, ទោសកម្ម ឬ ទុក្រិដ្ឋកម្ម : condamnation ។

ទណ្ឌិត= ជន ដែលតុលាការវិនិច្ឆ័យ កាត់ ទោសពិន័យ ឬ កាត់ ទោសជាប់គុក (condamné) ។

ទស្សនីយភាព= អ្វីៗ ដែលទាញភ្នែកឲ្យមើល, ល្ខោន, ភាពយន្ត ។ល។ spectacle ។

ទារកឃាត=អំពើសម្លាប់ក្មេង ដែលទើបនឹងកើត, មាត្រា ៤៥៨ infanticide ។

ទិដ្ឋាការ= ការចុះហត្ថលេខា របស់អាជ្ញាធរ ជាមុខក្រសួង លើលិខិត អ្វីមួយដើម្បីជាសញ្ញាថា បានឃើញ បានពិនិត្យ លិខិតនោះ ហើយ (visa) ។

ទោសកម្ម = តាមន័យ ទូលំទូលាយថា អំពើជាទោស ។ ពាក្យនេះជា ស្រប នឹងពាក្យថា បទល្មើស délit ។ ទោសកម្មព្រហ្មទណ្ឌ = délit pénal ។ ក្នុងន័យនេះសំដៅទៅថា បទល្មើសមជ្ឈិម ឬ មជ្ឈិមកម្ម ។ ទោសកម្ម គឺជា អំពើល្មើសមួយ ដែលមិនធ្ងន់ស្មើ នឹង ទុក្រិដ្ឋកម្ម ហើយ មិនស្រាលស្មើ នឹង លហុកម្ម ( ទោស

00222488



កម្មមជ្ឈិម = délit correctionnel)

ទ្វេពន្ធ = បុរស អ្នកមានប្រពន្ធទី២ ពីរនាក់ ឬ ស្ត្រី អ្នកមានប្ដីពីរនាក់ , មាត្រា ៤៥០ bigame ។

ទ្វេពន្ធភាព = ភាពនៃបុរសមានប្រពន្ធទី១ ពីរនាក់ ឬ ភាពនៃស្ត្រីមានប្ដីពីរនាក់ មានខាន់ស្លា មិនទាន់ដាច់ចាំងពីរ មាត្រា ៤៨០ la bigamie ។

ទ្វេភាព = ភាពពីរ, គុណទីពីរ double ។ ឧ. ប្រាំមួយ ជាទ្វេភាពរបស់បី

-ធ-

ធនទណ្ឌ = ទណ្ឌកម្មដែលធ្វើឲ្យខូចដល់ធនធាន condamnation pécuniaire

ធនបត្រ = ក្រដាសដែលធនាគារ ជាអ្នកបោះឲ្យចាយដោយសន្មតថាជាប្រាក់ billet de banque ។ ពាក្យសាមញ្ញថា : ក្រដាសប្រាក់ ។

ធម្មានុរូប = ដែលមានគុណភាព ស្របទៅតាមច្បាប់ ឬ ត្រូវនឹងសេចក្ដីតម្រូវរបស់ច្បាប់ légitime ។ កិច្ចការពារ ជាធម្មានុរូប : défence lègitime ។ អាជ្ញាធរជាធម្មានុរូប = autoritè légitime ។

នាមិក = ដែលប្រកបដោយឈ្មោះ, ដែលមានឈ្មោះ ។ សំបុត្រនាមិក = សំបុត្រ ដែលមានឈ្មោះ មានហត្ថលេខា របស់អ្នកសរសេរ ។ ផ្ទុយនឹងពាក្យថា សំបុត្រអនាមិក = សំបុត្រដែលអ្នកសរសេរមិនហ៊ានបញ្ចេញឈ្មោះខ្លួន ឱ្យគេដឹង ។

នាវាកំទព = យានជិះទឹក របស់ទ័ព flotte ។

និកម្មវេលា = ពេល, វេលា ដែលគ្មានការងារធ្វើសោះ chômage ។ និកម្មវេលាចាំបាច់ = ពេលវេលាដែល គ្មានការធ្វើដោយមានហេតុអ្វីមួយមកបង្ខំឱ្យគ្មាន chômage forcé ។

និគ្រោះ = ការបង្រ្កាប , repression réprimer ។ តុលាការនិគ្រោះ គឺតុលាការដែលមានភារៈដាក់អនុវត្តទោស tribunal repressif ។

និត្យានុកូល = ការកើតមកពីច្បាប់, ដែលច្បាប់ កាត់តែងមក légal ។ សន្ដោសទោស ជានិត្យានុកូល excuses légales ។

និទ្ទេស = កិរិយាសម្ដែង , សេចក្ដីចារិក mention

និយោជក = អ្នកប្រើ, អ្នកជួលការងាររបស់គេ employeur

និយោជិត = អ្នកបម្រើ, អ្នកស៊ីឈ្នួលគេ , អ្នកធ្វើការឱ្យ គេ ដើម្បីឈ្នួល employé ។

និរាករណ៍ = ការលប់ចោល, ការឈប់ឱ្យអនុវត្ត ។ ចុន

00222490





សេចក្ដីថា បទបញ្ញត្តិនៃច្បាប់ថ្មី លប់បទបញ្ញត្តិនៃច្បាប់ចាស់ មិនឲ្យអនុវត្ត តទៅទៀត abrogation កុំច្រឡំ និរាករណ៍ នឹងមោឃភាព nullité , មោឃៈ nul ។

នីតិបុគ្គល = ក្រុមមួយដែលច្បាប់សន្មត ថាជាបុគ្គល (personne morale) ។ នីតិបុគ្គលសាធារណៈ = ក្រុមកិច្ចការ សាធារណៈ (personne morale de droit public) នីតិបុគ្គលឯកជន = personne morale de droit privé

នីតិភាព = ភាពនៃជន អ្នកមានអាយុដល់កម្រិត ដែលច្បាប់កំណត់ទុកថា ជាមនុស្សពេញការ ជាមនុស្សត្រូវទទួលភារៈ ខុសត្រូវ ចំពោះអំពើដែលខ្លួនប្រព្រឹត្ត ។ អាយុដែលច្បាប់ កំណត់ទុកជានីតិភាព នោះគឺ ២១ ឆ្នាំ ( majorité ) ។

នីតិសម្បទា = ភាពនៃជន អ្នកមានច្បាប់ នឹងធ្វើអ្វីមួយបាន (habilité) ។

នេសាទុបករណ៍ = គ្រឿង, ប្រដាប់សម្រាប់ធ្វើ នេសាទ engins de pêche ។

## — ប —

បច្ឆាញាតិ = ពួកជន ដែលកើត ពីជនមួយពួកទៀត ។ descendant ឧ. — កូន, ចៅ, ចៅទួត ... ជាបច្ឆាញាតិ ។

ឪពុក-ម្តាយ , ជីដូន , ជីតា , ជីដូនទួត , ជីតាទួត . . . ជាបុព្វញាតិ របស់កូន , ចៅ , ចៅទួត ។

បដិមរូប= រូបជាដំណាង (emdlème ។ ឧ. ជញ្ជីងជាបដិមរូប នៃក្រសួងយុត្តិធម៌ , ។

បណ្ណាធិការ= អ្នកគ្រប់គ្រងកាលិកបត្រ ។ gérant d'un périodique ។

បទបញ្ញា= ច្បាប់បែបមួយ ដែលផ្សាយចេញ ពីអាជ្ញាធរណា មួយ ផ្សេង ពីរដ្ឋសភា règlement ។

បទបញ្ញត្តិ= សេចក្តីបញ្ញត្តិ របស់ច្បាប់ ឬ របស់មាត្រាណា មួយ នៃច្បាប់ , ១ សំខាន់ របស់លិខិតតុលាការ disposition ។

បន្ទុយសិទ្ធិស៊ីវិក = ដកសិទ្ធិខ្លះ ឬ ទាំងអស់ ពីជន ដែលមានទោសឧក្រិដ្ឋ ឬ មជ្ឈិម គឺសិទ្ធិដែលរដ្ឋធម្មនុញ្ញ បើកឱ្យ ដល់ ពលរដ្ឋម្នាក់ៗ ក្នុងប្រទេស ។ មើលមាត្រា ៤៩ dégradation civique ។ ពាក្យប្តូរណាថា : «បន្ទយអំណាចពីជនធម្មតា» ។

បរិធារភាព= បន្ទុក ដែលអចលវត្ថុមួយ ត្រូវទទួល ដើម្បី បំរើអចលនវត្ថុមួយទៀត ជារបស់កម្មសិទ្ធិករដទៃ servitude ។ មើល មាត្រា ៧៦០ និងតទៅនៃក្រមរដ្ឋប្បវេណីទៀតផង ។

បរិមាណ= ចំនួនដែលត្រូវគិត ឱ្យនឹង កំណត់ le quantum ។

00222492



បរមាធិភាព= អធិភាព , អំណាច ដែលធំស្រេចលើខ្លួន : souveraineté ។ ដោយបរមាធិភាព souverainement ។

បសន្នភាព= ភាពថ្លា , បរិសុទ្ធ , បើជាទឹក គឺទឹកដែលគេអាចបរិភោគជាអាហារបាន salubrité ។

ភាពគ្រោះ= គ្រោះអាក្រក់ , ព្រឹត្តិការណ៍អាក្រក់ ដែលនាំឲ្យមានទុក្ខព្រួយ ។ ឧ. ភ្លើងឆេះផ្ទះ , លង់ទូកជាដើម ជាភាពគ្រោះ sinistre ។

បាវចនា= រូប , គំនូរ ដែលសំដែងពីគតិគំនិតអ្វីមួយ (devise ) ។ ធនប័ត្រ ១០០ រៀល មានរូបព្រហ្មនៃប្រាសាទបាយ័ន ជាបាវចនា ។

បុព្វញាតិ= ពួកជន ដែលបង្កើត ជន មួយពួកទៀត ascendant ។ ឧ. ឪពុក , ម្ដាយ , ជីតា , ជីដូន... ជាបុព្វញាតិរបស់កូនចៅ ។

បុព្វសិទ្ធិ= សិទ្ធិជាពិសេស ដែលឲ្យជាប់ទៅលើមុខងារ ឬទៅលើក្រុមជនមួយ ។ prérogative ។ ពួកបព្វជិត ក្នុងសាសនា របស់រដ្ឋ មានបុព្វសិទ្ធិ លើសពីពលរដ្ឋសាមញ្ញ គឺថា ព្រះសង្ឃនោះ គ្មានជាប់ពាក់ព័ន្ធនឹងពន្ធដារទេ ។ រូបកាយលោកក្ដី , កេរ្តិ៍ឈ្មោះលោកក្ដី , ជនណាទៅរំលោភលើ ជននោះត្រូវបានទោសជាទម្ងន់ ។

00222493





បូជនីយដ្ឋាន= ទីដែលគួរដល់ការបូជា ដែលគួរដល់ការធ្វើកុសលផ្សេងៗ sanctuaire ។

បេតិកភណ្ឌ= ទ្រព្យ ដែលបានមក ពីឪពុក ឬ ពីម្ដាយ ។ ទ្រព្យ ដែលសម្រាប់យកទៅប្រើការអ្វីមួយ ជាពិសេស patrimoine ។

ប្រកាសទណ្ឌកម្ម= ការផ្សាយឱ្យសាធារណជន បានដឹងនូវទណ្ឌកម្មមួយ (publicité des condamnations) មើលមាត្រា ៦៨។

ប្រតិសកម្ម= គុណភាព ដែលហុចផលទៅឱ្យអំពើកន្លងអតីតកាល réactivité ។

ប្រត្យក្ស ឬ បច្ចក្ខ= ដែលមានពិតប្រាកដ, ដែលឃើញច្បាស់ដោយភ្នែក ( réel ) ។

ប្រភេទ= អ្វីៗ ដែលកើតមានឡើង តាមហេតុការណ៍របស់វា nature ។ ប្រភេទនៃហិង្សា=ហិង្សាបានកើតឡើង ដោយមានប្រើអាវុធ ឬ គ្មានប្រើអាវុធ, បណ្ដាលឱ្យមានរបួស ឬ គ្មានរបួស nature de la violence ។

ប្លម ( ក្លែងដោយ- ) ការធ្វើត្រាប់ឱ្យដូច របស់អ្វីមួយ ដើម្បីទីនក្លែងថា វត្ថុដែលធ្វើត្រាប់នេះ ជារបស់ត្រឹមត្រូវ contrefaçon ។

—ផ—

ផលបត្រ= គម្រូនៃធនបត្រ (effets) មើលមាត្រា ៣៨៨។

00222494



ព្យាបាល របស់ជនជៃ pupille ។

ព្យូហៈ (មហា–) = កងទ័ព ក្បួនទ័ព ។ សំដៅន័យថា កងទ័ព យានជំនិះទឹក ឬ យានអាកាស escadre ។

ព្រហ្មទណ្ឌ = ដំបងព្រហ្ម, អាជ្ញាព្រហ្ម, អាជ្ញាជាន់ខ្ពស់ pénal ។ សំដៅន័យថា : ធ្វើទោស, សំដែងពីអំពើដែលគួរដល់ទណ្ឌកម្ម ។ ក្រមព្រហ្មទណ្ឌ = ប្រជុំនៃច្បាប់ ដែលសំដែង ពីអំពើល្មើស គួរធ្វើទោស code pénal ។ ច្បាប់ព្រហ្មទណ្ឌ : loi pénale ។ ទោសព្រហ្មទណ្ឌ = ទោសដែលមានសំដែង ក្នុងច្បាប់ព្រហ្មទណ្ឌ peine pénale ។

—ភ—

ភាគី = អ្នកក្ដី, កូនក្ដី, ឬ គូរក្ដីម្ខាង partie ។ ភាគីស៊ីវិល = អ្នកក្ដី ដែលប្ដឹង សុំសំណងបង់ខាត សុំសោហ៊ុយជម្ងឺចិត្ត សុំឲ្យជួសជុលសេចក្ដីខូចខាត partie civile ។ ពាក្យបុរាណថា ដើមបណ្ដឹងរដ្ឋប្បវេណី ។

ភោគ = ទ្រព្យ ដែលអ្នកជាម្ចាស់ មានសិទ្ធិ មិនបរិបូណ៌ possission ។ នាកាល ជនអ្នកប្រើសិទ្ធិនេះ បានបំពេញគ្រប់លក្ខខណ្ឌ ដូចដែលមានសំដែង ក្នុងច្បាប់ហើយ សិទ្ធិភោគនេះ ក៏ប្រែក្លាយ ទៅជាកម្មសិទ្ធិវិញ ។ ពាក្យបុរាណថា : អំណាចកាន់កាប់ ។ មើល មាត្រា ៧០៨ និងតទៅក្នុងក្រមរដ្ឋប្បវេណីផង ។

00222495



មធ្យោបាយ= ឧបាយ ដែលយកទៅប្រើ ដើម្បីឲ្យបានសំរេច នូវកិច្ចការអ្វីមួយ : moyen ។

មាឌ= ទំហំ , ចំណុះ: volume ។

មាតិកា= មេសេចក្តី , ដើមសេចក្តី , ចំណែកធំ ៗ នៃ ក្រមព្រហ្មទណ្ឌ titre ។ ក្រមព្រហ្មទណ្ឌនេះ ចែកជា គន្ថ (livre) , គន្ថ ចែក ជាមាតិកា, មាតិកា ចែក ជាជំពូក (chapitre) , ជំពូកមួយ ៗ ចែក ជាផ្នែក (section) ។ ក្នុងមាតិកា , ជំពូក ឬ ផ្នែកនីមួយ ៗ មាន ច្រើនមាត្រា (article) ។ មាត្រានីមួយៗមានចែកជា កថាខណ្ឌ (paragraphe) ឬ ជាវគ្គ (alinéa) ។

មុខងារជាកិត្តិយស = បណ្ណាសក្តិ ដែលជនណាម្នាក់មាន នោះ គ្រាន់តែជាកិត្តិយស ប៉ុណ្ណោះទេ , មិនមែនជននោះមានមុខការ កាន់កាប់ដំណែងអ្វីទេ fonction honorifique ។

មុខងារ សាធារណៈ = មុខដំណែង ឬ ការងាររបស់រដ្ឋ ដែលប្រគល់ទៅ អ្នករាជការ ឲ្យកាន់កាប់បម្រើរដ្ឋ ។ ន័យមួយទៀតថា អំណាច , ភារកិច្ច របស់ភ្នាក់ងារ នៃក្រុមសាធារណៈ: fonction publique ។

មូលទោស= មើលន័យក្នុងមាត្រា ៣ នៃក្រមនេះ peine principale ។

00222496





មូលនិធិ = មើលន័យក្នុងមាត្រា ២៧១ នៃក្រមនេះ fonds

## យ

យថាហេតុ = ហេតុ ដែលពឹងផ្អែក ទៅលើព្រឹត្តិការណ៍ណាមួយ គឺថា បើព្រឹត្តិការណ៍នោះ កើតមានឡើងយ៉ាងណា ហេតុនោះ ក៏ត្រូវធ្វើយ៉ាងនោះដែរ éventuel ។

យុត្តិកម្ម = ការធ្វើឲ្យឃើញ ខុសត្រូវ , ឲ្យឃើញ យុត្តិធម៌ចំពោះអំពើណាមួយ ។ ភស្តុតាងនៃអំពើណាមួយ justification ។ យុត្តិកម្មនៃបទល្មើស = ការពិចារណា ឲ្យឃើញថា អំពើ ជនណាម្នាក់ដែលបានប្រព្រឹត្តមកនោះ , ពិតមែនតែខុសនឹងច្បាប់, ប៉ុន្តែ អំពើនោះជាអំពើសមហេតុ សមផលដែរ ឬទេ justification des infractions ។

យុត្តិនិសេធ = ការដែលចៅក្រមប្រកែកមិនព្រមជំនុំជំរះ រកយុត្តិធម៌ឲ្យគេ ព្រោះមិនមានការណែនាំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏ដោយ déni de justice ។ មើលមាត្រា ២៥២ ផងទៀត

## រ

រឹប = ការរឹបអូសគ្រឿងវត្ថុ ។ ទុកជាទ្រព្យរាជការ ឬ ទុកបំផ្លាញចោល confiscation ។ មើលន័យក្នុងមាត្រា ៦៦ ដល់ ៦៨ ។

រយៈពេល = ពេលដែលនៅជាបន្លោះ កាលពីរ គឺកាលខាងដើម និងកាលខាងចុង délai ។

00222497





រយៈវេលា= កាលជាទីប្រព្រឹត្តទៅ នៃកិច្ចការមួយ durée

-ល-

លក្ខខណ្ឌ= វគ្គ , ស្ថេរ , ការៈលេសៈ នៃកិច្ចការមួយ condition ។

លក្ខណៈ= ឫកពា , បែបបទ , (caractère) ។

លទ្ធការ= ជនអ្នកបាន ទទួលកម្មសិទ្ធិ ឬ ទទួលសិទ្ធិ ណាមួយ ពីកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិ ដែលគេបង្វេរមកឲ្យខ្លួន ដោយចេតនា ឬ តាមច្បាប់ acquéreur ។

លហុកម្ម= បទល្មើស ជាលហុ : contravention ។

លាភការ= រង្វាន់ , ផលនៃការងារ , ប្រាក់ជាសារគុណនៃកិច្ចការមួយ : rémunération ។

លេខា= ស្នាម ឬ តំនូស ដែលធ្វើដើម្បីសម្គាល់ ពីវត្ថុ , ពីបន្ទាត់ ឬ ពីរូបភាពមួយ graphique ។

លោហម័យ= ដែលធ្វើអំពីលោហៈធាតុ ដូចជាសំណ , ស្ពាន់ ដែកជាដើម ( métallique ) ។

-វ-

វ័យស្ន= មនុស្សកំលោះ adulte ។ មើលសេចក្តីពន្យល់ ក្នុងមាត្រា ១០៧ នៃក្រមនេះទៀត ។

វិកលចរិត= ចរិតប្រែប្រួល , ការខ្វះខាត ឬ ខូចខាត សតិបញ្ញា démence ។

វិចារបញ្ញា= ប្រាជ្ញាកើតមកពីការពិចារណា ឬ ប្រាជ្ញា សំរាប់ពិចារណា ឲ្យស្គាល់ខុសត្រូវ discernement ។

វិតិក្រម ឬ វ្យតិក្រម= មើលក្នុងមាត្រា ២៦៣ concussion ។ ពាក្យបកប្រែថា ឆក់ស្រូតប៉ាំងហូត ។

វិធាន= គោលច្បាប់ , ច្បាប់ règle ។

វិនិច្ឆ័យ= ជន ដែលមាន សិទ្ធិ គួរឲ្យតុលាការ ជំនុំជំរះឲ្យ Justiciable ។ មុនឆ្នាំ១៩៥៣ ជនបរទេស ដែលនៅក្នុងប្រទេសខ្មែរ ជាវិនិច្ឆ័យរបស់តុលាការបារាំង ។

វិបត្តិស្មារតី ឬ ពុទ្ធិវិបល្លាស= ការបាត់បង់ស្មារតី , ការខូចស្មារតី aliénation mentale ។

វិភាគទាន=ចំណែកឬភាគទ្រព្យ ដែលជនម្នាក់ៗ នាំយកទៅបង់ រៀងខ្លួនក្នុងចំណាយណាមួយ ។ គន្ធជាដែលបង់ជូនរដ្ឋ contribution ។

វិករណ= ការកែប្រែ សារជាតិ នៃវត្ថុណាមួយ ឲ្យក្លាយខុស ពាក ន័យ , តម្លៃ , ទំរង់ ដើមរបស់វា ដើម្បីឲ្យមាន ព្យសនកម្មណាមួយ : altération ។

វិរុទ្ធជន= ជនដែលមានពិរុទ្ធ ក្នុងបទឧក្រិដ្ឋ , មជ្ឈិម ឬ លហុ

00222499





ណាមួយតែមិនទាន់បានទទួលទោស : coupable ។ កាលណាបើតុលាការ កាត់ទោស ដាក់គុក ឬ ពិន័យ វិរុទ្ធជន រួចហើយ , វិរុទ្ធជននោះ ត្រូវបានឈ្មោះជា ទណ្ឌិត វិញ ។

វិស្រណ្ឋាបនកម្ម= កិរិយាឃុំឃាំងទុក នូវជន ណាម្នាក់ ដោយខុសច្បាប់ : séquestration ។ មើលមាត្រា ៤៨២ ផង ។

វិហិង្សា= សេចក្ដីបៀតបៀន , ការធ្វើទុក្ខបុកម្នេញ , អំពើឃោរឃៅ : violence ។ ពាក្យបុរាណថា បំពារបំពាន ។

-ស-

សក្ខិភាព=ភាពជាសាក្សី, ចម្លើយរបស់សាក្សី témoignage

សង្វាស (លំនៅ-)= លំនៅ ជាទីរួមរស់នៅ នៃគូស្វាមីភរិយា domicile conjugal ។

សង្ហារណា=កិរិយាប្រមូល ទិញផលាផល ស្បៀងអាហារក្ដី ឲ្យមូលមកនៅតែលើដៃ នៃជនម្នាក់ ឬ ជនមួយក្រុម ដោយមានចេតនាទុច្ចរិតចង់ឲ្យវត្ថុដែលបានប្រមូលទុកនោះ , ដល់ពេលលក់ទៅវិញ , មានតម្លៃផ្សេងពីតម្លៃធម្មតា គឺមានតម្លៃថោក ឬ ថ្លៃលើសពីតម្លៃធម្មតារបស់វា Accaparement ។

សន្និដ្ឋភាព= ការព្រមព្រៀងគ្នា , ការមត់គ្នា , ការសន្មតគ្នាដោយប្ដេជ្ញាយ៉ាងស្ងាត់ Entente ។

សន្ធិច្ឆេទកម្ម= អំពើកាត់របង: Effraction ។ មើល សេចក្តីពន្យល់ក្នុងមាត្រា ១៤៨ ថែមទៀត ។

សន្និធិ= ចំនួនទំនិញ ដែលនៅទុកស្បៀង stock ។

សមត្ថភាព= តាមន័យក្នុងច្បាប់, ភាពជាអ្នកមានអាយុ មានវិញ្ញា បរិបូណ៌ អាចប្រើសិទ្ធិគ្រប់យ៉ាងរបស់ខ្លួនបាន ។

សម្មតិបុគ្គល= មនុស្សដោយសន្មត ។ ឧ. ស្ត្រីម្នាក់ គា ឥតកូន ហើយទៅសុំ ឲ្យមន្ត្រីអត្រានុកូលដ្ឋានចុះ ក្នុងបញ្ជីជាតិ ថាខ្លួន មានកូនឈ្មោះនេះ ឬ ឈ្មោះនោះ ។ កូនដែលមានតែឈ្មោះយ៉ាងនេះ ហៅថា សម្មតិបុគ្គល Supposition de personne ។

សមាគម= មើលន័យក្នុងមាត្រា៦៨៧នៃក្រមនេះ association

សមុដ្ឋាន= ការតាំងឡើង ការកើតឡើង កន្លែងជាមូលហេតុ កន្លែងជាចំណុចលេចឡើង : source ។

សមូហភាព– ការប្រជុំព្រមនៃមនុស្ស ជនចំនួនតិច ច្រើន មករួម ជាសង្គមមួយ : colleetivité ។

សម្បូរណភាព– ឬសម្បូណ៌ភាព– ភាពនៃវត្ថុដែល មានរូបរាងគ្រប់គ្រាន់ ឥតខ្វះខាត : intégrité ។

សរណវត្ថុ= វត្ថុ ជាទីពឹង ទីលើក , វត្ថុក្នុងសាសនាណា មួយ ដែលគួរដល់ការគោរពបូជា របស់អ្នកកាន់សាសនានោះ objet

sacré à l'exercice d'un culte ។

សរីរៈ (ហេតុនាទ) = ហេតុការណ៍ ខាងជីវិត ខាងរាងកាយ :

raison physiologique ។

សរីរាង្គ — ភាគនៃរាងកាយ ដែលបំពេញមុខការ ជាចាំបាច់ ដើម្បីធ្វើឲ្យ ជីវិត រស់នៅបាន : organe ។ បេះដូង ជាសរីរាង្គ ខាងធ្វើឲ្យឈាមដើរ , ភ្នែក ជាសរីរាង្គសម្រាប់មើល ។

សល្យកម្ម — សេចក្ដីពន្យល់ក្នុងមាត្រា៤៨៩ នៃក្រមនេះ

opération chirurgicale ។

សល្យពេទ្យ — ពេទ្យខាងសល្យកម្ម : chirurgien ។

សវនាគារ — កន្លែងដែលចៅក្រម ជំនុំជំរះក្ដី : audience ។ ពាក្យបូរាណ ហៅថា កន្លែងជំនុំជំរះ បើកឱកាសដល់មហាជន ។ ពាក្យបូរាណ , មុនពាក្យនេះហៅទៀតថា ក្រឡាក្រម ។

សហចារី — អ្នករួមប្រព្រឹត្តិហើយ ដែលផល ដូចគ្នា co - auteur

សហព័ទ្ធ — ពាក្យសម្រាប់ហៅប្ដីឬប្រពន្ធឬ ទាំងប្ដីទាំងប្រពន្ធ

conjoint ។

សារជាតិ — ជាតិជូរ , ចត់ , ផ្អែម , ប្រៃ , ហឹរ , ទន់ ដែល មានគុណវិសេសមួយ ៗ : substance ។

សាលដីកា = (កាលពីដើម , ពាក្យនេះ មាន ន័យត្រឹម

00222502

D99/3/3



នៃ សេចក្ដីសម្រេច របស់សាលាវិនិច្ឆ័យ ប៉ុណ្ណោះទេ ; ប៉ុន្តែ គណកម្មការវប្បធម៌ យល់ឃើញថា បើ នឹងយកពាក្យនេះ ទៅហៅ សេចក្ដីសម្រេច របស់តុលាការជាន់ខ្ពស់ ឯទៀតផង ក៏មិនជាខុសដែរ ។ ដូច្នេះ គណកម្មការក៏ពង្រីកន័យរបស់ពាក្យនេះ ឲ្យប៉ុនគ្នានឹងពាក្យបារាំងថា arrêt ទៅ ) សេចក្ដីសម្រេច របស់តុលាការជាន់ខ្ពស់ ដូចជាសាលាឧទ្ធរណ៍ សាលាក្រុមហោទ , សាលាឧក្រិដ្ឋ , សាលាវិនិច្ឆ័យជាដើម ។

សាលក្រម = សេចក្ដីសម្រេច របស់តុលាការជាន់ទាប គឺ សាលាលហុ , សាលាដំបូង , សាលាក្ដី ជំនួញ : jugement សាលក្រម មាន ច្រើនយ៉ាងណាស់ , ប៉ុន្តែក្នុងទីនេះ យើងកប់តែបី :

ក) សាលក្រម ចំពោះមុខ ( jugement contradictoire ) សាលក្រមដែល សម្រេច ក្នុងទីចំពោះមុខ នៃគូក្ដី ។

ខ) សាលក្រម ជាចំណាត់ ( jugement par défaut ) សាលក្រម ដែលសម្រេច កំបាំងមុខ ពីមនុស្សត្រូវចោទ ។

គ) សាលក្រម ជាស្ថាពរ (jugement définitif ) សាលក្រម ដែលមានសេចក្ដី ជាស្រេច ដាច់ខាត , គឺថា , គូក្ដី មិនអាចប្ដឹងតស៊ូ ឬ ប្ដឹង ឧទ្ធរណ៍ តទៅទៀតបានទេ ។

សុពលភាព = ភាពជាអ្នកមានកម្លាំងពលល្អ , ជាអ្នកសុខសប្បាយ អាចធ្វើការកេស៊ីបាន : valide

សុរិយគតិ ( សង្ក្រាន្ត ) = ការរាប់ថ្ងៃ ខែ ឆ្នាំ តាមដំណើរព្រះអាទិត្យ (calendrier solaire ។ តាមសុរិយគតិ គេ រាប់ខែថា មករា ( ៣១ ថ្ងៃ) , កុម្ភៈ ( ២៨ ឬ ១៩ ថ្ងៃ ) ។ល។

សេចក្តីសម្រេច= décision

សេវនកិច្ច = ការសេពគប់ , ការស្និទ្ធស្នាល ; ន័យក្នុងទីនេះ ជាប្រុសនិងស្រី រួមរណីនិងគ្នាដល់ទីជម្រៅ : commerce charnel ។

ស្ថាពរ = មាំមួន , ជាប់រហូត définitif ។ សាលក្រមជាស្ថាពរ គឺ សាលក្រមដែលកាត់សេចក្តី ជាស្រេចជាប់ខាត ឥតត្រូវរើះ ទៀតទេ គឺថា គូក្តីមិនអាចប្តឹងឧទ្ធរណ៍ , ប្តឹងសាទុក្ខបានឡើង : jugement définitif ។

ស្លាកល័ក្ត= ផ្ទាំងក្រដាស ឬ សំពត់ដែលគេបិតជិតចុងចាំង សង្វាក់ដោយកាតល័ក្ត ហើយគេ បោះត្រា ជាផ្ការ លើកាតល័ក្តនោះ ។ កាលមានជនណាម្នាក់ស្លាប់ ហើយទាយាទនៃជននោះ មកមិនទាន់ជុំគ្នា ឬ ក៏ក្នុងពួកទាយាទនោះ មានខ្លះនៅ ក្នុងអនីតិភាព នៅឡើយ ឬក៏ ជនអ្នកស្លាប់នោះ មានមុខការ ជាអ្នករក្សា លិខិតកងការ នោះទ្រព្យសម្បត្តិទាំងឡាយ ជាសង្ហារឹម របស់ខ្មោចនេះ ត្រូវចៅក្រម ឬ អាជ្ញាសាលាប្រមូលទុកក្នុងបន្ទប់មួយ ឬ ក្នុងហិបមួយ , បិទទ្វារជាប់ទៅវិញ ហើយបិទស្លាកល័ក្តពីលើមាត់ទ្វារ ឬ មាត់ហិបនោះទៀត ។

-ហ-

ហឋកម្ម- សម្លាប់មនុស្សដោយចេតនា ដោយបានគិតទុកជាមុនទេ : assassinat

ហិតុបត្ថម្ភក៍ ជនអ្នកមានភារៈខាងឧបត្ថម្ភអនីតិជន ដែលបាននៅក្រោមអណាព្យាបាល ក្នុងការធ្វើកិច្ចសន្យាអ្វីមួយ ឬ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៃអនីតិជននេះ curateur

-អ-

អគ្គិភយ= សេចក្ដីអន្តរាយ កើតមកអំពីភ្លើង ៗ តាមទម្លាប់ គេហៅថាអគ្គិភ័យ : incendie ៗ

អដ្ឋធព= corps armé

អចេតនា= មិនមានចេតនា : involontaire ៗ

អត្តសញ្ញាណ= ភិនភាគគ្រប់យ៉ាង របស់ បុគ្គលម្នាក់ៗ ដើម្បីទុកជាចំណាំបុគ្គលនោះឲ្យបានច្បាស់ គ្មានច្រឡំ នឹងបុគ្គលដទៃទៀតឡើយ : identité ៗ អត្តសញ្ញាណប័ណ្ណ លិខិតដែលមានកត់ត្រា អត្តសញ្ញាណ titre d'identité

អតិក្រម= ការប្រព្រឹត្តល្មើសក្រៃពេក , ការប្រមាថមើលងាយដល់សារណៈវត្ថុ មានព្រះពុទ្ធជាដើម : violation

អតិថិជន ឬ អតិថិ- ភ្ញៀវ , ភ្ញៀវពន្ធ , ជនអ្នកផ្ញើផល

00222505

D99/3/3



ប្រយោជន៍របស់ខ្លួន លើមនុស្សអ្នកការ, លើមេធាវី ឬ ជនអ្នកផ្ញើសុខភាព ខ្លួនលើគេទៀត : client ។

អត្ថិភាព ភាពដែលមានមែន, ដែលរស់នៅមែន existence

អត្រា— តម្លៃជាកំណត់, តម្លៃដែលមានកំរិតសន្យា ឬ ដែលទំលាប់ធ្លាប់កំណត់ទុកមក ។ បុរីការនៃដើមប្រាក់ ១០០រៀល ដែលបង់ក្នុងមួយឆ្នាំ : taux ។

អនាចារ— ការប្រព្រឹត្តខុសបែបបទ, ខុសសណ្តាប់ធ្នាប់, ដូចជាផឹកស៊ី ស្រវឹងហួសហេតុ : débauche

អនាមិក— ដែលមិនមានឈ្មោះ, មិនចេញឈ្មោះ anonyme

អន្តរការី អ្នកប្រៀតចូល ក្នុងកិច្ចការនៃអ្នកដទៃ, ជនអ្នកដឹកនាំអ្នកទិញ ឱ្យជួបនឹងអ្នកលក់, ជនអ្នកទទួលប្រាក់ ពីអ្នកលេងល្បែង យកទៅដាក់ល្បែងឱ្យ : intermédiaire ។

អនីត្យានុកូល — ពាក្យផ្ទុយ នឹងពាក្យ និត្យានុកូល illégale

អនីតិជន — ជនមានអាយុមិនទាន់គ្រប់តាមច្បាប់ គឺជាមានអាយុតិចជាង ២១ ឆ្នាំ mineur ។ ពាក្យផ្ទុយ នឹងពាក្យ នីតិជន ។

អនុទោស—មើលសេចក្តីពន្យល់ក្នុងមាត្រា៣ ។ ពាក្យបុរាណថា បរិកក្ខុទោស ។ គណកម្មការប្រជុំយល់ថា ពាក្យនេះវែងពេក ជាហេតុនាំឱ្យអ្នកសិក្សាខ្វល់ថា ឱ្យរស់ ទោះហើយគណកម្មការ កំណត់

00222506



«បរិវារ» ទោស ទុកតែ «អនុទោស» : peines accessoires ។

អនុទ្ទេស – ការសម្ដែង, ការពន្យល់, ការឱ្យពត៌មាន ដើម្បីឱ្យធ្វើតាម instruction ។

អនុប្បទាន – ការទុកឱ្យ, ការបោះបង់ចោល, ការដកខ្លួនចេញ ដើម្បីឱ្យគេយកសិទ្ធិនេះ មកកាន់កាប់ចុះ : céder ។

អនុវត្ត – ប្រព្រឹត្តតាម, ធ្វើតាម, យកវត្ថុ មួយទៅបិទ លើវត្ថុមួយទៀត, appliquer ។ អនុវត្តទោស ធ្វើទោស ។

អគារវកម្ម – អំពើមិនគួរសម, ការប្រមាថ មើលងាយ ដល់សារវត្ថុ មានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម profanation

អវត្តមាន – តាមន័យធម្មតាថា ការបាត់មុខ, ការមិនឃើញមុខ កន្លែងណាមួយ ។ ន័យក្នុងច្បាប់ថា : ការបាត់ មនុស្សណាម្នាក់ ពីទីលំនៅ អស់កាល ជាយូរ ព្រមទាំង បាត់ដំណឹង អំពីមនុស្សនោះទៀត គឺថាក្រុមញាតិ មិនលេចឮ ដំណឹងថាជននោះ រស់ ឬ ស្លាប់ នោះ ។ មើល មាត្រា៨៤ដល់១០៨ នៃក្រមរដ្ឋប្បវេណីថែមទៀតផង ។

អវយវៈ – អង្គ, ប្រហង, សរីរាង្គ ។ ស្លាប់អវយវៈណាមួយជាស្ថាពរ – ពិការជាមួយ បណ្ដាលឱ្យ អវយវៈណាមួយមាន ដៃ និងជើងជាដើម កំរើកមិនរួច ហេតុ : impotence fonctionnelle définitive ។

00222507





អសមត្ថភាព ៈ ការមិនមានសមត្ថភាព ព្រោះនៅក្នុងអនីតិភាព, ព្រោះខូចវិចារបញ្ញា, ព្រោះវិកលចរិត, ព្រោះតុលាការ ដាក់ទណ្ឌកម្ម បន្ថយសិទ្ធិស៊ីវិល, ឬ បើជាស្ត្រី, ព្រោះមានភាពពាហ៍ពិពាហ៍ មានខាន់ស្លា ទីមួយ ឬ ទីពីរ : incapacité ។

អសាធនភាព — ភាពដែលគ្មានធនធាន ទិញបង់ពន្ធដារ ឬ សង សំណង ដល់គេបាន : insolvabilité ។

អហេតុកភ័យ — ភ័យ, ការភ្ញាក់ផ្អើល ដោយឥតហេតុ ឥតបច្ច័យ panique ។

អាជ្ញាធរ — អ្នកទ្រទ្រង់អំណាច autorité ។ អាជ្ញាធរខាងរដ្ឋបាល : autorité administrative ។ អាជ្ញាធរខាងតុលាការ : autorité judiciaire ។ ពាក្យបុរាណថា អ្នកកាន់ការ

អាជ្ញាយុកាល — មើលសេចក្ដីពន្យល់ នៅមាត្រា១០៩ និង១៧១ prescription ។ អាជ្ញាយុកាលនៃបទល្មើស — (prescription de l·infractiou) មើលសេចក្ដីពន្យល់នៅមាត្រា១០៩ ។ ពាក្យបុរាណថា ហួសព្រះរាជកំណត់ច្បាប់ ។ អាយុកាលនៃទោស (prescription de la peine) មើលសេចក្ដីពន្យល់ នៅមាត្រា ១៧១ ; ពាក្យបុរាណ ហួសព្រះរាជកំណត់ទោស ។

អានុភាព — លទ្ធផល នៃហេតុណាមួយ effet

00222508





អាយុកាល– ពេលកំណត់នៃអាយុប៉ុណ្ណះ ប៉ុណ្ណះ ។ អស់អាយុកាល – périmé ។

ឥទ្ធិពល – កម្លាំងនៃសេចក្តីសម្រេច , កម្លាំងអានុភាព ។

ជំនួញឥទ្ធិពល – ការធ្វើឲ្យគេជឿជាក់ ថា ខ្លួនមានឥទ្ធិពល , មានអានុភាព អាចទៅគិតការណ៍នេះ ការណ៍នោះ នឹងលោកនេះ ឬ លោកនោះ ឲ្យសម្រេចបាន ដើម្បីទទួលយកលាភការពីអ្នកដែលមកពឹងខ្លួន trafic d'influence ។ ពាក្យប្តូកណាថា ប្រើអំណាចយកប្រយោជន៍ មើលមាត្រា ៣១១ នៃក្រមនេះទៀត ។

ឧក្រិដ្ឋកម្ម– អំពើជាធ្ងន់ crime ។

ឧត្តរិមនុស្សធម៌– ធម៌ ឬ អំណាចរបស់មនុស្ស អ្នកមានគុណវិសេស លើសលែង មនុស្សធម្មតា pouvoir surnaturel ។

ឧទ្ទាម – មនុស្សដែលតាំងខ្លួន ជាខ្មាំងក្បត់ ផែនដី rebelle ។ មើលន័យក្នុងមាត្រា ៣៧០ ដល់ ៣៧៦ ។

ឧទ្ទាមកម្ម – អំពើរបស់ពួកឧទ្ទាម : rebellion ។ មើលន័យក្នុងមាត្រា ៣៧០ ដល់ ៣៧៦ ។

ឯកសារដ្ឋាន – កន្លែងទុកឯកសារ, ក្បួនខ្នាត archive ។

អំណាស – ការផ្ទេរទ្រព្យសង្ហារិម ឬ អសង្ហារិម ជារបស់កម្មសិទ្ធិករ ឬ ជារបស់កូនបំណុលណាម្នាក់ មកដាក់ដៃតុលាការ ឬ អាជ្ញា

ធនាធិរដ្ឋបាល ទាំងមានសេចក្ដីសម្រេចជាស្ថាពរ ដើម្បីកុំឲ្យកម្មសិទ្ធិករ ឬ កូនបំណុលនោះ លក់ដូរឲ្យខូច ផលប្រយោជន៍ របស់អ្នកសុំឲ្យអូស saisie ។ ទ្រព្យអំណូស - ទ្រព្យដែលត្រូវអូស objets saisis ។

អំណូសឃាត់ - ការអូស ដោយសំអាង លើលិខិត ឬ សំបុត្រ អនុញ្ញាតពីចៅក្រម ដែលបើកឲ្យម្ចាស់បំណុល អូសបំណុលរបស់កូនបំណុលខ្លួនទុក ដើម្បីកុំឲ្យកូនបំណុលនេះ ទារយកបំណុលនោះមកចាយវាយបាន saisie-arrêt ។ ឧ. ឈ្មោះ ខ ជាកូនបំណុល របស់ឈ្មោះ ក ហើយឈ្មោះ គ ជាកូនបំណុលរបស់ ឈ្មោះ ខ ៗ ក សុំឲ្យតុលាការឃាត់ មិនឲ្យឈ្មោះ គ សងបំណុលទៅឈ្មោះ ខ ទុកបំណុលនោះសម្រាប់សង ទៅខ្លួនឈ្មោះ ក វិញ ។ ការអូសយ៉ាងនេះហៅថា អំណូសឃាត់ ។ អំណូសបង្ការ - ការអូសទ្រព្យសម្បត្តិរបស់កូនបំណុលទុកបង្ការ ទាំងតុលាការកាត់សេចក្ដីជាស្ថាពរ saisie conservatoire ។ ចប់ ។

00222510

Sanuath

11.254 D99/3/3

មាត្រា ៣ នៃរដ្ឋធម្មនុញ្ញ.-

សេរីភាព ជាដំណើរ អាច ធ្វើ អ្វី បាន គ្រប់យ៉ាង កុំ ឱ្យតែប៉ះពាល់ ឱ្យខូច សិទ្ធិ អ្នកដទៃ ។ លក្ខខ័ណ្ឌ នៃការប្រើ សេរីភាព មានត្រាទុក ក្នុងច្បាប់ ។

អ្វី ដែលច្បាប់ មិនបង្គាប់, ជន ណា ក៏ដោយ មិនអាច ត្រូវ គេ បង្ខំ ឱ្យធ្វើ បាន ឡើយ ។

ដូច្នេះ

*ពលរដ្ឋ ម្នាក់ ៗ ត្រូវតែគោរព ច្បាប់ ដើម្បីឱ្យបានគោរព ប្រើសេរីភាព របស់ខ្លួន ផង ទាំង ដើម្បីការពារ សេរីភាព នោះ ផង ។*

00222511



# សេចក្ដីអធិដ្ឋាន

សូម អានិសង្ស នៃសេចក្ដីព្យាយាម របស់ខ្ញុំ ក្នុងចេតនា ចង់ពង្រីក អក្សរសាស្ត្រ ដើម្បីជាតិខ្ញុំ ជួយ :

១.– ឲ្យខ្ញុំ រក មុខចោរឃ្មានមាន ដែលបានលួច បោះពុម្ព សៀវភៅ នេះ ដោយម៉ាស៊ីនរូណេអូ ឲ្យបានឃើញ យ៉ាងឆាប់ រហ័ស,

២.– ដោយអានុភាព នៃមាត្រា ៤១៥, ៤១៦ នៃក្រមនេះ ឲ្យចោរប្រភេទ នេះ អន្តរធានពីប្រទេសកម្ពុជាយើងទៅ,

៣.– ឲ្យអក្សរសាស្ត្រខ្មែរ បាន ជាទីចាប់អាន នៃជនជាតិខ្មែរ ក្នុងប្រទេសខ្មែរ កាន់តែមាន ចំនួន ច្រើនឡើងៗ កុំបីខាន ។

ធ្វើ នៅថ្ងៃ ទី ៣០ តុលា ១៩៦៤

អេង-សុត

# សារទានក្រមព្រហ្មទណ្ឌ

## គន្ថីមួយ — អំពីទោស

### មាតិកា មួយ • — បទបញ្ញត្តិទូទៅ

មាត្រា


– ពន្យល់ បទល្មើស . . . . . . . . . . . ១

– របៀបទោសកាជា . . . . . . . . . . ២

– មូលទោស និង បរាំកខុស . . . . . . . . . ៣

– ទោសឧក្រិដ្ឋ មជ្ឈិម និង លហុ . . . . . . ៤

– វែកបទល្មើសជា ឧក្រិដ្ឋ, មជ្ឈិម, លហុ . . . . . ៥

– ច្បាប់ព្រហ្មទណ្ឌ គ្មានប្រតិសកម្មឡើយ . . . . . ៦

– កំណត់ ទោសគុក . . . . . . . . . ៧

– ការទូទាត់ ពេលជាប់ឃុំ និង ទោស . . . . . . ៨

– ពន្យល់ ពីក្រយាពិន័យ . . . . . . . . . ៩

– ការប្រាក់ ក្រយាពិន័យ, ប្រជាប់ក្តី, សំណង ជម្ងឺចិត្ត . . ១០

– ការប្រាក់ ក្រយាពិន័យ, និង ប្រាក់បង់ខាតជម្ងឺចិត្ត មុន . . ១២

– ដាក់គុកបង្ខំ ដល់រូបកាយ រឿងការជាតត . . . . . ១៣

– បទល្មើស ច្រើនសណ្តាន . . . . . . . . . ១៤

– ទណ្ឌកម្ម នៃបទឧក្រិដ្ឋ ច្រើនសណ្តាន . . . . . ១៥

– ទណ្ឌកម្ម នៃបទឧក្រិដ្ឋ និង បទមជ្ឈិម ច្រើនសណ្តាន . . ១៦

មាត្រា

- ទណ្ឌកម្មនៃបទ មជ្ឈិម ច្រើនសណ្ឋាន . . . . ១៧
- ទណ្ឌកម្មនៃបទ លហុ ច្រើនសណ្ឋាន . . . . ១៨
- ផលបទល្មើស ដែលប្រព្រឹត្តបន្តគ្នា ឬ ព្រមជំណាលគ្នា . . ១៩
- មាត្រានេះត្រូវ និរាករហើយ . . . . . . ២០

## មាតិកា ពីរ .— អំពីមូលទោស

- ទោសឧក្រិដ្ឋ-រៀបរាប់ទោស ហើយនិងថ្នាក់ទោសទាំងនេះ . ២១
- ទោសមជ្ឈិម-រៀបរាប់ទោស ហើយនិង ថ្នាក់ទោសទាំងនេះ . ២២
- ទោសលហុ-រៀបរាប់ទោសទាំងនេះ . . . . . ២៣

## ជំពូក មួយ.— អំពីទោសឧក្រិដ្ឋ

### ផ្នែក មួយ .— អំពីទោសសម្លាប់ជីវិតបង់

- បែបប្រហារជីវិត . . . . . . . . ២៤
- ប្រកាស ឲ្យជនានុជន បានដឹង ពីប្រហារជីវិត . . . ២៥
- កន្លែង ដែលប្រហារជីវិត . . . . . . ២៦
- ថ្ងៃ ដែលប្រហារជីវិត . . . . . . . ២៧
- ប្រគល់សព ដែលពិឃាត . . . . . . . ២៨
- ប្រហារជីវិត ស្ត្រីដែលមានគភ៌ . . . . . ២៩
- អំណាចលើក ទោសប្រហារជីវិត . . . . . ៣០

00222514



មាត្រា

## ផ្នែក ពីរ .— ទោសបង្ខំឱ្យធ្វើការជាទម្ងន់


— លក្ខណៈដែលធ្វើទោស . . . . . . ៣១

— កំណត់ទោស ឲ្យធ្វើការជាទម្ងន់ អស់មួយជីវិត . . ៣២

— កំណត់ទោស ឲ្យធ្វើការជាទម្ងន់ មានកំណត់ . . ៣៣


## ជំពូក ពីរ .— អំពីទោសមជ្ឈិម

## ផ្នែក មួយ .— អំពីការដាក់គុកមជ្ឈិម


— លក្ខៈដែលធ្វើទោស . . . . . . ៣៤

— របៀបច្បាប់សម្រាប់មនុស្សទោស . . . . ៣៥

— កំណត់ទោស . . . . . . . ៣៦

— ចំនួនប្រាក់ក្រយាពិន័យ . . . . . . ៣៧

— កំណត់ដែលចន់ ឬ ដែលខឹងតារបាន . . . ៣៧

— បន្ធន់ទោស បន្ធុំដល់រូបកាយ . . . . . ៣៩

— សុំចន់ ក្រយាពិន័យ មួយរំពេចបាន . . . ៤០


## ជំពូក បី .— អំពីទោសលហុ

## ផ្នែក មួយ.— អំពីទោស គុក ជាលហុ


— កំណត់ដាក់គុកជាលហុ . . . . . . ៤១

— ជនទូនដែលត្រូវទទួលទោស . . . . . ៤២

មាត្រា

[illegible] ប្រចាំ នៃខណ្ឌិត . . . . . . . . . ៤៣

ផ្នែក ពីរ .— អំពីពិន័យជាលហុ

— ចំនួនប្រាក់ក្រយាពិន័យ . . . . . . . ៤៤

— ការប្រាក់ក្រយាពិន័យ . . . . . . . ៤៥

— ធ្វើការងារ សាធារណៈ ជំនួសប្រាក់ក្រយាពិន័យ . ៤៦

— សុំបន់ ក្រយាពិន័យ មួយរំពេច . . . . . ៤៧

មាតិកា បី .— អំពី អនុទោស

— របៀបចាប់ពីអនុទោស . . . . . . . . ៤៨

ចំពូក មួយ .— អំពី ការបន្ថយសិទ្ធិស៊ីវិក

— ពន្យារទោស . . . . . . . . ៤៩

— អនុទោស នៃមូលទោសទុក្រិដ្ឋ . . . . . ៥០

— អនុទោស នៃមូលទោសមជ្ឈិម ដែលមិនធ្វើកំបាន . . ៥១

— ថ្ងៃដែលត្រូវគិតទោស . . . . . . . . ៥២

— កំណត់ទោស . . . . . . . . . ៥៣

ចំពូក ពីរ .— អំពី គំហាត់ ជានិត្យានុកូល

— សេចក្តីពន្យល់ . . . . . . . . ៥៤

— ការរំលាក នៃមូលទោសទុក្រិដ្ឋ . . . . . ៥៥

00222516

D99/3/3

មាត្រា | ទំព័រ


៤៣ – មិនឲ្យមនុស្សទោស ដែលកំពុងរងទោស មានសិទ្ធិចាត់ចែងគ្រប់គ្រង
មានសិរីភោគបរិភោគ សម្បត្តិទ្រព្យខ្លួន . . . . ៤៦


៤ ## ចំពូក បី .– អំពីគំហាត់លំនៅ


៥ – សេចក្តីពន្យល់ . . . . . . . . . ៤៧

– លក្ខណៈនៃការ មិនធ្វើកបាន . . . . . . . ៤៨

– អនុវត្តន៍បានដកប ក្នុងបទឧក្រិដ្ឋ . . . . . ៤៩

– អនុវត្តន៍ខានព្រំដែន ក្នុងបទមជ្ឈិម . . . . . ៦០

– ថ្ងៃដែលត្រូវគិតទោសនេះ . . . . . . . ៦១

– ត្រូវធ្វើទោសនេះ កាលណាបើ ផ្តួរទោសឧក្រិដ្ឋអស់មួយជីវិត . ៦២

– ឲ្យដំណឹងពីទោសនេះ ទីងខានមិនបាន . . . . ៦៣

– គម្រោងការដែលកើតឡើង ពីការឲ្យដំណឹងដោយឃើញយូរ . ៦៤


## ចំពូក បួន .– អំពី ប្រកាសទណ្ឌកម្ម


– ចំកន្លែង ដែលត្រូវបិទប្រកាស . . . . . . ៦៥


## ចំពូក ប្រាំ .– អំពី របឹប


– សេចក្តីពន្យល់ . . . . . . . . . ៦៦

– វត្ថុដែលទីងរើបអូសបាន (វត្ថុដែលគួរដល់រើប) . . . ៦៧

– អនុវត្ត ខ្លះទៅក្នុងបទឧក្រិដ្ឋ និងបទមជ្ឈិម លើកលែងបទលហុ . ៦៨

មាត្រា

## ចំពូក ប្រាំមួយ .– អំពី សំណង់ និង ជម្ងឺចិត្ត


– សិទ្ធិរបស់ជន ដែលមានព្យសនកម្ម ដោយសារបទល្មើស . ៦៩

– ភាតព្វកិច្ចរួមគ្នា របស់ទណ្ឌិតទាំងឡាយ . . . . ៧០

– ការប្រាក់សំណង នឹងប្រាក់ជម្ងឺចិត្ត . . . . . ៧១

– ប្រគល់ របស់កស្តុតាង ឲ្យវិញ . . . . . . ៧២


## ចំពូក ប្រាំពីរ.– អំពី បញ្ញាជនីយកម្ម


– សេចក្តីពន្យល់ . . . . . . . . ៧៣

– របបបញ្ញាជនីយកម្ម . . . . . . . ៧៤

– លក្ខណៈ ដែលធ្វើទោសទេះក៏បាន មិនធ្វើក៏បាន . . . ៧៥


## គន្ថី ពីរ .–

## អំពីបុគ្គលដែលគួរដាក់ទណ្ឌកម្ម


– បទបញ្ញត្តិ ប្រារក . . . . . . . . ៧៦


### មាតិកា មួយ .– អំពីបំណង


– ធាតុ នៃបំណង ដែលគប្បីធ្វើទណ្ឌកម្មបាន . . . ៧៧

– កិច្ចការទាំងឡាយ ដែលរៀបចំ នឹងប្រព្រឹត្ត . . . ៧៨

– បំណងនឹងប្រព្រឹត្ត បទឧក្រិដ្ឋ . . , . . . ៧៩

ទំព័រ


- បំណាន់ទីនប្រព្រឹត្ត បទមជ្ឈិម . . . . . . . ៨០
- បំណាន់ទីនប្រព្រឹត្ត បទលហុ . . . . . . ៨១

## មាតិកា ពីរ .— អំពីការរួមប្រព្រឹត្តជាមួយ

- សេចក្ដីពន្យល់ . . . . . . . . . ៨២
- ចូលប្រព្រឹត្ត ប្រយោល ឬ សមគំនិត . . . . ៨៣
- សមគំនិត ដោយញុះញង់ . . . . . . . ៨៤
- សមគំនិត ដោយបង្គាប់បញ្ជា . . . . . . ៨៥
- សមគំនិត ដោយឲ្យគ្រឿងប្រដាប់ . . . . . ៨៦
- សមគំនិត ដោយជួយទំនុកបំរុង. . . . . . ៨៧
- សមគំនិត ក្នុងបទលហុ . . . . . . . . ៨៨

## មាតិកា បី .— អំពីជន គ្មានការទទួលខុសត្រូវ

### ចំពូក មួយ .— អំពីវិបត្តិស្មារតី

- មនុស្សលេលា ឬ សតិទន់ខ្សោយមិនទទួលខុសត្រូវក្នុងបទអាជ្ញា ៨៩
- ពិនិត្យឲ្យឃើញជាលេលាឬ សតិទន់ខ្សោយ . . . ៩០

### ចំពូក ពីរ .— អំពីការខ្វះវិចារបញ្ញា

- នីតិភាព ក្នុងបទអាជ្ញា . . . . . . . ៩១
- អនីតិជន ប្រព្រឹត្ត ដោយគ្មាន វិចារបញ្ញា . . . . ៩២

00222519

D99/3/3

មាត្រា


– អនីតិជន ប្រព្រឹត្តដោយមានវិចារបញ្ញា . . . . ៩៣

– របបប្រដៅអនីតិជន . . . . . . . ៩៤

– គ្មានលិខិតអត្រានុកូលដ្ឋាន សំគាល់អាយុអនីតិជន . . ៩៥


## មាតិកា បួន .– អំពីយុត្តិកម្ម នៃបទល្មើស

### ចំពូក មួយ .– ករណី នៃប្រធានស័ក្តិ


– យុត្តិកម្មបណ្តាល មក ពីករណីប្រធានស័ក្តិ . . . ៩៦

– សេចក្តីពន្យល់ ពីការណ៍ចាំបាច់ . . . . . ៩៧

– ភស្តុតាង នៃការចាំបាច់. . . . . . . ៩៨


### ចំពូក ពីរ .– អំពីសេចក្តីបង្គាប់ របស់ច្បាប់


– យុត្តិកម្មបណ្តាល មក ពីបង្គាប់ ពីច្បាប់ . . . . ៩៩

– ប្រតិបត្តិតាមបង្គាប់ខុសច្បាប់ . . . . . . ១០០


### ចំពូក បី .– កិច្ចការពារ ជាធម្មានុរូប


– យុត្តិកម្ម បណ្តាល មក ពីសេចក្តីការពារខ្លួន . . . ១០១

– សេចក្តីពន្យល់ពីស្ថានការពារខ្លួន . . . . . ១០២

– កម្រិតកិច្ចដែលសម្រេច ក្នុងស្ថានការពារខ្លួន . . . ១០៣

– ករណីខ្លះ ដែលត្រូវទុកជាស្ថានការពារខ្លួន . . . ១០៤

មាត្រា

## ជំពូកបួន .— អំពី សន្តោសទោស

– សន្តោសទោស កើតមកពីទាន់ឃើញស្ត្រីផិតក្បត់ប្ដី . . . ១០៥

– សន្តោសទោស កើតមកពីទាន់ឃើញធ្វើអាស្រូវកាស . . ១០៦

– សន្តោសទោស កើតមកពីសិទ្ធិនាយក្រាន . . . . ១០៧

– សន្តោសទោស កើតមកពីសិទ្ធិវាយប្រដៅ - - - - ១០៨

## មាតិកា បួន .— អាជ្ញាយុកាល នៃបទល្មើស

– ការផុតរលត់នៃបណ្ដឹង ជាបទអាជ្ញា - - . . - ១០៩

– ការផុតរលត់នៃបណ្ដឹងស៊ីវិល . . . . . . ១១០

– ថ្ងៃទីមួយ នៃរយៈវេលារបស់អាជ្ញាយុកាល . . . ១១១

– ការបង្អាក់ដំណើរនៃអាជ្ញាយុកាល . . . . . ១១២

– អាជ្ញាយុកាលនៃបទល្មើស ដែលទើបគេឃើញ ក្នុងវេលា
ស៊ើបសួរ . . . . . . . . . . ១១៣

– អានុភាព នៃការបង្អាក់ដំណើរ នៃអាជ្ញាយុកាល - . . ១១៤

## គន្ថី បី .—

## អំពីអនុវត្តន៍ទោស

– បទបញ្ញត្តិ ប្រាក . . . . . . . . ១១៥

# មាត្រា

## មាតិកា មួយ .— អំពីការសម្រាលទោស និងការបង្អង់ ប្រតិបត្តិទោស –

— បទបញ្ញត្តិទូទៅ . . . . . . . . . ១១៦

## ជំពូក មួយ .— អំពីការបន្ថយទោស បណ្តាលមក ពីអនីតិភាព នៃទណ្ឌិត

— អនីតិភាព ក្នុងបទគាថ្ង . . . . . . ១១៧

— ការបន្ថយទោស ក្នុងបទឧក្រិដ្ឋ . . . . . ១១៨

— ការបន្ធូរបន្ថយទោស ក្នុងបទមជ្ឈិម . . . . ១១៩

— របប ប្រតិបត្តិទោស . . . . . . . ១២០

— ឲ្យរួចពីអនុទោស បន្ថយសិទ្ធិស៊ីវិល គំហាត់លំនៅ ផ្សាយទោស ១២១

— ការបន្ថយទោស ក្នុងបទលហុ . . . . . . . ១២២

## ជំពូក ពីរ .— អំពីការកែទម្រង់ ទោសឧក្រិដ្ឋ មកជាទោសគុកមជ្ឈិមវិញ ព្រោះជរាភាពនៃទណ្ឌិត

— ការប្តូរទោសឧក្រិដ្ឋ មកជាទោសគុកមជ្ឈិម . . . ១២៣

— របបគម្រូវទោសគុកមជ្ឈិមដល់ទណ្ឌិតឧក្រិដ្ឋពីថ្ងៃគ្រប់អាយុ៦០ឆ្នាំ ១២៤

— ទុកអនុទោសដូចដែល . . . . . . . ១២៥

— ការបន្ថយទោស ក្នុងបទលហុ . . . . . ១២៦

## ចំពូក បី .— អំពីការបន្ថយទោស ព្រោះមានកាលៈទេសៈ គួរសំរាល


– សេចក្តីពន្យល់ . . . . . . . . . ១២៧

– អានុភាព នៃរឿងឧក្រិដ្ឋ . . . . . . . ១២៨

– អនុវត្តន៍ អនុទោស . . . . . . . . . ១២៩

– អានុភាពដែលទាក់ទងដល់ទណ្ឌិតមិនកន់តាណ . . . ១៣០

– អានុភាពដែលទាក់ទង ដល់អតិបរមា នៃទោស ដែលបញ្ញត្តិ . ១៣១

– អានុភាព នៃរឿងមជ្ឈិម . . . . . . . . ១៣២

– អនុវត្តន៍ អនុទោស . . . . . . . . ១៣៣

– អានុភាព នៃបទលហុ . . . . . . . . ១៣៤


## ចំពូក បួន .— អំពីការបង្អង់ ប្រតិបត្តិទោស


– សេចក្តីពន្យល់ អំពីបង្អង់ ប្រតិបត្តិទោស . . . ១៣៥

– ឲ្យអនុទោស គឺបន្ថយសិទ្ធិស៊ីវិល និង កំហាត់លំនៅ . . ១៣៦

– បញ្ជូនសំណុំរឿងដែលបង្អង់ប្រតិបត្តិទោស . . . ១៣៧


## មាតិកា ពីរ .— អំពីធ្ងន់ទោស


– បទបញ្ញត្តិទូទៅ . . . . . . . . . ១៣៨

# មាត្រា

## ចំពូក មួយ .— អំពីទម្ងន់ទោស បណ្តាលមកពីលក្ខខណ្ឌ របស់បទល្មើស

– កាលៈទេសៈដែលនាំឲ្យ មានទម្ងន់ទោស . . . ១៣៩

– កាលៈទេសៈទម្ងន់ទោសព្រោះប្រព្រឹត្ត បទល្មើសច្រើនបទ . ១៤០

– បទល្មើសជាមជ្ឈិម ដែលត្រូវកែ ជាបទឧក្រិដ្ឋ . . . ១៤១

– មនុស្សឃាតប្រព្រឹត្តជាមួយ បទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ . ១៤២

– សេចក្តីពន្យល់ ពីបទល្មើស ដែលប្រព្រឹត្តព្រមគ្នា . . ១៤៣

– សេចក្តីពន្យល់ ពីការគិតទុកជាមុន . . . . ១៤៤

– សេចក្តីពន្យល់ ពីគ្នាច្រើនប្រព្រឹត្តបទល្មើស . . . ១៤៥

– សេចក្តីពន្យល់ ពីគ្រឿងសស្ត្រាវុធ . . . . ១៤៦

– សេចក្តីពន្យល់ ពីកំហែង បង្ខំវាយដំ . . . . ១៤៧

– សេចក្តីពន្យល់ ពីសន្និបេទកម្ម . . . . . . ១៤៨

– សេចក្តីពន្យល់ ពីផ្លូវដើរគោក ផ្លូវដើរទឹក គេហស្ថាន សាធារណៈ;
និងបូជនីយដ្ឋាន . . . . . . . . ១៤៩

## ចំពូក ពីរ .— អំពីទម្ងន់ទោស បណ្តាលមកពីគុណភាព នៃអ្នករងបទល្មើស

– បទល្មើស បណ្តាលឲ្យខូចខាតប្រយោជន៍ រាជការផែនដី . ១៥០

មាត្រា

– បទល្មើសលើអ្នករាជការនៅវេលាកំពុងស្តីការមុខក្រសួង . ១៥១

– បទល្មើស ប្រព្រឹត្តលើអនីតិជន, មនុស្សចាស់ឬពិការ . . ១៥២

ចំពូក បី .— អំពីទម្ងន់ទោស បណ្តាលមក ពីគុណភាព
នៃអ្នក ដែលប្រព្រឹត្ត បទល្មើស

– បទល្មើស ដែលនាម៉ឺនសព្វមុខមន្ត្រី ប្រព្រឹត្ត . . . ១៥៣

– បទល្មើស ដែលមនុស្សបំរើ ធ្វើការឲ្យគេ ប្រព្រឹត្ត . . . ១៥៤

ចំពូក បួន .— អំពីទម្ងន់ទោស បណ្តាលមក ពីភាព
មិនរាងចាល របស់ទណ្ឌិត

ផ្នែកទី មួយ .— អំពីភាពមិនរាងចាល ក្នុងបទឧក្រិដ្ឋ

– សេចក្តីពន្យល់ ពីការមិនរាងចាល . . . . . ១៥៥

– ទម្ងន់ទោស . . . . . . . . ១៥៦

– គាទុភាពនៃសេចក្តី មិនរាងចាល ផ្សំនឹងសេចក្តីត្រាប្រណី . ១៥៧

ផ្នែកទី ពីរ .— អំពីភាព មិនរាងចាល ក្នុងបទមជ្ឈិម

– ភាពមិនរាងចាល . . . . . . . ១៥៨

– បទមជ្ឈិម ដែលទុកជាដូចគ្នា . . . . . ១៥៩

– ទម្ងន់ទោសក្នុងបទមជ្ឈិម . . . . . . ១៦០

គាទុភាព នៃសេចក្តីមិនរាងចាលផ្សំនឹងសេចក្តីត្រាប្រណី , . ១៦១

00222525



មាត្រា


– ភាពមិនរាងចាលមនុស្សទោសតែពីគុក . . . . . ១៦២

ផ្នែក ទីបី.– អំពីភាព មិនរាងចាល បណ្ដាលឱ្យមានបញ្ញាផនីយកម្ម

– មនុស្សទោស មិនរាងចាលគួរធ្វើទោស បញ្ញាផនីយកម្ម . ១៦៣

– កម្មវិបាកនៃទោសបញ្ញាផនីយកម្ម . . . . . ១៦៤

– មនុស្សមិនរាងចាល ត្រូវឱ្យរួចទោស បញ្ញាផនីយកម្ម. . ១៦៥

– បញ្ជូនសំណុំរឿងដែលធ្វើទោស បញ្ញាផនីយកម្ម . . ១៦៦

ផ្នែក ទីបួន.– អំពីភាពមិនរាងចាល ក្នុងបទលហុ

– លក្ខខណ្ឌពុំរាងចាល . . . . . . ១៦៧

– ឱ្យរួចទោសលហុ . . . . . . . ១៦៨

– ទម្ងន់ទោស លហុ . . . . . . . ១៦៩


## គន្ថី បួន.–

## អំពីការរំលត់ និង ការរំលោះទោស


– បទបញ្ញត្តិ ប្រារភ . . . . . . . ១៧០

មាតិកា មួយ.– អំពីអាជ្ញាយុកាល នៃទោស

– សេចក្ដីពន្យល់ . . . . . . . ១៧១

– រយៈវេលា . . . . . . . . ១៧២

– ថ្ងៃដែលត្រូវគិតកំណត់ . . . . . . ១៧៣

| | មាត្រា |
|---|---|
| – ប្រតិបត្តិទោសខ្លះ | ១៧៤ |
| – អានុភាពអនុទោស | ១៧៥ |
| – អានុភាព ដែលទាក់ទងនឹងបញ្ឈើផ្ដាលទោស | ១៧៦ |

## មាតិកា ពីរ.— អំពី សេរីការ មានលក្ខខណ្ឌ

| | |
|---|---|
| – សេចក្ដីពន្យល់ | ១៧៧ |
| – លក្ខខណ្ឌដែលនឹងសុំបាន | ១៧៨ |
| – អាជ្ញាធរ មានសមត្ថកិច្ច | ១៧៩ |
| – ដោះលែងព្រោះមានអាការកេត | ១៨០ |
| – បដិសេធន៍ សេចក្ដីដោះលែង | ១៨១ |
| – ដីការដោះលែង | ១៨២ |
| – អានុភាព នៃការដោះលែង | ១៨៣ |
| – អានុភាព នៃការបដិសេធន៍សេចក្ដីដោះលែងវិញ | ១៨៤ |
